អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia Organization

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

អូឌីស៊ី៖ ២០២៤/១៣៨...

**សូមគោរពជូន**

# ឯកឧត្តម សាយ សំអាល់

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ៖** ស្នើសុំបញ្ចូលធាតុចូលលើកទីពីរក្នុងសេចក្តីព្រាងច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា

**យោង៖** សេចក្តីព្រាងច្បាប់ភូមិបាល ដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានផ្តល់នៅក្នុងកិច្ចពិភាក្សាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ភូមិបាល នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤

យោងតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ហៅកាត់ថាអូឌីស៊ី) បានទទួលសេចក្តីព្រាងច្បាប់ភូមិបាល ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤។

អង្គការអូឌីស៊ី បាននិងកំពុងធ្វើការជាមួយក្រុមការងារបច្ចេកទេសមកពីគំនិតផ្តួចផ្តើម Advancing Land-based Investment Governance (ALIGN) (អនុវត្តដោយវិទ្យាស្ថានអន្តរជាតិ សម្រាប់បរិស្ថាននិងការអភិវឌ្ឍ (IIED)) និង Columbia Center on Sustainable Investment (CCSI) ក៏ដូចជាអង្គការ LANDESA លើការផ្តល់ធាតុចូលទៅក្នុងសេចក្តីព្រាងច្បាប់ភូមិបាល ដោយផ្អែកលើមូលដ្ឋានបទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធវិស័យដីធ្លី ជាពិសេសស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលធានាសិទ្ធិស្មើគ្នារវាងស្ត្រី និងបុរស ដោយគ្មានការរើសអើង និងសិទ្ធិលើកម្មសិទ្ធិ ការកាន់កាប់ ប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដី និងអចលនវត្ថុដទៃទៀត។ នៅទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ អង្គការអូឌីស៊ី និងក្រុមការងារបានបញ្ជូនធាតុចូលលើកទីមួយលើសេចក្តីព្រាងច្បាប់ភូមិបាលជូនចំពោះក្រសួងម្តងរួចមកហើយ។ ដោយយល់ឃើញថា មានមតិយោបល់មួយចំនួនសំខាន់ និងមិនទាន់បានដាក់បញ្ចូលនៅក្នុងធាតុចូលលើកទីមួយ អង្គការអូឌីស៊ី និងក្រុមការងារបានពិនិត្យយ៉ាងយកចិត្តទុក និងបានរៀបចំកិច្ចពិភាក្សាពិគ្រោះយោបល់បន្ថែមទៀត ដើម្បីប្រមូលធាតុចូលទៅក្នុងសេចក្តីព្រាងច្បាប់ភូមិបាលនេះ។

ក្នុងបរិបទនេះ អង្គការអូឌីស៊ី និងក្រុមការងារសូមស្នើបន្ថែមចំណុច និងអនុសាសន៍សំខាន់ៗក្នុងសេចក្តីព្រាងច្បាប់ភូមិបាល ដូចមានក្នុងឯកសារភ្ជាប់។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមថ្លែងអំណរគុណដល់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ដែលបានផ្តល់ឱកាសឱ្យអង្គការអូឌីស៊ី បានត្រួតពិនិត្យ និងផ្តល់ធាតុចូលលើសេចក្តីព្រាងច្បាប់ភូមិបាលនេះ ក៏ដូចជាបានទទួលយក និងបញ្ចូលធាតុចូលមួយចំនួនទៅក្នុងសេចក្តីព្រាងច្បាប់ភូមិបាលលើកទីមួយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងដាក់បញ្ចូលធាតុចូលទាំងនេះក្នុងសេចក្តីព្រាងច្បាប់ភូមិបាលចុងក្រោយដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ទទួលយកនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃសុក្រ ១កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៤

**នាយកប្រតិបត្តិ**

អង្គការទិន្នន័យអំពីការអភិវឌ្ឍ
OPEN DEVELOPMENT CAMBODIA ORGANIZATION

**ធី ទ្រី**

# ធាតុចូលលើកទី២
# លើ
# សេចក្តីព្រាងច្បាប់ភូមិបាល
# (សម្រាប់សិក្ខាសាលាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤)

# មាតិកា


| | | |
|---|---|---|
| យោបល់ទូទៅ សម្រាប់សេចក្តីព្រាងច្បាប់នេះទាំងមូលៈ | | 11 |
| មាត្រា១._ | គោលដៅនិងគោលបំណង | 19 |
| មាត្រា២._ | វិសាលភាព | 21 |
| មាត្រា៣._ | និយមន័យ | 21 |
| មាត្រា៤._ | សមត្ថកិច្ច | 26 |
| មាត្រា៥._ | គោលការណ៍ | 26 |
| មាត្រា៦._ | ទំនាក់ទំនងរវាងក្រមរដ្ឋប្បវេណីនិងច្បាប់ភូមិបាល | 27 |
| មាត្រា៧._ | ការការពារកម្មសិទ្ធិនិងសិទ្ធិផ្សេងទៀតលើដីនិងអចលនវត្ថុដទៃទៀត | 28 |
| មាត្រា៨._ | បទប្បញ្ញត្តិស្តីពីកម្មសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ | 29 |
| មាត្រា៩._ | ការដកហូតកម្មសិទ្ធិឯកជន និងសិទ្ធិផ្សេងទផតលើអចលនវត្ថុ | 29 |
| មាត្រា១០._ | ការលុបចោលរបបកម្មសិទ្ធិមុនឆ្នាំ១៩៧៩ | 30 |
| មាត្រា១១._ | ការទទួលស្គាល់ភោគៈស្របច្បាប់ | 30 |
| មាត្រា១២._ | ការកំណត់សញ្ជាតិរបស់កម្មសិទ្ធិករលើដី | 31 |
| មាត្រា១៣._ | ការកំណត់សញ្ជាតិខ្មែររបស់នីតិបុគ្គល | 32 |
| មាត្រា១៤._ | ការក្លែងបន្លំឯកសារពាក់ព័ន្ធនឹងសញ្ជាតិខ្មែរដោយបុគ្គលសញ្ជាតិបរទេសដើម្បីក្លាយជាកម្មសិទ្ធិករ លើដីនៅកម្ពុជា | 32 |
| មាត្រា១៤.១_ | ការបាត់បង់សញ្ជាតិខ្មែរ (បំបែកមកពីមាត្រា១៣) | 33 |
| មាត្រា១៥._ | កាតព្វកិច្ចរបស់កម្មសិទ្ធិករនៃដីដែលបានបាត់សញ្ជាតិខ្មែរ | 34 |
| មាត្រា១៦._ | សេចក្តីសម្រេចស្តីពីការចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិបានក្នុងករណីកម្មសិទ្ធិករ នៃដីបានបាត់សញ្ជាតិខ្មែរ | 36 |
| មាត្រា១៧._ | ការគ្រប់គ្រងដីដែលជាកម្មវត្ថុនៃការចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ | 37 |
| មាត្រា១៨._ | ការអនុវត្តក្រមនិតិវិធីរដ្ឋប្បវេណី | 37 |
| មាត្រា១៩._ | ការតាំងបទប្បញ្ញត្តិបន្ថែមនិងការតាំងបដិប្បញ្ញត្តិចំពោះនៃច្បាប់នេះ | 38 |
| មាត្រា២០._ | កម្មសិទ្ធិករជារដ្ឋ | 39 |
| មាត្រា២១._ | កម្មសិទ្ធិករជានីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត | 41 |
| មាត្រា២២._ | ការដកហូតអចលនវត្ថុដោយអាជ្ញាធរសាធារណៈ | 42 |

| | | |
|---|---|---|
| មាត្រា២៣._ | ទ្រព្យសម្បត្តិរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត | 42 |
| មាត្រា២៤._ | លក្ខណៈវិនិច្ឆ័យនៃទ្រព្យសម្បត្តិសាធារណៈជាអចលនវត្ថុ | 43 |
| មាត្រា២៤.១_ | ការកំណត់ព្រំដីសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គសាធារណៈដទៃទៀត | 45 |
| មាត្រា២៥._ | របបគតិយុត្តនៃទ្រព្យសម្បត្តិសាធារណៈ | 46 |
| មាត្រា២៦._ | ការហាមឃាត់លទ្ធកម្មកម្មសិទ្ធិលើទ្រព្យសម្បត្តិសាធារណៈ | 47 |
| មាត្រា២៧._ | ការហាមឃាត់ការចុះបញ្ជីនិងការចេញឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុលើទ្រព្យសម្បត្តិសាធារណៈ | 48 |
| មាត្រា២៨._ | ការចាត់ចែងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដទៃទៀត | 48 |
| មាត្រា២៩._ | ការរំលោភបំពាន ការកាន់កាប់ និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុដោយខុសច្បាប់ | 49 |
| មាត្រា៣០._ | វិធានការចំពោះការរំលោភបំពាន ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុដោយខុសច្បាប់ | 50 |
| មាត្រា៣១._ | និយមន័យនៃអចលនវត្ថុរបស់វត្ត | 51 |
| មាត្រា៣២._ | របបគតិយុត្តនៃអចលនវត្ថុរបស់វត្ត | 52 |
| មាត្រា៣៣._ | ទីកន្លែងសក្ការបូជានិងអចលនទ្រព្យនៃជំនឿសាសនាដទៃទៀត | 52 |
| មាត្រា៣៤._ | និយមន័យនៃដីបញ្ចុះសព | 53 |
| មាត្រា៣៥._ | របបគតិយុត្តនៃដីបញ្ចុះសព | 54 |
| មាត្រា៣៥.១_ | ដីបញ្ចុះសពដែលស្ថិតក្រោមទម្រង់សហកម្មសិទ្ធិ និងដីបញ្ចុះសពដែលស្ថិតក្នុងដីសហគមន៍ ជនជាតិដើមភាគតិចមិនស្ថិតនៅក្រោមរបរគតិយុត្តនៃផ្នែកនេះទេ | 54 |
| មាត្រា៣៦._ | ការគ្រប់គ្រងសហគមន៍និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណីក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់ នូវលក្ខន្តិកៈរបស់សហគមន៍ | 54 |
| មាត្រា៣៧._ | និយមន័យនៃសមាជិករបស់សហគមន៍ជនជាតិដើមភាគតិច | 55 |
| មាត្រា៣៨._ | សមាសភាគនៃដីសហគមន៍ជនជាតិដើមភាគតិច | 56 |
| មាត្រា៣៩._ | របបគតិយុត្តនៃដីសហគមន៍ជនជាតិដើមភាគតិច | 57 |
| មាត្រា៤១._ | ភាពផ្តាច់មុខក្នុងការទទួលបានសិទ្ធិលើអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច | 60 |
| មាត្រា៤២._ | និយមន័យនៃសហកម្មសិទ្ធិ | 61 |
| មាត្រា៤៣._ | ការចាប់ផ្តើមអនុវត្តរបបគតិយុត្តនៃសហកម្មសិទ្ធិ | 61 |
| មាត្រា៤៤._ | និយមន័យនៃចំណែកឯកជន | 61 |
| មាត្រា៤៥._ | អវិភាជន៍ភាពនៃសហកម្មសិទ្ធិ | 62 |

| | | |
|---|---|---|
| មាត្រា៤៦._ | សិទ្ធិរបស់កម្មសិទ្ធិករនៃចំណែកឯកជន | 62 |
| មាត្រា៤៧._ | និយមន័យនៃចំណែករួមនៃសហកម្មសិទ្ធិ | 62 |
| មាត្រា៤៨._ | របបគតិយុត្តនៃកម្មសិទ្ធិអវិភាគលើចំណែករួម | 63 |
| មាត្រា៤៩._ | សិទ្ធិរបស់សហកម្មសិទ្ធិករលើចំណែករួម | 64 |
| មាត្រា៥០._ | ការផ្លាស់ប្តូរចំណែកឯកជនទៅជាចំណែករួម | 64 |
| មាត្រា៥១._ | ការផ្លាស់ប្តូរចំណែករួមទៅជាចំណែកឯកជន | 65 |
| មាត្រា៥២._ | ការពង្រីកចំណែករួមទៅលើក្បាលដីដែលជាប់ឬជិតខាង | 65 |
| មាត្រា៥៣._ | ឯកសិទ្ធិលើទ្រព្យរបស់សហកម្មសិទ្ធិករជាកូនបំណុល | 65 |
| មាត្រា៥៤._ | សិទ្ធិកម្មសិទ្ធិរបស់ជនបរទេសលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ | 66 |
| មាត្រា៥៥._ | ការហាមឃាត់សិទ្ធិកម្មសិទ្ធិរបស់សហកម្មសិទ្ធិករដែលមានសញ្ជាតិបរទេស | 66 |
| មាត្រា៥៦._ | ការផ្ទេរចំណែកឯកជននៃអគារសហកម្មសិទ្ធិរវាងបុគ្គលដែលមានសញ្ជាតិខ្មែរនិងបុគ្គលដែលមាន សញ្ជាតិបរទេស | 66 |
| មាត្រា៥៧._ | សន្តតិកម្មនៃចំណែកឯកជនរបស់សហកម្មសិទ្ធិករដែលជាបុគ្គលដែលមានសញ្ជាតិបរទេស | 67 |
| មាត្រា៥៨._ | អគារជួលអចិន្ត្រៃយ៍រួមគ្នានិងបុរីដែលអភិវឌ្ឍលើដីជួលអចិន្ត្រៃយ៍ឬផលុបភោគ | 67 |
| មាត្រា៥៩._ | និយមន័យនៃសម្បទានដី | 67 |
| មាត្រា៦០._ | ប្រភេទនៃសម្បទានដី | 68 |
| មាត្រា៦១._ | ការការពារប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ពីការបង្កើតសិទ្ធិសម្បទានដី (មាត្រា៧២) | 68 |
| មាត្រា៦២._ | ប្រភេទសម្បទានដែលមិនស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ | 69 |
| មាត្រា៦៣._ | ថ្លៃសម្បទានដី (មាត្រា៦៣) | 69 |
| មាត្រា៦៤._ | លក្ខខណ្ឌនៃសម្បទានដី | 69 |
| មាត្រា៦៥._ | លក្ខខណ្ឌនៃការដកហូតដីសម្បទាន | 70 |
| មាត្រា៦៦._ | ការបង្កើតសម្បទានដី | 71 |
| មាត្រា៦៧._ | សិទ្ធិពិសេសរបស់សម្បទានិកក្នុងការទទួលបានការការពារដោយអាជ្ញាធរមានសមត្ថកិច្ច | 71 |
| មាត្រា៦៨._ | ការទាញយកផលិតផលពីដីសម្បទាន (មាត្រា៦៩) | 71 |
| មាត្រា៦៩._ | លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់សម្បទានដីសង្គមកិច្ច (មាត្រា៧០) | 72 |
| មាត្រា៧០._ | ការផ្ទេរសិទ្ធិសម្បទានដីសង្គមកិច្ច (មាត្រា៦៨) | 73 |
| មាត្រា៧១._ | សិទ្ធិរបស់សម្បទានិកនៃសម្បទានដីសេដ្ឋកិច្ច | 73 |

| | | |
|---|---|---|
| មាត្រា៧២._ | លក្ខខណ្ឌនៃការដកហូតសម្បទានដីសេដ្ឋកិច្ច | 74 |
| មាត្រា៧៣._ | លក្ខខណ្ឌតតាំងនៃការបង្កើតសិទ្ធិសម្បទានដីសេដ្ឋកិច្ច | 76 |
| មាត្រា៧៤._ | | 76 |
| មាត្រា៧៥._ | | 77 |
| មាត្រា៧៦._ | សិទ្ធិបុព្វក្រៃលើអចលនវត្ថុ | 77 |
| មាត្រា៧៦.១_ | ការប៉ះពាល់ដល់កម្មសិទ្ធិឯកជនក្នុងស្ថានភាពប្រទេសជាតិស្ថិតក្នុងភាពអាសន្ន | 78 |
| មាត្រា៧៦.២_ | ការអនុវត្តបន្ទាន់នៃវិធាននៃដី | 78 |
| មាត្រា៧៧._ | សញ្ញាណសេវភាពសាធារណៈ | 78 |
| មាត្រា៧៨._ | ការអនុវត្តតាមប្លង់គម្រង់ជួរ | 79 |
| មាត្រា៧៩._ | និយមន័យនៃឯកតាសុរិយោដី | 80 |
| មាត្រា៨០._ | ករណីលើកលែងចំពោះដីរដ្ឋ | 80 |
| មាត្រា៨១._ | និយាមកានៃក្បាលដី | 80 |
| មាត្រា៨២._ | ប្លង់សុរិយោដី | 81 |
| មាត្រា៨៣._ | សៀវភៅគោលបញ្ជីដីធ្លី | 81 |
| មាត្រា៨៤._ | សៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុ | 82 |
| មាត្រា៨៥._ | ប្រព័ន្ធទិន្នន័យសុរិយោដីឌីជីថល | 82 |
| មាត្រា៨៦._ | អានុភាពនៃឯកសារសុរិយោដី | 83 |
| មាត្រា៨៧._ | ការរក្សាទុកឯកសារសុរិយោដី | 83 |
| មាត្រា៨៨._ | បណ្ណនិងព័ត៌មានសុរិយោដី | 84 |
| មាត្រា៨៩._ | ការហាមឃាត់ការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ | 84 |
| មាត្រា៩០._ | រចនាសម្ព័ន្ធរបស់រដ្ឋបាលសុរិយោដី | 85 |
| មាត្រា៩១._ | លក្ខន្តិកៈគតិយុត្តរបស់មន្ត្រីសុរិយោដី | 85 |
| មាត្រា៩២._ | ក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីសុរិយោដី | 85 |
| មាត្រា៩៣._ | ការគ្រប់គ្រងមុខជំនាញរបស់មន្ត្រីសុរិយោដី | 86 |
| មាត្រា៩៤._ | ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីសុរិយោដី | 86 |
| មាត្រា៩៥._ | សមត្ថកិច្ចរបស់រដ្ឋបាលសុរិយោដី | 86 |
| មាត្រា៩៦._ | ភារកិច្ចរបស់រដ្ឋបាលសុរិយោដី | 87 |
| មាត្រា៩៧._ | សិទ្ធិអំណាចរបស់រដ្ឋបាលសុរិយោដី | 87 |

| | | |
|---|---|---|
| មាត្រា៩៨._ | ការទទួលខុសត្រូវរបស់រដ្ឋបាលសុរិយោដី | 88 |
| មាត្រា៩៩._ | លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់សេវាសាធារណៈដោយរដ្ឋបាលសុរិយោដី | 88 |
| មាត្រា១០០._ | កម្រៃសេវាសាធារណៈផ្តល់ដោយរដ្ឋបាលសុរិយោដី | 89 |
| មាត្រា១០១._ | ឪដីថលភាវូបនីយកម្មនៃការផ្តល់សេវាសាធារណៈ | 89 |
| មាត្រា១០២._ | ការចូលរួមក្នុងដំណើរការនៃការធ្វើសម្រង់សុរិយោដី | 90 |
| មាត្រា១០៣._ | កាតព្វកិច្ចរបស់អ្នកកាន់កាប់ដីឬអ្នកតំណាងស្របច្បាប់របស់ខ្លួន | 90 |
| មាត្រា១០៤._ | សិទ្ធិរបស់បុគ្គលដែលពាក់ព័ន្ធ | 91 |
| មាត្រា១០៥._ | ការចូលរួមរបស់អាជ្ញាធរដែនដី និងកងកម្លាំងប្រដាប់អាវុធ | 91 |
| មាត្រា១០៦._ | ការបង្កើតគណៈកម្មការសុរិយោដី | 94 |
| មាត្រា១០៧._ | រចនាសម្ព័ន្ធនៃគណៈកម្មការសុរិយោដី | 94 |
| មាត្រា១០៨._ | សមត្ថកិច្ចដោះស្រាយបណ្តឹង | 94 |
| មាត្រា១០៩._ | | 95 |
| មាត្រា១១០._ | | 95 |
| មាត្រា១១១._ | | 95 |
| មាត្រា១១២._ | | 95 |
| មាត្រា១១៣._ | ភារកិច្ចនិងសិទ្ធិរបស់មន្ត្រីអធិការកិច្ចសុរិយោដី | 96 |
| មាត្រា១១៤._ | សិទ្ធិរបស់មន្ត្រីអធិការកិច្ចសុរិយោដីចូលទៅក្នុងបរិវេណក្បាលដីនិងអចលនវត្ថុដទៃទៀត | 96 |
| មាត្រា១១៥._ | ការអនុវត្តនីតិវិធីព្រហ្មទណ្ឌដោយមន្ត្រីអធិការកិច្ចសុរិយោដី | 96 |
| មាត្រា១១៥.១_ | គោលការណ៍នៃការចុះបញ្ជីអចលនវត្ថុលើកដំបូង | 97 |
| មាត្រា១១៦._ | លក្ខខណ្ឌនៃភោគៈស្របច្បាប់ | 98 |
| មាត្រា១១៧._ | ការការពារភោគីស្របច្បាប់ | 99 |
| មាត្រា១១៨._ | សិទ្ធិដែលត្រូវបានបង្កើតលើអចលនវត្ថុមុនពេលធ្វើលទ្ធកម្មកម្មសិទ្ធិដោយភោគៈ | 100 |
| មាត្រា១១៩._ | វិធានចំពោះភោគៈមិនស្របច្បាប់ | 100 |
| មាត្រា១២០._ | សិទ្ធិរបស់ភោគីស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ | 101 |
| មាត្រា១២១._ | ភស្តុតាងនៃសិទ្ធិកាន់កាប់ | 102 |
| មាត្រា១២២._ | សិទ្ធិស្នើសុំចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ | 102 |

| | | |
|---|---|---|
| មាត្រា១២៣._ | ការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដោយរដ្ឋបាលសុរិយោដី ឱ្យបុគ្គលក្រៅពីភោគីពិតប្រាកដដែលបានកាន់កាប់អចលនវត្ថុ | 103 |
| មាត្រា១២៤._ | បន្ទុកក្នុងការចំណាយលើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ | 103 |
| មាត្រា១២៥._ | គោលការណ៍នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ | 104 |
| មាត្រា១២៦._ | ការកំណត់តំបន់វិនិច្ឆ័យ | 104 |
| មាត្រា១២៧._ | ការកំណត់ព្រំដី | 104 |
| មាត្រា១២៨._ | ការងារវាស់វែង | 105 |
| មាត្រា១២៩._ | ការងារវិនិច្ឆ័យ | 105 |
| មាត្រា១៣០._ | ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ | 106 |
| មាត្រា១៣១._ | ការសម្រុះសម្រួល | 107 |
| មាត្រា១៣១.១_ | | 108 |
| មាត្រា១៣២._ | លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ | 108 |
| មាត្រា១៣៣._ | សិទ្ធិស្នើសុំចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ | 109 |
| មាត្រា១៣៤._ | លក្ខខណ្ឌនៃក្បាលដីសម្រាប់ធ្វើការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ | 109 |
| មាត្រា១៣៥._ | ប្រភេទនៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ | 110 |
| មាត្រា១៣៦._ | ការបញ្ចូលក្បាលដីដែលត្រូវបានចុះបញ្ជីមានលក្ខណៈដាច់ដោយដុំរួចហើយ | 110 |
| មាត្រា១៣៧._ | លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ | 110 |
| **មាត្រា១៣៧.១_** | | 111 |
| **មាត្រា១៣៧.២_** | | 111 |
| **មាត្រា១៣៧.៣_** | | 111 |
| **មាត្រា១៣៧.៤_** | | 112 |
| **មាត្រា១៣៧.៥_** | | 112 |
| **មាត្រា១៣៧.៦_** | | 113 |
| មាត្រា១៣៨._ | ការចាប់ផ្តើមធ្វើការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិ | 113 |
| មាត្រា១៣៩._ | ក្បាលដីសហកម្មសិទ្ធិ | 114 |
| មាត្រា១៤០._ | ទំហំ ព្រំប្រទល់ និងមុខងារប្រើប្រាស់នៃចំណែកឯកជននៃសហកម្មសិទ្ធិ | 114 |
| មាត្រា១៤១._ | វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃសហកម្មសិទ្ធិ | 115 |
| មាត្រា១៤២._ | ការបំបែកក្បាលដីសហកម្មសិទ្ធិ | 115 |

| | | |
|---|---|---|
| មាត្រា១៤៣._ | ការបំបែកក្បាលដីសហកម្មសិទ្ធិក្នុងករណីមានការដកហូតដើម្បីផលប្រយោជន៍សាធារណៈ | 115 |
| មាត្រា១៤៤._ | សិទ្ធិស្នើសុំចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច | 116 |
| មាត្រា១៤៥._ | គោលការណ៍នៃការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច | 116 |
| មាត្រា១៤៦._ | ដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច | 116 |
| មាត្រា១៤៧._ | បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិច | 117 |
| មាត្រា១៤៨._ | លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច | 118 |
| មាត្រា១៤៩. | អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិប្ដឹងតវ៉ាចំពោះការចុះបញ្ជី | 119 |
| មាត្រា១៥០._ | ការកាន់កាប់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ | 120 |
| មាត្រា១៥១._ | ការកែតម្រូវការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ | 120 |
| មាត្រា១៥២._ | ការដកហូតវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ | 120 |
| មាត្រា១៥២._ | ការបង្កើតនិងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី (មាត្រា១០៦) | 121 |
| មាត្រា១៥២.១_ | រចនាសម្ព័ន្ធនៃគណៈកម្មការសុរិយោដី (មាត្រា១០៧) | 121 |
| មាត្រា១៥២.២_ | ការទាមទារសិទ្ធិលើដីសាធារណៈរបស់រដ្ឋឬនីតិបុគ្គលសាធារណៈដទៃទៀត (១០៩) | 122 |
| មាត្រា១៥២.៣_ | វិវាទវាងភោគីចំពោះអចលនវត្ថុដែលមិនទាន់ត្រូវបានចុះបញ្ជី (មាត្រា ១១០) | 122 |
| មាត្រា១៥២.៤_ | ការដោះស្រាយវិវាទនៅក្នុងតំបន់វិនិច្ឆ័យ | 122 |
| មាត្រា១៥២.៥_ | ការដោះស្រាយវិវាទនៅក្រៅតំបន់វិនិច្ឆ័យ | 123 |
| មាត្រា១៥៣._ | គោលបំណង | 124 |
| មាត្រា១៥៤._ | វិសាលភាព | 124 |
| មាត្រា១៥៥._ | ស្ថាប័នមានសមត្ថកិច្ច | 125 |
| មាត្រា១៥៦._ | លំដាប់នៃការធ្វើនីតិវិធីចុះបញ្ជី | 125 |
| មាត្រា១៥៧._ | លំដាប់អាទិភាពនៃសិទ្ធិ | 125 |
| មាត្រា១៥៨._ | ការផ្ដល់អាណត្តិឱ្យទៅលិខិតបទដ្ឋានគិយុត្ត | 126 |
| មាត្រា១៥៩._ | សិទ្ធិក្នុងការចុះបញ្ជីអំពីការកែប្រែព័ត៌មាននិងទិន្នន័យនៃក្បាលដី | 126 |
| មាត្រា១៦០._ | ការហាមឃាត់ការកែប្រែព័ត៌មាននិងទិន្នន័យនៃក្បាលដី | 126 |
| មាត្រា១៦១._ | ការចុះបញ្ជីដោយផ្អែកលើការស្នើសុំចុះបញ្ជីឬការផ្ទុកផ្ដាក់ឱ្យចុះបញ្ជី ឬការជូនដំណឹង | 127 |
| មាត្រា១៦២._ | ការធ្វើនិងដាក់ពាក្យស្នើសុំចុះបញ្ជីរួមគ្នា | 128 |
| មាត្រា១៦៣._ | ការស្នើសុំចុះបញ្ជីអំពីកិច្ចសន្យាហាមឃាត់មិនឱ្យបែងចែកអចលនវត្ថុអវិភាគ | 128 |
| មាត្រា១៦៤._ | ការស្នើសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរលំដាប់ហ៊ីប៉ូតែកនិងសិទ្ធិដទៃទៀត | 128 |

| | | |
|---|---|---|
| មាត្រា១៦៥._ | ការស្នើសុំចុះបញ្ជីដោយឯកតោភាគី | 129 |
| មាត្រា១៦៦._ | ការស្នើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬកែតម្រូវឈ្មោះរបស់បុគ្គលមានឈ្មោះក្នុងបញ្ជី | 129 |
| មាត្រា១៦៧._ | ការស្នើសុំចុះបញ្ជីដោយប្រតិសិទ្ធិសាកល | 129 |
| មាត្រា១៦៨._ | ការស្នើសុំចុះបញ្ជីដោយអ្នកតំណាង | 130 |
| មាត្រា១៦៩._ | ការផ្តល់អាណត្តិឱ្យទៅលិខិតបទដ្ឋានគតិយុត្ត | 130 |
| មាត្រា១៧០._ | ការបង្គាប់ឱ្យកែតម្រូវការស្នើសុំចុះបញ្ជី | 131 |
| មាត្រា១៧១._ | ការបដិសេធការស្នើសុំចុះបញ្ជី | 131 |
| មាត្រា១៧២._ | ការស្រាវជ្រាវដោយរដ្ឋបាលសុរិយោដីពាក់ព័ន្ធនឹងបុគ្គលដែលស្នើសុំចុះបញ្ជី | 132 |
| មាត្រា១៧៣._ | ការដកការស្នើសុំចុះបញ្ជីបន្ត | 133 |
| មាត្រា១៧៤._ | ការចុះបញ្ជីអំពីការផ្លាស់ប្តូរឬការចុះបញ្ជីអំពីការកែតម្រូវសិទ្ធិដោយការចុះបញ្ជីបន្ថែម | 133 |
| មាត្រា១៧៥._ | ការចុះបញ្ជីអំពីការកែតម្រូវ | 134 |
| មាត្រា១៧៦._ | ការលុបការចុះបញ្ជី | 135 |
| មាត្រា១៧៧._ | ការលុបការចុះបញ្ជីដោយផ្អែកលើការសន្យាពិសេស | 135 |
| មាត្រា១៧៨._ | ការលុបការចុះបញ្ជីដោយពុំចាំបាច់មានការស្នើសុំ | 135 |
| មាត្រា១៧៩._ | ការធ្វើបដិទានការចុះបញ្ជីដែលត្រូវបានលុប | 136 |
| មាត្រា១៨១._ | ការយកមកអនុវត្តដូចគ្នានូវបទប្បញ្ញត្តិស្តីពីការចុះបញ្ជីតាមរយៈការស្នើសុំចុះបញ្ជី | 137 |
| មាត្រា១៨២._ | បទប្បញ្ញត្តិទូទៅស្តីពីចំណុចដែលត្រូវចុះបញ្ជី | 138 |
| មាត្រា១៨៣._ | ចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិជួលអចិន្ត្រៃយ៍ | 139 |
| មាត្រា១៨៤._ | ចំណុចដែលត្រូវចុះបញ្ជីអំពីផលុបភោគ | 139 |
| មាត្រា១៨៥._ | ចំណុចដែលត្រូវចុះបញ្ជីអំពីសេវភាព | 139 |
| មាត្រា១៨៦._ | ករណីដែលដីប្រើស្ថិតនៅក្នុងដែនសមត្ថកិច្ចផ្សេង | 140 |
| មាត្រា១៨៧._ | ចំណុចដែលត្រូវចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ | 141 |
| មាត្រា១៨៨._ | ចំណុចដែលត្រូវចុះបញ្ជី អំពីឯកសិទ្ធិ | 141 |
| មាត្រា១៨៩._ | ចំណុចដែលត្រូវចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ | 142 |
| មាត្រា១៩០._ | ចំណុចដែលត្រូវចុះបញ្ជីអំពីហ៊ីប៉ូតែក | 142 |
| មាត្រា១៩១._ | ចំណុចដែលត្រូវចុះបញ្ជីអំពីហ៊ីប៉ូតែកជានាបំណុលអណ្តែត | 143 |
| មាត្រា១៩២._ | ចំណុចដែលត្រូវចុះបញ្ជីអំពីការចាត់ចែងហ៊ីប៉ូតែក | 144 |
| មាត្រា១៩៣._ | ចំណុចដែលត្រូវចុះបញ្ជីអំពីឧបាទេសកម្មហ៊ីប៉ូតែករួម | 144 |

| | | |
|---|---|---|
| មាត្រា១៩៤._ | ការផ្តល់អាណត្តិឱ្យទៅបទដ្ឋានគិយុត្ត | 145 |
| មាត្រា១៩៥._ | ការលុបការចុះបញ្ជីដែលធ្វើឡើងក្រោយការចុះបញ្ជីចាត់ចែងជាបណ្តោះអាសន្ន | 145 |
| មាត្រា១៩៦._ | ការផ្តល់អាណត្តិឱ្យទៅបទដ្ឋានគិយុត្ត | 146 |
| មាត្រា១៩៧._ | ការដាក់ពាក្យសុំតវ៉ា | 146 |
| មាត្រា១៩៨._ | | 147 |
| មាត្រា១៩៩._ | | 148 |

**យោបល់ទូទៅ សម្រាប់សេចក្តីព្រាងច្បាប់នេះទាំងមូល៖**

1. ដើម្បីឱ្យស្របតាមការប្តេជ្ញាក្នុងរដ្ឋធម្មនុញ្ញចំពោះសិទ្ធិស្មើគ្នារវាងស្ត្រី និងបុរសដោយគ្មានការរើសអើង ព្រមទាំងគោលការណ៍មិនរើសអើង និងការចូលរួមដោយស្មើភាពរបស់ស្ត្រី ដូចមានកំណត់ក្នុងកតិកាសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ និងពិធីសារបន្ថែមនៃកតិកាសញ្ញានេះដែរ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន និងទម្លាប់អនុវត្តល្អជាអន្តរជាតិ (ឧ. គោលការណ៍ណែនាំបែបស្ម័គ្រចិត្តរបស់ UN FAO ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដីធ្លី ជលផល និងព្រៃឈើក្នុងបរិបទសន្តិសុខស្បៀងជាតិ) សេចក្តីព្រាងច្បាប់នេះអាចត្រូវបានកែលម្អដោយការបញ្ចូលនូវប្រការជាក់លាក់មួយចំនួនដែលគាំទ្រចំពោះសិទ្ធិស្មើគ្នាក្នុងការគ្រប់គ្រង ការចូលទៅប្រើប្រាស់ និងការធ្វើជាម្ចាស់ ព្រមទាំងការហាមឃាត់នូវការរើសអើងចំពោះស្ត្រីភេទដែលឆ្លុះបញ្ចាំងក្នុងមាត្រា ៣១ និងមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ក៏ដូចជាការហាមឃាត់ការរើសអើងចំពោះអ្នកស្រលាញ់ភេទដូចគ្នាស្របតាមបទដ្ឋានអន្តរជាតិពាក់ព័ន្ធ។
2. លើសពីនេះ គួរមានបទប្បញ្ញត្តិកំណត់អំពីយន្តការស្ថាប័ន និងនីតិវិធីកំណត់លក្ខណៈវិនិច្ឆ័យចុះបញ្ជី និងទទួលស្គាល់សញ្ជាតិខ្មែរសម្រាប់សហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនានាដែលមិនមែនជាសហគ្រាសពាណិជ្ជកម្ម ឬនីតិបុគ្គលសាធារណៈ ព្រោះច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងច្បាប់ជាធរមានផ្សេងៗទៀត មិនបានចែងអំពីការកំណត់សញ្ជាតិរបស់សហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទេ។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពី សហគមន៍កសិករ និងអនុក្រឹត្យស្តីពីនីតិវិធីចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចគ្រាន់តែមានចែងថា ក្រោយពីបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ឬក្រសួងកសិកម្ម សហគមន៍ជនជាតិដើមភាគតិច សមាគមន៍កសិកម្ម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទទួលបានឋានៈជា **នីតិបុគ្គល** ប៉ុន្តែពុំមានការកំណត់សញ្ជាតិរបស់សហគមន៍ជនជាតិដើមភាគតិច សមាគមន៍កសិកម្ម ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកទេ ដូច្នេះនាំឱ្យមានសំណួរផ្នែកច្បាប់ថា តើសហគមន៍ជនជាតិដើមភាគតិច សមាគមន៍កសិកម្ម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកអាចមានសិទ្ធិក្នុងការធ្វើជាកម្មសិទ្ធិករពេញលេញផ្តាច់មុខដោយស្របច្បាប់លើដីនៅកម្ពុជា ឬទេ។

3. ក្នុងការអនុវត្តដើម្បីទទួលបាននូវការការពារជាបណ្តោះអាសន្ននូវដីសម្ងហភាពជនជាតិដើមភាគតិចបាន ជាពិសេសនៅពេលដែលមានការរំលោភយកដីសម្ងហភាពជនជាតិដើមភាគតិចកើតឡើង ក្រុមជនជាតិដើមភាគតិចជាសមាជិកត្រូវដាក់ឯកសារមួយនៃឯកសារតម្រូវផ្សេងៗគឺឯកសារដែលមានឈ្មោះថា "ស្វ័យអត្តសញ្ញាណជនជាតិដើមភាគតិច"។ ដើម្បីទទួលបានឯកសារនេះ សមាជិកជនជាតិដើមភាគតិចបានជួបប្រទះនូវការលំបាកជាច្រើនដោយមិនមានឯកសារគតិយុត្តណាមួយបញ្ជាក់ពីតម្រូវឯកសារនេះ និងបញ្ជាក់ពីអាជ្ញាធរកម្រិតណាមួយដែលនឹងចេញឯកសារនេះបាន។ ជាលទ្ធផល ជនជាតិដើមភាគតិចជាសមាជិក មិនទទួលបាននូវការការពារពីការរំលោភបំពានយកដីសម្ងហភាពជនជាតិដើមភាគតិចឡើយ ដោយមូលហេតុមិនមានឯកសារគ្រប់គ្រាន់។ ច្បាប់នេះគួរបញ្ញត្តិឱ្យ

បានច្បាស់លាស់ពីលក្ខខណ្ឌតម្រូវបែបនេះ និងកម្រិតនៃការចេញលិខិតស្ញ័យអត្តសញ្ញាណជនជាតិដើមភាគតិចនេះគួរតែត្រឹមថ្នាក់ឃុំពីព្រោះមន្ត្រីអាចស្គាល់ និងដឹងពីអត្តសញ្ញាណជនជាតិដើមភាគតិច។

4. ច្បាប់នេះគួរចែងក្នុងជំពូកដោយឡែកអំពីកម្មសិទ្ធិឯកជនដែលខុសពីកម្មសិទ្ធិសាធារណៈ និងកម្មសិទ្ធិសមូហភាព។

5. ច្បាប់នេះចាំបាច់ត្រូវគោរព និងការពារសិទ្ធិឯកជន និងកម្មសិទ្ធិសមូហភាពស្របច្បាប់ (សិទ្ធិភោគៈ សិទ្ធិកម្មសិទ្ធិ និងសិទ្ធិប្រត្យក្សផ្សេងៗទៀតលើដី និងអចលនវត្ថុនៅកម្ពុជា) ពីការដកហូតតាមទំនើងចិត្ត ការរឹបអូស ដកហូត ឬកម្រិតរឹតត្បិតដោយសេចក្តីសម្រេចរដ្ឋបាល ឬលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ រួមទាំង ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសសេចក្តីជូនដំណឹង (សជណ) អំពីការប្រកាសទ្រព្យរដ្ឋ ការកំណត់តំបន់ដែនព្រៃបម្រុងទុក តំបន់ការពារបរិស្ថាន ការកំណត់របស់អាជ្ញាធរអំពីដីចំណីផ្លូវ ទន្លេ ស្ទឹង ព្រែក បឹងបួ ធ្នេរ ប្រាំងផ្លូវទឹក ដែលចេះតែពង្រីកធំឡើងៗជាបន្តបន្ទាប់ដើម្បីជៀសវាងនូវកាតព្វកិច្ចផ្តល់សំណងសមរម្យ និងយុត្តិធម៌ ការផ្តល់ដីឱ្យវិនិយោគ ការផ្តល់សម្បទានគ្រប់ប្រភេទ ការប្រគល់ដីឱ្យប្រើប្រាស់ និងផែនការនគររូបនីយកម្ម ឬផែនការប្រើប្រាស់ដីនានា រួមទាំងវិធានការបម្រុងដីទុកសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការបង្កកដីទុកដែលបម្រើឱ្យផលប្រយោជន៍របស់បុគ្គលឯកជននានាដែលផ្ទុយនឹងស្មារតី មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញ និងបទប្បញ្ញត្តិនៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០។

ក្នុងករណីដែលបុគ្គលណាមួយត្រូវបានដកហូតនូវសិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួនសម្រាប់ផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ ជាការសំខាន់ដែលរដ្ឋត្រូវអនុវត្តដំណើរការពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ និងមានផ្តល់សំណងជូនទាំងលើការបាត់បង់ ឬខូចខាតជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ចំពោះកម្មសិទ្ធិ ឬសិទ្ធិប្រត្យក្សផ្សេងៗទៀត រួមទាំងសិទ្ធិភោគៈ សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិផលុបភោគ សិទ្ធិក្រោមកិច្ចសន្យាសម្បទានសង្គមកិច្ច ហើយរបៀបគណនានូវសំណងនោះគួរមានតម្លាភាពមានលក្ខណៈអាចយល់បាន និងស្របតាមគោលការណ៍អន្តរជាតិ។

សូមឱ្យរដ្ឋអនុវត្តច្បាប់ស្តីពីអស្សាមិករណ៍ ហើយនៅមានចន្លោះសម្រាប់កែលម្អចំពោះបញ្ហាសំណងឱ្យហួសពីអ្វីដែលមានចែងក្នុងច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០ ជាឧទាហរណ៍ ការផ្តល់សំណងក្រោមគោលនយោបាយដោះស្រាយផលប៉ះពាល់នៃការធ្វើលទ្ធកម្មដីដោយគ្មានការស្ម័គ្រចិត្ត។ រាល់សំណង គួរមានបញ្ចូលយ៉ាងហោចមិនត្រឹមតែស្មើនឹងថ្លៃពេញលេញនៃសិទ្ធិណាមួយដែលគេមានលើចលនវត្ថុ និងអចលនវត្ថុនោះទេ ប៉ុន្តែថែមទាំងសំណងចំពោះការប៉ះពាល់ផ្នែករាងកាយ ឬស្មារតី ការបាត់បង់ឱកាស ឬបាត់បង់ប្រាក់ចំណូល និងថ្លៃចំណាយលើដំណើរការផ្លាស់ប្តូរទីតាំងផងដែរ។

សំណងសមរម្យ និងយុត្តិធម៌ គួរគោរពតាមគោលការណ៍អន្តរជាតិ ហើយគោលការណ៍ណែនាំស្តីពីសំណងសមរម្យ និងយុត្តិធម៌ត្រូវរៀបចំដោយក្រសួងមានសមត្ថកិច្ច ដោយយោងទៅសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការដោះស្រាយផលប៉ះពាល់ដែលការិយាល័យ OHCHR ប្រចាំប្រទេសកម្ពុជា បានស្នើជាយោបល់ជូនរដ្ឋាភិបាលកម្ពុជាក្នុងការកំណត់សំណងសមរម្យ និងយុត្តិធម៌៖

i. ក្នុងករណីដែលការបណ្តេញចេញដែលជៀសវាងមិនបានហើយជាការចាំបាច់សម្រាប់លើកកម្ពស់សុខមាលភាពទូទៅសំណងត្រឹមត្រូវយុត្តិធម៌ និងសមរម្យចំពោះរាល់ការបាត់បង់ចលនទ្រព្យ អចលនវត្ថុ និងទ្រព្យសម្បត្តិ ឬរបស់របរផ្សេងៗទៀតរួមទាំងសិទ្ធិ ឬផលប្រយោជន៍នានាលើទ្រព្យគួរត្រូវបានធានា។ គណៈកម្មការអន្តរក្រសួងនិងអនុគណៈកម្មការនានា គួរមានការទទួលខុសត្រូវចំពោះរាល់បញ្ហាពាក់ព័ន្ធនឹងសំណង។ សំណងគួរតែត្រូវបានផ្តល់ឱ្យចំពោះរាល់ការខូចខាតដែលអាចប៉ាន់ប្រមាណតម្លៃខាងសេដ្ឋកិច្ចបាន ស្របតាមសមាមាត្រនៃកម្រិតប៉ះពាល់សិទ្ធិ និងកាលទេសៈនៃករណីនីមួយៗ ដូចជា (ក) ការបាត់បង់ជីវិត ឬអវយវៈ (ខ) ការប៉ះពាល់ផ្នែករាងកាយ ឬស្មារតី (គ) ការបាត់បង់ឱកាសនានារួមទាំងឱកាសការងារ ឱកាសអប់រំ និងឱកាសទទួលបានអត្ថប្រយោជន៍សង្គមកិច្ច (ឃ) ការខូចខាតសម្ភារៈនិងការបាត់បង់ប្រាក់ចំណូលរួមទាំងការបាត់បង់ឱកាសរកប្រាក់ចំណូល (ង) ការបាត់បង់ឬខូចខាតក្រៅពីផ្នែកសេដ្ឋកិច្ច និង (ច) ថ្លៃចំណាយលើជំនួយផ្នែកច្បាប់ ឬអ្នកជំនាញថ្នាំពេទ្យ និងសេវាវេជ្ជសាស្ត្រ ព្រមទាំងសេវាផ្នែកសង្គមកិច្ច និងចិត្តសាស្ត្រ។

ii. សំណងជាប្រាក់ មិនគួរជំនួសឱ្យការសងជាទ្រព្យក្នុងទម្រង់ជាដី និងធនធានរួមសម្រាប់សហគមន៍ឡើយ។ ករណីមានការដកហូតដី ជនរងផលប៉ះពាល់ គួរទទួលបានសំណងជាដីដែលមានគុណភាព ទំហំ និងតម្លៃប្រហែលគ្នា ឬប្រសើរជាង។ មានការសិក្សាចំនួន ៥៧ ស្តីពីស្ថានភាពសិទ្ធិមនុស្សរបស់សហគមន៍ដែលរស់នៅទីតាំងនៃការតាំងទីលំនៅថ្មីនៅកម្ពុជា និងអំពីសេចក្តីព្រាងគោលការណ៍ណែនាំសម្រាប់ការដោះស្រាយផលប៉ះពាល់។

iii. រាល់ជនដែលត្រូវបានបណ្តេញចេញ ដោយមិនគិតថាពួកគេមានសិទ្ធិលើទ្រព្យនោះឬអត់ទេ គួរទទួលបានសំណងចំពោះការបាត់បង់ ការខូចខាត និងថ្លៃដឹកជញ្ជូនចេញនូវទ្រព្យសម្បត្តិរបស់ពួកគេដែលរងផលប៉ះពាល់ រួមទាំងលំនៅដ្ឋានដើម និងដីដែលត្រូវបានបាត់បង់ ឬខូចខាតក្នុងដំណើការបណ្តេញចេញនោះ។ ការពិចារណាលើកាលទេសៈនៃករណីនីមួយៗ ត្រូវអនុញ្ញាតឱ្យមានការផ្តល់សំណងចំពោះការបាត់បង់នូវការកាន់កាប់ទ្រព្យបែបមិនរៀបរយ ដូចជាសំណង់បណ្តោះអាសន្ន ការចូលបរបាញ់សត្វ ការនេសាទ និងការប្រមូលអនុផល។

iv. ស្ត្រី និងបុរសជាសហព័ទ្ធ ត្រូវតែជាសហអត្ថគាហកនៃកញ្ចប់សំណងទាំងអស់។ ស្ត្រីនៅលីវ និងមេម៉ាយគួរទទួលបានសំណងដោយផ្ទាល់។

v. ត្រឹមកម្រិតដែលមិនគ្របដណ្តប់ដោយជំនួយសម្រាប់ការផ្លាស់ប្តូរទីតាំង ការប៉ាន់ប្រមាណអំពីការខូចខាតផ្នែកសេដ្ឋកិច្ច គួរពិចារណាលើការខូចខាត និងថ្លៃចំណាយ ជាឧទាហរណ៍លើដី និងសំណង់ផ្ទះសម្បែង

របស់របរនានា ហេដ្ឋារចនាសម្ព័ន្ធ ការពិន័យចំពោះបំពានលើហ៊ីប៉ូតែក កិច្ចសន្យាបញ្ចាំ ឬលើបំណុល ការចំណាយលើកន្លែងស្នាក់នៅបណ្តោះអាសន្ន ឬថ្លៃសេវារដ្ឋបាល និងសេវាផ្នែកច្បាប់ ថ្លៃចំណាយលើផ្ទះថ្មីជំនួសឱ្យផ្ទះដែលបាត់បង់ ការបាត់បង់ប្រាក់ឈ្នួល និងចំណូល ការបាត់បង់ឱកាសអប់រំ សេវាពិនិត្យ និងថែទាំងសុខភាព ថ្លៃចំណាយលើការដឹកជញ្ជូន និងការតាំងទីលំនៅថ្មី (ជាពិសេសក្នុងករណីធ្វើការផ្លាស់ប្តូរទៅទីតាំងឆ្ងាយពីប្រភពរកចំណូលចិញ្ចឹមជីវិត)។ ករណីដែលផ្ទះ និងដីនោះ ផ្តល់ផងដែរនូវប្រភពចំណូលចិញ្ចឹមជីវិតរបស់ជនស្នាក់នៅដែលត្រូវបណ្តេញចេញ ត្រូវមានការគិតគូប៉ាន់ប្រមាណលើផលប៉ះពាល់ និងការខូចខាតជាតម្លៃនៃការខូចខាតផ្នែកអាជីវកម្ម សម្ភារៈ/សារពើភ័ណ្ឌ សត្វចិញ្ចឹម ដីដើមឈើ/ដំណាំ និងការបាត់បង់ ឬថយចុះនូវប្រាក់ឈ្នួល/ប្រាក់ចំណូលដែលបានទទួលតាមរយៈការងារក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

6. ច្បាប់នេះគួរកំណត់អំពីយន្តការ និងដំណើរការដោះស្រាយ មានប្រសិទ្ធភាពចំពោះការរំលោភបំពានលើ សិទ្ធិភោគៈ សិទ្ធិកម្មសិទ្ធិ និងសិទ្ធិប្រត្យក្សផ្សេងៗទៀតលើដី និងអចលនវត្ថុនៅកម្ពុជា ការដកហូតតាមទំនើងចិត្ត ការរឹបអូសដកហូត ឬកម្រិតរិតត្បិតដោយសេចក្តីសម្រេចរដ្ឋបាល ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ទាំងតាមយន្តការតុលាការ និងយន្តការសម្រុះសម្រួលដែលជឿទុកចិត្តបាន អាចទៅប្រើប្រាស់ មានតម្លាភាព សមធម៌ ។

7. ដើម្បីធានា និងគាំពារសិទ្ធិស្របច្បាប់ (មិនមែនស្របតាមការកំណត់ក្នុងបទដ្ឋានគតិយុត្ត ឬសេចក្តីសម្រេចរបស់រដ្ឋបាលសាធារណៈ ឬស្ថាប័នផ្សេងទៀត ដែលមិនចុះសម្រុងជាមួយច្បាប់ដែលអនុម័តដោយអង្គនីតិបញ្ញត្តិ) លើដីធ្លី និងអចលនវត្ថុនានា ច្បាប់នេះគួរចែងបញ្ជាក់ថា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីជូនដំណឹងអំពីការប្រកាសទ្រព្យរដ្ឋ ការកំណត់តំបន់ដែនព្រៃបម្រុងទុករបស់រដ្ឋ តំបន់ការពារធម្មជាតិ តំបន់ការពារសត្វព្រៃ (ដែនជំរកសត្វព្រៃ) តំបន់ការពារផ្សេងទៀត ការកំណត់ដីចំណីផ្លូវ ទន្លេ ស្ទឹង ព្រែក បឹងបួ ប្រឡាយ ឆ្នេរ ច្រាំង និងផែនការនគររូបនីយកម្មនានាជាភស្តុតាងមួយ ប៉ុន្តែមិនមែនមិនអាចតវ៉ាបាន និងមិនមែនត្រូវតែយកធ្វើជាបន្ទាល់សម្រាប់ការកំណត់ ចាត់ថ្នាក់ និងចុះបញ្ជីដីរដ្ឋ ឬការចុះបញ្ជីដីធ្លីលើកដំបូង ក្នុងលក្ខណៈធ្វើឱ្យប៉ះពាល់ និងកម្រិតការប្រើប្រាស់មិនសមរម្យ លុបចោល មោឃៈ កាត់ចេញ ឬដកហូតដោយឥតផ្តល់សំណងសមរម្យ និងយុត្តិធម៌ជាមុន ចំពោះសិទ្ធិភោគៈ និងសិទ្ធិប្រត្យក្សផ្សេងៗទៀតរបស់បុគ្គលឯកជន ឬសមូហភាព ដែលមានមុនកាលបរិច្ឆេទនៃព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីជូនដំណឹង និងផែនការនគររូបនីយកម្មពាក់ព័ន្ធនោះឡើយ។

8. ជាងនេះទៅទៀត រដ្ឋអំណាច និងរដ្ឋបាលសាធារណៈក៏គួរតែមានការទទួលខុសត្រូវ តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងដី និងអចលនវត្ថុរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ដូចបុគ្គលឯកជន និងសមូហភាពផងដែរ ដូច្នេះគោលការណ៍នៃលទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាល គួរដាក់ឱ្យអនុវត្តចំពោះដី និងអចលនវត្ថុរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ដែលបានចុះបញ្ជីកម្មសិទ្ធិលើកដំបូងរួចហើយផងដែរ។

9. ច្បាប់នេះគួរមានបញ្ញត្តិពិសេសដើម្បីលើកកម្ពស់សមភាពយេនឌ័រ សិទ្ធិសេរីភាពបុគ្គលក្នុងជីវិតឯកជន សម្រួល និងលើកទឹកចិត្តដល់ការចុះបញ្ជីអចលនវត្ថុ ជាទ្រព្យរួមប្តីប្រពន្ធ ឬទ្រព្យអវិភាគរបស់គ្រួសារដែលរួមរស់ជាមួយគ្នា ដោយមានតែអាពាហ៍ពិពាហ៍តាមបែបប្រពៃណី ឬរស់នៅជាមួយគ្នាដោយគ្មានអាពាហ៍ពិពាហ៍អ្វីទាំងអស់ ឬរស់នៅតាមបែបមនុស្សស្រលាញ់ភេទដូចគ្នាក្នុងនីតិវិធីចុះបញ្ជីដីធ្លីលើកដំបូង ព្រមទាំងបញ្ញត្តិពិសេសសម្រាប់ការប្រើប្រាស់សិទ្ធិចាត់ចែងទ្រព្យរួម ឬទ្រព្យអវិភាគ ប្រកបដោយភាពវិជ្ជមាន ដោយភាគីដែលនៅកាន់កាប់ប្រើប្រាស់ ឬគ្រប់គ្រងជាក់ស្តែងលើអចលនវត្ថុ ក្នុងករណីចាំបាច់ ឬនិងករណីចុះចោលគ្នា បែកបាក់បោះបង់គ្រួសារ បាត់ខ្លួន ឬលែងលះតាមបែបប្រពៃណី ឬដោយគ្មានអាពាហ៍ពិពាហ៍ស្របច្បាប់ ដោយមិនចាំបាច់តម្រូវមានសាលក្រម ឬដីកាសម្រេចរបស់តុលាការ ដែលត្រូវឆ្លងកាត់នីតិវិធីវែងឆ្ងាយ ស្មុគ្រស្មាគ និងច្រើនថ្នាក់រាប់ឆ្នាំឡើយ។ ច្បាប់នេះគួរមានចែងអនុគ្រោះពន្ធប្រថាប់ត្រា ក្នុងករណីមានការយល់ព្រមយកទ្រព្យដែលបានចូលកាន់កាប់ជា ភោគៈ ទិញ ទទួលមរតក ឬបានធ្វើលទ្ធកម្មតាមមធ្យោបាយផ្សេងទៀតក្នុងជាលក្ខណៈបុគ្គល ទោះក្នុងពេលនៅលីវ ពេលរស់នៅម្នាក់ឯង ឬពេលរស់នៅជាគ្រួសារមកចុះបញ្ជីលើកដំបូងជាទ្រព្យរួមប្តីប្រពន្ធ ឬទ្រព្យអវិភាគរបស់គ្រួសារដែលរួមរស់ជាមួយគ្នា។

10. លើសពីនេះ ច្បាប់នេះគួរមានបញ្ញត្តិពិសេស អំពីយន្តការដែលមានសមាសភាពចម្រុះអន្តរក្រសួង និងតំណាងអង្គការគាំពារជនជាតិដើមភាគតិចដឹកនាំដោយទីស្តីការគណៈរដ្ឋមន្ត្រី ហើយកំណត់ស្ថាប័នអាណាព្យាបាលសម្រាប់ការកំណត់ព្រំប្រទល់ ដាក់ចេញ និងអនុវត្តវិធានការបណ្តោះអាសន្ន ការដោះស្រាយវិវាទដីធ្លី និងការចាត់ចែងលើដី និងអចលនវត្ថុដែលកាន់កាប់ប្រើប្រាស់ ទាមទារ និងគ្រប់គ្រងដោយសហគមន៍ជនជាតិដើមភាគតិច វត្តអារាមនៃព្រះពុទ្ធសាសនា និងដីកប់សពរបស់សហគមន៍ផ្សេងៗទៀត។

11. ជាការចាំបាច់ដែលរដ្ឋត្រូវលើកកម្ពស់គោលការណ៍ និងការទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ដូចដែលមានកំណត់ក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចដែលប្រទេសកម្ពុជាបានចូលរួមបោះឆ្នោតគាំទ្រនៅឆ្នាំ២០០៧ ជាពិសេស មាត្រា ៣ មាត្រា ៥ មាត្រា ២៥ ដល់មាត្រា ២៧ និង មាត្រា ៣២ និងកាតព្វកិច្ចគោរព ការពារ និងបំពេញសិទ្ធិមនុស្សរបស់ជនជាតិដើមភាគតិច ដូចមានកំណត់ក្នុងសន្ធិសញ្ញាសិទ្ធិ មនុស្សអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន មានដូចជាកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង។

12. ស្របតាមស្មារតីនៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច និងកាតព្វកិច្ចគោរព ការពារ និងបំពេញសិទ្ធិមនុស្ស ដូចមានចែងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន និងអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១១១ (ឆ្នាំ១៩៥៨) ស្តីពីការរើសអើង (ការងារ និងមុខរបរ) ដែលកម្ពុជាជារដ្ឋសមាជិកដែលអនុសញ្ញានេះ ផ្តល់ឱ្យជនជាតិដើមភាគតិចនូវការទទួលបានដោយសមភាពនូវ

ការងារ និងមុខរបរ រួមទាំងមុខរបរលក្ខណៈប្រពៃណី ច្បាប់នេះគួរឆ្លុះបញ្ចាំងថារដ្ឋគោរពសិទ្ធិស្វ័យសម្រេចរដ្ឋបាល អំពីការកំណត់អត្តសញ្ញាណសមាជិកភាព ការគ្រប់គ្រងនូវការចេញចូលសមាជិក និងការគ្រប់គ្រងលើផែនការប្រើប្រាស់ បែងចែក និងអភិវឌ្ឍន៍ផ្ទៃក្នុងនូវដីសមូហភាពគ្រប់ប្រភេទរបស់សហគមន៍ជនជាតិដើមភាគតិច រួមទាំងខ្លឹមសារ និងភាសានៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិច។ ច្បាប់នេះគួរកំណត់ភារកិច្ចឱ្យក្រសួងពាក់ព័ន្ធដូចជា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី ក្រសួងធម្មការ និងសាសនា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឋានៈជាស្ថាប័នជំនាញ ឬស្ថាប័នអាណាព្យាបាលផ្តល់ជំនួយបច្ចេកទេសហិរញ្ញប្បទានអភិវឌ្ឍន៍ និងការកសាងសមត្ថភាពដល់ថ្នាក់ដឹកនាំ និងសមាជិកសកម្មរបស់សហគមន៍ សម្របសម្រួលដោះស្រាយបញ្ហា និងទំនាស់ស្មុគ្រស្មាញដែលសហគមន៍មិនអាចដោះស្រាយដោយខ្លួនឯងបាន និងថ្លឹងថ្លែងសម្រេចឯកភាពលើ ជម្រើសដែលល្អបំផុតសម្រាប់សហគមន៍ពាក់ព័ន្ធនឹងការចាត់ចែងក្បាលដីកម្មសិទ្ធិសមូហភាពណាមួយ តាមសំណើពីគណៈកម្មការរបស់សហគមន៍ស្របតាមស្ថានភាពជាក់ស្តែងនៃករណីនីមួយៗ និងតាមគោលនយោបាយរបស់រដ្ឋដែលលើកកម្ពស់សមធម៌យេនឌ័រ និងសិទ្ធិចូលរួមរបស់ជនជាតិដើមភាគតិច ព្រមទាំងយុវជនក្នុងការដឹកនាំសហគមន៍ និងក្នុងរាល់សកម្មភាពអភិវឌ្ឍន៍ទាំងនៅក្នុង និងក្រៅតំបន់សហគមន៍ជនជាតិដើមភាគតិច ហើយបង្គាប់ឱ្យក្រសួងពាក់ព័ន្ធជៀសវាងនូវការរៀបចំ និងដាក់ឱ្យអនុវត្តនូវទម្រង់ស្តង់ដារ ឬគំរូនៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍។

លើសពីនេះស្របតាមបទដ្ឋានអន្តរជាតិដែលបានលើកឡើងក្នុងវាក្យខ័ណ្ឌខាងលើ និងស្រមតាមគោលនយោបាយជាតិអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២០០៩ ច្បាប់នេះគួរចែងពីគោលការណ៍ព្រមព្រៀងដោយសេរី ជាមុន និងមានព័ត៌មានគ្រប់គ្រាន់ (FPIC)។ FPIC ជាសិទ្ធិជាក់លាក់ដែលទទួលស្គាល់ដោយសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ដែលសេចក្តីប្រកាសតម្រូវឱ្យរដ្ឋពិគ្រោះ និងសហការដោយស្មោះត្រង់ជាមួយជនជាតិដើមភាគតិចតាមរយៈស្ថាប័នតំណាងរបស់ពួកគេ ដើម្បីទទួលបានការព្រមព្រៀងដោយសេរី ជាមុន និងមានព័ត៌មានគ្រប់គ្រាន់ នៅមុនការអនុម័ត និងអនុវត្តវិធានការរដ្ឋបាល ឬវិធានការច្បាប់ដែលប៉ះពាល់ដល់ពួកគេ (មាត្រា ១៩)។ រដ្ឋធ្វើការពិគ្រោះយោបល់មានលក្ខណៈងាយស្រួលយល់បាន និងមានការព្រមព្រៀងពីជនជាតិដើមភាគតិច (មាត្រា ៣២ និង មាត្រា ១០)។

13. ក្រៅពីគោលការណ៍គោរពស្វ័យភាពរដ្ឋបាលរបស់សហគមន៍ជនជាតិដើមភាគតិច ច្បាប់នេះគួរកំណត់គោលការណ៍ និង នីតិវិធីទន់ភ្លន់ ឆាប់រហ័ស សមធម៌ ភាពជាស្ថាពរ និងភាពម៉ឺងម៉ាត់ក្នុងការគោរព និងការពារដីដែលសហគមន៍ជនជាតិដើមភាគតិចទាមទារ ឬដែលបានចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងចំពោះដំណើរការ និងនីតិវិធីនៃការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ស្របតាមការសន្យារបស់រដ្ឋាភិបាលកម្ពុជានៅយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR) ជុំទី៣ ក្នុងខែមករា ឆ្នាំ

២០១៩ (UPR) ដែលកម្ពុជាទទួលយកអនុសាសន៍ពីរ ទាក់ទងជាពិសេសទៅនឹងសេចក្តីត្រូវការនៃការសម្រួលឱ្យមានភាពងាយស្រួលនិ ងឆាប់រហ័សដល់យន្តការ និងដំណើរការចុះបញ្ជីដីធ្លីរបស់ជនជាតិដើមភាគតិច។

14. ច្បាប់នេះគួរមានវិធានសមស្រប និងមានតម្លាភាពក្នុងការចាត់វិធានការរដ្ឋបាលចំពោះម្ចាស់ដីដែលបាត់បង់សញ្ជាតិខ្មែរ និងជនបរទេសដែលរងគ្រោះដោយអំពើបោកបញ្ឆោត ឬក្លែងបន្លំឯកសារអត្តសញ្ញាណសញ្ជាតិខ្មែរដែលបានវិនិយោគដោយសុចរិតលើដីធ្លីនៅកម្ពុជា។

15. ក្នុងកិច្ចធានា និងការពារកម្មសិទ្ធិ និងសិទ្ធិស្របច្បាប់លើដី និងអចលនវត្ថុ ច្បាប់នេះគួរចែងកំណត់ឱ្យ រដ្ឋបាលសុរិយោដី និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទទួលខុសត្រូវជួសជុលការខូចខាតដល់តតីយជនសុចរិតឥតកំហុស (គ្មានចេតនាទុច្ចរិត) ដែលបង្កឡើងដោយការប្រព្រឹត្តកំហុស ឬសេចក្តីសម្រេចមិនត្រឹមត្រូវរបស់មន្ត្រីដែលធ្វើឡើងក្នុងនាមរដ្ឋបាលសុរិយោដី ឬក្រសួងរៀបចំដែនដី។

16. រាល់បញ្ហាដែលគ្របដណ្តប់ក្នុងច្បាប់នេះគួរតែមានវិធានគោល ឬវិធានលម្អិតគ្រប់គ្រាន់សម្រាប់អនុវត្ត ហើយប្រសិនបើមិនទាន់ដឹងត្រូវចែងយ៉ាងណាទេនោះ គួរដកបញ្ហានោះចេញ ហើយទុកចែងក្នុងច្បាប់ដោយឡែកដែលអាចនឹងតាក់តែងបំពេញបន្ថែមឱ្យច្បាប់នេះ។

17. ច្បាប់នេះគួរសម្រួលបន្ធូរបន្ថយអំពីការកំណត់ជាបទល្មើសព្រហ្មទណ្ឌ និងទោសទណ្ឌពាក់ព័ន្ធការប្រើប្រាស់ហឹង្សាបន្តិចបន្តួច ឬនិងការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិបន្តិចបន្តួច ក្នុងទំនាស់ ឬវិវាទទាមទារសិទ្ធិលើដីធ្លីដែលមិនទាន់បានចុះបញ្ជី ដើម្បីលើកកម្ពស់សមធម៌ និងសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លី។

18. ជាចុងក្រោយ ផលប៉ះពាល់នៃច្បាប់នេះចំពោះច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍អនុវត្តជាធរមាន គួរតែមានការសិក្សាច្បាស់លាស់ ហើយចែងរៀបរាប់ក្នុងអវសានប្បញ្ញត្តិ ឬនិងបញ្ចូលក្នុងកំណត់ពន្យល់ជាលាយល័ក្ខណ៍អក្សរ។ លើសពីនេះរដ្ឋគួរតែជៀសវាងនូវការធ្វើច្បាប់ថ្មីជំនួសឱ្យច្បាប់ដែលមានស្រាប់ម្តងហើយម្តងទៀត ប៉ុន្តែគួរធ្វើច្បាប់កែប្រែមាត្រាពាក់ព័ន្ធជាក់លាក់តាមការចាំបាច់ ឬតាមការផ្លាស់ប្តូរនៃគោលនយោបាយសាធារណៈ ដើម្បីឱ្យអ្នកអានច្បាប់អាចដឹងថាអ្វីខ្លះដែលត្រូវបានកែប្រែ និងអ្វីខ្លះដែលរក្សានៅដដែល។

**<u>កំណត់សម្គាល់៖</u>** យោបល់ ឬនិងសំណើកែសម្រួលបន្ថែម ឬលុបចោលសម្រាប់មាត្រានីមួយៗខាងក្រោមនេះជាយោបល់ ឬសំណើកែសម្រួល ឬលុបចោល ចំពោះមាត្រាដែលនៅជាប់ខាងលើយោបល់នីមួយៗ។ ដោយសារកត្តាពេលវេលា និងភាពលំបាកក្នុងការលើកសំណើកែសម្រួលជាក់លាក់ នៅពេលមិនទាន់ការសុខចិត្តទទួលយកគំនិតកែទម្រង់ប្រទាក់ក្រឡាគ្នាដែលមានក្នុងយោបល់មួយចំនួន ថ្វីបើមិនមានសំណើកែសម្រួល

ដាក់លាក់សម្រាប់មាត្រាពាក់ព័ន្ធ ក៏យើងខ្ញុំសូមស្នើឱ្យអ្នកតាក់តែងពិនិត្យសេចក្តីព្រាងច្បាប់នេះ ពិចារណាកែសម្រួលមាត្រាពាក់ព័ន្ធ ផ្អែកតាមស្មារតីនៃគំនិតយោបល់ដែលបានលើកឡើងសម្រាប់មាត្រានោះ។

# មាតិកាទី១
# បទប្បញ្ញត្តិទូទៅ

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១._ គោលដៅនិងគោលបំណង

ច្បាប់នេះ កំណត់អំពីគោលការណ៍ វិធាន និងនីតិវិធីក្នុងការគ្រប់គ្រងដីនិងអចលនវត្ថុដទៃទៀតក្នុងគោលបំណងដើម្បី៖

- ធានាការគ្រប់គ្រងដីនិងអចលនវត្ថុដទៃទៀត ដែលជាមូលដ្ឋានគ្រឹះក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ប្រកបដោយប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន
- ធានាការពារដីនិងអចលនវត្ថុដទៃទៀត របស់រដ្ឋនិងដីរបស់នីតិបុគ្គលសាធារណៈដទៃទៀត
- ធានាការពារកម្មសិទ្ធិនិងសិទ្ធិផ្សេងទៀតពាក់ព័ន្ធនឹងដីនិងអចលនវត្ថុរបស់បុគ្គលឯកជន
- ធានាការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈក្នុងវិស័យដីធ្លី ប្រកបដោយជំនាញវិជ្ជាជីវៈ និរន្តរភាព ឯកភាព ប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ
- ធានាសុវត្ថិភាពនៃការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដីដែលជាទុនរបស់ប្រជាពលរដ្ឋ ប្រកបដោយទំនុកចិត្ត សំដៅបង្កើនប្រាក់ចំណូលនិងលើកកម្ពស់សេដ្ឋកិច្ចគ្រួសារឱ្យកាន់តែប្រសើរឡើង
- បង្កើនជំនឿទុកចិត្តរបស់វិនិយោគិនលើទីផ្សារអចលនទ្រព្យ។

**យោបល់៖** មាត្រានេះ មិនបានរំលេចនូវកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀត របស់សមូហភាព ដែលមិនមែនជារដ្ឋ នីតិបុគ្គលសាធារណៈ ឬបុគ្គលឯកជន ព្រមទាំងមិនបានបង្ហាញច្បាស់នូវការគោរព និងគាំពារឥតងាករេដោយរដ្ឋអំណាចនូវសិទ្ធិឯកជន និងសិទ្ធិសមូហភាពលើដីធ្លី និងទ្រព្យសម្បត្តិផ្សេងទៀត ជាពិសេសសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិចលើដីធ្លីនិងធនធានដែលគ្រប់គ្រងប្រើប្រាស់ជាប្រពៃណីដែលធានាដោយរដ្ឋធម្មនុញ្ញ សន្ធិសញ្ញា និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនានាដែលប្រទេសកម្ពុជាគឺជារដ្ឋភាគី។ ភាពចាំបាច់ក្នុងការកែទម្រង់ និងការជម្រុញដោះស្រាយបញ្ហាសម្បទានដីសេដ្ឋកិច្ច ដែលជាយន្តការផ្តល់ដីរបស់រដ្ឋឱ្យក្រុមហ៊ុនឯកជនវិនិយោគ ដែលនាំមកនូវទាំងផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមាន ហើយដែលផលប៉ះពាល់អវិជ្ជមាន ដូចជាបញ្ហាទំនាស់ដីធ្លីរវាងក្រុមហ៊ុន និងសហគមន៍មូលដ្ឋានជាដើម តម្រូវឱ្យមានការដោះស្រាយប្រកបដោយយកចិត្តទុកដាក់តាមរយៈយន្តការគ្រប់កម្រិត ព្រមទាំងយន្តការថ្នាក់តំបន់និងកម្រិតអន្តរជាតិ ព្រមទាំងក្នុងរដ្ឋសាមីរបស់ក្រុមហ៊ុនបើជាក្រុមហ៊ុនបរទេស។ ភាពចាំបាច់នៃការពិនិត្យមើលឡើងវិញលើការអនុវត្តយន្តការសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ព្រមទាំងការជម្រុញលើកកម្ពស់

បន្ថែមទៀតនូវដំណើរការប្រកបដោយតម្លាភាព សមធម៌ និងសមភាពយេនឌ័រក្នុងការកាន់កាប់ ការទទួលបានកម្មសិទ្ធិ និងការចាត់ចែងដី និងអចលនវត្ថុ។

ភាពចាំបាច់នៃដំណើរការពិនិត្យត្រឹមត្រូវលើសិទ្ធិមនុស្ស (Human rights due diligence) ដែលជាកាតព្វកិច្ចអន្តរជាតិរបស់ធុរកិច្ច (ក្រុមហ៊ុនវិនិយោគលើដីសម្បទានសេដ្ឋកិច្ច) និងរដ្ឋដើម្បីធានាថាពួកគេត្រូវធ្វើការ កំណត់ បង្ការ កាត់បន្ថយ និងមានគណនេយ្យភាព ចំពោះរបៀបដោះស្រាយផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្សដែលបង្កដោយប្រតិបត្តិការរបស់ពួកគេ (គោលការណ៍ណែនាំលេខ ១៧ ដល់លេខ២៤ នៃគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស)។ កាតព្វកិច្ចនេះមានគោលបំណង រួមចំនែកយ៉ាងសកម្មក្នុងការទប់ស្កាត់ផលប៉ះពាល់ជាសក្តានុពលលើសង្គម បរិស្ថាន និងផលប៉ះពាល់សិទ្ធិមនុស្ស ព្រមទាំងការរក្សាទំនាក់ទំនងជាមួយបុគ្គល និងសហគមន៍ដែលរងផលប៉ះពាល់តាមរយៈទំនាក់ទំនងផ្ទាល់។

### សំណើចែងបន្ថែម ដូចខាងក្រោម៖

ច្បាប់នេះ កំណត់អំពីគោលការណ៍ វិធាន និងនីតិវិធីក្នុងការគ្រប់គ្រងដីនិងអចលនវត្ថុដទៃទៀតនៅក្នុង ព្រះរាជាណាចក្រកម្ពុជាស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សន្ធិសញ្ញា និងបទដ្ឋានអន្តរជាតិនានា ដែលប្រទេសកម្ពុជាគឺជារដ្ឋភាគី ក្នុងគោលបំណងដើម្បី៖

- ធានានូវសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរសនិងនារី និងសិទ្ធិលើការកាន់កាប់ប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដី និងអចលនវត្ថុដទៃទៀត
- ធានាសមធម៌ និងសមភាព ផ្នែកយេនឌ័រ និងសង្គម ក្នុងការកាន់កាប់ប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដី និងអចលនវត្ថុដទៃទៀត
- បង្ហាញនូវការទទួលស្គាល់ពេញលេញ និងគាំពារសិទ្ធិរបស់ជនជាតិដើមភាគតិច ស្របតាមស្មារតីនៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច និងកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច វត្តអារាមនៃព្រះពុទ្ធសាសនា សហគមន៍កសិករ និងសហគមន៍ផ្សេងៗទៀតស្របតាមការកំណត់ក្នុងច្បាប់នេះ
- ពង្រឹងប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពឥតលម្អៀងនៃការកំណត់អត្តសញ្ញាណកម្ម និងការវិនិច្ឆ័យក្បាលដី ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ការចុះបញ្ជីដី និងរដ្ឋបាលកិច្ចសុរិយោដី
- បង្កើនជម្រើស និងពង្រឹងសមធម៌ សមភាព តម្លាភាព និងប្រសិទ្ធភាពនៃការបែងចែកដីរដ្ឋតាមរយៈយន្តការ ដីសម្បទានសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ច រួមទាំង គម្រោងសម្បទានដីសេដ្ឋកិច្ចខ្នាតគ្រួសារ
- បង្កើនទំនុកចិត្ត និងការទទួលខុសត្រូវរបស់វិនិយោគិនសម្បទានដីសេដ្ឋកិច្ច និងដៃគូលើការអភិវឌ្ឍន៍ដីសម្បទានសេដ្ឋកិច្ចប្រកបដោយចីរភាព ផលិតភាព និងការទទួលខុសត្រូវចំពោះសង្គម (coporate social responsibility) កម្ពុជា និងដំណើរការត្រឹមត្រូវ ( due diligence)

- លើកកម្ពស់ និងការពារសិទ្ធិបុគ្គល និងសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច ក្នុងដំណើរការគ្រប់គ្រងដីធ្លី និងធនធានដែលប្រើប្រាស់ជាប្រពៃណី។
- ធានាថា មិនមានសកម្មភាពណាមួយអនុវត្តក្រោមច្បាប់នេះ រួមចំណែកដល់ការរំលោភសិទ្ធិលើដីធ្លីរបស់ពលរដ្ឋ សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិចឡើយ។

### មាត្រា២._ វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះដីនិងអចលនវត្ថុដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោបល់៖** យោងតាមការចែងក្នុងមាត្រា១ ច្បាប់នេះមិនមែនអនុវត្តចំពោះតែដី និងអចលនវត្ថុដទៃទៀតប៉ុណ្ណោះទេ ប៉ុន្តែអនុវត្តផងដែរចំពោះសកម្មភាពប្រកបវិជ្ជាជីវៈអង្កេតវាស់វែងសុរិយោដី និងការផ្តល់សេវាសាធារណៈក្នុងវិស័យដីធ្លីផងដែរ។

**សំណើកែសម្រួលដូចខាងក្រោម ៖**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះដី និងអចលនវត្ថុដទៃទៀត ព្រមទាំងរាល់សកម្មភាពប្រកបវិជ្ជាជីវៈអង្កេតវាស់វែងសុរិយោដី និងសកម្មភាពផ្តល់សេវាសាធារណៈក្នុងវិស័យដីធ្លី (រួមមាន រដ្ឋបាលកិច្ចសុរិយោដី ការបែងចែង និងការគ្រប់គ្រងដីធ្លី) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះតាមមធ្យោបាយ ឬធ្វើឡើងដោយអង្គភាព រដ្ឋបាល ឬស្ថាប័នណានៅថ្នាក់ណាក៏ដោយ។

### មាត្រា៣._ និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

**យោបល់៖** ថ្វីត្បិតវាបានក្លាយជាទម្លាប់នៃការតាក់តែងច្បាប់ និងបទដ្ឋានគតិយុត្តនៅកម្ពុជា ក្នុងការដាក់សេចក្តីពន្យល់ ឬនិយមន័យនៃពាក្យគន្លឹះនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធ ប៉ុន្តែគោលបំណង និងការកំណត់និយមន័យទាំងឡាយមិនមានភាពច្បាស់លាស់ ឬមិនអាចយកជាមូលដ្ឋានក្នុងបកស្រាយខ្លឹមសារនៃច្បាប់ និងបទដ្ឋានគតិយុត្តនោះទេ ហើយក៏មិនបានដាក់ឱ្យសមាជិកនៃអង្គនីតិបញ្ញត្តិ ពិនិត្យ ពិភាក្សា និងបោះឆ្នោតអនុម័តលើនិយមន័យនៃពាក្យក្នុងសទ្ទានុក្រម នោះផងដែរទេ ដូច្នេះគួរតែបញ្ឈប់ទម្លាប់ងាយស្រួល ប៉ុន្តែមិនសូវមានប្រយោជន៍នេះ ហើយជំនួសដោយការដាក់បញ្ចូលនូវសេចក្តីពន្យល់ ឬ/និងនិយមន័យនៃពាក្យគន្លឹះៗទាំងឡាយដែលមានប្រើក្នុងច្បាប់នេះ ដើម្បីឱ្យអង្គនីតិបញ្ញត្តិពិនិត្យ ពិភាក្សា និងអនុម័តសម្រាប់ជាមូលដ្ឋានក្នុងការបកស្រាយច្បាប់នេះ។

**សំណើបញ្ចូលសេចក្តីពន្យល់ ឬនិយមន័យនៃពាក្យគន្លឹះទាំងឡាយដូចខាងក្រោម ក្នុងមាត្រានេះ៖**

- ច្បាប់
- បទដ្ឋានគតិយុត្ត
- ដី (ដីធ្លី)
- អចលនវត្ថុ
- រដ្ឋបាលសុរិយោដី
- រដ្ឋបាលដីធ្លី
- រដ្ឋ
- នីតិបុគ្គលសាធារណៈផ្សេងទៀត
- ភោគៈ
- ភោគី
- អ្នកជិតខាង
- តតីយជន
- បុគ្គល
- នីតិបុគ្គលសញ្ជាតិខ្មែរ
- នីតិបុគ្គលសាធារណៈ
- កម្មសិទ្ធិករ (ម្ចាស់កម្មសិទ្ធិ)
- កម្មសិទ្ធិ (សិទ្ធិកម្មសិទ្ធិ)
- កម្មសិទ្ធិសាធារណៈ
- កម្មសិទ្ធិឯកជន
- កម្មសិទ្ធិសមូហភាព
- សហកម្មសិទ្ធិ
- សហកម្មសិទ្ធិករ
- កម្មសិទ្ធិអវិភាគ
- ម្ចាស់កម្មសិទ្ធិអវិភាគ
- ទ្រព្យរួម
- ទ្រព្យអវិភាគ
- ទ្រព្យសម្បត្តិឯកជន (ទ្រព្យសម្បត្តិរបស់បុគ្គលឯកជន)
- ទ្រព្យសម្បត្តិសមូហភាព
- ទ្រព្យសម្បត្តិរដ្ឋ
- ទ្រព្យសម្បត្តិសាធារណៈ

- ដីសាធារណៈរបស់រដ្ឋ
- ដីសាធារណៈរបស់នីតិបុគ្គលសាធារណៈផ្សេងទៀត
- ដីឯកជនរបស់រដ្ឋ
- ដីឯកជនរបស់នីតិបុគ្គលសាធារណៈផ្សេងទៀត
- ដីសម្បទាន
- អឌ្ឍសិទ្ធិ
- អឌ្ឍសិទ្ធិភាព
- សិទ្ធិប្រត្យក្ស
- សិទ្ធិសេវភាព
- សេវភាពសាធារណៈ
- សេវភាពរដ្ឋបាល
- សិទ្ធិផលុបភោគ
- សិទ្ធិជួលអចិន្ត្រៃយ៍
- សិទ្ធិសម្បទានដី
- សម្បទានដី (សម្បទានដីសង្គមកិច្ច សម្បទានដីសេដ្ឋកិច្ច)
- សម្បទានិក
- អ្នកទទួលប្រយោជន៍នៃសម្បទានដីសេដ្ឋកិច្ច
- សិទ្ធិវន្តនៃសម្បទានដីសេដ្ឋកិច្ច
- សិទ្ធិវន្តនៃសម្បទានដីសង្គម
- មុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ច
- សម្បទានផ្សេងៗ
- ជនជាតិដើមភាគតិច
- សហគមន៍ជនជាតិដើមភាគតិច
- គណៈកម្មការសហគមន៍
- សិទ្ធិកាន់កាប់
- សិទ្ធិអាស្រ័យផល
- សិទ្ធិប្រើប្រាស់
- សិទ្ធិគ្រប់គ្រង
- សិទ្ធិចាត់ចែង
- សិទ្ធិបុព្វក្រៃ

- លទ្ធកម្មកម្មសិទ្ធិតាមរយៈភោគៈ
- លទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាល
- និយ័តកម្ម
- អនុប្បយោគ
- អធិប្បយោគ
- អស្សាមិករណ៍
- ការដូកហូត
- ការរឹបអូស
- ប្រយោជន៍សាធារណៈ
- ផលប្រយោជន៍ជាតិ
- ផលប្រយោជន៍ទូទៅ
- តម្រូវការបន្ទាន់របស់ជាតិ
- វិស័យដីធ្លី
- ការស្នើសុំចុះបញ្ជី
- ការផ្ទុកផ្តាក់ឱ្យចុះបញ្ជី
- ការបង្គាប់ឱ្យចុះបញ្ជី
- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- បុគ្គលមានឈ្មោះក្នុងបញ្ជី
- ម្ចាស់បំណុលនៃការចុះបញ្ជី
- កូនបំណុលនៃការចុះបញ្ជី
- ការចុះបញ្ជីលើកដំបូង
- ការចុះបញ្ជីបន្ថែម
- ការចុះបញ្ជីបន្ត
- ការចុះបញ្ជីចម្បង
- ការចុះបញ្ជីអំពីការផ្លាស់ប្តូរ
- ការចុះបញ្ជីអំពីការតម្រូវ
- ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ
- ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- ក្បាលដី
- ឯកតាសុរិយោដី

- ព្រំដាប់មិនដាច់
- ឯកសារសុរិយោដី
- ប្លង់សុរិយោដី
- សម្រង់សុរិយោដី
- សៀវភៅគោលបញ្ជីដីធ្លី
- សៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុ
- ប្រព័ន្ធទិន្នន័យសុរិយោដីឌីជីថល
- បណ្ណសម្គាល់សិទ្ធិ
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ
- បន្ទុក
- និទាឃាទភាព
- លេខាចារឹក
- ប្លង់តម្រង់ជួរ
- ខ្សែបន្ទាត់ជួរតម្រង់ផ្លូវសាធារណៈ
- គណៈកម្មការរដ្ឋបាល
- មន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យ
- មន្ត្រីសុរិយោដី
- គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ រាជធានី ខេត្ត
- គណៈកម្មការសុរិយោដី
- អាជ្ញាធរមានសមត្ថកិច្ច
- អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- អាជ្ញាធរមានសមត្ថកិច្ចផ្តល់សម្បទានដីសង្គមកិច្ច
- អាជ្ញាធរកាន់កាប់ដីរដ្ឋ (អាជ្ញាធរកាន់កាប់ដីទ្រព្យរដ្ឋ)
- ក្រសួងទទួលបន្ទុកវិស័យដីធ្លីសំដៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លើកលែងតែរាជរដ្ឋាភិបាល សម្រេចកែប្រែឈ្មោះក្រសួង ឬផ្លាស់ប្តូរមុខងាររបស់ក្រសួងនេះ ហើយប្រគល់មុខងារទទួលបន្ទុកវិស័យដីធ្លីទៅឱ្យក្រសួងផ្សេង។

## ជំពូកទី២
## សមត្ថកិច្ច

**មាត្រា៤._ សមត្ថកិច្ច**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងវិស័យដីធ្លី។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចផ្ទេរមុខងារមួយចំនួនក្នុង ការគ្រប់គ្រងវិស័យដីធ្លីដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

រដ្ឋបាលសុរិយោដីជួយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការបំពេញការងាររដ្ឋបាលដីធ្លី។

**យោបល់៖** ការប្រើប្រាស់ឈ្មោះពេញរបស់ក្រសួងនាពេលបច្ចុប្បន្នក្នុងច្បាប់នេះអាចនាំឱ្យមានការប៉ះពាល់ និងពិបាកធ្វើវិសោធនកម្មក្នុងករណីមានការកែសម្រួលឈ្មោះ ឬនិងមុខងាររបស់ក្រសួងនេះនាពេលអនាគត ដូច្នេះគួរប្រើពាក្យថា ក្រសួងទទួលបន្ទុកវិស័យដីធ្លី ជំនួសឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ជាការសំខាន់ផងដែរដែលច្បាប់នេះ ចែងច្បាស់ពីការអនុវត្ត និងបំពេញសមត្ថកិច្ច តាមច្បាប់នេះ។

**សំណើកែសម្រួលមាត្រានេះ និងមាត្រាផ្សេងៗទៀត៖**

ឃ្លាថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជំនួសដោយក្រសួងទទួលបន្ទុកវិស័យដីធ្លី។

ក្រសួងទទួលបន្ទុកវិស័យដីធ្លី បំពេញសមត្ថកិច្ចក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យដីធ្លីដោយអនុលោមតាមច្បាប់នេះ។

## ជំពូកទី៣
## គោលការណ៍

**មាត្រា៥._ គោលការណ៍**

ការគ្រប់គ្រងដីនិងអចលនវត្ថុដទៃទៀតត្រូវគោរពគោលការណ៍៖

- ជានាអធិបតេយ្យរបស់រដ្ឋ និងបូរណភាពទឹកដី
- ការពារផលប្រយោជន៍សាធារណៈ និងសិទ្ធិរបស់បុគ្គលឯកជន
- ប្រព័ន្ធឯកភាព
- អភិបាលកិច្ចល្អ សុក្រឹត្យភាព និងភាពឆាប់រហ័ស
- ចីរភាព សមធម៌ និងបរិយាបន្ន។

**យោបល់៖** មាត្រានេះមិនបានរំលេចសិទ្ធិរបស់សមូហភាព និងភាពចាំបាច់ក្នុងការធានានូវផលិតភាពនៃការប្រើប្រាស់ដីធ្លី វិជ្ជាជីវៈ ការទទួលខុសត្រូវ សមធម៌ និងសមភាពយេនឌ័រ សមធម៌ និងសមភាពសង្គម ក្នុងវិស័យដីធ្លី ផងដែរទេ ហើយពាក្យថាប្រព័ន្ធឯកភាព មិនមានលក្ខណៈច្បាស់លាស់។

**សំណើកែសម្រួល៖**

ចំនុចទ្រទី១ កែថា ការពារផលប្រយោជន៍សាធារណៈ តម្កល់ផលប្រយោជន៍ជាតិ ធានា និងការពារសិទ្ធិរបស់បុគ្គលឯកជន សមូហភាព រដ្ឋ និងនីតិបុគ្គលសាធារណៈផ្សេងៗទៀត

ចំនុចទ្រទី៣ កែថា ប្រព័ន្ធសុរិយោដី និងរដ្ឋបាលដីធ្លីដែលមានលក្ខណៈឯកភាពទូទាំងប្រទេស

ចំនុចទ្រទី៥ កែថា ចីរភាព ផលិតភាព វិជ្ជាជីវៈ ការទទួលខុសត្រូវ សមធម៌ និងសមភាពផ្នែកយេនឌ័រ និងសង្គម និងបរិយាបន្ន។

## មាតិកាទី២
## កម្មសិទ្ធិនិងសិទ្ធិផ្សេងទៀតលើអចលនវត្ថុ
## ជំពូកទី១
## គោលការណ៍ទូទៅនៃកម្មសិទ្ធិនិងសិទ្ធិផ្សេងទៀតលើអចលនវត្ថុ

### មាត្រា៦._ ទំនាក់ទំនងរវាងក្រមរដ្ឋប្បវេណីនិងច្បាប់ភូមិបាល

បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះនិយមន័យនៃអចលនវត្ថុ និយមន័យនៃសិទ្ធិប្រត្យក្ស គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់ ប្រភេទនៃសិទ្ធិប្រត្យក្ស គោលការណ៍នៃការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ លើកលែងតែមានកំណត់ផ្សេងនៅក្នុងច្បាប់នេះ។

ក្រៅពីទម្រង់ដែលបានបញ្ញត្តនៅក្នុងក្រមរដ្ឋប្បវេណី កម្មសិទ្ធិនិងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុមានទម្រង់ជាកម្មសិទ្ធិសមូហភាពនិងសហកម្មសិទ្ធិដូចមានបញ្ញត្តក្នុងច្បាប់នេះ។

**យោបល់៖** និយមន័យនៃពាក្យគន្លឹះគួរតែដាក់បញ្ចូលក្នុងមាត្រា ៣ ដូចបានផ្តល់យោបល់ខាងលើ ទោះជាចម្លងទាំងស្រុងចេញពីបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី មកដាក់ក្នុងច្បាប់នេះក៏ដោយ ព្រោះវាផ្តល់ភាពងាយស្រួលដល់អ្នកអានច្បាប់នេះ។ គួរមានការចង្អុលបង្ហាញនូវមាតិកា ជំពូក និងមាត្រានៃបដិប្បញ្ញត្តិ និងប្បញ្ញត្តិអំពីទម្រង់កម្មសិទ្ធិសមូហភាព និងសហកម្មសិទ្ធិ ដែលចែងក្នុងច្បាប់នេះ។

**សំណើកែសម្រួល៖**

និយមន័យនៃអចលនវត្ថុ និងនៃសិទ្ធិប្រត្យក្ស មានកំណត់ក្នុងមាត្រា ៣ នៃច្បាប់នេះ។

បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី មាត្រា ១៣០ ដល់មាត្រា ១៣២ ដែលចែងអំពីគោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយស្របច្បាប់ ប្រភេទនៃសិទ្ធិប្រត្យក្ស គោលការណ៍នៃការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្សនៃអចលនវត្ថុត្រូវយកមកអនុវត្ត លើកលែងតាមការកំណត់ផ្សេងក្នុងមាត្រា ១៥១ នៃច្បាប់នេះ។

ក្រៅពីទម្រង់ដែលបានបញ្ញត្តនៅក្នុងក្រមរដ្ឋប្បវេណី កម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុមានទម្រង់ជាកម្មសិទ្ធិសមូហភាព និងសហកម្មសិទ្ធិដូចមានបញ្ញត្តិក្នុងមាត្រា ៣៤ និង មាត្រា ៤២ នៃច្បាប់នេះ។

### មាត្រា៧._ ការការពារកម្មសិទ្ធិនិងសិទ្ធិផ្សេងទៀតលើដីនិងអចលនវត្ថុដទៃទៀត

បុគ្គលគ្រប់រូបត្រូវគោរពកម្មសិទ្ធិនិងសិទ្ធិផ្សេងទៀតលើដីនិងអចលនវត្ថុដទៃទៀត ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋរបស់នីតិបុគ្គលសាធារណៈដទៃទៀត និងរបស់បុគ្គលឯកជន។

កម្មសិទ្ធិលើអចលនវត្ថុត្រូវបានធានាដោយរដ្ឋនិងគាំពារដោយច្បាប់។

**យោបល់៖** មាត្រានេះមិនបានរំលេចកម្មសិទ្ធិសមូហភាព ហើយមិនបានចែងពន្យល់អំពីវិសាលភាព និងអត្ថន័យនៃការធានាដោយរដ្ឋ និងគាំពារដោយច្បាប់ចំពោះកម្មសិទ្ធិលើអចនវត្ថុ។

**សំណើកែសម្រួល៖**

បុគ្គលគ្រប់រូប ទោះក្នុងឋានៈអ្វី ឬស្ថានភាពគតិយុត្តិបែបណាក៏ដោយ ត្រូវគោរពកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើដី និងអចលនវត្ថុដទៃទៀតដែលជាទ្រព្យសម្បត្តិសាធារណៈ ទ្រព្យសម្បត្តិរបស់សមូហភាព ឬទ្រព្យសម្បត្តិរបស់បុគ្គលឯកជន។

កម្មសិទ្ធិ និងសិទ្ធិផ្សេងៗលើដី និងអចលនវត្ថុដទៃទៀតត្រូវបានធានាដោយរដ្ឋ និងគាំពារដោយច្បាប់ក្នុងន័យថា រដ្ឋទទួលខុសត្រូវចំពោះរាល់ការប៉ះពាល់ ការខូចខាត ឬការបាត់បង់ កម្មសិទ្ធិ និងសិទ្ធិផ្សេងៗលើទ្រព្យសម្បត្តិទាំងឡាយដែលបង្កឡើងដោយអំពើ ឬសេចក្តីសម្រេចរបស់ភ្នាក់ងាររដ្ឋ ទោះក្នុងឋានៈអ្វីក៏ដោយ រួមទាំងការធ្វេសប្រហែស ការភាន់ច្រឡំ ការប្រព្រឹត្តិកំហុសធ្ងន់ដោយចេតនា ការខកខានក្នុងការបំពេញភារកិច្ចតាមច្បាប់កំណត់ ឬការបំពានអំណាចដែលបានធ្វើឡើងក្នុងពេលបំពេញតួនាទីភារកិច្ចជូនរដ្ឋតាមការចែងក្នុងរដ្ឋធម្មនុញ្ញ ច្បាប់នេះ និងច្បាប់ពាក់ព័ន្ធជាធរមានផ្សេងៗទៀតដែលមិនអាចកែប្រែ ឬប៉ះពាល់ដោយបទដ្ឋានគតិយុត្តក្រោមច្បាប់ ឬដែលមានឋានានុក្រមទាបជាងច្បាប់ ឬដោយនីតិវិធីរដ្ឋបាល សេចក្តីសម្រេច ឬការកំណត់ណាមួយរបស់រដ្ឋបាលសាធារណៈថ្នាក់ណាក៏ដោយ។ រដ្ឋធានាថាដី និងអចលនវត្ថុដែលជាកម្មវត្ថុ និងប្រើប្រាស់ក្រោមវិធាននៃសម្បទានមិនមានទំនាស់ជាមួយបុគ្គល សហគមន៍មូលដ្ឋាន និងភាគីដទៃឡើយ។

## មាត្រា៨._ បទប្បញ្ញត្តិស្តីពីកម្មសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ

បទប្បញ្ញត្តិស្តីពីកម្មសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ អនុវត្តទៅលើអចលនវត្ថុទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងច្បាប់នេះ ក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ផ្សេងទៀត។

**យោបល់៖** គួរបញ្ជាក់មាត្រានៃរដ្ឋធម្មនុញ្ញបញ្ចូលពាក្យទ្រព្យសម្បត្តិ ព្រមទាំងរាប់បញ្ចូលនូវច្បាប់អស្សាមិករណ៍ក្នុងមាត្រានេះផង។

**សំណើកែសម្រួល៖**

បទប្បញ្ញត្តិនៃមាត្រា ៤៤ មាត្រា ៥៨ និងមាត្រា ៥៩ នៃរដ្ឋធម្មនុញ្ញ ដែលចែងអំពីទ្រព្យសម្បត្តិរដ្ឋ ការគ្រប់គ្រងដីធ្លី និងកម្មសិទ្ធិលើដីធ្លី កម្មសិទ្ធិរបស់បុគ្គល ឬសមូហភាពត្រូវអនុវត្តចំពោះដី និងអចលនវត្ថុដទៃ ទៀតទាំងអស់នៅកម្ពុជា ស្របតាមគោលការណ៍ លក្ខខណ្ឌ បែបបទ និងនីតិវិធីកំណត់ក្នុងច្បាប់នេះ និងច្បាប់ស្តីពី អស្សាមិករណ៍ ក្រមរដ្ឋប្បវេណី បទប្បញ្ញត្តិនៃច្បាប់ ឬបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានត្រឹមកម្រិតដែលមិនមានទំនាស់ ជាមួយច្បាប់នេះ។

## មាត្រា៩._ ការដកហូតកម្មសិទ្ធិឯកជន និងសិទ្ធិផ្សេងទៀតលើអចលនវត្ថុ

គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតលើអចលនវត្ថុរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។ ការដកហូតត្រូវធ្វើតាមគោលការណ៍ និងនីតិវិធីដែលបញ្ញត្តដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានបន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

**យោបល់៖** គួរចែងបញ្ជាក់ថាការដកហូត គឺជាការធ្វើអស្សាមិករណ៍ដែលអាចធ្វើឡើងដោយយន្តការតំណាងរដ្ឋ តាមគោលការណ៍ លក្ខខណ្ឌ និងនីតិវិធីដែលបញ្ញត្តិក្នុងច្បាប់ស្តីពីអស្សាមិករណ៍ ឬច្បាប់បំពេញបន្ថែម ឬកែសម្រួលច្បាប់អស្សាមិករណ៍ជាធរមាន។

**សំណើកែសម្រួល៖**

គ្មានបុគ្គល ឬសមូហភាពណាមួយត្រូវបានរដ្ឋអំណាចដកហូតជាក់ស្តែង ឬដកហូតដោយបទដ្ឋានគតិយុត្តនូវកម្មសិទ្ធិ សិទ្ធិភោគៈស្របច្បាប់ ឬសិទ្ធិផ្សេងៗទៀតលើដី ឬអចលនវត្ថុដទៃទៀតរបស់ខ្លួន ឬដែលខ្លួនមានសិទ្ធិគ្រប់គ្រង កាន់កាប់ ប្រើប្រាស់ ឬអាស្រ័យផល តាមការកំណត់ក្នុងច្បាប់ លិខិតគតិយុត្ត កិច្ចព្រមព្រៀង ឬកិច្ចសន្យាផ្ទាល់មាត់ ឬលាយល័ក្ខណ៍អក្សរ បានឡើយ ប្រសិនបើការដកហូត (ការធ្វើអស្សាមិករណ៍) នោះមិនមែនដើម្បីប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិដែលត្រូវបានកំណត់ច្បាស់លាស់ក្នុងច្បាប់នោះទេ។

ការដេកហូត (ការធ្វើអស្សាមិករណ៍) ត្រូវធ្វើឡើងដោយសេចក្តីសម្រេចលាយលក្ខណ៍អក្សររបស់យន្តការតំណាងរដ្ឋតាមគោលការណ៍ លក្ខខណ្ឌ និងនីតិវិធីដែលបញ្ញត្តិក្នុងច្បាប់ស្តីពីអស្សាមិករណ៍ ឬច្បាប់បំពេញបន្ថែម ឬកែសម្រួលច្បាប់អស្សាមិករណ៍ជាធរមានបន្ទាប់ពីបានផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌។

ក្នុងករណីណាក៏ដោយបុគ្គល ឬសមូហភាពដែលរងការដេកហូតសិទ្ធិ ដូចមានចែងខាងលើដែលមិនសុខចិត្តនឹងការដោះស្រាយ ឬការផ្តល់សំណងអាចធ្វើបណ្តឹងតវ៉ាទៅតុលាការ និងឬស្វែងរកដំណោះស្រាយតាមយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលមានសមត្ថកិច្ចផ្តល់ដំណោះស្រាយស្ថាពរ។

## មាត្រា១០._ ការលុបចោលរបបកម្មសិទ្ធិមុនឆ្នាំ១៩៧៩

របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់ឡើយ។

**យោបល់៖** មិនមានយោបល់កែប្រែ

## មាត្រា១១._ ការទទួលស្គាល់ភោគៈស្របច្បាប់

មានតែភោគៈត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះ ដែលអាចនាំឱ្យទទួលបានកម្មសិទ្ធិ។

ភោគៈស្របច្បាប់អាចជាកម្មវត្ថុនៃការផ្លាស់ប្តូរ ផ្ទេរសិទ្ធិ ឬជាកម្មវត្ថុនៃកិច្ចការជំនួញបាន។

**យោបល់៖** គួរចែងយោងទៅលក្ខខណ្ឌដែលកំណត់ក្នុងមាត្រា ១១៦ ព្រមទាំងក្នុងមាត្រា ២៩ មាត្រា ១១៧ ដល់មាត្រា ១២០ នៃច្បាប់នេះ និងចែងបញ្ជាក់ក្នុងមាត្រា ១១៦ ថាការកាន់កាប់ជាភោគៈអាចស្របច្បាប់តែក្នុងករណីដែលក្បាលដី ឬអចលនវត្ថុដទៃទៀតជាកម្មវត្ថុនៃការទាមទារសិទ្ធិភោគៈ (សិទ្ធិកាន់កាប់ផ្តាច់មុខដែលមានឆន្ទៈយកធ្វើជាកម្មសិទ្ធិនោះ) មិនមែនជា ឬមិនត្រូវបានកំណត់និយាមការ និងព្រំប្រទល់ច្បាស់លាស់ឥតប្រកែកតវ៉ាបានថាជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មុនពេលមានការចាប់ផ្តើមកាន់កាប់ ហើយបន្តកាន់កាប់ជាប់លាប់ឥតអាក់ខានហួសពី ៣ឆ្នាំជាប់ៗគ្នាផង។

**សំណើចែងបន្ថែម៖**

ភោគៈស្របច្បាប់ គឺជាការកាន់កាប់ផ្តាច់មុខនូវក្បាលដី ឬនិងអចលនវត្ថុដទៃទៀត ដែលមិនទាន់បានចុះបញ្ជីលើកដំបូង ហើយមានឆន្ទៈយកធ្វើជាកម្មសិទ្ធិ តាមលក្ខខណ្ឌដែលកំណត់ក្នុងមាត្រា ១១៦ មាត្រា ២៩ និងមាត្រា ១១៧ ដល់មាត្រា ១២០ នៃច្បាប់នេះ។

## មាត្រា១២._ ការកំណត់សញ្ជាតិរបស់កម្មសិទ្ធិករលើដី

មានតែរូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាកម្មសិទ្ធិករលើដីនៃព្រះរាជាណាចក្រកម្ពុជា។

បុគ្គលមានឧបនិស្ស័យជាកម្មសិទ្ធិករលើដី គឺពលរដ្ឋខ្មែរទាំងអស់ រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ សហគមន៍ សមាគម អង្គការមិនមែនរដ្ឋាភិបាល សហគ្រាសពាណិជ្ជកម្ម និងគ្រប់អង្គការចាត់តាំងដទៃទៀតដែលបានចុះបញ្ជីនិងទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គលដែលមានសញ្ជាតិខ្មែរ។

**យោបល់៖** បច្ចុប្បន្នមិនទាន់មានបទប្បញ្ញត្តិច្បាប់កំណត់អំពីយន្តការស្ថាប័ន និងនីតិវិធីកំណត់លក្ខណៈវិនិច្ឆ័យចុះបញ្ជី និងទទួលស្គាល់សញ្ជាតិខ្មែរ សម្រាប់សហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនានា ដែលមិនមែនជាសហគ្រាសពាណិជ្ជកម្ម ឬនីតិបុគ្គលសាធារណៈ ព្រោះច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងច្បាប់ជាធរមានផ្សេងៗទៀត មិនបានចែងអំពីការកំណត់សញ្ជាតិរបស់សហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទេ។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសហគមន៍កសិករ និងអនុក្រឹត្យស្តីពីនីតិវិធីចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច គ្រាន់តតែមានចែងថាក្រោយពីបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ឬក្រសួងកសិកម្ម សហគមន៍ជនជាតិដើមភាគតិច សហគមន៍កសិកម្ម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ទទួលបានឋានៈជានីតិបុគ្គល ប៉ុន្តែពុំមានការកំណត់សញ្ជាតិរបស់សហគម ន៍ជនជាតិដើមភាគតិច សមាគមន៍កសិកម្ម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទេ ដូច្នេះនាំឱ្យមានសំណួរផ្នែកច្បាប់ថា តើសហគមន៍ជនជាតិដើមភាគតិច សមាគមន៍កសិកម្ម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកអាចមានសិទ្ធិក្នុងការធ្វើជាកម្មសិទ្ធិករពេញលេញផ្តាច់មុខដោយស្របច្បាប់លើដីនៅកម្ពុជា ឬទេ។ ច្បាប់នេះគួរតែផ្តល់បទប្បញ្ញត្តិបំពេញ ភាពខ្វះចន្លោះនេះដោយចែងផ្តល់សិទ្ធិឱ្យរាជរដ្ឋាភិបាលចេញអនុក្រឹត្យ ឬឱ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម និងក្រសួងដែលមានសមត្ថកិច្ចចុះបញ្ជីផ្តល់នីតិបុគ្គលភាពដល់សហគមន៍ជនជាតិដើមភាគតិច សមាគមន៍កសិកម្ម សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬអង្គការចាត់តាំងដទៃទៀតក្នុងការចេញប្រកាសកំណត់លក្ខណៈវិនិច្ឆ័យលម្អិត និងចេញលិខិតបញ្ជាក់ការទទួលស្គាល់សញ្ជាតិខ្មែរដល់សហគមន៍ជនជាតិដើមភាគតិច សមាគមន៍កសិកម្ម សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬអង្គការចាត់តាំងដទៃទៀត។

**សំណើចែងបន្ថែម៖**

លក្ខណៈវិនិច្ឆ័យ បែបបទ និងនីតិវិធីសម្រាប់ការកំណត់សញ្ជាតិខ្មែរ និងការចេញលិខិតបញ្ជាក់ការទទួលស្គាល់សញ្ជាតិខ្មែរដល់សហគមន៍ជនជាតិដើមភាគតិច សហគមន៍កសិកម្ម សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬអង្គការចាត់តាំងដទៃទៀតត្រូវកំណត់ដោយអនុក្រឹត្យ (ឬដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម និងក្រសួងដែលមានសមត្ថកិច្ចចុះបញ្ជីផ្តល់នីតិបុគ្គលភាព)។

### មាត្រា១៣._ ការកំណត់សញ្ជាតិខ្មែររបស់នីតិបុគ្គល

ការកំណត់សញ្ជាតិខ្មែររបស់សហគ្រាសពាណិជ្ជកម្មឬរបស់នីតិបុគ្គលផ្សេងទៀត ដែលអាចជាកម្មសិទ្ធិករនៃដី ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឬតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមានផ្សេងទៀតដែលពាក់ព័ន្ធនឹងនីតិបុគ្គលនោះ។

**យោបល់៖** គួរកែសម្រួលឱ្យស្របតាមការចែងបន្ថែមក្នុងមាត្រា១២ ខាងលើ។

**សំណើកែសម្រួល៖**

ការកំណត់សញ្ជាតិខ្មែររបស់សហគ្រាសពាណិជ្ជកម្ម ឬរបស់នីតិបុគ្គលផ្សេងទៀត ដែលមានឧបនិស្ស័យជាកម្មសិទ្ធិករលើដីនៅកម្ពុជា ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឬបទដ្ឋានគតិយុត្តដែលកំណត់ក្នុងកថាខណ្ឌចុងក្រោយនៃមាត្រា ១២ នៃច្បាប់នេះ។

### មាត្រា១៤._ ការក្លែងបន្លំឯកសារពាក់ព័ន្ធនឹងសញ្ជាតិខ្មែរដោយបុគ្គលសញ្ជាតិបរទេសដើម្បីក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជា

ជនបរទេសដែលបានក្លែងបន្លំឯកសារពាក់ព័ន្ធនឹងសញ្ជាតិខ្មែរដើម្បីក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជា នឹងត្រូវផ្តន្ទាទោសដូចមានចែងក្នុងច្បាប់នេះ។
ទ្រព្យដែលបានមកក្នុងលក្ខខណ្ឌនេះត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋដោយរដ្ឋមិនចេញសំណងឱ្យឡើយ។

**យោបល់៖** គួរមានការយកចិត្តទុកដាក់ និងញែកឱ្យដាច់ពីគ្នារវាងចេតនារបស់ជនបរទេសក្នុងការក្លែងបន្លំឯកសារសញ្ជាតិខ្មែរ និងការរងគ្រោះរបស់ជនបរទេសដោយសារអំពើអូសទាញ ឬអំពើបំពានច្បាប់ក្លែងឯកសារសញ្ជាតិខ្មែរឱ្យជនបរទេស ដោយបុគ្គលផ្សេង ទោះជាមន្ត្រី ឬមិនមែនមន្ត្រីក៏ដោយ។

**សំណើចែងបន្ថែម៖**

សាលាដំបូងរាជធានី ខេត្ត មានសមត្ថកិច្ចផ្តាច់មុខក្នុងការសម្រេចរឹបអូសដីរបស់បុគ្គលនោះ តាមពាក្យសុំរបស់រដ្ឋមន្ត្រីនៃក្រសួងទទួលបន្ទុកវិស័យដីធ្លី ឬតំណាងរបស់រដ្ឋមន្ត្រី និងបន្ទាប់ពីមានការទាញហេតុផល ឬស្តាប់យោបល់របស់បុគ្គល និងភាគីពាក់ព័ន្ធ។

ជនបរទេសដែលត្រូវបានតុលាការរកឃើញថាជាជនរងគ្រោះនៃអំពើអូសទាញ ឬអំពើបំពានច្បាប់លើកលែងឯកសារសញ្ជាតិខ្មែរដោយបុគ្គលផ្សេងទោះជាមន្ត្រី ឬមិនមែនមន្ត្រី ត្រូវមានសិទ្ធិទទួលបានសំណងសមរម្យចំពោះការវិនិយោគរបស់ខ្លួន ចេញពីផលនៃការលក់ដោយបង្ខំនូវទ្រព្យនោះ តាមការកំណត់របស់សាលាដំបូងរាជធានីខេត្តដែលមានសមត្ថកិច្ច។

**មាត្រា១៤.១_ ការបាត់បង់សញ្ជាតិខ្មែរ (បំបែកមកពីមាត្រា១៣)**

ក្នុងករណីសហគ្រាសពាណិជ្ជកម្មឬនីតិបុគ្គលផ្សេងទៀតលែងមានសញ្ជាតិខ្មែរ សហគ្រាសពាណិជ្ជកម្ម ឬនីតិបុគ្គលផ្សេងទៀតនោះ មានកាតព្វកិច្ចផ្តល់ព័ត៌មានទៅរដ្ឋបាលសុរិយោដីអំពីការប្រែប្រួលនេះដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ជាធរមាន។

តុលាការ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវជូនដំណឹងមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីករណីការលះបង់សញ្ជាតិនិងបាត់សញ្ជាតិក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ ចាប់ពីថ្ងៃចេញព្រះរាជក្រឹត្យអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ឬថ្ងៃចូលជាស្ថាពរនៃសេចក្តីសម្រេចរបស់តុលាការ ឬថ្ងៃចូលជាធរមាននៃការកែប្រែលក្ខន្តិកៈ។

បន្ទាប់ពីពេលបានទទួលសេចក្តីជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌខាងលើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញសេចក្តីសម្រេចស្តីពីការចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ និងបញ្ជូនសេចក្តីសម្រេចនោះទៅរដ្ឋបាលសុរិយោដីមានសមត្ថកិច្ចដើម្បីអនុវត្ត។

**យោបល់៖** បទប្បញ្ញត្តិនេះគួរអនុវត្តចំពោះដីកម្មសិទ្ធិ និងដីភោគៈ ហើយដើម្បីតម្លាភាព និងធានានូវសិទ្ធិតវ៉ា ឬជំទាស់របស់សហគ្រាស ឬនីតិបុគ្គលពាក់ព័ន្ធ ក្រសួងទទួលបន្ទុកវិស័យដីធ្លី គួរត្រូវបានតម្រូវឱ្យជូនដំណឹងទៅអ្នកតំណាងរបស់សហគ្រាស ឬនីតិបុគ្គលជាកម្មសិទ្ធិករ ឬភោគីដែលមានឈ្មោះក្នុងសៀវភៅគោលបញ្ជីដីធ្លី ឬ និងសៀវភៅចុះបញ្ជីអចលនវត្ថុពាក់ព័ន្ធអំពីសេចក្តីសម្រេចរបស់ក្រសួងយ៉ាងឆាប់បំផុត តាមមធ្យោបាយដែលមានប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសឱ្យប្រើសិទ្ធិតវ៉ា ឬជំទាស់ចំពោះសេចក្តីសម្រេចនោះ។ ក្នុងករណីមានការតវ៉ា ឬជំទាស់ជាលាយលក្ខណ៍អក្សរ ប្រសិនបើមានហេតុផលសមស្របច្បាស់លាស់អំពីភាពមន្ទិលសង្ស័យចំពោះការលះបង់ ឬបាត់សញ្ជាតិខ្មែរនោះ ក្រសួងទទួលបន្ទុកវិស័យដីធ្លី អាចសម្រេចលុបចោលសេចក្តីសម្រេចរបស់ខ្លួននោះវិញបាន។

ការហាមឃាត់ចំពោះការកែប្រែសិទ្ធិលើដី ក្នុងករណីអចលនវត្ថុពាក់ព័ន្ធ រួមមានទាំងដី និងសំណង់ តើត្រូវអនុវត្តយ៉ាងដូចម្តេច? គួរមានវិធានការសមស្របចំពោះសិទ្ធិលើសំណង់ ឬអនុញ្ញាតឱ្យសុំកែប្រែសិទ្ធិលើដីដោយអនុវត្តគោលនយោបាយស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃទ្រព្យសហកម្មសិទ្ធិដល់ជនបរទេស ដូចមានចែងក្នុងមាត្រា ៥៤ និងមាត្រា ៥៥ នៃច្បាប់នេះ។

**សំណើកែសម្រួល កថាខណ្ឌទី៣ និងចែងបន្ថែមដូចខាងក្រោម៖**

កថាខណ្ឌទី៣ ៖ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌខាងលើ ក្រសួងទទួលបន្ទុកវិស័យដីធ្លី ត្រូវចេញសេចក្តីសម្រេចស្តីពីការចុះបញ្ជីអំពីការហាមឃាត់នូវការបង្កើតសិទ្ធិប្រត្យក្សថ្មីណាមួយ ឬកែប្រែដើម្បីពង្រីកវិសាលភាព ឬពន្យាតថិរវេលានៃសិទ្ធិប្រត្យក្សដែលមានស្រាប់លើដីនោះ ប៉ុន្តែមិនហាមឃាត់ចំពោះការចាត់ចែងដើម្បីរំលត់សិទ្ធិប្រត្យក្សដែលមានស្រាប់លើដីនោះ ឬការស្នើសុំបំប្លែងដីដែលមានអគារសមស្របសម្រាប់

បង្កើតជាទ្រព្យសហកម្មសិទ្ធិ ហើយអនុវត្តស្របតាមបទប្បញ្ញត្តិស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជន នៃអគារសហកម្មសិទ្ធិដល់ជនបរទេសទេ។

ក្រសួងទទួលបន្ទុកវិស័យដីធ្លី ត្រូវជូនដំណឹងលាយល័ក្ខណ៍អក្សរទៅ អ្នកតំណាងស្របច្បាប់របស់សហគ្រាស ឬនីតិបុគ្គលជាកម្មសិទ្ធិករនៃដី ឬភោគីនៃដី ដែលមានឈ្មោះក្នុងសៀវភៅគោលបញ្ជីដីធ្លី ឬនិងសៀវភៅចុះបញ្ជីអចលនវត្ថុពាក់ព័ន្ធអំពីសេចក្តីសម្រេចរបស់ខ្លួនយ៉ាងឆាប់បំផុត តាមមធ្យោបាយដែលមានប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសឱ្យប្រើសិទ្ធិតវ៉ា ឬជំទាស់ចំពោះសេចក្តីសម្រេចនោះ។

ក្នុងករណីមានការតវ៉ា ឬជំទាស់ជាលាយលក្ខណ៍អក្សរ ប្រសិនបើក្រសួងទទួលបន្ទុកវិស័យដីធ្លី យល់ថាមានហេតុផលសមស្របច្បាស់លាស់អំពីភាពមន្ទិលសង្ស័យចំពោះការលះបង់ ឬបាត់សញ្ជាតិខ្មែរនោះ ក្រសួងអាចសម្រេចលុបចោលសេចក្តីសម្រេចរបស់ខ្លួននោះវិញបាន។

## មាត្រា១៥._ កាតព្វកិច្ចរបស់កម្មសិទ្ធិករនៃដីដែលបានបាត់សញ្ជាតិខ្មែរ

កម្មសិទ្ធិករនៃដីដែលបានបាត់សញ្ជាតិខ្មែរ មានកាតព្វកិច្ចធ្វើអនុប្បទាននិងស្នើសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិដីនោះក្នុងរយៈពេលយ៉ាងយូរ ៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃចេញព្រះរាជក្រឹត្យអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ឬថ្ងៃមានសេចក្តីសម្រេចស្ថាពររបស់តុលាការ ឬថ្ងៃចូលជាធរមាននៃការកែប្រែលក្ខន្តិកៈ។ ក្នុងរយៈពេលនេះ កម្មសិទ្ធិករនៃដីដែលបានបាត់សញ្ជាតិខ្មែរ អាចបន្តប្រើប្រាស់និងអាស្រ័យផលដីនោះដោយរក្សាស្ថានភាពដើមឱ្យនៅដដែល ប៉ុន្តែមិនអាចបង្កើតសិទ្ធិថ្មីផ្សេងទៀត ទាំងសិទ្ធិប្រត្យក្ស ទាំងសិទ្ធិលើបំណុលពាក់ព័ន្ធនឹងដីនោះដល់តតិយជន។

ក្នុងករណីកម្មសិទ្ធិករនៃដីដែលបានបាត់សញ្ជាតិខ្មែរ ពុំអាចធ្វើអនុប្បទាននិងស្នើសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិដីនោះក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបង្គាប់ទៅរដ្ឋបាលសុរិយោដីមានសមត្ថកិច្ចឱ្យដាក់ពាក្យស្នើសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុជាដីនោះទៅតុលាការ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់កម្មសិទ្ធិករដែលបានបាត់សញ្ជាតិខ្មែរ អំពីការស្នើសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុជាដីនោះដោយធ្វើតាមវិធីលក់ដោយបង្ខំ។ កម្មសិទ្ធិករនៃដីដែលបានបាត់សញ្ជាតិខ្មែរមិនអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដីដែលត្រូវបានចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិឡើយ។ ប៉ុន្តែកម្មសិទ្ធិករនោះ អាចធ្វើសកម្មភាពចាត់ចែងទាក់ទងនឹងការរលត់សិទ្ធិដែលត្រូវបានបង្កើតលើដីនោះបាន។

**យោបល់៖** គួរលុបចោលវាក្យខណ្ឌចុងក្រោយនៃកថាខណ្ឌទី១ ព្រោះមានចែងស្រដៀងគ្នាក្នុងកថាខណ្ឌទី៣ នៃមាត្រា ១៤-១ រួចហើយ។ លើសពីនេះ ដោយសារក្រសួងទទួលបន្ទុកវិស័យដីធ្លី មានសិទ្ធិ និងកាតព្វកិច្ច តាមការចែងក្នុងមាត្រា ១៤-១ ក្នុងការចេញសេចក្តីសម្រេចស្តីពីការចុះបញ្ជីអំពីការហាមឃាត់នូវការបង្កើតសិទ្ធិប្រត្យក្សថ្មីណាមួយ ឬកែប្រែដើម្បីពង្រីកវិសាលភាព ឬពន្លាតថិរវេលានៃសិទ្ធិប្រត្យក្សដែលមានស្រាប់លើដីនោះ ដោយគ្មានកម្រិតអំឡុងពេល

សុពលភាពនៃការហាមឃាត់នោះទេ ដូច្នេះមិនចាំបាច់មានការស្នើសុំអនុវត្តដោយបង្ខំនូវការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិទៀតឡើយ។ អ្វីដែលគួរចែងបន្ថែមក្នុងមាត្រានេះ គឺការស្នើសុំរឹបអូសដើម្បីដាក់លក់ដោយបង្ខំ និងគួរចែងបញ្ជាក់អំពីរដ្ឋបាលសុរិយោដីមានសមត្ថកិច្ចក្នុងការដាក់ពាក្យស្នើសុំរឹបអូសដើម្បីដាក់លក់ដោយបង្ខំ។
ជាការចាំបាច់ត្រូវមានការចែងបន្ថែមទៀតថាការរឹបអូសដើម្បីដាក់លក់ដោយបង្ខំ មិនត្រូវប៉ះពាល់ដល់ លុបចោល ឬតម្រូវឱ្យដោះបន្ទុកនូវ សិទ្ធិប្រត្យក្សដែលបានចុះបញ្ជីស្រាប់ និងអំពីការចាត់ចែងប្រាក់ដែលបានមកពី ការលក់ដោយបង្ខំនោះ ព្រមទាំងការកំណត់លំដាប់អាទិភាពនៃថ្លៃសោហ៊ុយគ្រប់គ្រងដីដោយរដ្ឋបាលរាជធានី ខេត្ត ក្នុងអំឡុងពេលរឹបអូសដីដើម្បីដាក់លក់ដោយបង្ខំ។

**សំណើកែសម្រួល និងចែងបន្ថែម ដូចខាងក្រោម៖**

ក្នុងកថាខណ្ឌទី១៖ បន្ថែមពាក្យថា ឬ ភោគី លុបចោលឃ្លាថា ប៉ុន្តែមិនអាចបង្កើតសិទ្ធិថ្មីផ្សេងទៀត ទាំងសិទ្ធិប្រត្យក្ស ទាំងសិទ្ធិលើបំណុលពាក់ព័ន្ធនឹងដីនោះដល់តតីយជនឡើយ។

ក្នុងកថាខណ្ឌទី ២៖ បន្ថែមពាក្យថា ឬភោគី ហើយកែឃ្លាចុងក្រោយទៅជា ក្រសួងទទួលបន្ទុកវិស័យដីធ្លីត្រូវបង្គាប់ទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត នៃទីតាំងក្បាលដីពាក់ព័ន្ធឱ្យដាក់ពាក្យស្នើសុំទៅសាលាដំបូងរាជធានីខេត្តដែលមានសមត្ថកិច្ចលើទីតាំងដី រឹបអូសដីនោះដើម្បីដាក់លក់ដោយបង្ខំស្របតាមនីតិវិធីដែលកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬនីតិវិធីពិសេសដែលកំណត់ដោយច្បាប់ដោយឡែក។

លុបចោលកថាខណ្ឌចុងក្រោយ ព្រោះតុលាការជាអ្នកអនុវត្តនីតិវិធីដាក់លក់ដោយបង្ខំ មិនមែនក្រសួងទទួលបន្ទុកវិស័យដីធ្លី រដ្ឋបាលសុរិយោដី ឬរដ្ឋបាលរាជធានី ខេត្ត ជាអ្នកអនុវត្តនោះទេ។

ការចែងបន្ថែម៖ ការរឹបអូសដើម្បីដាក់លក់ដោយបង្ខំ ព្រមទាំងការអនុវត្តនូវការលក់ដោយបង្ខំ មិនត្រូវប៉ះពាល់ដល់លុបចោល ឬតម្រូវឱ្យដោះបន្ទុកនូវសិទ្ធិប្រត្យក្សដែលបានចុះបញ្ជីស្រាប់ទេ។ ក្នុងការអនុវត្តនីតិវិធីនៃការលក់ដោយបង្ខំនូវដីដែលបានរឹបអូសនោះ តុលាការត្រូវកំណត់អំពីសោហ៊ុយគ្រប់គ្រងដីសមស្រប ដែលរដ្ឋបាលរាជធានី ខេត្ត បានចំណាយក្នុងអំឡុងពេលរឹបអូសដីដើម្បីដាក់លក់ដោយបង្ខំ ហើយទូទាត់សោហ៊ុយចំណាយលើការគ្រប់គ្រងដីនោះជូនរដ្ឋបាលរាជធានី ខេត្ត បន្ទាប់ពីកាត់ប្រាក់ប្រដាប់ក្តី ថ្លៃសេវាសុរិយោដី ពន្ធប្រថាប់ត្រា បន្ទុកពន្ធផ្សេងៗលើដីនោះ និងសោហ៊ុយដែលរដ្ឋបាលសុរិយោដីរាជធានីខេត្តបានចំណាយពាក់ព័ន្ធនឹងការដាក់ពាក្យស្នើសុំតុលាការឱ្យរឹបអូសដីដើម្បីដាក់លក់ដោយបង្ខំ ហើយប្រាក់នៅសល់ពីការលក់ដីនោះ ត្រូវប្រគល់ជូន កម្មសិទ្ធិករ ឬភោគីដែលបានលះបង់ ឬបាត់សញ្ជាតិខ្មែរនោះ។

**មាត្រា១៦._ សេចក្តីសម្រេចស្តីពីការចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិបានក្នុងករណីកម្មសិទ្ធិករនៃដីបានបាត់សញ្ជាតិខ្មែរ**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចចេញសេចក្តីសម្រេចស្តីពីការចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិបាន ទោះបីដីនោះត្រូវបានចុះបញ្ជីអំពីការអនុវត្តដោយបង្ខំឬការចាត់ចែងរក្សាការពារ ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីរួចហើយក៏ដោយ។

ក្នុងករណីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរកឃើញថា នីតិបុគ្គលបានបាត់សញ្ជាតិខ្មែរ ហើយប៉ុន្តែមិនបានធ្វើការផ្លាស់ប្តូរលក្ខន្តិកៈទេ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញសេចក្តីសម្រេចជាបន្ទាន់ស្តីពីការចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ រួចបញ្ជូនសេចក្តីសម្រេច នោះទៅរដ្ឋបាលសុរិយោដីមានសមត្ថកិច្ច ដើម្បីអនុវត្ត។

សិទ្ធិទាំងឡាយដែលមានលើដីរបស់កម្មសិទ្ធិករដែលបានបាត់សញ្ជាតិខ្មែរ មុនពេលចេញសេចក្តីសម្រេចស្តីពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ និងដែលបានបំពេញលក្ខខណ្ឌតតាំងត្រឹមត្រូវ ត្រូវបានរក្សាការពារ។

**យោបល់៖** រាល់សិទ្ធិប្រត្យក្សដែលបានចុះបញ្ជីតាមពាក្យស្នើសុំរបស់បុគ្គលដែលមានសិទ្ធិស្នើសុំចុះបញ្ជី ឬតាមការចាត់ចែងរក្សាការពារ ឬតាមការអនុវត្តដោយបង្ខំ ដោយស្ថាប័នមានសមត្ថកិច្ចស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី ឬនីតិវិធីពិសេសផ្សេងទៀតដែលកំណត់ដោយច្បាប់ មុនពេលមានដីកាសម្រេចរឹបអូសដីដើម្បីដាក់លក់ដោយបង្ខំ ស្របតាមការចែងក្នុងមាត្រា ១៥ ខាងលើនេះ មិនអាចប៉ះពាល់ ឬលុបចោលបានឡើយ។ ក្រសួងទទួលបន្ទុកវិស័យដីធ្លីគ្រាន់តែមានសិទ្ធិ និងកាតព្វកិច្ច ចេញសេចក្តីសម្រេចស្តីពីការចុះបញ្ជីអំពីការហាមឃាត់នូវការបង្កើតសិទ្ធិប្រត្យក្សថ្មីណាមួយ ឬកែប្រែដើម្បីពង្រីកវិសាលភាព ឬពន្លាតថិរវេលានៃសិទ្ធិប្រត្យក្សដែលមានស្រាប់លើដីនោះប៉ុណ្ណោះ។ ប្រសិនបើក្រសួងទទួលបន្ទុកវិស័យដីធ្លី មានព័ត៌មានថា នីតិបុគ្គលណាមួយបានបាត់ឋានៈគតិយុត្តិជាសញ្ជាតិខ្មែរ ក្រសួងនេះអាចត្រឹមមានសិទ្ធិដាក់ពាក្យស្នើសុំឱ្យតុលាការមានសមត្ថកិច្ចកំណត់ឋានៈគតិយុត្តិនោះ មុននឹងក្រសួងនេះមានសិទ្ធិ និងកាតព្វកិច្ចតាមការចែងក្នុងមាត្រា ១៤-១ និងមាត្រា ១៥ ខាងលើ។

**សំណើលុបចោល៖**

លុបកថាខណ្ឌទាំង ៣ នៃមាត្រា ១៦ នេះចោល ហើយជំនួសដោយកថាខណ្ឌដែលចែងថា ក្នុងករណីដែលក្រសួងទទួលបន្ទុកវិស័យដីធ្លីមានព័ត៌មានថា នីតិបុគ្គលណាមួយបានបាត់សញ្ជាតិខ្មែរហើយ ប៉ុន្តែមិនបានធ្វើការផ្លាស់ប្តូរលក្ខន្តិកៈទេ ក្រសួងទទួលបន្ទុកវិស័យដីធ្លីត្រូវដាក់ពាក្យស្នើសុំទៅតុលាការមានសមត្ថកិច្ចឱ្យកំណត់ឋានៈគតិយុត្តិពាក់ព័ន្ធនឹងសញ្ជាតិនោះ មុននឹងក្រសួងនេះអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនតាមការចែង ក្នុងមាត្រា ១៤-១ និងមាត្រា ១៥ ខាងលើ។

### មាត្រា១៧._ ការគ្រប់គ្រងដីដែលជាកម្មវត្ថុនៃការចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ

ដីដែលជាកម្មវត្ថុនៃការចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត។

ក្នុងករណីសិទ្ធិរបស់តតិយជនដែលអាចតតាំងចំពោះការចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ ជាសិទ្ធិបង្កើតដោយកិច្ចសន្យាយកតម្លៃថ្នូរ រដ្ឋបាលរាជធានី ខេត្ត ត្រូវទទួលនិងគ្រប់គ្រងតម្លៃថ្នូរនោះដោយព្យាយាមប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។

ការចំណាយលើការបង់ពន្ធផ្សេងៗ ការចំណាយលើការអនុវត្តនីតិវិធីលក់ដោយបង្ខំ ការចំណាយលើការគ្រប់គ្រងនិងថែរក្សាដីដែលជាកម្មវត្ថុនៃការរឹបអូស និងការចំណាយចាំបាច់ផ្សេងៗទៀត ជាបន្ទុករបស់កម្មសិទ្ធិករនៃដីដែលបានបាត់សញ្ជាតិខ្មែរនោះ។

**យោបល់៖** ក្នុងអំឡុងពេល ៦ ខែ តាមការចែងក្នុងកថាខណ្ឌទី១ នៃមាត្រា ១៥ កម្មសិទ្ធិករ ឬភោគីនៃដីនៅតែមានសិទ្ធិគ្រប់គ្រងដីរបស់ខ្លួន គ្រាន់តែត្រូវបានហាមឃាត់មិនឱ្យបង្កើតសិទ្ធិប្រត្យក្សថ្មី ឬកែប្រែពង្រីក ឬពន្យាពេលនៃសិទ្ធិប្រត្យក្សដែលមានស្រាប់ ហើយក៏មិនចាំបាច់ឱ្យមានការរឹបអូសដីដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ ឬកែប្រសិទ្ធភាពនោះទេ។ រដ្ឋបាលរាជធានី ខេត្ត អាចទទួលភារកិច្ចគ្រប់គ្រងដីនោះ នៅពេលដែលកម្មសិទ្ធិករ ឬភោគីនៃដីនេះ ខកខានមិនបានអនុវត្តកាតព្វកិច្ចដែលកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា ១៥ ហើយរដ្ឋបាល សុរិយោដីរាជធានី ខេត្ត តាមបង្គាប់របស់ក្រសួងទទួលបន្ទុកវិស័យដីធ្លី បានដាក់ពាក្យស្នើសុំទៅសាលាដំបូង មានសមត្ថកិច្ចលើទីតាំងដីឱ្យរឹបអូសដីដើម្បីដាក់លក់ដោយបង្ខំ ហើយតុលាការបានសម្រេចឱ្យរឹបអូសដី តាមការស្នើសុំនោះ។ ដូច្នេះ មាត្រានេះគួរកែសម្រួល ការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ ទៅជាការរឹបអូសដី ដើម្បីដាក់លក់ដោយបង្ខំ។

**សំណើកែសម្រួល៖**

ក្នុងកថាខណ្ឌទី១ និងទី២ ជំនួសឃ្លាថា ការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ ដោយឃ្លាថា ការរឹបអូសដីដើម្បីដាក់លក់ដោយបង្ខំ។

### មាត្រា១៨._ ការអនុវត្តក្រមនិតិវិធីរដ្ឋប្បវេណី

សេចក្តីសម្រេចស្តីពីការចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិដែលមានចែងក្នុងច្បាប់នេះ ត្រូវមានអានុភាពដូចគ្នានឹងលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

នីតិវិធីនៃការអនុវត្តដោយបង្ខំដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជីអំពីការរឹបអូសដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិផ្អែកតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** គួរបញ្ជាក់ថាសេចក្តីសម្រេចអំពីការរឹបអូសដី ជាសេចក្តីសម្រេចរបស់តុលាការ ដើម្បីដាក់លក់ដោយបង្ខំ មិនមែនដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិទេ រីឯក្រសួងទទួលបន្ទុកវិស័យដីធ្លីមានសិទ្ធិ និងកាតព្វកិច្ចត្រឹមតែចេញសេចក្តីសម្រេចស្តីពីការចុះបញ្ជីអំពីការហាមឃាត់ការបង្កើតសិទ្ធិថ្មី ឬកែប្រែពង្រីក ឬពន្យារពេលនៃសិទ្ធិប្រត្យក្សដែលមានស្រាប់។

**សំណើលុបចោល៖** លុបមាត្រានេះចោលទាំងស្រុង។

## មាត្រា១៩._ ការតាំងបទប្បញ្ញត្តិបន្ថែមនិងការតាំងបដិប្បញ្ញត្តិចំពោះនៃច្បាប់នេះ

របបគតិយុត្តនៃកម្មសិទ្ធិលើអចលនវត្ថុ ប្រែប្រួលទៅតាមតម្រូវការរបស់សង្គមខ្មែរ មានជាអាទិ៍ ដីកសិកម្ម ព្រៃឈើ ផ្លូវទឹក ត្រពាំង បឹងបួ ឬធារទឹក ត្រើយសមុទ្រ ឬច្រាំងទន្លេ ដីស្រែអំបិល អចលនវត្ថុក្នុងទីក្រុង និងដីសម្រាប់សាងសង់តំបន់អភិវឌ្ឍឧស្សាហកម្ម សួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ប្រព័ន្ធទឹកកខ្វក់ និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

ច្បាប់ដោយឡែកផ្សេងទៀតត្រូវបំពេញបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះឬតាំងបដិប្បញ្ញត្តិដើម្បីរក្សានូវការចាំបាច់ខាងសង្គម សេដ្ឋកិច្ច ការរៀបចំដែនដី នគរូបនីយកម្ម និងលំនៅឋាន។

លិខិតបទដ្ឋានក្រោមច្បាប់ ត្រូវកំណត់លម្អិតនូវរបបផ្សេងៗនៃកម្មសិទ្ធិដោយគោរពតាមបទប្បញ្ញត្តិនៃច្បាប់។

**យោបល់៖** ការរៀបរាប់ក្នុងប្រការនេះ មិនមែនជាប្រភេទរបបគតិយុត្តនៃកម្មសិទ្ធិ ប៉ុន្តែជាប្រភេទផ្សេងៗនៃអចលនវត្ថុ។ របបគតិយុត្តិនៃកម្មសិទ្ធិមានដូចជា កម្មសិទ្ធិសាធារណៈ កម្មសិទ្ធិសមូហភាព កម្មសិទ្ធិឯកជន សហកម្មសិទ្ធិ កម្មសិទ្ធិអវិភាគ ទ្រព្យរួមប្តីប្រពន្ធ និងអឌ្ឍសិទ្ធិ។ ប្រសិនបើមានបំណងចង់ចែងបន្ថែមអំពីប្រភេទដីដែលចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈផ្សេងៗទៀត ចូរបញ្ចូលនូវសេចក្តីបន្ថែមនោះក្នុងមាត្រា ២៤ ខាងក្រោមនេះ។ ប្លង់គោលនៃនគរូបនីយកម្ម និងប្លង់កំណត់តំបន់ប្រើប្រាស់ដី អាចកំណត់ ឬកម្រិតនូវលក្ខណៈ និងប្រភេទនៃការប្រើប្រាស់សិទ្ធិលើដីពាក់ព័ន្ធ ដូច្នេះតើត្រូវមានបទដ្ឋានក្រោមច្បាប់កំណត់លម្អិតនូវរបបគតិយុត្តិ ផ្សេងៗ ឬទេ? នៅពេលមានច្បាប់ដោយឡែក ឬច្បាប់បន្ថែមបំពេញ ឬតាំងបដិប្បញ្ញត្តិចំពោះច្បាប់នេះ ដែលចេញក្រោយច្បាប់នេះ គឺត្រូវតែអនុវត្តតាមច្បាប់នោះហើយ ដូច្នេះគ្មានប្រយោជន៍អ្វីក្នុងការបញ្ចូលមាត្រា ១៩ ក្នុងច្បាប់នេះទេ។

ជាការចាំបាច់ដែលត្រូវគោរពគោលការណ៍ថា រាល់ច្បាប់ដោយឡែក ឬច្បាប់បន្ថែមបំពេញ ឬតាំងបដិប្បញ្ញត្តិចំពោះច្បាប់នេះ និងបទដ្ឋានគតិយុត្តក្រោមច្បាប់ មិនត្រូវមានអានុភាពជាការដកហូត លុបចោល ឬកាត់បន្ថយមួយផ្នែក ឬទាំងស្រុងតាមអំណាចច្បាប់ ឬអំណាចបទដ្ឋានគតិយុត្តនូវសិទ្ធិប្រត្យក្សស្របច្បាប់របស់ សមូហភាព ឬរបស់បុគ្គលឯកជនដែលមានលើអចលនវត្ថុពាក់ព័ន្ធមុនពេលមានច្បាប់ដោយឡែក ឬច្បាប់បន្ថែម ឬនិងបទដ្ឋានគតិយុត្តថ្មី

ដោយគ្មានការផ្តល់សំណងសមរម្យ និងយុត្តិធម៌ ឬដោយគ្មានការយល់ព្រមពីម្ចាស់សិទ្ធិ ប្រត្យក្សឡើយ។ មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញ អនុវត្តចំពោះទាំងការដកហូតជាក់ស្តែង និងការដកហូត តាមអំណាចច្បាប់ ឬអំណាចបទដ្ឋានគតិយុត្ត។

**សំណើលុបចោល ៖** លុបមាត្រា ១៩ នេះចោលទាំងស្រុង។

## ជំពូកទី២
## កម្មសិទ្ធិសាធារណៈ

### មាត្រា២០._ កម្មសិទ្ធិករជារដ្ឋ

រដ្ឋជាកម្មសិទ្ធិករនៃអចលនវត្ថុដូចខាងក្រោម៖

១. អចលនវត្ថុទាំងឡាយក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ។

២. អចលនវត្ថុដែលបានមកពីការលក់ទិញ ការដូរ ប្រទានកម្ម ឬអច្ច័យទាន។

៣. អចលនវត្ថុនិទាយាទភាព។

៤. អចលនវត្ថុគ្មានម្ចាស់។

៥. អចលនវត្ថុដែលបានពីការអនុវត្តសិទ្ធិពិសេសរបស់រដ្ឋ។

៦. អចលនវត្ថុដែលម្ចាស់ប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត។

៧. អចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃការយកធ្វើជារបស់ឯកជនតាមច្បាប់ ឬ ដែលមិនមែន កំពុងត្រូវបានកាន់កាប់ជារបស់ឯកជនស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

៨. អចលនវត្ថុដទៃទៀតដែលច្បាប់កំណត់ថាជាទ្រព្យរដ្ឋឬរដ្ឋជាកម្មសិទ្ធិករ។

រដ្ឋបរទេសអាចជាកម្មសិទ្ធិករនៃដីដែលស្ថានទូតនិងស្ថានកុងស៊ុលរបស់រដ្ឋបរទេសនោះតាំងនៅ អនុលោមតាម អនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូតឆ្នាំ១៩៦១ និងទំនាក់ទំនងកុងស៊ុលឆ្នាំ១៩៦៣ និងដោយឈរលើ គោលការណ៍គោលការណ៍បដិការ។

**យោបល់៖** រដ្ឋធម្មនុញ្ញ មាត្រា ៥៨ ចែងថា ៖

*"ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ។*

*ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរបស់រដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់។"*

តាមខ្លឹមសារនៃមាត្រារបស់រដ្ឋធម្មនុញ្ញ ដើម្បីចាត់ទុកថាជាទ្រព្យសម្បត្តិរបស់រដ្ឋ លុះត្រាតែមានការកំណត់ច្បាស់លាស់ដោយច្បាប់ ហើយមិនមែនមានន័យថាទ្រព្យទាំងអស់នោះ ត្រូវតែ ឬសុទ្ធតែជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនោះទេ។ ម្យ៉ាងទៀត ភ្នំ កោះ សមុទ្រដែនដី ឆ្នេរសមុទ្រ ទន្លេ ព្រែក ស្ទឹង បឹង គឺជាភាគចំណែកនៃដីធ្លី។

ជាងនេះទៅទៀត មិនមែនព្រៃឈើទាំងអស់សុទ្ធតែជាសម្បត្តិរបស់រដ្ឋនោះទេ (សូមមើលមាត្រា ១០ នៃច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២)។

សូមមើលមាត្រា ១៧៩ ដល់១៨៦ នៃក្រមរដ្ឋប្បវេណី និងមាត្រា ២៩ ដល់មាត្រា ៣៥ នៃច្បាប់ភូមិបាលឆ្នាំ១៩៩២ ព្រមទាំង មាត្រា ១២ មាត្រា ១៥ និងមាត្រា ៩៩ ដល់មាត្រា ១០៥ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ផង។

ហើយច្បាប់ជាធរមាន មិនទទួលស្គាល់របបកម្មសិទ្ធិលើដីធ្លី មុនឆ្នាំ១៩៧៩ ខណៈដែលចន្លោះពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨៩ ដីធ្លីទាំងអស់នៅកម្ពុជា ជាសម្បត្តិរបស់រដ្ឋ (តាមស្មារតី មាត្រា ១ និងមាត្រា ៤ នៃច្បាប់ភូមិបាលឆ្នាំ១៩៩២ ចែងថា ដីធ្លីនៃរដ្ឋកម្ពុជា ជាសម្បត្តិរបស់រដ្ឋ ហើយ រ៉ែ បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រជាតិ ដែលមាននៅក្នុងដី នៅលើដី នៅបាតសមុទ្រ និងនៅក្រោមបាតសមុទ្រ ក៏ជាសម្បត្តិរបស់រដ្ឋ) ដែលក្នុងនោះដីធ្លីខ្លះមានលក្ខណៈសម្បត្តិជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ (ដែលហាមមិនមានសិទ្ធិឯកជន តាមស្មារតីមាត្រា ៥ នៃច្បាប់ភូមិបាលឆ្នាំ១៩៩២ គឺដែនបំរុងរុក្ខា នេសាទ អាងតំកល់ទឹកស្រោចស្រព បរិវេណមណ្ឌលរ៉ែ មណ្ឌលបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រជាតិ វត្តអារាម ទីស្មសាន សាលារៀន សួន និងទួលសាធារណៈ អតីតសំណង់រដ្ឋ ដីបំរុងនិងដីចំណីសំរាប់ថ្នល់ ដីបំរុង និងដី សំរាប់ផ្លូវដែក ទន្លេ សមុទ្រ ពោល ពុំមានរាប់បញ្ចូលកោះដែលដុះថ្មី ឬចាស់នោះទេ) ព្រមទាំងហាមមិនឱ្យមានការសាងសង់លើទីធ្លាដែលមានលក្ខណៈ សាធារណៈ លើកលែងតែសំណង់ ឬលំនៅដ្ឋានធុនស្រាលបណ្តោះអាសន្ន (មាត្រា ១២ នៃច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤) ហើយសល់ពីនេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ លើកលែងតែមានការកំណត់ចំណាត់ថ្នាក់សារជាថ្មី ស្របតាមច្បាប់អនុប្រយោគ (មាត្រា ១៦ នៃច្បាប់ភូមិបាលឆ្នាំ ២០០១)។

ចាប់ពីឆ្នាំ១៩៨៩ រហូតដល់ថ្ងៃដែលច្បាប់ភូមិបាល ឆ្នាំ២០០១ ចូលជាធរមាន (៣១ សីហា ២០០១) ដីធ្លីជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋជាច្រើន នៅគ្រប់ភូមិសាស្ត្ររដ្ឋបាល ត្រូវបានប្រជាពលរដ្ឋខ្មែរកាន់កាប់ ប្រើប្រាស់អាស្រ័យផលក្នុងរូបភាពជាភោគៈស្របច្បាប់ ដែលរដ្ឋមានកាតព្វកិច្ចការពារ ដូចករណីសិទ្ធិកម្មសិទ្ធិដែរ ហើយរដ្ឋមិនអាចសម្រេច តាមឆន្ទានុសិទ្ធិក្នុងការបដិសេធ លុបចោល មោឃៈ ឬដកហូត តាមការចេញ សេចក្តីសម្រេចរដ្ឋបាល ឬបទដ្ឋានគតិយុត្តក្រោមច្បាប់បានទេ។ សេចក្តីសម្រេចរដ្ឋបាល ឬបទដ្ឋានគតិយុត្តក្រោមច្បាប់ ដែលកំណត់ចាត់ទុក ឬធ្វើចំណាត់ថ្នាក់ក្បាលដី ឬតំបន់ដីធ្លីណាមួយថាជាទ្រព្យសម្បត្តិរដ្ឋ មានអានុភាពគតិយុត្តិ ដែលមិនអាចជំទាស់បានតែក្នុងករណីក្បាលដីនោះ ឬ ផ្នែកនៃដីក្នុងតំបន់នោះ មិនមានបន្ទុកភោគៈស្របច្បាប់។

ប្រសិនបើគោលការណ៍អំពីបន្ទុកភោគៈស្របច្បាប់លើដីឯកជនរបស់រដ្ឋ ដែលបានលើកជាយោបល់ខាងលើនេះមិនត្រូវបានការពារទេនោះ បទដ្ឋានគតិយុត្តមួយចំនួនធំដែលបានចេញកន្លងមកដូចជា អនុក្រឹត្យដែលកំណត់ដែនបម្រុងព្រៃឈើអចិន្ត្រៃយ៍ចេញក្រោយឆ្នាំ១៩៩៣ ជាពិសេសក្រោមច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ អនុក្រឹត្យលេខ ៥៣ អនក្រ.បក ឆ្នាំ១៩៩៥ ស្តីពីការប្រកាសទ្រព្យសម្បត្តិរដ្ឋ (ដែលប្រកាសថា ដីដែលដុះចាស់ ឬថ្មី ជាកោះនៅសមុទ្រ

ទន្លេ ព្រែក ស្ទឹង បឹងបួរ ទូទាំងព្រះរាជាណាចក្រកម្ពុជា ជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយមិនអនុញ្ញាតអោយឯកជន ឬសមូហភាពណា ប្រកាសជាកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ) ព្រមទាំងអនុក្រឹត្យដែលកំណត់តំបន់ដីរដ្ឋផ្សេងៗទៀត អាចមិនស្របនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាលទេ ហើយគួរតែសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងបកស្រាយអំពីធម្មនុញ្ញភាពនៃបទដ្ឋានគតិយុត្តទាំងនោះ។

យោងតាមសេចក្តីរៀបរាប់ខាងលើ ការដាក់បញ្ចូលចំនុចលេខ១ នៃមាត្រានេះ អាចនាំឱ្យមានការអេះអាង អនុវត្ត ឬ បកស្រាយច្បាប់មិនត្រឹមត្រូវថា *ភ្នំ កោះដុះថ្មី ឬចាស់* **ទាំងអស់នៅកម្ពុជា** សុទ្ធតែជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលមិនអនុញ្ញាតឱ្យយកធ្វើជាកម្មសិទ្ធិឯកជនតាមរូបភាពភោគៈទេ។ ដូច្នេះគួរលុបចំណុចទ្រនេះចេញ ដើម្បីធានាបាននូវការគោរពសិទ្ធិភោគៈស្របច្បាប់លើដី ភ្នំ ឬកោះ។

គួរចែងបញ្ជាក់អំពីសិទ្ធិពិសេសរបស់រដ្ឋដែលការអនុវត្តសិទ្ធិនោះនាំឱ្យរដ្ឋទទួលបាននូវសិទ្ធិលើអចលនវត្ថុ។ និងគួរមានការពន្យល់ពាក្យថា ច្បាប់ ដែលប្រើក្នុងច្បាប់នេះ ជាពិសេសដែលប្រើក្នុងមាត្រានេះ។

**សំណើលុបចោល និងកែសម្រួល៖**

លុបចំនុចលេខ១ ចេញ។

ចំនុចលេខ ៥ ចែងថា៖ អចលនវត្ថុដែលបានពីការអនុវត្តសិទ្ធិពិសេសរបស់រដ្ឋ ដូចជា ការដកហូត ឬ ការធ្វើអស្សាមិករណ៍ ដែលបម្រើប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិ
ក្រោយពីមានការពិគ្រោះយោបល់ជាសាធារណៈ និងមានការផ្តល់សំណងជាមុន សមរម្យ និងយុត្តិធម៌ ស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ។

**មាត្រា២១._ កម្មសិទ្ធិករជានីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត**

ក្រៅពីរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ និងនីតិបុគ្គលសាធារណៈដទៃទៀតដែលបានទទួលស្គាល់ដោយច្បាប់ថា ជា**នីតិបុគ្គលនៃនីតិសាធារណៈ** អាចជាកម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុក្នុងលក្ខខណ្ឌដែលបានកំណត់ក្នុងជំពូកនេះ។

**យោបល់៖** ដាក់ស្តែងច្បាប់ជាធរមានគ្រាន់តែកំណត់ថាជា នីតិបុគ្គល ហើយមិនប្រើពាក្យ នីតិបុគ្គលសាធារណៈ ទេ។

**សំណើកែសម្រួលដូចខាងក្រោម៖**

ក្រៅពីរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ និងនីតិបុគ្គលសាធារណៈដទៃទៀតដែលត្រូវបានកំណត់ឋានៈ ឬទទួលស្គាល់ដោយច្បាប់ ថាជា**នីតិបុគ្គល** អាចជាកម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុក្នុងលក្ខខណ្ឌដែលបានកំណត់ក្នុងជំពូកនេះ។

## មាត្រា២២._ ការដកហូតអចលនវត្ថុដោយអាជ្ញាធរសាធារណៈ

ក្នុងករណីមានការដកហូតអចលនវត្ថុដោយអាជ្ញាធរសាធារណៈ អចលនវត្ថុនោះត្រូវរក្សាទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយ ប្រសិនបើគ្មានបណ្ដឹងទាមទារដោយភោគីស្របច្បាប់នៃអចលនវត្ថុដែលត្រូវបានដកហូតទៅអាជ្ញាធរនោះក្នុងរយៈពេល ៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃទទួលសេចក្ដីជូនដំណឹងស្ដីពីការដកហូត។

**យោបល់៖** ការចែងក្នុងមាត្រានេះផ្ទុយនឹងស្មារតីនៃមាត្រា ៩ ខាងលើ ហើយក៏ផ្ទុយនឹងមាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញ។ ការដកហូតអចលនវត្ថុមិនដូចគ្នានឹង ការដកហូតឯកសារក្លែងបន្លំ ឬឯកសារដែលចេញដោយបំពានច្បាប់ ឬការរឹបអូសអចលនវត្ថុដែលកម្មសិទ្ធិករ ឬភោគី ល្មើសច្បាប់ទាក់ទងនឹងលក្ខខណ្ឌសញ្ជាតិខ្មែរ ឬបទល្មើសព្រហ្មទណ្ឌ ជាធរមានតាមសេចក្ដីសម្រេចរបស់តុលាការ ឬស្ថាប័នអនុវត្តច្បាប់នោះទេ។ ករណីបុគ្គល ឬសមូហភាពណាមួយ ទន្ទ្រានកាន់កាប់ ឬប្រើប្រាស់ដីរបស់រដ្ឋ របស់នីតិបុគ្គលសាធារណៈ របស់បុគ្គលឯកជន ឬរបស់សមូហភាពផ្សេងទៀត ដោយបំពានច្បាប់ រដ្ឋអំណាចអាចចាត់វិធានការបណ្ដេញបុគ្គល ឬសមូហភាពដែលបំពាននោះចេញពីទីតាំងដីពាក់ព័ន្ធ ហើយទង្វើនៃការបណ្ដេញចេញនេះមិនហៅថាជាការដកហូតអចលនវត្ថុទេ។ ម៉្យាងទៀតមាត្រានេះមិនបានកំណត់ឱ្យច្បាស់ថានរណាជាអាជ្ញាធរសាធារណៈ ដែលអាចសម្រេចដកហូតអចលនវត្ថុពីភោគីបាន ដែលការចែងបែបនេះ បើកផ្លូវឱ្យអាជ្ញាធរនានាធ្វើការដកហូតដី ឬអចលនវត្ថុដទៃទៀតរបស់ភោគី ដោយបំពានអំណាច ឬបំពានច្បាប់ និងរដ្ឋធម្មនុញ្ញ។ ម៉្យាងទៀតច្បាប់នេះគួរបញ្ជាក់ និងតម្កល់គោលនយោបាយដែលកំណត់ថា ភោគីត្រូវកាន់កាប់ថែទាំដីភោគៈឱ្យជាប់លាប់ឥតអាក់ខាន ដោយមិនទុកចោលឥតមើលថែទាំលើសពី ៣ឆ្នាំជាប់ៗគ្នា និងករណីមានភស្តុតាងបញ្ជាក់ច្បាស់អំពីការខកខានបំពេញលក្ខខណ្ឌនេះ រដ្ឋបាលសុរិយោដី ឬតុលាការអាចបដិសេធមិនទទួលស្គាល់សិទ្ធិភោគៈនោះ ទោះជាអចលនវត្ថុនោះបាន ឬមិនទាន់ចុះបញ្ជីសិទ្ធិកាន់កាប់ប្រើប្រាស់សិទ្ធិប្រើប្រាស់ អាស្រ័យផល ឬសិទ្ធិភោគៈក៏ដោយ ហើយអចលនវត្ថុនោះត្រូវធ្លាក់ជាទ្រព្យសម្បត្តិរដ្ឋដោយស្វ័យប្រវត្តិ។

**សំណើលុបចោល និងកែសម្រួល៖**

លុបមាត្រានេះចេញ ហើយកែសម្រួលលក្ខខណ្ឌនៃភោគៈស្របច្បាប់ ដែលចែងក្នុង មាត្រា ១១៦ ខាងក្រោម ដោយបញ្ជាក់នូវគោលនយោបាយក្នុងយោបល់ខាងលើនេះ។

## មាត្រា២៣._ ទ្រព្យសម្បត្តិរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត

អចលនវត្ថុមួយចំនួនរបស់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ដែលត្រូវបានដាក់នៅក្រោមរបបគតិយុត្តពិសេស គឺជាទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គលសាធារណៈ។

អចលនវត្ថុមួយចំនួនទៀតត្រូវគ្រប់គ្រងដូចកម្មសិទ្ធិឯកជន និងអាចជាកម្មវត្ថុនៃកិច្ចការជំនួញ គឺជាទ្រព្យសម្បត្តិឯកជនរបស់នីតិបុគ្គលសាធារណៈ។

អចលនវត្ថុរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដទៃទៀតទាំងអស់ត្រូវចុះបញ្ជីនៅរដ្ឋបាលសុរិយោដី។

**យោបល់៖** គួរលុបឃ្លាថា ត្រូវបានគ្រប់គ្រងដូចកម្មសិទ្ធិឯកជន ចេញដើម្បីកុំឱ្យមានការយល់ច្រលំរវាងកម្មសិទ្ធិសាធារណៈ និងកម្មសិទ្ធិឯកជន។ គួរចែងថាជាកម្មវត្ថុនៃការលក់ ការដូរ ការជួល ការប្រវាស់ ការដាក់ជាដើមទុនវិនិយោគ ប្រទានកម្ម អំណោយ អច្ច័យទាន ប្រាតិភោគ សម្បទានដី កិច្ចការជំនួញផ្សេងទៀត ការរឹបអូស ការរឹបអូសជាបណ្ដោះអាសន្ន ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងកម្មសិទ្ធិ ការលក់ដោយបង្ខំ។ ម្យ៉ាងទៀតគួររក្សាភាពផ្សេងគ្នានៃទ្រព្យសម្បត្តិរបស់រដ្ឋ និងទ្រព្យសម្បត្តិរបស់នីតិបុគ្គលសាធារណៈ ផ្សេងៗទៀត។

### សំណើកែសម្រួល កថាខណ្ឌទី ១ និងទី២៖

កថាខណ្ឌទី១៖ អចលនវត្ថុមួយចំនួនរបស់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ឬរបស់នីតិបុគ្គលដទៃទៀត ដែលបម្រើប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ និងត្រូវបានដាក់ឱ្យនៅក្រោមរបបគតិយុត្តពិសេស គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈផ្សេងទៀត។

កថាខណ្ឌទី២៖ អចលនវត្ថុផ្សេងទៀតរបស់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ឬរបស់នីតិបុគ្គលដទៃទៀត ដែលត្រូវបានដាក់ឱ្យនៅក្រោមរបបគតិយុត្តធម្មតា អាចជាកម្មវត្ថុនៃការលក់ ការដូរ ការជួល ការប្រវាស់ ការដាក់ជាដើមទុនវិនិយោគ ប្រទានកម្ម អំណោយ អច្ច័យទាន ប្រាតិភោគ សម្បទានដី កិច្ចការជំនួញផ្សេងទៀត ការរឹបអូស ការរឹបអូសជាបណ្ដោះអាសន្ន ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងកម្មសិទ្ធិ ការលក់ដោយបង្ខំ ក្រោមក្របខណ្ឌនៃច្បាប់ឯកជន។

### មាត្រា២៤._ លក្ខណៈវិនិច្ឆ័យនៃទ្រព្យសម្បត្តិសាធារណៈជាអចលនវត្ថុ

លក្ខណៈវិនិច្ឆ័យនៃទ្រព្យសម្បត្តិសាធារណៈជាអចលនវត្ថុ រួមមានអចលនវត្ថុដែលត្រូវបានប្រើប្រាស់ជាប្រយោជន៍សាធារណៈ ឬជាប្រយោជន៍ក្នុងការបម្រើសេវាសាធារណៈ ឬជាប់ប្រយោជន៍សាធារណៈ។ ទ្រព្យសម្បត្តិសាធារណៈជាអចលនវត្ថុ មានជាអាទិ៍៖

១. អចលនវត្ថុទាំងឡាយដែលកើតឡើងតាមធម្មជាតិ មានជាអាទិ៍ ដីដែលលិចទឹកអចិន្ត្រៃយ៍ ដីព្រៃឈើ ភ្នំ ជ្រោះ បឹងបួ អាងទឹក ទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយដែលនាវាឬក្បូនចេញចូលបានឬបណ្ដែតបាន ត្រើយសមុទ្រ ឆ្នេរសមុទ្រ កោះ។

២. អចលនវត្ថុទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍សាធារណៈមានជាអាទិ៍ តំបន់ស្ថាន កំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង សំណង់ការងារទឹក អាកាសយានដ្ឋាន ប្រឡាយ ព្រែកជីក។

៣. អចលនវត្ថុទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើតឬក្រោយពីបានរៀបចំ មានជាអាទិ៍ ផ្លូវថ្នល់ សួនច្បារ ឧទ្យាន រមណីយដ្ឋាន។

៤. អចលនវត្ថុទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ មានជាអាទិ៍ សាលារៀនឬអគារសិក្សាសាធារណៈ អគាររដ្ឋបាលសាធារណៈ មន្ទីរពេទ្យសាធារណៈ។

៥. ដីទាំងឡាយដែលបង្កើតជាដែនបម្រុងធម្មជាតិការពារដោយច្បាប់។

៦. អចលនវត្ថុជាបេតិកភណ្ឌវប្បធម៌ បេតិកភណ្ឌបុរាណវិទ្យា បុរាណស្ថាន រមណីយដ្ឋានវប្បធម៌និងប្រវត្តិសាស្ត្រ សំណង់ប្រវត្តិសាស្ត្រ។

៧. អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។

៨. ក្រៅពីទ្រព្យសម្បត្តិសាធារណៈជាអចលនវត្ថុខាងលើ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់ប្រភេទអចលនវត្ថុផ្សេងទៀតជាទ្រព្យសម្បត្តិសាធារណៈ ដើម្បីដាក់ឱ្យប្រើប្រាស់ស្របតាមរបបគតិយុត្តដែលបានកំណត់ដោយច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

យោបល់៖ គួរនិយាយថា អចលនវត្ថុជាទ្រព្យសម្បត្តិសាធារណៈ ជំនួសឱ្យការនិយាយថា ទ្រព្យសម្បត្តិសាធារណៈជាអចលនវត្ថុ។ ក្នុងចំនុចលេខ ១ គួរលុបពាក្យថា ភ្នំ កោះ អាងទឹក ចេញ ហើយចំពោះដីព្រៃឈើ គួរកែសម្រួលថាដីព្រៃឈើរបស់រដ្ឋ ហើយមិនរាប់បញ្ចូលដីព្រៃឈើរបស់បុគ្គលឯកជន ឬសមូហភាព ឬព្រៃឈើដែលបុគ្គលឯកជន ឬសមូហភាព ទទួលបានសិទ្ធិស្របច្បាប់ក្នុងការដាំដុះលើដីរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈផ្សេងទៀត។ ក្នុងចំនុចលេខ ២ បន្ថែមពាក្យថា ជារាទឹក អាងតម្កល់ទឹកស្រោចស្រព បរិវេណមណ្ឌលរ៉ែ មណ្ឌលបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រជាតិ ទំនប់វារីអគ្គីសនី ប្រាំងទន្លេ សួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ប្រព័ន្ធទឹកកខ្វក់ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ ក្នុងចំនុចលេខ ៥ គួរមានការកែសម្រួលដើម្បីដោះស្រាយបញ្ហាទំនាស់ទាមទារសិទ្ធិ កម្មសិទ្ធិឯកជន ឬកម្មសិទ្ធិសមូហភាពក្នុងតំបន់ដែលត្រូវបានកំណត់ថាជាតំបន់ការពារធម្មជាតិ។

## សំណើកែសម្រួល៖

លក្ខណៈវិនិច្ឆ័យនៃអចលនវត្ថុជាទ្រព្យសម្បត្តិសាធារណៈ រួមមានអចលនវត្ថុដែលត្រូវបានប្រើប្រាស់ជាប្រយោជន៍សាធារណៈ ឬ ជាប្រយោជន៍ក្នុងការបម្រើសេវាសាធារណៈ ឬ ជាប់ប្រយោជន៍សាធារណៈ ជាអាទិ៍៖

១- អចលនវត្ថុទាំងឡាយដែលកើតឡើងតាមធម្មជាតិ មានជាអាទិ៍ ដីដែលលិចទឹកជាអចិន្ត្រៃយ៍ ដីព្រៃឈើរបស់រដ្ឋដែលមិនរាប់បញ្ចូលដីព្រៃឈើរបស់បុគ្គលឯកជន ឬសមូហភាព ឬព្រៃឈើដែលបុគ្គលឯកជន ឬសមូហភាព ទទួលបានសិទ្ធិស្របច្បាប់ក្នុងការដាំដុះលើដីរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈផ្សេងទៀត ជ្រោះ បឹងបួ ទន្លេ ស្ទឹង ព្រែក អូរ ត្រើយសមុទ្រ ឆ្នេរសមុទ្រ។

២- អចលនវត្ថុទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍សាធារណៈ មានជាអាទិ៍ តិរបាន កំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង អាកាសយានដ្ឋាន ជារាទឹក សំណង់ការងារទឹក អាងតម្កល់ទឹកស្រោចស្រព

បរិវេណមណ្ឌលរ៉ែ មណ្ឌលបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ ទំនប់វារីអគ្គិសនី ប្រឡាយ ព្រែកជីក ច្រាំងទន្លេ សួនវិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ ប្រព័ន្ធទឹកកខ្វក់ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

ចំនុចលេខ ៣ និង ៤ រក្សាទុកដោយគ្មានការកែប្រែ។

៥- ដីក្នុងតំបន់ស្នូលនៃតំបន់ការពារធម្មជាតិ និងដីដែលគ្មានបន្ទុកសិទ្ធិភោគៈស្របច្បាប់របស់បុគ្គលឯកជន ឬសមូហភាព ក្នុងតំបន់ដែលត្រូវបានកំណត់ថាជាតំបន់ការពារធម្មជាតិ។

ចំនុចលេខ ៦ និង ៧ រក្សាទុកដោយគ្មានការកែប្រែ។

បន្ថែមក្នុងកថាខណ្ឌចុងក្រោយ៖ អាជ្ញាធរមានសមត្ថកិច្ច មិនអាចចាត់ប្រភេទអចលនវត្ថុផ្សេងទៀតដែលមិនទាន់បានចុះបញ្ជីដីធ្លីពេញលេញជាស្ថាពរ ថាជាទ្រព្យសម្បត្តិសាធារណៈ ក្នុងលក្ខណៈដែលនាំឱ្យប៉ះពាល់ លុបចោល ដកហូត កម្រិត បង្រួម រារាំង និងហាមឃាត់ការស្នើសុំកម្មសិទ្ធិឯកជន ឬកម្មសិទ្ធិសមូហភាព ចំពោះអចលនវត្ថុដែលឋិតក្រោម ភោគៈស្របច្បាប់ ឬ ដែលមានការកាន់កាប់ប្រើប្រាស់ជាក់ស្តែងតាមលក្ខណៈប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ស្របតាមច្បាប់នេះឡើយ។

## មាត្រា២៤.១_ ការកំណត់ព្រំដីសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត

ការកំណត់ព្រំដីនិងកម្មសិទ្ធិដែលស្ថិតនៅតាមបណ្តោយផ្លូវសាធារណៈ ឆ្នេរសមុទ្រ ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រលាយ បឹងបួ និងអាងទឹក ត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច យោងតាមសេចក្តីត្រូវការជាក់ស្តែងនៃផលប្រយោជន៍រួម ពិសេសតាមសេចក្តីត្រូវការនៃការធ្វើចរាចរ។

ផ្លូវថ្នល់ត្រូវកំណត់ដោយព្រំដីចំណីថ្នល់។

ផ្លូវទឹកដែលមានទំហំតូច មានជាអាទិ៍ អូរ ប្រឡាយ ត្រូវកំណត់ដោយព្រំដីចំណីផ្លូវទឹក។

ឆ្នេរសមុទ្រត្រូវកំណត់ដោយខ្សែបន្ទាត់ក្រិតកម្ពស់ទឹកខ្ពស់បំផុតនៃសមុទ្រ។ កោះ ទន្លេ ស្ទឹង ព្រែក បឹងបួ និងអាងទឹកត្រូវកំណត់ដោយខ្សែបន្ទាត់ក្រិតកម្ពស់ទឹកខ្ពស់បំផុតនៅរដូវវស្សាលើកលែងតែករណីមានទឹកជំនន់ខុសធម្មតា។

ដីសាធារណៈដទៃទៀត មានជាអាទិ៍ ដីអភិរក្ស ដីព្រៃឈើ ដីដែនជលផល ដីដែនបម្រុងធម្មជាតិ ដីបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ដោយព្រំដែលមាននិយាមកាកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**យោបល់៖** សូមមើលយោបល់ ក្នុងមាត្រា ២០ ខាងលើ។ គួរលុបមាត្រានេះចេញ ដើម្បីជៀសវាងនូវការបំពានលើ ឬដកហូតតាមអំណាចច្បាប់ ឬអំណាចបទដ្ឋានគតិយុត្តនូវសិទ្ធិភោគៈស្របច្បាប់ និងសិទ្ធិកម្មសិទ្ធិស្របច្បាប់ដែលបានចុះបញ្ជីដីធ្លី ឬមិនទាន់បានចុះបញ្ជីដីធ្លី ហើយត្រូវបានធានាការពារដោយរដ្ឋធម្មនុញ្ញ។ ការកំណត់ដីចំណីផ្លូវ ចំណីផ្លូវរថភ្លើង ចំណីផ្លូវទឹក អាចបង្កើតបានជាបន្ទុកសេវភាពសាធារណៈ ដែលហាមឃាត់ការសាងសង់សំណង់ថ្មី ឬការពង្រីកសំណង់មកលើដីចំណីផ្លូវ ចំណីផ្លូវរថភ្លើង ចំណីផ្លូវទឹកនោះ ប៉ុន្តែមិនត្រូវមានអានុភាពជាការដកហូតដោយឥតផ្តល់សំណងសមរម្យ និងយុត្តិធម៌ជាមុនឡើយ។

**សំណើលុបចោល និងកែសម្រួល៖**

ប្តូរចំណងជើងមាត្រានេះថា ការកំណត់ព្រំដីនៃឆ្នេរសមុទ្រ ទន្លេ ស្ទឹង ព្រែក បឹងបួ

លុបកថាខណ្ឌទី១ ទី២ ទី៣ និងទី៥ ចេញ។

កថាខណ្ឌទី៤៖ ព្រំខាងលើនៃឆ្នេរសមុទ្រត្រូវកំណត់ដោយខ្សែបន្ទាត់ក្រិតកម្ពស់ទឹកខ្ពស់បំផុតនៃជំនោរសមុទ្រ។ ច្រាំងជាព្រំនៃទន្លេ ស្ទឹង ព្រែក បឹងបួ ត្រូវកំណត់ដោយខ្សែបន្ទាត់ក្រិតកម្ពស់ទឹកខ្ពស់បំផុតនៅរដូវវស្សាលើកលែងករណីមានទឹកជំនន់ខុសធម្មតា។

**មាត្រា២៥._ របបគតិយុត្តនៃទ្រព្យសម្បត្តិសាធារណៈ**

អចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ពុំអាចជាកម្មវត្ថុនៃការលក់ ការដូរ ប្រទានកម្ម អច្ច័យទាន ប្រាតិភោគ សម្បទានដី ការរឹបអូស ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ការលក់ដោយបង្ខំ និងពុំមានកំណត់អាជ្ញាយុកាលនៃការរលត់សិទ្ធិ។

អចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត មិនអាចស្ថិតនៅក្រោមរបបលទ្ធកម្មពិសេសនៃភោគៈដូចមានចែងក្នុងច្បាប់នេះបានឡើយ។

ប៉ុន្តែអចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត អាចជាកម្មវត្ថុនៃការអនុញ្ញាតឱ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្នមិនទៀង ហើយអាចដកហូតវិញបាន បើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ លើកលែងតែករណីត្រូវបានទទួលស្គាល់និងអនុញ្ញាតតាមគោលការណ៍នៃកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ការអនុញ្ញាតទាំងនេះ មិនអាចប្រែក្លាយទៅជាកម្មសិទ្ធិ ឬជាសិទ្ធិប្រត្យក្សជាប្រយោជន៍ដល់អ្នកកាន់កាប់ទ្រព្យទាំងនោះបានឡើយ។

អចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត អាចជាកម្មវត្ថុនៃការជួល ការធ្វើសម្បទានហេដ្ឋារចនាសម្ព័ន្ធ និងសម្បទានគ្រប់គ្រងសេវាសាធារណៈ លើកលែងតែទ្រព្យសម្បត្តិដែលមានលក្ខណៈជាបេតិកភណ្ឌវប្បធម៌ជាតិ។

អចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ដែលបាត់បង់ផលប្រយោជន៍សាធារណៈឬលែងជាកម្មវត្ថុនៃការបម្រើសេវាសាធារណៈ អាចក្លាយជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**យោបល់៖** ជាការសមស្របក្នុងការហាមឃាត់មិនឱ្យមានការធ្វើលទ្ធកម្មភាពកម្មសិទ្ធិតាមរបបលទ្ធកម្មពិសេសនៃភោគៈចំពោះករណីអចលនវត្ថុមិនទាន់ចុះបញ្ជី។ ប៉ុន្តែដើម្បីធានាគណនេយ្យភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

សាធារណៈ ក្រោយពីមានការកំណត់ព្រំប្រទល់ច្បាស់លាស់ និងចុះបញ្ជីដីធ្លីលើកដំបូងរួច គួរអនុញ្ញាតឱ្យមានលទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាល ចំពោះអចលនវត្ថុជាទ្រព្យសម្បត្តិរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈ ដូចករណី ទ្រព្យសម្បត្តិរបស់បុគ្គលឯកជនផងដែរ។ ម្យ៉ាងទៀត កម្មសិទ្ធិ គឺជាសិទ្ធិពេញលេញ និងផ្តាច់មុខបំផុត។ ករណីដែលមានត្រឹមតែ សិទ្ធិគ្រប់គ្រប់ ប្រើប្រាស់ អាស្រ័យផល ជាលក្ខណៈបុគ្គល ឬសមូហភាព មិនត្រូវហៅថា ជាកម្មសិទ្ធិទេ។ តាមន័យនេះបើមិនព្រមផ្តល់កម្មសិទ្ធិពេញលេញឱ្យសហគមន៍ជនជាតិដើមភាគតិចទេនោះ គួរមានការផ្លាស់ប្តូរវិសាលភាពនៃរបបកម្មសិទ្ធិសមូហភាពឱ្យនៅក្រៅរបបកម្មសិទ្ធិសាធារណៈ ឬលុបចោលនូវទស្សនទាន និងរបបកម្មសិទ្ធិសមូហភាព ហើយជំនួសដោយសិទ្ធិប្រត្យក្ស (ដូចជាសិទ្ធិគ្រប់គ្រងប្រើប្រាស់អាស្រ័យផល ផលុបភោគ សម្បទាន ឬសេវភាពពិសេសនៃការប្រើប្រាស់ដីតាមបែបប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ។ល។)។ ប៉ុន្តែយើងខ្ញុំសំណូមពរឱ្យរដ្ឋ និងច្បាប់នេះផ្តល់សិទ្ធិកម្មសិទ្ធិពេញលេញជូនសហគមន៍ជនជាតិដើមភាគតិច ដោយចំណុះឱ្យរបបអាណាព្យាបាល។ គួររៀបរាប់បន្ថែមនូវសម្បទានទេសចរណ៍ សម្បទានរ៉ែ សម្បទាននេសាទ និងសម្បទានផ្សេងទៀតដែលមានកំណត់ក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្ត។

**សំណើកែសម្រួល៖**

កថាខណ្ឌទី១៖ លុបចោលឃ្លាចុងក្រោយថា និងពុំមានកំណត់អាជ្ញាយុកាលនៃការរលត់សិទ្ធិ។

កថាខណ្ឌទី២៖ បន្ថែមខាងចុងថា ប៉ុន្តែអាចជាកម្មវត្ថុនៃលទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាល ក្រោយពេលដែលអចលនវត្ថុនោះត្រូវបានកំណត់ព្រំប្រទល់ច្បាស់លាស់ និងចុះបញ្ជីដីធ្លីពេញលេញលើកដំបូងរួចរាល់។

កថាខណ្ឌទី៣៖ លុបចោលចាប់ពី លើកលែងតែករណីត្រូវបានទទួលស្គាល់និងអនុញ្ញាតតាម ... ។

កថាខណ្ឌទី៤៖ បន្ថែម សម្បទានទេសចរណ៍ សម្បទានរ៉ែ សម្បទាននេសាទ និងសម្បទានផ្សេងទៀតដែលមានកំណត់ក្នុងច្បាប់ ឬបទដ្ឋានគតិយុត្ត។

## មាត្រា២៦._ ការហាមឃាត់លទ្ធកម្មកម្មសិទ្ធិលើទ្រព្យសម្បត្តិសាធារណៈ

អចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬនីតិបុគ្គលសាធារណៈដទៃទៀត មិនអាចជាកម្មវត្ថុនៃលទ្ធកម្មកម្មសិទ្ធិបានឡើយ ទោះបីក្នុងករណីណាក៏ដោយ។

ស្ថានភាពនៃអ្នកកាន់កាប់អចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬនីតិបុគ្គលសាធារណៈដទៃទៀតនៅតែមិនទៀងទាត់ និងខុសច្បាប់ដដែល ប្រសិនជាស្ថានភាពនោះមិនកើតចេញពីការអនុញ្ញាតតាមលក្ខខណ្ឌ និងនីតិវិធីដែលបានកំណត់ដោយច្បាប់នេះ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត។

**យោបល់៖** តាមហេតុផលនៃយោបល់ក្នុងមាត្រា ២៥ ខាងលើ គួរអនុញ្ញាតឱ្យធ្វើលទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាល។

**សំណើលុបចោល៖** លុបមាត្រានេះចេញ។

**មាត្រា២៧._ ការហាមឃាត់ការចុះបញ្ជីនិងការចេញឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុលើទ្រព្យសម្បត្តិសាធារណៈ**

ការចុះបញ្ជី ឬចេញឯកសារបញ្ជាក់សិទ្ធិលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ដោយមន្ត្រីមានសមត្ថកិច្ច ឱ្យដល់បុគ្គលឯកជន ត្រូវចាត់ទុកជាមោឃៈ។

មន្ត្រីមានសមត្ថកិច្ចដែលចុះបញ្ជីនិងចេញបណ្ណឬឯកសារសម្គាល់សិទ្ធិកាន់កាប់នេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ទាំងផ្នែករដ្ឋបាល ទាំងផ្នែករដ្ឋប្បវេណី ទាំងផ្នែកព្រហ្មទណ្ឌ។

មន្ត្រីសាធារណៈដែលព្រងើយកន្តើយទាំងដែលខ្លួនបានដឹង ចំពោះការចុះបញ្ជី ឬឯកសារបញ្ជាក់សិទ្ធិលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀតឱ្យដល់បុគ្គលឯកជន ត្រូវចាត់ទុកជាអ្នកសមគំនិត ហើយត្រូវទទួលទោសដូចគ្នានឹងចារីដែរ។

**យោបល់៖** គួរអនុវត្តចំពោះតែករណីដែលទ្រព្យសម្បត្តិនោះត្រូវបានចុះក្នុងប្រព័ន្ធព័ត៌មានទិន្នន័យទ្រព្យរដ្ឋ ឬចុះបញ្ជីជាទ្រព្យសម្បត្តិរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈរួច ហើយមានបោះបង្គោលសម្គាល់ព្រំដីច្បាស់លាស់ និងងាយស្រួលយល់។ ម្យ៉ាងទៀត ចេតនា អំពើស៊ីសំណូក ឬការធ្វេសប្រហែលធ្ងន់ធ្ងរ ត្រូវកំណត់ជាលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់មន្ត្រីសាធារណៈ ឬមន្ត្រីមានសមត្ថកិច្ច ដែលបំពានមាត្រានេះ។ អាជ្ញាធរកាន់កាប់ ដីទាំងនោះ ត្រូវមានកម្មវិធីបោះបង្គោលសម្គាល់ព្រំដីបឋម និងព្រំដីស្ថាពរ ហើយបង្ហាញណែនាំដល់តំណាង រដ្ឋបាលមូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ និងប្រជាជនរស់នៅក្បែរទីតាំងដីឱ្យដឹង និងស្គាល់ព្រំដី ហើយចូលរួមការពារទ្រព្យសម្បត្តិសាធារណៈ រួមទាំងការដាក់បណ្តឹង បរិហារអំពីការបំពានលើដីនោះ ដល់អាជ្ញាធរមាន សមត្ថកិច្ច ឬនិងតុលាការ។ ម្យ៉ាងទៀតមាត្រានេះចែងពាក់ព័ន្ធការចុះបញ្ជី និងការចេញឯកសារបញ្ជាក់សិទ្ធិ គួរតែលើកទៅដាក់ក្នុងមាតិកាទី៤ ជំពូកទី២ បន្ទាប់ពីមាត្រា ១១៥-១ ជាការសមស្របជាង។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា២៨._ ការចាត់ចែងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដទៃទៀត**

អចលនវត្ថុដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដទៃទៀត អាចជាកម្មវត្ថុនៃការចាត់ចែងដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អចលនវត្ថុដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត អាចជាកម្មវត្ថុនៃសម្បទានដីក្នុងលក្ខខណ្ឌដូចមានចែងក្នុងច្បាប់នេះ។ ប៉ុន្តែដីដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀតដែលនៅទំនេរ អាចត្រូវបានបែងចែកទៅឱ្យបុគ្គលដែលត្រូវការដីក្នុងគោលដៅសង្គមកិច្ច។

**យោបល់៖** គួរលុបចោល ដោយសារតាមយោបល់ និងសំណើកែសម្រួលក្នុង មាត្រា ២៣ ខាងលើ ប្រការស្រដៀងគ្នានេះ ត្រូវបានដាក់បញ្ចូលក្រោមមាត្រា ២៣ រួចហើយ។

**សំណើលុបចោល៖** សូមលុបចោលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា២៩._ ការរំលោភបំពាន ការកាន់កាប់ និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុដោយខុសច្បាប់**

រាល់ការរំលោភបំពាន ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុដោយខុសច្បាប់ ត្រូវទុកជាមោឃៈនិងគ្មានអានុភាព ហើយមិនអាចធ្វើនិយ័តកម្ម ទោះតាមរូបភាពណាក៏ដោយ។

អំពើដូចខាងក្រោមត្រូវចាត់ទុកជាការរំលោភបំពាន ឬជាការកាន់កាប់ឬការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុ ដោយខុសច្បាប់៖

១. រាល់ការចូលកាន់កាប់អចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដទៃទៀត និងរាល់ការបំប្លែងការកាន់កាប់អចលនវត្ថុដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ទៅជាកម្មសិទ្ធិរបស់បុគ្គលឯកជន ទោះបីការកាន់កាប់និងការបំប្លែងនេះកើតមាននៅពេលណាក៏ដោយ ដែលមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក។

២. រាល់ការបំប្លែងដីសម្បទាន ទៅជាកម្មសិទ្ធិរបស់បុគ្គលឯកជន ទោះជាការបំប្លែងនោះ កើតឡើងមុនពេលច្បាប់នេះ ចូលជាធរមានក៏ដោយ លើកលែងតែសម្បទានដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គម។

៣. រាល់សម្បទានមិនស្របនឹងបញ្ញត្តិទាំងឡាយនៃច្បាប់នេះ។

៤. រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ទោះតាមរូបភាពណាក៏ដោយ ដែលបានកើតឡើងក្រោយថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១

៥. រាល់អំពើដែលច្បាប់ដោយឡែកផ្សេងទៀត ចាត់ទុកជាការរំលោភបំពាន ការកាន់កាប់ ឬការប្រើប្រាស់អចលនវត្ថុជាទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់។

**យោបល់៖** តើនិយ័តកម្មមានន័យបែបណាក្រោមច្បាប់នេះ។ តាមការសង្កេតលើការអនុវត្តយុទ្ធសាស្ត្រស្បែកខ្លា និងគោលនយោបាយដោះស្រាយសំណង់បណ្តោះអាសន្នកន្លងមក ការកាន់កាប់ដីខុសច្បាប់មួយចំនួនត្រូវបានធ្វើ

និយ័តកម្ម។ ដូច្នេះគួរលុប ឬកែសម្រួលឃ្លាថា ហើយមិនអាចធ្វើនិយ័តកម្ម ទោះតាមរូបភាពណាក៏ដោយ ដើម្បីទុកលទ្ធផលជូនរាជរដ្ឋាភិបាលក្នុងការសម្រេចកាត់ដីរដ្ឋ និងប្រទាន ឬផ្តល់ដីសម្បទានសង្គមកិច្ច សម្បទានសេដ្ឋកិច្ចខ្នាតគ្រួសារ ផលុបភោគ ជួលអចិន្ត្រៃយ៍ សេវភាព ឬការប្រើប្រាស់ដីក្នុងរូបភាពផ្សេងទៀត ដែលច្បាប់នេះអនុញ្ញាត។ ម្យ៉ាងទៀត មាត្រានេះចែងអំពីការកាន់កាប់ដីដោយបុគ្គលឯកជន ឬការបំលែងការកាន់កាប់ក្នុងបំណងទទួលបានកម្មសិទ្ធិឯកជនលើដីរដ្ឋ ដូច្នេះគួរលើកទៅដាក់ក្រោមជំពូក ឬផ្នែកដែលចែងអំពីការកាន់កាប់ ឬភោគៈជាការសមស្របជាង ហើយវានឹងជួយពន្យល់បន្ថែមអំពីអត្ថន័យនៃការកាន់កាប់ ឬភោគៈស្របច្បាប់ និងមិនស្របច្បាប់។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។ សូមកែសម្រួលចំណុច ៣ ថារាល់សម្បទានដីមិនស្របនឹងញត្តិទាំងឡាយនៃច្បាប់នេះ។

### មាត្រា៣០._ វិធានការចំពោះការរំលោភបំពាន ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុដោយខុសច្បាប់

បុគ្គលដែលកំពុងប្រព្រឹត្ត ឬបានទទួលការចុះបញ្ជីនិងចេញបណ្ណដោយបានប្រព្រឹត្តការរំលោភបំពាន ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុដោយខុសច្បាប់ មិនអាចទាមទារសំណងទូទាត់ ឬសោហ៊ុយសម្រាប់ការថែទាំ ឬការរៀបចំដែលបានធ្វើនៅលើអចលនវត្ថុនោះ។

លទ្ធកម្មណាមួយដោយខុសច្បាប់ និងដោយចេតនា ឬដោយបោកប្រាស់លើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ត្រូវបានហាមឃាត់។

ចំពោះការកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ ដែលបណ្តាលឱ្យខូចខាតឬធ្វើឱ្យយឺតយ៉ាវដល់ការងារដែលជាប្រយោជន៍ទូទៅ ពិសេសចំពោះការកាន់កាប់ដីចំណីផ្លូវ កម្រិតទោសនឹងត្រូវកំណត់ជាទ្វេ។

ក្នុងគ្រប់ករណី បើជនល្មើសមិនបញ្ឈប់ការកាន់កាប់របស់ខ្លួនក្នុងរយៈពេលដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចទេ អាជ្ញាធរមានសមត្ថកិច្ចអាចដំណើរការបណ្តេញជនល្មើសចេញ ហើយសោហ៊ុយនៃការរុះរើសំណង់ផ្សេងៗជាបន្ទុករបស់ជនល្មើស។

**យោបល់៖** គួរអនុញ្ញាតនូវលទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាល ហើយចាត់ទុកដីចំណីជាបន្ទុកសេវភាពលើក្បាលប៉ុន្តែមិនមែនដើម្បីដកហូត លុបចោល បដិសេធ ឬមោឃៈ លើសិទ្ធិប្រត្យក្សស្របច្បាប់ឡើយ។ គួរតែ កាត់បន្ថយការបង្កើត និងប្រើបទល្មើសព្រហ្មទណ្ឌដើម្បីដាក់បន្ទុកលើភោគី កម្មសិទ្ធិករ ឬម្ចាស់សិទ្ធិប្រត្យក្សស្របច្បាប់ដែលរងផលប៉ះពាល់ដោយសារសេចក្តីសម្រេចរបស់រដ្ឋអំណាច ឬអាជ្ញាធរមានសមត្ថកិច្ចដែលគ្មានបទប្បញ្ញត្តិកំណត់ផ្តល់សមត្ថកិច្ចច្បាស់លាស់។ មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញគួរត្រូវបានគោរព និងប្រកាន់យ៉ាងខ្ជាប់ខ្ជួនពេញលេញ ដោយរដ្ឋអំណាចនិងអាជ្ញាធរទាំងឡាយ។ ចំពោះទ្រព្យសម្បត្តិសាធារណៈដែលមានការកំណត់ព្រំប្រទល់ បោះបង្គោលសម្គាល់ព្រំនិងចុះក្នុងប្រព័ន្ធទិន្នន័យដីរដ្ឋ ឬនិង ចុះបញ្ជីដីធ្លីរួច តំណាងរបស់អាជ្ញាធរកាន់កាប់ដីរដ្ឋ ឬគណៈកម្មការគ្រប់គ្រងដីរដ្ឋ

គួរត្រូវបានផ្តល់សិទ្ធិ និងកាតព្វកិច្ចច្បាស់លាស់មឹងម៉ាត់ក្នុងការចាត់វិធានការ តាមផ្លូវច្បាប់ដើម្បីបណ្តេញបុគ្គលដែលបំពានចេញយ៉ាងឆាប់រហ័ស ដោយមិនបង្អែរបង្អង់យូរដែលនាំឱ្យរដ្ឋថ្លោះសិទ្ធិក្រោមគោលការណ៍នៃលទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាល។

លើសពីនេះ ដើម្បីធានាបាននូវអភិបាលកិច្ចល្អផ្នែកដីធ្លី ការគោរពដំណើរការត្រឹមត្រូវនៃការអនុវត្តច្បាប់ ការគោរពសិទ្ធិផ្សេងៗលើដីធ្លី ដែលមិនកម្រិតចំពោះតែសិទ្ធិកម្មសិទ្ធិ ការគោរពនូវសិទ្ធិមានលំនៅឋានសមរម្យ និងការអនុវត្តដោយសមធម៌នូវគោលនយោបាយស្តីពីការដោះស្រាយបញ្ហាសំណង់បណ្តោះអាសន្ន និងគោលនយោបាយដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ បំពេញបន្ថែមឱ្យការអនុវត្តច្បាប់ស្តីពីអស្សាមិករណ៍ សូមលុបកថាខណ្ឌទី៣ និងទី៤ ចោល។

**សំណើកែសម្រួល៖** សូមកែសម្រួល និងលុបចោលកថាខណ្ឌទី៣ និងទី៤នៃ មាត្រានេះ ស្របតាមយោបល់ខាងលើ។

## ជំពូកទី៣
## កម្មសិទ្ធិសម្ហភាព
## ផ្នែកទី១
## អចលនវត្ថុរបស់វត្ត

### មាត្រា៣១._ និយមន័យនៃអចលនវត្ថុរបស់វត្ត

អចលនវត្ថុជាដីនិងជាសំណង់ដែលមាននៅក្នុងនិងក្រៅបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនាជាបេតិកភណ្ឌប្រើប្រាស់ជានិច្ចកាលសម្រាប់ព្រះពុទ្ធសាសនា និងដាក់ឱ្យពុទ្ធសាសនិកប្រើប្រាស់ក្រោមការថែទាំរបស់គណៈកម្មការវត្ត។

អចលនវត្ថុទាំងអស់របស់វត្តអារាមនៃព្រះពុទ្ធសាសនា ត្រូវស្ថិតក្រោមរបបគតិយុត្តនៃកម្មសិទ្ធិសមូហភាព និងត្រូវគ្រប់គ្រងដោយគណៈកម្មការវត្តស្របតាមច្បាប់និងលិខិតបទដ្ឋាគតិយុត្តជាធរមាន។

**យោបល់៖** បើហៅថាជាកម្មសិទ្ធិ ត្រូវតែជាសិទ្ធិដែលពេញលេញ និងផ្តាច់មុខ រួមទាំងសិទ្ធិចាត់ចែង ប៉ុន្តែអាចកំណត់ឱ្យចំណុះទៅស្ថាប័នអាណាព្យាបាលសមស្របមួយ ដើម្បីធានាចីរភាព និងឧត្តមប្រយោជន៍នៃទ្រព្យសមូហភាព។ បើទទួលស្គាល់ និងផ្តល់ឱ្យត្រឹមតែសិទ្ធិគ្រប់គ្រងការប្រើប្រាស់ជាលក្ខណៈសមូហភាព គួរឈប់ហៅ ឬឈប់ប្រើពាក្យថាកម្មសិទ្ធិ ហើយជំនួសដោយសិទ្ធិប្រត្យក្ស។ គួរកំណត់ថាក្រសួងធម្មការ និងសាសនា ជាស្ថាប័នអាណាព្យាបាលសម្រាប់អចលនវត្ថុរបស់វត្ត ហើយមានឈ្មោះក្នុងសៀវភៅគោលបញ្ជីដីធ្លី និងលើប័ណ្ណអចលនវត្ថុ ថាជាអាណាព្យាបាលបន្ថែមពីលើឈ្មោះកម្មសិទ្ធិករ និងតំណាងរបស់វត្ត។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា៣២._ របបគតិយុត្តនៃអចលនវត្ថុរបស់វត្ត**

អចលនវត្ថុទាំងអស់របស់វត្ត ត្រូវចាត់ទុកជាកម្មសិទ្ធិសមូហភាព ហើយមិនអាចលក់ ដូរផ្ទើអំណោយ ឬជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគឡើយ ហើយគ្មានកំណត់អាជ្ញាយុកាល។ អចលនវត្ថុរបស់វត្តអាចជួលឬប្រវាស់បាន តែផលទុនដែលបានមកពីការជួលឬប្រវាស់នេះ ត្រូវទុកសម្រាប់តែកិច្ចការក្នុងសាសនាប៉ុណ្ណោះ។

កិច្ចការពារអចលនវត្ថុទាំងនេះត្រូវធានាដោយតំណាងគណៈកម្មការវត្ត។ នីតិវិធីនៃការជ្រើសរើសគណៈកម្មការនិងតំណាងដើម្បីការពារផលប្រយោជន៍វត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា។ ការគ្រប់គ្រងសំណង់បេតិកភណ្ឌដែលស្ថិតនៅលើដីវត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**យោបល់៖** ដោយមានការអនុញ្ញាតយល់ព្រមរបស់ស្ថាប័នអាណាព្យាបាល (ក្រសួងធម្មការ និងសាសនា) តាមសំណើរបស់គណៈកម្មការវត្ត ឬសមាជិកភាគច្រើននៃសហគមន៍ចំណុះជើងវត្ត ផ្អែកលើឧត្តមប្រយោជន៍របស់វត្ត ឬនិងប្រយោជន៍ខាងសាសនារបស់សហគមន៍នោះ ការដោះដូរ ឬលក់អចលនវត្ថុរបស់វត្ត ក្រៅពីសំណង់បេតិកភណ្ឌនៅលើដីវត្តគួរត្រូវបានអនុញ្ញាតដោយច្បាប់នេះ។ សិទ្ធិជួល ឬប្រវាស់អចលនវត្ថុរបស់វត្ត ដើម្បីបានផលទុនបម្រើឱ្យកិច្ចការក្នុងសាសនាគឺរក្សាទុកដដែល ប៉ុន្តែគួរហាមឃាត់មិនឱ្យមានការជួលបន្ត ឬការផ្ទេរសិទ្ធិជួល ឬផ្ទេរសិទ្ធិប្រវាស់ទៅឱ្យតតីយជន។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា៣៣._ ទីកន្លែងសក្ការបូជានិងអចលនទ្រព្យនៃជំនឿសាសនាដទៃទៀត**

ទីកន្លែងសក្ការបូជានិងអចលនទ្រព្យនៃជំនឿសាសនាដទៃទៀត មិនស្ថិតនៅក្រោមរបបដែលមានបញ្ញត្តិនៅក្នុងច្បាប់នេះឡើយ។ ទីកន្លែងសក្ការបូជានិងអចលនទ្រព្យទាំងនោះត្រូវគ្រប់គ្រងដោយសមាគមនៃសាសនិកដែលបង្កើតឡើងទៅតាមបញ្ញត្តិនៃច្បាប់។

**យោបល់៖** សូមចែងក្នុងច្បាប់នេះនូវបទប្បញ្ញត្តិដែលផ្តល់សមត្ថកិច្ចឱ្យកំណត់លក្ខណៈវិនិច្ឆ័យ បែបបទ និង ឮនីតិវិធីចុះបញ្ជី និងចេញលិខិតទទួលស្គាល់សញ្ជាតិខ្មែរចំពោះសមាគមដែលមានលក្ខណៈសម្បត្តិទទួលបានឋានៈជា នីតិបុគ្គលដែលមានសញ្ជាតិខ្មែរ។ សូមមើលយោបល់ និងសំណើរចែងបន្ថែមក្នុងមាត្រា ១២ ខាងលើ។

លើសពីនេះទៀត ក្នុងការអនុវត្តជាក់ស្តែង គេសង្កេតឃើញថា ដើម្បីទទួលបាននូវការការពារជាបណ្តោះអាសន្ននូវដីសម្បូហាភាពជនជាតិដើមភាគតិចបាន ក្រុមជនជាតិដើមភាគតិចជាសមាជិកត្រូវដាក់ឯកសារមួយនៃឯកសារតម្រូវផ្សេងៗ គឺឯកសារដែលមានឈ្មោះថា "ស្វ័យអត្តសញ្ញាណជនជាតិដើមភាគតិច" ដែលសមាជិកនៃក្រុមជនជាតិដើមភាគតិចលើដីសម្បូហាភាពនោះ។ ដើម្បីទទួលបានឯកសារនេះ សមាជិកជនជាតិដើមភាគតិចបានជួបប្រទះនូវការលំបាកជាច្រើន និងយឺតយ៉ាវ ពេលវេលាដោយពួកគេមិនមានឯកសារគតិយុត្តណាមួយយោងបញ្ជាក់ពីតម្រូវឯកសារនេះ និងត្រូវទៅបញ្ជាក់ពី អាជ្ញាធរកម្រិតណាមួយដែលនឹងទទួលបានឯកសារនេះ។ ជាលទ្ធផល ជនជាតិដើមភាគតិចជាសមាជិកមិនទទួលបាននូវការការពារ ពីការរំលោភបំពានយកដីសម្បូហាភាពជនជាតិដើមភាគតិចឡើយ ដោយមូលហេតុមិនមានឯកសារគ្រប់គ្រាន់។ ប្រសិនបើច្បាប់នេះមានចេតនាការពារដីសម្បូហាភាពជនជាតិដើមភាគតិច គួរមានបញ្ញត្តិឱ្យបានច្បាស់លាស់ពីល័ក្ខខ័ណ្ឌតម្រូវពីឯកសារបែបនេះ និងគួរតែកម្រិតអាជ្ញាធរកម្រិតណា ដែលត្រូវចេញលិខិតស្វ័យអត្តសញ្ញាណជនជាតិដើមភាគតិចនេះ។ ជាសំណើ កម្រិតអាជ្ញាធរគួរតែត្រឹមថ្នាក់ឃុំ ពីព្រោះមន្ត្រីឃុំអាចស្គាល់និងដឹងពីអត្តសញ្ញាណជនជាតិដើមភាគតិច។ ផ្ទុយទៅវិញ បើមិនមានបញ្ញត្តិចែងពីលក្ខខណ្ឌតម្រូវនេះទេ ការអនុវត្តដែលតម្រូវបែបគួរចាត់ទុកជាមោឃៈ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

ផ្នែកទី២

ដីបញ្ចុះសព

**មាត្រា៣៤._ និយមន័យនៃដីបញ្ចុះសព**

ដីទាំងឡាយដែលប្រជាពលរដ្ឋទូទៅបាននិងកំពុងប្រើប្រាស់ជាដីបញ្ចុះសពតាមជំនឿ ទំនៀមទម្លាប់ និងប្រពៃណី ស្ថិតនៅក្នុងដែនដីនៃឃុំ សង្កាត់ ឬដីដែលត្រូវបានរៀបចំដោយរដ្ឋបាលឃុំ សង្កាត់ ជាដីបញ្ចុះសពទៅតាមជំនឿប្រពៃណី និងទំនៀមទម្លាប់នីមួយៗ ត្រូវចាត់ទុកជាកម្មសិទ្ធិសម្បូហាភាព។

**យោបល់៖** គួរចែងបញ្ជាក់ថាមាត្រានេះ មិនអនុវត្តចំពោះក្បាលដីឯកជនដែលភោគី ឬកម្មសិទ្ធិករ ប្រើប្រាស់ដើម្បីបញ្ចុះសពសាច់ញាតិតាមជំនឿទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួនឡើយ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា៣៥._ របបគតិយុត្តនៃដីបញ្ចុះសព**

ដីបញ្ចុះសពមិនអាចលក់ ទិញ ដូរ ធ្វើអំណោយ ឬជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគឡើយ និង គ្មានកំណត់អាជ្ញាយុកាល។

ដីបញ្ចុះសពដែលបានចុះបញ្ជីរួចជាកម្មសិទ្ធិសមូហភាព មិនអាចបំប្លែងទៅជាកម្មសិទ្ធិឯកជនបានឡើយ ទោះជាតាមរូបភាពណាក៏ដោយ។

លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីបញ្ចុះសព ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** គួរយកលំនាំតាមអចលនវត្ថុរបស់វត្តដែរ ហើយកំណត់សមត្ថកិច្ចឱ្យក្រសួងធម្មការ និងសាសនា ជាស្ថាប័នអាណាព្យាបាល និងដោយមានការអនុញ្ញាតយល់ព្រមរបស់ស្ថាប័នអាណាព្យាបាល តាមសំណើររបស់រដ្ឋបាលឃុំសង្កាត់ដែលបានរៀបចំទីតាំងដីបញ្ចុះសពនោះ ផ្អែកលើឧត្តមប្រយោជន៍ផ្នែកជំនឿរបស់សហគមន៍ប្រើប្រាស់ ទីតាំងបញ្ចុះសពនោះ ការដោះដូរ ឬលក់ដីបម្រុងទុកសម្រាប់កប់សពដែលមិនទាន់មានការប្រើប្រាស់ ឬទីតាំងកប់សពដែលលែងមានការប្រើប្រាស់អស់ពេលយ៉ាងតិច ៥ ឆ្នាំជាប់ៗគ្នា គួរត្រូវបានអនុញ្ញាតដោយច្បាប់នេះ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា៣៥.១_ ដីបញ្ចុះសពដែលស្ថិតក្រោមទម្រង់សហកម្មសិទ្ធិ និងដីបញ្ចុះសពដែលស្ថិតក្នុងដីសហគមន៍ ជនជាតិដើមភាគតិចមិនស្ថិតនៅក្រោមរបរគតិយុត្តនៃផ្នែកនេះទេ**

## ផ្នែកទី៣
## អចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច

**មាត្រា៣៦._ ការគ្រប់គ្រងសហគមន៍និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណីក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍**

ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះ នឹងបន្តគ្រប់គ្រងសហគមន៍និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។

រដ្ឋបាលខេត្តត្រូវដាក់ចេញវិធានការណ៍ការពារបណ្តោះអាសន្នតាមសំណើក្រុមសមាជិកសហគមន៍ដែលបានសម្តែងការឯកភាពជាតិពន្ធនិងធន្ទះបន្តគ្រប់គ្រងសហគមន៍និងអចនវត្ថុរបស់ខ្លួនតាមប្រពៃណីស្របតាមច្បាប់នេះ។

បែបបទនិងនីតិវិធីនៃការចេញវិធានការជាបណ្ដោះអាសន្នដើម្បីការពារអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** គួរបង្កើតឱ្យមានផងនូវយន្តការអន្តរក្រសួងស្ថាប័ន និងអង្គការគាំពារជនជាតិដើមភាគតិចដឹកនាំដោយតំណាងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យទទួលភារកិច្ចពិនិត្យ ឆ្លើយតប និងដោះស្រាយចំពោះបញ្ហាប្រទាក់ក្រឡាគ្នាដែលត្រូវការដំណោះស្រាយមានប្រសិទ្ធភាពទាន់ពេលវេលា ហើយដែលហួសពីសមត្ថភាពរបស់រដ្ឋបាលខេត្ត ដើម្បីការពារសិទ្ធិរបស់ជនជាតិដើមភាគតិចដែលចូល ឬមិនចូលជាសមាជិក ឬចេញពីសមាជិករបស់សហគមន៍ជនជាតិដើមភាគតិចដែលត្រូវបានកំពុងរៀបចំក្នុងដំណាក់កាលណាក៏ដោយ ព្រមទាំងលើកតម្កើងឆន្ទៈគ្រប់គ្រងការប្រើប្រាស់ដីធ្លីតាមលក្ខណៈប្រពៃណី និងទំនើបកម្មកសិកម្មដើម្បីលើកកម្ពស់ផលិតភាព និងចីរភាពធនធានដីរបស់សហគមន៍។

**សំណើកែសម្រួល៖** សូមកែសម្រួល និងបន្ថែមមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា៣៧._ និយមន័យនៃសមាជិករបស់សហគមន៍**ជនជាតិដើមភាគតិច

ចាត់ទុកជាសមាជិករបស់សហគមន៍ជនជាតិដើមភាគតិចដែលអាចទទួលគុណប្រយោជន៍ពីការធានាសិទ្ធិ និងការការពារដែលរៀបចំឡើងដោយច្បាប់នេះ រាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃជាតិពន្ធុ អំពីវប្បធម៌ និងសង្គមរបស់សហគមន៍ដែលទទួលស្គាល់ដោយមតិភាគច្រើននៃសមាជិកដទៃទៀត និងដោយព្រមទទួលនូវសាមគ្គីភាព និងភាពចំណុះដែលនាំឱ្យមានការចូលក្នុងសហគមន៍។

**យោបល់៖** និយមន័យក្នុងមាត្រានេះ គួរដាក់ឱ្យជនជាតិដើមភាគតិចទាំងឡាយពិនិត្យពិភាក្សាជិតដល់ និងលើកអនុសាសន៍កែសម្រួលតាមគំនិតឯកភាពគ្នារបស់ពួកគាត់។ គួរថែងបន្ថែមថាការកំណត់អំបូរជនជាតិដើមភាគតិចជាសមត្ថកិច្ចរបស់ក្រសួង អភិវឌ្ឍន៍ជនបទ ហើយក្រុមបុគ្គលជានីតិជនជនជាតិដើមភាគតិចយ៉ាងតិច ១០ រូប ជាបុរស ឬស្ត្រីរស់នៅក្នុងតំបន់ភូមិសាស្ត្រក្នុងខេត្ត ឬឆ្លងព្រំប្រទល់ខេត្តណាមួយ ដែលបានប្រកាសជាលាយល័ក្ខណ៍អក្សរដល់អាជ្ញាធររដ្ឋបាល ឬក្រសួងមហាផ្ទៃ និងមានចេញជាប័ណ្ណសម្គាល់ ឬលិខិតរដ្ឋបាលដែលមានសេចក្តីសម្គាល់ថាជាជនជាតិដើមភាគតិច មានសិទ្ធិរៀបចំចងក្រង សហគមន៍ជនជាតិដើមភាគតិច ដោយមិនចំណុះឱ្យតំបន់រដ្ឋបាលណាមួយឡើយ ហើយត្រូវរៀបចំលក្ខន្តិកៈសហគមន៍ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ជាភាសាជនជាតិដើមភាគតិច ឬភាសាខ្មែរតាមឆន្ទៈ និងស្វ័យភាពរបស់ពួកគេ ដោយមិនចំណុះលក្ខខណ្ឌទម្រង់ និងភាសា ដែលកំណត់ដាក់ចេញ ឬណែនាំដោយក្រសួងស្ថាប័នណាមួយឡើយ ប៉ុន្តែដើម្បីអាចចុះបញ្ជីជានីតិបុគ្គល និងមានការទទួលស្គាល់នូវសញ្ជាតិរបស់សហគមន៍ជនជាតិដើមភាគតិចបាន លក្ខន្តិកៈសហគមន៍ ត្រូវមានខ្លឹមសារតម្រូវជាអប្បបរមាកំណត់ដោយក្រសួងមហាផ្ទៃ ហើយមានការបកប្រែជាភាសាខ្មែរសម្រាប់កិច្ច សម្របសម្រួលផ្នែករដ្ឋបាល។

គួរចែងថា មិនចាំបាច់មានការទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីមានសិទ្ធិបង្កើតសហគម ន៍ជនជាតិដើមភាគតិចឡើយ ប៉ុន្តែក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវមានកម្មវិធីគ្រប់គ្រាន់សម្រាប់ផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញប្បទានអភិវឌ្ឍន៍ ដល់ជនជាតិដើមភាគតិច និងសហគមន៍របស់ពួកគេ ដោយគិតដល់សេចក្តីត្រូវការជាពិសេសរបស់ជនជាតិដើមភាគតិច តម្រូវឱ្យរដ្ឋចាត់វិធានការនានាដែលមានលក្ខណៈពិសេស និងប្រសិទ្ធភាព និងដោយគោរពនូវសិ ទ្ធិស្វ័យភាព និងលក្ខណៈដោយឡែកផ្នែកវប្បធម៌ សង្គមរបស់សហគមន៍ ស្របតាមគោលបំណងស្នូលរបស់គោលដៅអភិវឌ្ឍដោយចិរភាព ដែលមិនទុកចោលនរណាម្នាក់ឡើយ (SDG with a focus of leaving no one behind) និងការប្តេជ្ញាចិត្តរបស់កម្ពុជាអនុវត្តតាមក្រមខណ្ឌគោលដៅអភិវឌ្ឍដោយចីរភាពរបស់ខ្លួន ក៏ដូចជាអ្វីដែលបានកំណត់ក្នុងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចអនុម័តក្នុងខែមេសា ឆ្នាំ២០០៩ ដោយកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី។

គួរចែងផងដែរថា រដ្ឋបាលខេត្ត មានភារកិច្ចពិនិត្យសិក្សា ស្រាវជ្រាវតាមការចាំបាច់ និងលើកអនុសាសន៍ជូនក្រសួងមហាផ្ទៃ ក្នុងអំឡុងពេលមិនលើសពី ៦០ ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានសំណើសុំចុះបញ្ជី និងកំណត់សញ្ញាតិរបស់សហគមន៍ជនជាតិដើមភាគតិច។ ក្រសួងមហាផ្ទៃ ត្រូវសម្រេចលើសំណើសុំចុះបញ្ជី និងកំណត់សញ្ញាតិរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងរយៈពេល ៣០ថ្ងៃប្រតិទិន បន្ទាប់ពីទទួលសំណុំឯកសារសំណើសុំ និងអនុសាសន៍របស់រដ្ឋបាលខេត្ត។

***សំណើកែសម្រួល៖*** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។
ហើយសូមចែងបន្ថែមក្នុងមាត្រានេះថា រដ្ឋផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ទ្រទ្រង់ដល់ដំណើការកសាងសហគមន៍ជនជាតិដើមភាគតិច ការចុះបញ្ជីដី និងការអភិវឌ្ឍដីធ្លីរបស់ សហគមជនជាតិដើមភាគតិចប្រកបដោយនិរន្តរភាព សមធម៌ ការគោរពនូវ សិទ្ធិស្វ័យភាព និងលក្ខណៈដោយឡែកផ្នែកវប្បធម៌សង្គមរបស់សហគមន៍។

## មាត្រា៣៨._ **សមាសភាគនៃដីសហគមន៍**ជនជាតិដើមភាគតិច

ដីសហគមន៍ជនជាតិដើមភាគតិចមានដីសម្រាប់លំនៅឋាន និងដីសម្រាប់ប្រកបរបរកសិកម្មប្រពៃណី និងដីសម្រាប់ប្រតិបត្តិប្រពៃណី ជំនឿ និងវប្បធម៌។

សហគមន៍ជនជាតិដើមភាគតិច អាចមានដីបម្រុងដែលជាដីសាធារណៈរបស់រដ្ឋចាំបាច់ក្នុងការរូវេនដំណាំបន្ថែមទៅលើដីដែលបានដាំដុះដាក់ស្តែង ដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធរកាន់កាប់ដីរដ្ឋ។

ដីសាធារណៈរបស់រដ្ឋផ្សេងទៀតដែលសហគមន៍ជនជាតិដើមភាគតិចធ្លាប់ប្រើប្រាស់តាមបែបប្រពៃណីកន្លងមក ដូចជាដីព្រៃឈើសម្រាប់ការប្រមូលផលនៃអនុផលព្រៃឈើ ឬកន្លែងប្រើប្រាស់ទឹក មិនអាចចាត់ចូលជាសមាសភាគនៃដីសហគមន៍ជនជាតិភាគតិចបានឡើយ។ ទោះជាយ៉ាងណាសហគមន៍ជនជាតិភាគតិចធ្លាប់ប្រើប្រាស់

តាមបែបប្រពៃណីកន្លងមក អាចបន្តប្រើប្រាស់និងអាស្រ័យផលតាមប្រពៃណីរបស់ខ្លួន ប៉ុន្តែត្រូវចុះកិច្ចព្រមព្រៀងជាមួយស្ថាប័នសាមីដែលមានអាណាត្តិកាន់កាប់ដីរដ្ឋនោះ។

**យោបល់៖** គួរជំនួសពាក្យ កសិកម្មប្រពៃណី ទៅជាពាក្យថា កសិកម្ម ព្រោះគោលដៅសំខាន់នៃការរក្សានូវកម្មសិទ្ធិសមូហភាព មិនមែនដើម្បីចងខ្លួនជនជាតិដើមភាគតិចភ្ជាប់ទៅនឹងរបៀបធ្វើកសិកម្មបែបប្រពៃណីដែលអាចទទួលបានផលិតភាពទាប ដោយប្រើកម្លាំងមនុស្ស និងការដុតព្រៃដើម្បីដាំដំណាំនោះទេ។ គួរបញ្ចូលផងដែរនូវដីសម្រាប់ដូរវេនដំណាំចំការវិលជុំ ដីបម្រុងទុក និងដីដាំដុះអចិន្ត្រៃយ៍ ប្រភេទដីបេតិកភណ្ឌវប្បធម៌ និងធម្មជាតិរបស់ជនជាតិដើមភាគតិច (ប្រសិនបើមាន) ដីព្រៃឈើសហគមន៍ កន្លែងប្រើប្រាស់ទឹក វាលស្មៅចិញ្ចឹមសត្វ (ប្រសិនបើមាន) កន្លែងផ្តល់សេវាសហគមន៍ដីផ្លូវក្នុងសហគមន៍ ដែលទុកសម្រាប់តែ ការប្រើប្រាស់ដោយសមាជិកសហគមន៍ និងអាជ្ញាធរមានសមត្ថកិច្ចដែលមានសិទ្ធិ ឬទទួលបានការអនុញ្ញាតឱ្យចេញចូលសហគមន៍។ សូមមើលបន្ថែមនូវយោបល់ក្នុងមាត្រា ៣៩ ខាងក្រោមនេះ។ លើសពីនេះទំហំនៃ ដីប្រភេទនីមួយៗ ត្រូវកំណត់តាមស្ថានភាពប្រើប្រាស់ និងតម្រូវការជាក់ស្តែង និងតម្រូវការរបស់សហគមន៍ក្នុងអំឡុង ២០ ឆ្នាំខាងមុខ ហើយមិនត្រូវមានការចេញបទដ្ឋានគតិយុត្តកម្រិតទំហំដីណាមួយឡើយ។ រាល់បទដ្ឋានគតិយុត្តដែ លកម្រិតទំហំដីរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវអស់សុពលភាពអនុវត្ត។

តាមស្មារតីនៃយោបល់ខាងលើ និងយោបល់ក្នុងមាត្រា ៣៩ គួរលុបចោលនូវការតម្រូវឱ្យមានការទទួលស្គាល់ដោយអាជ្ញាធរកាន់កាប់ដីរដ្ឋ ប៉ុន្តែគួរតម្រូវឱ្យមានការចរចាជាមួយអាជ្ញាធរកាន់កាប់ដីរដ្ឋ ហើយអាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវធ្វើកំណត់ហេតុនៃការចរចានោះ។ ករណីពុំអាចសម្រេចបាននូវការព្រមព្រៀងជាមួយអាជ្ញាធរកាន់កាប់ដីរដ្ឋ អំពីការកាត់ដីចេញតំបន់គ្រប់គ្រងរបស់អាជ្ញាធរកាន់កាប់ដីរដ្ឋនោះ ក្នុងអំឡុងពេលមិនលើសពី ៥ ឆ្នាំ គិតពីពេលដាក់ពាក្យស្នើសុំចុះបញ្ជីដីសមូហភាពរបស់សហគមន៍ តាមសំណើ និងអនុសាសន៍របស់យន្តការ អន្តរក្រសួង ស្ថាប័ន និងអង្គការគាំពារជនជាតិដើមភាគតិចដឹកនាំដោយតំណាងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីត្រូវចេញសេចក្តីសម្រេចរដ្ឋបាលអារកាត់ចំពោះការទាមទារសិទ្ធិលើដីនោះ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា៣៩._ របបគតិយុត្តនៃដីសហគមន៍**ជនជាតិដើមភាគតិច

កម្មសិទ្ធិនៃអចលនវត្ថុដែលរដ្ឋចុះបញ្ជីទទួលស្គាល់និងផ្តល់ជូនសហគមន៍ជនជាតិដើមភាគតិច ដូចមានចែងក្នុងជំពូកនេះ ត្រូវស្ថិតក្រោមរបបគតិយុត្តនៃកម្មសិទ្ធិសមូហភាព។ ក្នុងនាមជាម្ចាស់កម្មសិទ្ធិសមូហភាពសហគមន៍ ជនជាតិដើមភាគតិច ទទួលបាននូវរាល់សិទ្ធិនិងការការពារកម្មសិទ្ធិដូចកម្មសិទ្ធិឯកជន ប៉ុន្តែគ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាពដែលជាដីសាធារណៈរបស់រដ្ឋឬសិទ្ធិសមូហភាពរបស់ដីសហគមន៍ជនជាតិដើមភាគតិច។

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ត្រូវត្រួតពិនិត្យតាមដាន បង្ការ និងទប់ស្កាត់រាល់ការបំពានកម្មសិទ្ធិសមូហភាពរបស់ដីសហគមន៍ជនជាតិដើមភាគតិច។

ការអនុវត្តនូវសិទ្ធិជាកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដី ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី និងយន្តការនៃការធ្វើសេចក្ដីសម្រេចរបស់សហគមន៍ អនុលោមតាមទំនៀមទម្លាប់របស់សហគមន៍ ហើយត្រូវដាក់ឱ្យនៅក្រោមការអនុវត្តច្បាប់ពិសេសទាក់ទងនឹងទ្រព្យសម្បត្តិរដ្ឋ ដូចជាបញ្ញត្តិពាក់ព័ន្ធនឹងការការពារបរិស្ថាននិងធនធានធម្មជាតិជាដើម។

បញ្ញត្តិនៃមាត្រានេះមិនមែនជាឧបសគ្គដល់សកម្មភាពការងាររបស់រដ្ឋដែលជាតម្រូវការនៃផលប្រយោជន៍ជាតិឬតម្រូវការជាបន្ទាន់របស់ជាតិឡើយ។

**យោបល់៖** ដើម្បីលើកកម្ពស់សិទ្ធិរបស់ជនជាតិដើមភាគតិច ស្របតាមស្មារតីនៃសេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិ ស្ដីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ទាមទារឱ្យមានការពង្រីករបបកម្មសិទ្ធិសមូហភាពលើអចលនវត្ថុរបស់សហគមន៍ ជនជាតិដើមភាគតិចឱ្យមានលក្ខណៈស្រដៀងគ្នានឹងសហកម្មសិទ្ធិ (ដែលមានជាចំណែកឯកជនរបស់សមូហភាព និង ចំណែករួមរបស់សមូហភាព) នៅក្រៅរបបកម្មសិទ្ធិសាធារណៈ (ពោលគឺពេលដែលចុះបញ្ជីរួច ដី និងអចលនវត្ថុ ដទៃទៀតទាំងឡាយរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងទម្រង់ជាកម្មសិទ្ធិសមូហភាពត្រូវបានកាត់ចេញពីរបប កម្មសិទ្ធិសាធារណៈ (របបកម្មសិទ្ធិរបស់រដ្ឋ) ប៉ុន្តែឋិតក្រោមរបបអាណាព្យាបាលចំពោះការចាត់ចែងដោយការលក់ ឬការដោះដូរ ជាមួយអ្នកខាងក្រៅ ឬជាមួយរដ្ឋបាលសាធារណៈ ឬនីតិបុគ្គលសាធារណៈ ត្រឹមកម្រិត ១០% នៃ ដីសរុបរបស់សហគមន៍។ ការធ្វើផែនការប្រើប្រាស់ ការកំណត់ប្រភេទ និងគោលដៅប្រើប្រាស់ និងមធ្យោបាយអភិវឌ្ឍន៍អចលនវត្ថុក្នុងចំណែកឯកជនរបស់សមូហភាព រួមទាំងការជួល ប្រវាស់ ឬការអនុញ្ញាតឱ្យប្រើប្រាស់រយៈពេលខ្លី (ក្រោម ៥ ឆ្នាំ) នូវដី ឬអចលនវត្ថុណាមួយរបស់សហគមន៍ មិនចាំបាច់ត្រូវមានការយល់ព្រមពីស្ថាប័នអាណាព្យាបាល (ក្រសួងមហាផ្ទៃ) ទេ។ សូមលុបកថាខណ្ឌចុងក្រោយចេញ។

សិទ្ធិទាក់ទងនឹងជនជាតិដើមភាគតិច គឺស្វះស្វែងឱ្យមានការការពារ ដែលបន្ថែមពីលើសិទ្ធិរបស់បុគ្គល គឺសិទ្ធិសមូហភាពរបស់ពួកគេ ដោយសារការទទួលស្គាល់សិទ្ធិនេះជាការចាំបាច់ដើម្បីធានាដល់ការបន្តវត្តមានរបស់ពួកគេ ជីវភាពរស់នៅសុខុមាលភាព និងការអភិវឌ្ឍទាំងស្រុងរបស់ជនជាតិដើមភាគតិចក្នុងស្ថានភាពជាក្រុមដែលងាយរងគ្រោះ ដែលមានលក្ខណៈដោយឡែកផ្នែកវប្បធម៌និងសង្គម ហើយ បទពិសោធន៍អតីតកាលបានបង្ហាញថា បើគ្មានការគោរពដល់សិទ្ធិសមូហភាពជនជាតិដើមភាគតិច នោះហានិភ័យនៃការបាត់បង់វប្បធម៌នឹងកើតឡើងតាមរយៈការបង្ខំពួកគេចូលលាយឡំក្នុងសង្គមនៃមនុស្សភាគច្រើន។ បុព្វកថានៃសេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ទទួលស្គាល់ពីការមិនរើសអើង និងសមភាពទទួលស្គាល់នូវបញ្ហាដែលជាអំពើអយុត្តិធម៌ជាប្រវត្តិសាស្ត្រ ការធ្វើ អាណានិគម និងការដកហូតយកដីធ្លី ដែនដីនិងធនធាន ទទួលស្គាល់នូវវប្បធម៌ផ្សេងពីគេនៃជនជាតិដើមភាគតិច ទទួលស្គាល់សិទ្ធិសមូហភាពដែលសំខាន់មិនអាចផ្ដាច់ឬដកហូតបានឡើយ សម្រាប់ជីវភាពរស់នៅ សុខុមាលភាព និង

ការអភិវឌ្ឍទាំងស្រុងរបស់ជនជាតិដើមភាគតិច និងបញ្ជាក់ថាជាលិខិតុបករណ៍ពង្រឹងដល់ភាពសុខដមនិងទំនាក់ទំនងប្រកបដោយកិច្ចសហការគ្នារវាងរដ្ឋ និងជនជាតិដើមភាគតិច។

**សំណើកែសម្រួល៖** សូមកែសម្រួល និងលុបកថាខណ្ឌចុងក្រោយនៃមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា៤០._** សមាជិកភាពនៃសហគមន៍ជនជាតិដើមភាគតិច

ការស្នើសុំចូលជាសមាជិកសហគមន៍ជនជាតិដើមភាគតិចឬការស្នើសុំចេញពីសហគមន៍ជនជាតិដើមភាគតិចត្រូវអនុលោមតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិចនោះ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីបុគ្គលជាជនជាតិដើមភាគតិចណាម្នាក់ស្នើសុំចូលជាសមាជិកសហគមន៍ជនជាតិដើមភាគតិចណាមួយ បុគ្គលនោះត្រូវយកដីដែលជាកម្មសិទ្ធិឯកជនរបស់ខ្លួនទាំងអស់ ទៅដាក់បញ្ចូលជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនោះ។

ដីដែលជាកម្មសិទ្ធិឯកជនសម្រាប់ដាក់បញ្ចូល រួមមានដីដែលស្ថិតនៅក្នុងប្លង់រួមនៃក្បាលដីទាំងអស់របស់សហគមន៍ និងដីដែលស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលជាប់គ្នានិងភូមិសាស្ត្ររដ្ឋបាលដែលប្លង់រួមតាំងនៅ។

សមាជិកសហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិស្នើសុំចេញពីសហគមន៍បាន ប៉ុន្តែគ្មានសិទ្ធិទាមទារដីដែលជាចំណែកឯកជននៃកម្មសិទ្ធិសមូហភាព ដើម្បីយកធ្វើជាកម្មសិទ្ធិឯកជនបានឡើយ។

លក្ខខណ្ឌក្នុងការទទួលបានដីនៅពេលសមាជិកសហគមន៍ជនជាតិដើមភាគតិចសុំចូល ឬសុំចេញ និងការរំសាយសហគមន៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** គួរកំណត់ថា ការទទួលស្គាល់ និងអនុញ្ញាតឱ្យចូលជាសមាជិកថ្មី ឬឱ្យចាកចេញ ឬបណ្តេញចេញ ពីសហគមន៍ជនជាតិដើមភាគតិច ក្រោយពីបានចុះបញ្ជីលក្ខន្តិកៈសហគមន៍រួច ត្រូវអនុវត្តតាមខ្លឹមសារនៃលក្ខន្តិកៈច្បាប់ ដើម ហើយការបែងចែកឱ្យប្រើប្រាស់ ការកែប្រែ ឬការដកយកមកវិញនូវដី ឬអចលនវត្ថុណាដែលគ្រប់គ្រងដោយ សហគមន៍ ព្រមទាំងការផ្តល់សំណងចំពោះការវិនិយោគលើដី ឬអចលនវត្ថុដែលគ្រប់គ្រងដោយសហគមន៍ ត្រូវអនុវត្តតាមការកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងច្បាប់ដើមរបស់សហគមន៍។ ការចុះបញ្ជីដី និងអចលនវត្ថុដទៃទៀតរបស់សហគមន៍ គឺដើម្បីបង្កើនសុវត្ថិភាពនៃការកាន់កាប់ និងមានអានុភាពតតាំងជាមួយតតីយជន និងជាមួយរដ្ឋបាលសាធារណៈ រួមទាំងអាជ្ញាធរកាន់កាប់ដីរដ្ឋផងដែរ ប៉ុន្តែការមិនទាន់បានចុះបញ្ជីដី ឬអចលនវត្ថុណាមួយដែលគ្រប់គ្រងដោយសហគមន៍ មិនប៉ះពាល់ដល់សិទ្ធិរបស់សហគមន៍ក្នុងការគ្រប់គ្រងកិច្ចការផ្ទៃក្នុងរបស់សហគមន៍ឡើយ។

គួរចែងឱ្យមាននីតិវិធីទន់ភ្លន់ និងឆាប់រហ័សសម្រាប់កំណត់ព្រំប្រទល់ វាស់វែង វិនិច្ឆ័យ និងចុះបញ្ជីដីដែលទាមទារដោយសហគមន៍ជនជាតិដើមភាគតិច ដោយអនុវត្តតាមអភិក្រមដែលថា ក្បាលដីដែលគ្មានវិវាទ ឬដែលបាន ដោះស្រាយវិវាទចប់ជាស្ថាពរ ចុះបញ្ជីក្បាលដីនោះ និងចេញប័ណ្ណឱ្យភ្លាម។ ប្លង់រួមក្បាលដីរបស់សហគមន៍អាចកសាងជាសន្សឹមៗ ហើយមិនចាំបាច់ចំណុះឱ្យភូមិសាស្ត្ររដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។ ក្នុងរយៈពេលយ៉ាងយូរ ៥

ឆ្នាំ គិតចាប់ពីថ្ងៃចាប់ផ្ដើមអនុវត្តនីតិវិធីចុះបញ្ជីដីធ្លីលើកដំបូងដែលវិនិច្ឆ័យក្បាលដីមានទំនាស់ណាមួយ ហើយបើគ្មានការសម្រេចរដ្ឋបាលក្នុងរយៈពេលកំណត់ ៥ ឆ្នាំនេះទេ ត្រូវបានចាត់ទុកថាការអះអាងរបស់សហគមន៍ជនជាតិដើមភាគតិចនោះ មានលក្ខណៈស្របច្បាប់ ហើយអនុញ្ញាតឱ្យរដ្ឋបាលសុរិយោដី ចុះបញ្ជី និងចេញប័ណ្ណជូនសហគមន៍នោះដោយពេញលក្ខណៈច្បាប់ និងមិនអាចតវ៉ាដោយបុគ្គលឯកជន សមូហភាពផ្សេង អាជ្ញាធរកាន់កាប់ដីរដ្ឋ នីតិបុគ្គលសាធារណៈ ឬអាជ្ញាធររដ្ឋណាមួយផ្សេងទៀតបានឡើយ។

**សំណើកែសម្រួលៈ** សូមកែសម្រួលមាត្រានេះ និងមាត្រាពាក់ព័ន្ធ ស្របតាមយោបល់ខាងលើ។

**មាត្រា៤១._** **ភាពផ្ដាច់មុខក្នុងការទទួលបានសិទ្ធិលើអចលនវត្ថុរបស់សហគមន៍**ជនជាតិដើមភាគតិច

គ្មានអាជ្ញាធរ ឬបុគ្គលឯកជនណាមួយក្រៅពីសមាជិកសហគមន៍ អាចទទួលបានសិទ្ធិលើអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិចបានឡើយ។

ក្នុងគោលបំណងធានាសុខមាលភាពសង្គម រក្សាប្រពៃណីនិងទំនៀមទំលាប់ល្អ និងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់អាជ្ញាធរមានសមត្ថកិច្ច ដីសហគមន៍ជនជាតិដើមភាគតិចត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពស្របតាមលក្ខខណ្ឌនិងនីតិវិធីដូចមានចែងក្នុងច្បាប់នេះ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**យោបល់ៈ** តាមយោបល់ ក្នុងមាត្រា ៣៩ គួរលុបមាត្រានេះចោល។ គួរចែងថា លទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាលមិនអនុវត្តចំពោះដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចទេ។ ប៉ុន្តែ លទ្ធកម្មកម្មសិទ្ធិលើដីរបស់សហគមន៍ជនជាតិដើមភាគតិច ដោយអ្នកខាងក្រៅ ឬរដ្ឋបាលសាធារណៈ ឬនីតិបុគ្គលសាធារណៈ អាចធ្វើបានតាមការព្រមព្រៀងលក់ ឬការដោះដូរ ដែលមានការយល់ព្រមពីស្ថាប័នអាណាព្យាបាល (ក្រសួងមហាផ្ទៃ) ដោយមានការពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍ជនជាតិដើមភាគតិច ហើយនិងមិននាំឱ្យថយចុះទំហំដី ហួសពី ១០% នៃដីសរុបរបស់សហគមន៍នោះឡើយ។

**សំណើលុបចោល និងចែងបន្ថែមៈ** សូមលុបចោល និងចែងបន្ថែមមាត្រានេះ ស្របតាមយោបល់ខាងលើ។

## ជំពូកទី៤
## សហកម្មសិទ្ធិ

## មាត្រា៤២._	និយមន័យនៃសហកម្មសិទ្ធិ

រាល់កម្មសិទ្ធិលើអចលនទ្រព្យ ដែលកម្មសិទ្ធិករមានកម្មសិទ្ធិដោយឯករាជ្យលើចំណែកជន និងមានកម្មសិទ្ធិអវិភាគលើចំណែករួមចំពោះអចលនទ្រព្យ ត្រូវបានកំណត់ថាជាសហកម្មសិទ្ធិ។

**យោបល់៖** មិនមានយោបល់

## មាត្រា៤៣._	ការចាប់ផ្ដើមអនុវត្តរបបគតិយុត្តនៃសហកម្មសិទ្ធិ

ក្នុងករណីអគារមានស្រាប់ របបគតិយុត្តនៃសហកម្មសិទ្ធិត្រូវបានអនុវត្តចាប់ពីពេលចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិនៃចំណែកឯកជនដំបូងគេ។

ក្នុងករណីអគារគ្រោងនឹងសាងសង់ថ្មី របបគតិយុត្តនៃសហកម្មសិទ្ធិត្រូវបានអនុវត្តចាប់ពីពេលចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិនៃចំណែកឯកជនដំបូង។

ក្នុងករណីបុរី របបគតិយុត្តនៃសហកម្មសិទ្ធិត្រូវបានអនុវត្តចាប់ពីពេលចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិនៃក្បាលដីចំណែកឯកជនដំបូង។

ក្នុងករណីដីកប់សព របបគតិយុត្តនៃសហកម្មសិទ្ធិត្រូវបានអនុវត្តចាប់ពីពេលចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិនៃក្បាលដីចំណែកឯកជនដំបូង។

**យោបល់៖** មិនមានយោបល់

## មាត្រា៤៤._	និយមន័យនៃចំណែកឯកជន

រាល់ចំណែកនៃដីឬអគារសម្រាប់ប្រើប្រាស់ផ្ដាច់មុខដោយសហកម្មសិទ្ធិករណាមួយបង្កើតបានជាចំណែកឯកជន។

រាល់ចំណែកដែលត្រូវបានខណ្ឌចែកច្បាស់លាស់ដោយព្រំឬរចនាសម្ព័ន្ធគ្រឿងផ្គុំ និងមានមុខងារប្រើប្រាស់ជាក់លាក់ អាចត្រូវបានកំណត់ជាចំណែកឯកជន។ ចំណែកឯកជននេះជាកម្មវត្ថុនៃកម្មសិទ្ធិដោយឯករាជ្យតាមច្បាប់នេះ។

ដើម្បីទទួលស្គាល់កម្មសិទ្ធិលើចំណែកឯកជន តម្រូវឱ្យធ្វើការចុះបញ្ជីចំណែកឯកជននោះនៅរដ្ឋបាលសុរិយោដីតាមលក្ខខណ្ឌនិងនីតិវិធីដែលមានចែងក្នុងច្បាប់នេះ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**យោបល់៖** មិនមានយោបល់

## មាត្រា៤៥._ អឡុសិទ្ធិភាពនៃសហកម្មសិទ្ធិ

ព្រំដែលខ័ណ្ឌចំណែកឯកជន ត្រូវបានសន្មតជាព្រំអឡុសិទ្ធិ។

បទប្បញ្ញត្តិស្តីពីអឡុសិទ្ធិភាពនៃសហកម្មសិទ្ធិ ត្រូវកំណត់ដោយច្បាប់ដោយឡែក។

**យោបល់៖** គួរតែចែងអំពីអឡុសិទ្ធិភាពនៃសហកម្មសិទ្ធិ នៅក្នុងច្បាប់នេះតែម្តង។

## មាត្រា៤៦._ សិទ្ធិរបស់កម្មសិទ្ធិករនៃចំណែកឯកជន

សហកម្មសិទ្ធិករទាំងឡាយមានសិទ្ធិពេញលេញលើចំណែកឯកជនរបស់ខ្លួនដោយមិនបំពានទៅលើចំណែករួម និងមិនរំខានឬរាំងស្ទះដល់ការប្រើប្រាស់ចំណែករួមដោយសហកម្មសិទ្ធិករដទៃទៀត។

សហកម្មសិទ្ធិករទាំងនោះអាចផ្ទេរសិទ្ធិ ជួលឬបង្កើតផលុបភោគ រៀបចំសិទ្ធិប្រើប្រាស់និងសិទ្ធិអាស្រ័យ នៅដាក់ហ៊ីប៉ូតែក ដាក់បញ្ចាំនូវចំណែកឯកជនរបស់ខ្លួនដោយសេរី។

សហកម្មសិទ្ធិករអាចទាមទារប្រើប្រាស់ចំណែកឯកជនរបស់សហកម្មសិទ្ធិករដទៃទៀត និងចំណែករួមដែលខ្លួនមិនមានសិទ្ធិប្រើប្រាស់បាន ក្នុងទំហំចាំបាច់សម្រាប់ការថែទាំឬការកែលម្អចំណែកឯកជនរបស់ខ្លួនបាន។ ប្រសិនបើសហកម្មសិទ្ធិករដទៃទៀតរងការខូចខាតដោយសារការថែទាំឬកែលម្អនោះ សហកម្មសិទ្ធិករដែលទាមទារត្រូវសងការខូចខាត។

**យោបល់៖** មិនមានយោបល់

## មាត្រា៤៧._ និយមន័យនៃចំណែករួមនៃសហកម្មសិទ្ធិ

ក្រៅពីចំណែកឯកជនសមាសភាគនៃអគារនិងក្បាលដីដែលអគារនោះតាំងនៅជាអាទិ៍ ដែលផ្តល់អត្ថប្រយោជន៍ និងការប្រើប្រាស់សម្រាប់សហកម្មសិទ្ធិករទាំងអស់ ឬសហកម្មសិទ្ធិករមួយចំនួន ដែលបញ្ញត្តដោយច្បាប់ឬអនុក្រឹត្យ ហៅថាចំណែករួមកំណត់ដោយច្បាប់។

បទបញ្ជាផ្ទៃក្នុងនៃសហកម្មសិទ្ធិអាចកំណត់ចំណែករួមផ្សេងទៀតដោយគោរពតាមច្បាប់នេះ និងបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីពុំមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃសហកម្មសិទ្ធិឬមានការចែងផ្ទុយគ្នា ខាងក្រោមនេះត្រូវចាត់ទុកជាចំណែករួម៖

- ដី ទីធ្លា ឧទ្យាននិងសួនច្បារ ស្រះទឹក អាងទឹក ផ្លូវ ច្រកចេញចូល
- ជញ្ជាំង ដំបូលអគារ សសរទ្រូងបន្ទុកនៃអគារ បរិក្ខារ មានជាអាទិ៍ បណ្តាញមេកានិក ទឹក និងអគ្គិសនី ដែលអាចឆ្លងកាត់ចំណែកឯកជន

- ទូរម បំពង់និងក្បាលបំពង់ផ្សេង
- ទីកន្លែងសេវារួម។

ក្នុងករណីពុំមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃសហកម្មសិទ្ធិ ឬមានការចែងផ្ទុយគ្នា សិទ្ធិបន្ទាប់បន្សំខាងក្រោមនេះក៏ត្រូវទុកជាសិទ្ធិរួមដែរ៖

- សិទ្ធិជីករុករកវត្ថុដែលមានក្នុងដី
- សិទ្ធិសាងសង់អគារថ្មីក្នុងទីធ្លា ឧទ្យាន ឬសួនច្បារដែលជាចំណែករួម
- សិទ្ធិជីកស្រះ រណ្តៅ ឬអណ្តូងជាអាទិ៍ ក្នុងទីធ្លា ឧទ្យាន ឬសួនច្បារទាំងនោះ
- សិទ្ធិនៃអឡ្សសិទ្ធិភាពដែលជាប់ទៅនឹងចំណែករួមទាំងឡាយ
- សិទ្ធិសាងសង់បន្ថែមនូវអគារសម្រាប់ប្រើប្រាស់រួមឬសម្រាប់បង្កើតចំណែកឯកជនបន្ថែមទៀត។

គ្មានករណីណាមួយដែលម្ចាស់ចំណែកឯកជនដែលនៅជាន់លើបំផុតនៃអគារសហកម្មសិទ្ធិ អាចសាងសង់បន្ថែមជាន់សម្រាប់តែខ្លួនឯងផ្ទាល់ឬលក់សិទ្ធិនៃការសាងសង់បន្ថែមជាន់នេះឡើយ។ បញ្ញត្តិនេះមានលក្ខណៈជាសណ្តាប់ធ្នាប់សាធារណៈ។

**យោបល់៖** មិនមានយោបល់

## មាត្រា៤៨._ របបគតិយុត្តនៃកម្មសិទ្ធិអវិភាគលើចំណែករួម

ចំណែកនៃកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធិករម្នាក់ៗលើចំណែករួម ត្រូវចំណុះទៅនឹងការចាត់ចែងចំណែកឯកជន។ ការចាត់ចែងឬការបោះបង់ចំណែកនៃកម្មសិទ្ធិអវិភាគលើចំណែករួមដាច់ដោយឡែកពីចំណែកឯកជនត្រូវបានហាមឃាត់ លើកលែងតែករណីមានចែងក្នុងច្បាប់នេះ។

ម្ចាស់បំណុលរបស់សហកម្មសិទ្ធិករមិនអាចស្នើសុំធ្វើការរឹបអូស រឹបអូសជាបណ្តោះអាសន្ន ឬចាត់ចែងជាបណ្តោះអាសន្ន ចំពោះតែចំណែកកម្មសិទ្ធិអវិភាគលើចំណែករួមដាច់ដោយឡែកពីកម្មសិទ្ធិលើចំណែកឯកជនដែលកូនបំណុលមានបានឡើយ។

បញ្ញត្តិដែលមានចែងក្នុងក្រមរដ្ឋប្បវេណីដូចខាងក្រោម មិនត្រូវយកមកអនុវត្តចំពោះចំណែករួមនៃសហកម្មសិទ្ធិ៖

១. បញ្ញត្តិស្តីពីលក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស។

២. បញ្ញត្តិស្តីពីលក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង។

បញ្ញត្តិដែលមានចែងក្នុងក្រមរដ្ឋប្បវេណីដូចខាងក្រោម មិនត្រូវយកមកអនុវត្តចំពោះកម្មសិទ្ធិអវិភាគនៃសហកម្មសិទ្ធិ៖

១. បញ្ញត្តិស្តីពីការបោះបង់សិទ្ធិនៃចំណែក ជាអាទិ៍

២. បញ្ញត្តិស្តីពីសិទ្ធិទាមទារបែងចែកវត្ថុកម្មសិទ្ធិអវិភាគ។

ការចាត់ថ្នាក់និងវិសាលភាពនៃចំណែករួម ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** មិនមានយោបល់

## មាត្រា៤៩._ សិទ្ធិរបស់សហកម្មសិទ្ធិករលើចំណែករួម

សហកម្មសិទ្ធិករនីមួយៗអាចប្រើប្រាស់ចំណែករួមទៅតាមមុខងារប្រើប្រាស់នៃចំណែករួមនោះបាន ដោយមិនគិតពីសមាមាត្រនៃចំណែកកម្មសិទ្ធិអវិភាគលើចំណែករួមរបស់ខ្លួនឡើយ។

សហកម្មសិទ្ធិករមិនត្រូវធ្វើសកម្មភាពដែលប៉ះពាល់ដល់ការថែរក្សាអចលនវត្ថុសហកម្មសិទ្ធិ និងសកម្មភាពផ្សេងទៀតដែលផ្ទុយនឹងផលប្រយោជន៍រួមរបស់សហកម្មសិទ្ធិករនៅក្នុងការការគ្រប់គ្រង ឬប្រើប្រាស់ចំណែកឯកជន និងចំណែករួមនោះឡើយ។

បញ្ញត្តិនៃកថាខណ្ឌទី១ និងកថាខណ្ឌទី២ ត្រូវយកមកអនុវត្តដូចគ្នាចំពោះអ្នកកាន់កាប់ចំណែកឯកជនក្រៅពីសហកម្មសិទ្ធិករផងដែរ។

**យោបល់៖** មិនមានយោបល់

## មាត្រា៥០._ ការផ្លាស់ប្តូរចំណែកឯកជនទៅជាចំណែករួម

រាល់ចំណែកឯកជននៃសហកម្មសិទ្ធិ អាចត្រូវបានផ្លាស់ប្តូរទៅជាចំណែករួមវិញបានតាមលក្ខខណ្ឌ និងនីតិវិធីដែលមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃសហកម្មសិទ្ធិ ប៉ុន្តែមិនត្រូវបំពានសិទ្ធិរបស់តតិយជនឡើយ។ ការផ្លាស់ប្តូរនេះមិនមានអានុភាពឡើយ បើមិនបានចុះបញ្ជីនៅរដ្ឋបាលសុរិយោដីតាមលក្ខខណ្ឌនិងនីតិវិធីដែលមានចែងក្នុងច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**យោបល់៖** ក្នុងមាត្រានេះប្រើពាក្យថា លិខិតបទដ្ឋានគតិយុត្ត ចំណែកឯក្នុងមាត្រាខាងដើមៗ ប្រើពាក្យថា បទដ្ឋានគតិយុត្តិ។ គួរប្រើពាក្យតែមួយដូចគ្នា ដោយប្រើពាក្យថា បទដ្ឋានគតិយុត្ត។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ និងមាត្រាពាក់ព័ន្ធ ស្របតាមយោបល់ខាងលើ។

### មាត្រា៩១._ ការផ្លាស់ប្តូរចំណែករួមទៅជាចំណែកឯកជន

រាល់ចំណែករួមនៃសហកម្មសិទ្ធិអាចត្រូវបានផ្លាស់ប្តូរទៅជាចំណែកឯកជនវិញបានតាមលក្ខខណ្ឌនិងនីតិវិធីដែលមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃសហកម្មសិទ្ធិ ប៉ុន្តែមិនត្រូវបំពានសិទ្ធិរបស់តតិយជនឡើយ។ ការផ្លាស់ប្តូរនេះមិនមានអានុភាពឡើយ បើមិនបានចុះបញ្ជីនៅរដ្ឋបាលសុរិយោដីតាមលក្ខខណ្ឌនិងនីតិវិធីដែលមានចែងក្នុងច្បាប់នេះ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**យោបល់៖** មិនមានយោបល់

### មាត្រា៩២._ ការពង្រីកចំណែករួមទៅលើក្បាលដីដែលជាប់ឬជិតខាង

សហកម្មសិទ្ធិករអាចធ្វើលទ្ធកម្មដីនៅជាប់ឬនៅជិតអចលនវត្ថុសហកម្មសិទ្ធិ ហើយកំណត់ដីនោះជាចំណែករួមនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃសហកម្មសិទ្ធិបាន។ ការកំណត់នេះមិនមានអនុភាពឡើយ បើមិនបានចុះបញ្ជីនៅរដ្ឋបាលសុរិយោដីតាមលក្ខខណ្ឌនិងនីតិវិធីដែលមានចែងក្នុងច្បាប់នេះ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**យោបល់៖** មិនមានយោបល់

### មាត្រា៩៣._ ឯកសិទ្ធិលើទ្រព្យរបស់សហកម្មសិទ្ធិករជាកូនបំណុល

គណៈគ្រប់គ្រង អ្នកគ្រប់គ្រង និងសហកម្មសិទ្ធិករនៃសហកម្មសិទ្ធិ មានឯកសិទ្ធិទូទៅលើទ្រព្យរបស់សហកម្មសិទ្ធិករផ្សេងទៀតដែលជាកូនបំណុលនៅក្នុងសហកម្មសិទ្ធិជាមួយគ្នា ដើម្បីធានាសិទ្ធិដូចខាងក្រោម៖

- សិទ្ធិលើបំណុលដែលពាក់ព័ន្ធនឹងចំណែករួម
- សិទ្ធិលើបំណុលផ្សេងទៀតដែលកើតឡើងដោយសារការអនុវត្តបទបញ្ជាផ្ទៃក្នុង ឬការសម្រេចចិត្តរបស់សហកម្មសិទ្ធិករ។

ឯកសិទ្ធិលើទ្រព្យរបស់សហកម្មសិទ្ធិករជាកូនបំណុល ត្រូវចាត់ទុកថាមានលំដាប់អាទិភាពនិងអានុភាពដូចគ្នានឹងឯកសិទ្ធិចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួមដែរ។

សិទ្ធិលើបំណុលដែលមានចែងក្នុងមាត្រានេះ អាចត្រូវទាមទារចំពោះប្រតិសិទ្ធិដោយឡែករបស់សហកម្មសិទ្ធិករដែលជាកូនបំណុលបានផងដែរ។

**យោបល់៖** មិនមានយោបល់

## មាត្រា៥៤._ សិទ្ធិកម្មសិទ្ធិរបស់ជនបរទេសលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ

បុគ្គលដែលមានសញ្ជាតិបរទេសអាចមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិចាប់ពីជាន់ទី១ (មួយ)ឡើងទៅ។ ជាន់ផ្ទាល់ដីនិងជាន់ក្រោមដីមិនត្រូវបានអនុញ្ញាតឱ្យបុគ្គលដែលមានសញ្ជាតិបរទេសមាន សិទ្ធិកម្មសិទ្ធិឡើយ។

សមាមាត្រនិងរបៀបគិតគូរនៃចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលអាចជាកម្មសិទ្ធិរបស់បុគ្គលដែលមានសញ្ជាតិបរទេសត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** មិនមានយោបល់

## មាត្រា៥៥._ ការហាមឃាត់សិទ្ធិកម្មសិទ្ធិរបស់សហកម្មសិទ្ធិករដែលមានសញ្ជាតិបរទេស

ក្នុងករណីណាក៏ដោយក៏ក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនៅ និងចំណែករួមនៃអគារសហកម្មសិទ្ធិមិនអាចជាកម្មវត្ថុនៃកម្មសិទ្ធិរបស់សហកម្មសិទ្ធិករដែលមានសញ្ជាតិបរទេសបានឡើយ ប៉ុន្តែសហកម្មសិទ្ធិករដែលមានសញ្ជាតិបរទេសអាចទទួលបានសិទ្ធិប្រើប្រាស់និងអាស្រ័យផលលើចំណែករួមនៃអគារសហកម្មសិទ្ធិបាន។

បុគ្គលដែលមានសញ្ជាតិបរទេសមិនត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលស្ថិតនៅក្នុងចំងាយ ៣០ (សាមសិប)គីឡូម៉ែត្រពីព្រំដែនគោកឡើយ និងតំបន់ផ្សេងទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល លើកលែងតែអគារសហកម្មសិទ្ធិស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទីប្រជុំជនសំខាន់ៗ និងតំបន់ផ្សេងទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល។

ការផ្ទេរឬទិញចំណែកឯកជននៃអគារសហកម្មសិទ្ធិដោយបុគ្គលដែលមានសញ្ជាតិបរទេសដោយរំលោភបំពានបញ្ញត្តិនៃមាត្រានេះត្រូវទុកជាមោឃៈ ហើយភាគីដែលធ្វើប្រតិបត្តិការជាមួយគ្នាត្រូវធ្វើបដិទានត្រលប់វិញ។

**យោបល់៖** មិនមានយោបល់

## មាត្រា៥៦._ ការផ្ទេរចំណែកឯកជននៃអគារសហកម្មសិទ្ធិរវាងបុគ្គលដែលមានសញ្ជាតិខ្មែរនិងបុគ្គលដែលមានសញ្ជាតិបរទេស

នៅពេលដែលសហកម្មសិទ្ធិករសញ្ជាតិខ្មែរ បានផ្ទេរកម្មសិទ្ធិលើចំណែកឯកជនរបស់ខ្លួនទៅបុគ្គលដែលមានសញ្ជាតិបរទេស សហកម្មសិទ្ធិករសញ្ជាតិបរទេសនេះទទួលបានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និងទទួលបានត្រឹមតែសិទ្ធិប្រើប្រាស់និងអាស្រ័យផលលើចំណែករួមតែប៉ុណ្ណោះ។ ក្នុងករណីនេះ អតីតសហកម្មសិទ្ធិករសញ្ជាតិខ្មែរបាត់បង់នូវកម្មសិទ្ធិអវិភាគរបស់ខ្លួនលើចំណែករួម។

ក្នុងករណីដែលសហកម្មសិទ្ធិករនៃចំណែកឯកជនជាបុគ្គលដែលមានសញ្ជាតិបរទេសបានផ្ទេរចំណែកឯកជនរបស់ខ្លួនមកឱ្យបុគ្គលដែលមានសញ្ជាតិខ្មែរ សហកម្មសិទ្ធិករដែលមានសញ្ជាតិខ្មែរនោះត្រូវទទួលបាននូវសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននិងកម្មសិទ្ធិអវិភាគលើចំណែករួម។

**យោបល់៖** មិនមានយោបល់

**មាត្រា៩៧._ សន្តតិកម្មនៃចំណែកឯកជនរបស់សហកម្មសិទ្ធិករដែលជាបុគ្គលដែលមានសញ្ជាតិបរទេស**

សន្តតិជននៃសហកម្មសិទ្ធិករលើចំណែកឯកជនដែលជាបុគ្គលដែលមានសញ្ជាតិបរទេស ត្រូវទទួលបន្តនូវសិទ្ធិនិងកាតព្វកិច្ចរបស់មតកជនដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីដែលមរតកនៅទំនេរដោយគ្មានសន្តតិជនទទួលបន្តឬសន្តតិជនបោះបង់ចោល ឬមរតកមិនត្រូវបានចាត់ចែងឱ្យទៅជនណាមួយតាមបញ្ញត្តិច្បាប់ មរតកនៅទំនេរនោះត្រូវធ្លាក់ទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ។

**យោបល់៖** មិនមានយោបល់

**មាត្រា៩៨._ អគារជួលអចិន្ត្រៃយ៍រួមគ្នានិងបុរីដែលអភិវឌ្ឍលើដីជួលអចិន្ត្រៃយ៍ឬផលុបភោគ**

បទប្បញ្ញត្តិនៃសហកម្មសិទ្ធិត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះអគារជួលអចិន្ត្រៃយ៍រួមគ្នា ដែលត្រូវបានពសាងសង់នៅលើដីជួលអចិន្ត្រៃយ៍ និងចំពោះបុរីដែលអភិវឌ្ឍលើដីជួលអចិន្ត្រៃយ៍ឬផលុបភោគ លុះត្រាតែមានការផ្ទុយពីលក្ខណៈរបស់វា។

**យោបល់៖** មិនមានយោបល់

គួរបង្កើតជំពូកថ្មីមួយ ត្រង់នេះ ស្តីពី ភោគៈ (ការកាន់កាប់ដីរដ្ឋដែលមិនទាន់បានចុះបញ្ជី) មុនជំពូកស្តីពីសម្បទានដី។

## ជំពូកទី៩
## សម្បទានដី

**មាត្រា៩៩._ និយមន័យនៃសម្បទានដី**

សម្បទានដីជាសិទ្ធិស្របច្បាប់ដែលបានចែងក្នុងឯកសារគតិយុត្ត ចេញដោយអាជ្ញាធរមានសមត្ថកិច្ច តាមអំណាចធន្ទានុសិទ្ធិ ឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្ស ដើម្បីកាន់កាប់ដី និងប្រើប្រាស់សិទ្ធិលើដីនោះតាមការកំណត់នៃច្បាប់នេះ។

**យោបល់៖** រាល់និយមន័យនៃពាក្យគន្លឹះគួរដាក់ក្នុងមាត្រា៣ទាំងអស់។ ដូច្នេះគួរដកនិយមន័យនេះទៅដាក់ក្នុងមាត្រា៣។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា៦០._ ប្រភេទនៃសម្បទានដី

សម្បទានដីមាន២(ពីរ)ប្រភេទ រួមមាន សម្បទានដីសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ច។

សម្បទានដីសង្គមកិច្ចត្រូវឆ្លើយតបទៅនឹងប្រយោជន៍សង្គមអនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍រៀបចំដីដើម្បីសង់លំនៅឋានឬ/និងដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋ ដើម្បីជានាការស្នាក់នៅនិង/ឬ ការប្រកបរបរចិញ្ចឹមជីវិត។

សម្បទានដីសេដ្ឋកិច្ចត្រូវឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច អនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍កាប់ឆ្ការទាញយកផលដោយធ្វើអាជីវកម្មកសិកម្មនិង/ឬកសិឧស្សាហកម្ម។ (មាត្រា៦១)

**យោបល់៖** មិនមានយោបល់

### មាត្រា៦១._ ការការពារប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ពីការបង្កើតសិទ្ធិសម្បទានដី (មាត្រា៧២)

សម្បទានដីអាចធ្វើឡើងបានតែនៅលើដីដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀតដែលបានចុះបញ្ជីរួចនោរដ្ឋបាលសុរិយោដីតែប៉ុណ្ណោះ។ សម្បទានដីមិនអាចប៉ះពាល់ដីចំណីផ្លូវថ្នល់ ដីចំណីឆ្នេរសមុទ្រ ទន្លេ ស្ទឹង ដីចំណីព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក និងដែលទឹកបម្រុងដែលមានប្រយោជន៍ដល់ការរស់នៅ របស់ប្រជាពលរដ្ឋក្នុងសហគមន៍ ឡើយ។

**យោបល់៖** គួរបន្ថែមក្នុងឃ្លាចុងក្រោយថា និងដីដែលប្រើប្រាស់ជាប្រយោជន៍របស់សហគមន៍ដែលនៅក្បែរ ឬ នៅជាប់ដីសម្បទាន ។ ក្នុងករណីសម្បទានដីប៉ះពាល់ដី អចលនវត្ថុដទៃទៀត និងផលប្រយោជន៍ស្របច្បាប់របស់ ប្រជាពលរដ្ឋទោះដោយការធ្វេសប្រហែស ឬអចេតនាពីភ្នាក់ងាររដ្ឋក្តី រដ្ឋត្រូវខិតខំដោះស្រាយឱ្យបានឆាប់រហ័ស ព្រមទាំងផ្តល់សំណងចំពោះព្យសនកម្មដែលកើតចេញពីសកម្មភាព និងសេចក្តីសម្រេចនោះ។ គួរចែងបន្ថែមនូវវិធានការចំពោះសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ចដែលបានផ្តល់ឱ្យកន្លងមក ហើយដែលមិនទាន់បានចុះបញ្ជីដីនៅរដ្ឋបាលសុរិយោដីផង។

**សំណើបែងបន្ថែម៖** សូមថែងបន្ថែមអំពីបញ្ហា ដែលមានក្នុងយោបល់ខាងលើ។

**មាត្រា៦២._ ប្រភេទសម្បទានដែលមិនស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ**

សម្បទានអាចមានប្រភេទផ្សេងទៀត ដូចជាការអនុញ្ញាតឱ្យប្រើប្រាស់ រៀបចំ ឬធ្វើអាជីវកម្មដីដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ទោះជាភ្ជាប់ឬមិនភ្ជាប់ទៅនឹងការបំពេញសេវាសាធារណៈក៏ដោយ មានជាអាទិ៍ សម្បទានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សម្បទានរ៉ែ សម្បទានកំពង់ផែ សម្បទានព្រលានយន្តហោះ អាកាសយានដ្ឋាន សម្បទានរៀបចំតំបន់អភិវឌ្ឍឧស្សាហកម្ម សួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត សម្បទានដីស្រែអំបិល សម្បទាននេសាទ មិនស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះទេ។

**យោបល់៖** គួររាប់បញ្ចូលនូវសម្បទានទេសចរណ៍ សម្បទាននេសាទ សម្បទានព្រៃឈើផងដែរ។
**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា៦៣._ ថ្លៃសម្បទានដី (មាត្រា៦៣)**

សម្បទានដីមិនអាចប្រគល់ឱ្យដោយឥតគិតថ្លៃទេ លើកលែងតែសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម ដែលប្រគល់ឱ្យគ្រួសារក្រីក្រសម្រាប់តាំងទីលំនៅឬ/និងដាំដំណាំចិញ្ចឹមជីវិត។

**យោបល់៖** មិនមានយោបល់

**មាត្រា៦៤._ លក្ខខណ្ឌនៃសម្បទានដី**

សម្បទានដីត្រូវមានលក្ខខណ្ឌនិងត្រូវតែអនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ដែលជាសណ្តាប់ធ្នាប់សាធារណៈ។

សម្បទានដីអាចបង្កើតបានតែសិទ្ធិក្នុងរយៈពេលមួយជាកំណត់តាមកិច្ចសន្យាដែលបានបង្កើតសម្បទាននោះ ស្របតាមបញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិដទៃទៀតជាធរមាន។

លិខិតសម្បទានដីអាចមានខ/លក្ខខណ្ឌដោយឡែកផ្សេងទៀត ដែលមានតម្លៃជាកិច្ចសន្យា។

**យោបល់៖** គួរមានថែងបន្ថែមថា ឋអាចផ្តល់សម្បទានដីលើទីតាំងដីរបស់ឯកជនរបស់រដ្ឋ ឬ របស់នីតិបុគ្គលសាធារណៈណាមួយ តែក្នុងករណីដែលដីនោះត្រូវបានកំណត់ព្រំប្រទល់ដាក់ស្តែងច្បាស់លាស់ បានចុះបញ្ជីសុរិយោដីពេញលេញរួច ហើយមានការពិគ្រោះយោបល់ជាសាធារណៈជាមួយសហគមន៍ជុំវិញតំបន់ទីតាំងដីនោះ ព្រមទាំងមានការប៉ាន់ប្រមាណ

ហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលមានរបាយការណ៍ពេញលេញពិនិត្យឯកភាពដោយក្រសួងបរិស្ថាន និង ផ្សព្វផ្សាយជាសាធារណៈ។

**សំណើថែងបន្ថែម៖** សូមថែងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា៦៥._ លក្ខខណ្ឌនៃការដកហូតដីសម្បទាន

អាជ្ញាធរមានសមត្ថកិច្ចត្រូវសម្រេចដកហូតសម្បទានដី ក្នុងករណីសម្បទានិកមិនគោរពតាមលក្ខខណ្ឌដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធបានកំណត់ និងដែលមានចែងនៅក្នុង ខ/លក្ខខណ្ឌទូទៅនៃកិច្ចសន្យា។ ក្នុងករណីនេះ សម្បទានិកមានសិទ្ធិប្តឹងទៅតុលាការតាមលក្ខខណ្ឌនិងនីតិវិធីដែលច្បាប់បានកំណត់។

សម្បទានដីអាចត្រូវបានទុកជាមោឃៈដោយតុលាការ កាលបើសម្បទានិកមិនគោរពខ/លក្ខខណ្ឌដោយឡែកដែលមានចែងក្នុងកិច្ចសន្យា អាជ្ញាធរមានសមត្ថកិច្ចត្រូវប្តឹងទៅតុលាការ។

**យោបល់៖** គួរមានការចែងដោយឡែកពីគ្នាសម្រាប់ករណីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច។ សម្រាប់ករណីដីសម្បទានសង្គមកិច្ច គួរចែងឱ្យអាជ្ញាធរផ្តល់សម្បទានដីសង្គមកិច្ច ឬមេឃុំចៅសង្កាត់នៃទីតាំងដីសម្បទានដែលតំណាងឱ្យអាជ្ញាធរផ្តល់សម្បទានដីនោះ ធ្វើការតាមដាន ណែនាំ និង ជូនដំណឹងអំពីសេចក្តីសម្រេចរដ្ឋបាលស្តីពីការដកដីសម្បទានពីមុខសញ្ញាអ្នកទទួលដី ដែលបំពានលក្ខខណ្ឌសារវន្តនៃគោលនយោបាយសម្បទានដីសង្គមកិច្ច ហើយបើកសិទ្ធិឱ្យប្តឹងតវ៉ាក្នុងអំឡុង ៦០ ថ្ងៃប្រតិទិន។ សម្រាប់សម្បទានដីសេដ្ឋកិច្ច ករណីយល់ថាមានការបំពានខចែង ឬលក្ខខណ្ឌក្នុងកិច្ចសន្យាដោយសម្បទានិក មិនត្រូវចាត់ទុកជាមោឃៈទេ គួរតែទាមទារឱ្យមានការអនុវត្ត និងសងការខូចខាតដោយសារការបំពានកិច្ចសន្យាសិន ចាំឱ្យតុលាការប្រកាសលុបចោលសម្បទាននោះប្រសិនបើ នៅតែមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា។ ការបំពានអាចតែបន្តិចបន្តួច (តូចតាច) ឬអាចធ្ងន់ធ្ងរ (ធំដុំ) ដូច្នេះវាមិនយុត្តិធម៌ទេក្នុងការលុបចោល ឬទុកជាមោឃៈនូវសម្បទាន ដោយសារតែ ការបំពានតូចតាច។ ម្យ៉ាងទៀតចាំបាច់ត្រូវជានានូវភាពចុះសម្រុងគ្នារវាងខ្លឹមសានៃមាត្រានេះ ជាមួយខ្លឹមសារនៃមាត្រា ៧២ ព្រោះសុទ្ធតែចែងអំពីករណីដែលសម្បទានិក បំពានច្បាប់ បទដ្ឋានគតិយុត្ត ឬនិងកិច្ចសន្យាដីសម្បទាន ប៉ុន្តែក្នុងមាត្រានេះថាត្រូវសុំឱ្យតុលាការ លុបចោល ឬមោឃៈកិច្ចសន្យា រីឯក្នុងមាត្រា ៧២ ថាឱ្យអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាដីសម្បទាន បញ្ចប់កិច្ចសន្យាជាឯកតោ ភាគី និងដកហូតរាល់សិទ្ធិទាំងឡាយពីសម្បទានិក។ ការសម្រេចបញ្ចប់កិច្ចសន្យាជាឯកតោភាគី ឬនិង សម្រេចដកហូតសិទ្ធិរបស់សម្បទានិក អាចជាកម្មវត្ថុនៃការប្តឹងតវ៉ាទៅតុលាការដោយសម្បទានិក ដើម្បីវិនិច្ឆ័យអំពីករណីចោទប្រកាន់ ទាមទារការអនុវត្តតាមកិច្ចសន្យា និងឬទាមទារសំណងការខូចខាត។ ដូច្នេះ វាអាចជាការប្រសើរ និងមានសុវត្ថិភាពជាងត្រឹមតែធ្វើការសម្រេចឱ្យផ្អាក ឬព្យួរសកម្មភាព សម្បទាន

ហើយដាក់ពាក្យស្នើសុំទៅតុលាការឱ្យសម្រេចអំពីករណីបំពាន និងឧបាស័យ មុននឹងបញ្ចប់ លុបចោល ឬ មោឃៈកិច្ចសន្យាដីសម្បទាន និងដកហូតរាល់សិទ្ធិរបស់សម្បទានិកមកវិញ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា៦៦._ ការបង្កើតសម្បទានដី

សម្បទានដីមិនអាចកើតចេញពីស្ថានភាពកាន់កាប់ដីជាក់ស្តែងបានទេ។ សម្បទានដីត្រូវសំអាងលើលិខិតគតិយុត្តជាក់លាក់ដែលបានចេញមុនការកាន់កាប់ដីដោយរដ្ឋ ឬដោយនីតិបុគ្គលសាធារណៈដទៃទៀតដែលជាកម្មសិទ្ធិករនៃដីដែលជាកម្មវត្ថុនៃសម្បទាន។

**យោបល់៖** មិនមានយោបល់

## មាត្រា៦៧._ សិទ្ធិពិសេសរបស់សម្បទានិកក្នុងការទទួលបានការការពារដោយអាជ្ញាធរមានសមត្ថកិច្ច

សម្បទានិកមានសិទ្ធិជាពិសេសក្នុងការការពារស្ថានភាពរបស់ខ្លួន ដោយអាជ្ញាធរមានសមត្ថកិច្ច។ សម្បទានិកត្រូវការពារដីដែលបានផ្តល់ជាសម្បទានឱ្យខ្លួន ចំពោះការទន្ទ្រានឬការប៉ះពាល់ទោះជាតាមរូបភាពណាក៏ដោយ។

**យោបល់៖** គួរបញ្ជាក់ថានរណាជាអាជ្ញាធរមានសមត្ថកិច្ច សម្រាប់មាត្រានេះ។ គួរមានចែងអំពីករណីផ្តល់សម្បទានដីដែលបំពានលើសិទ្ធិភោគៈស្របច្បាប់ សិទ្ធិកម្មសិទ្ធិឯកជន ឬសិទ្ធិសមូហភាព ដោយសារដីសម្បទាននោះមិនទាន់ត្រូវបានវិនិច្ឆ័យ និងចុះបញ្ជីកម្មសិទ្ធិដីនៅឡើយផងដែលមានកន្លងមក។ គួរលុបឃ្លាថា ទោះជាតាមរូបភាពណាក៏ដោយនេះចេញ ដើម្បីសម្រួលដល់ការប្រើប្រាស់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ដូចកំណត់ក្នុងមាត្រា ៦១។ ដើម្បីជៀសវាង ឬកាត់បន្ថយនូវការអនុវត្តវិធានការមិនសមស្រប គួរចែងពន្យល់ថាតើ ការការពារស្ថានភាពរបស់សម្បទានិកដោយអាជ្ញាធរមានសមត្ថកិច្ច និងការការពារដីដោយសម្បទានិក មានន័យដូចម្តេច ឬអាចធ្វើឡើងតាមរបៀបណាខ្លះ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា៦៨._ ការទាញយកផលិតផលពីដីសម្បទាន (មាត្រា៦៩)

សម្បទានិកអាចទាញយកនូវផលិតផលពីដីសម្បទាន ធ្វើការរៀបចំ ដាំដុះ ស្របតាមគោលបំណងនៃសម្បទាន។

**យោបល់៖** គួរចែងបន្ថែមទៀតថា សម្បទានិកមិនអាចធ្វើសកម្មភាពអ្វីផ្សេងទៀតដែលមិនបានកំណត់ក្នុងលិខិតសម្បទាន ឬកិច្ចសន្យាសម្បទាន និងមិនត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចឡើយ។ ការធ្វើសកម្មភាពផ្សេងក្រៅពីការកំណត់ក្នុងលិខិតសម្បទាន ឬកិច្ចសន្យាសម្បទាន ឬដែលមិនត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ច អាចបើកសិទ្ធិឱ្យអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ឬកម្មសិទ្ធិករនៃដី ស្នើសុំតុលាការលុបចោលសិទ្ធិសម្បទាន និងទាមទារសំណងការខូចខាតពីសម្បទានិក។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា៦៩._ លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់សម្បទានដីសង្គមកិច្ច (មាត្រា៧០)**

សម្បទានិកនៃសម្បទានដីសង្គមកិច្ច អាចស្នើសុំចុះបញ្ជីកម្មសិទ្ធិទៅតាមនីតិវិធី និងអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើដីនោះនៅពេលដែលលក្ខខណ្ឌត្រូវបានគោរព។

ប្រសិនបើមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចណា ខកខានមិនបានបំពេញតាមលក្ខខណ្ឌនៃការកាន់កាប់និងប្រើប្រាស់ដីសម្បទាននោះ អាជ្ញាធរមានសមត្ថកិច្ចត្រូវដកហូតដីនេះមកវិញ ដើម្បីធ្វើការបែងចែកសាជាថ្មី។

មុខសញ្ញាអ្នកទទួលដីមិនអាចលក់ ដូរ ជួល ឬធ្វើអំណោយដីសម្បទានសង្គមកិច្ចក្នុងរយៈពេល៥(ប្រាំ)ឆ្នាំដំបូងនៃការអនុវត្តកម្មវិធីសម្បទានសង្គមកិច្ចទេ។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់សម្បទានដីសង្គមកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** មុន ឬក្រោយពេលបានផ្តល់សម្បទានដីសង្គមកិច្ចរួច អ្នកផ្តួចផ្តើម ឬអ្នកអនុវត្តគម្រោងដីសម្បទាននេះគួរស្នើសុំបំបែកក្បាលដី និងចុះបញ្ជីបន្តនូវក្បាលដីដែលបានបំបែកនោះ ព្រោះដីដែលអាចយកមកផ្តល់សម្បទានដីសង្គមកិច្ចជាដីឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈដែលបានធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីលើកដំបូងរួចហើយ។ ក្រោយពេល ផ្តល់សម្បទានដីសង្គមកិច្ចភ្លាម អ្នកផ្តួចផ្តើម ឬអ្នកអនុវត្តគម្រោងដីសម្បទាននេះគួររៀបចំស្នើសុំចុះបន្ទុកសម្បទាន។ បន្ទាប់មក អ្នកផ្តួចផ្តើមគម្រោងដីសម្បទាននេះ គួរតែមានកម្មវិធីជួយដល់សម្បទានិកដីសង្គមកិច្ចដែលមានសិទ្ធិសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ (ចុះបញ្ជីបន្ត) ដោយសារដីសម្បទានត្រូវបានចុះបញ្ជីលើកដំបូងរួចហើយមុនពេលផ្តល់សម្បទាន ឬក្រោយពីការផ្តល់សម្បទានចំពោះគម្រោងផ្តល់សម្បទានដីសង្គមកិច្ចកន្លងមកណាមួយដែលមិនទាន់បានចុះបញ្ជីដីលើកដំបូង។ រដ្ឋគួរពិចារណាបន្ថែមជម្រើសផ្សេងទៀតនៃការផ្តល់សម្បទានដីសង្គមកិច្ចក្នុងទម្រង់ជាសិទ្ធិផលុបភោគ ឬសិទ្ធិជួលអចិន្ត្រៃយ៍ដែលមានថ្លៃឈ្នួលស្មើសូន្យផង។ គួរចែងបញ្ជាក់អំពីអាជ្ញាធរមានសមត្ថកិច្ចដែលយោងក្នុងមាត្រានេះផង។ ដើម្បីជួយដល់សម្បទានិកដែលខ្វះខាតមធ្យោបាយផលិតកម្ម កម្លាំងពលកម្ម ឬនិងថវិកាសម្រាប់ចំណាយលើការរៀបចំសម្អាតដីដើម្បីដាំដុះក្នុងដំណាក់កាលដំបូង គួរមានការចែងអនុញ្ញាតឱ្យជួលដី

សម្បទានសម្រាប់ដាំដុះ ឬប្រវាស់ផ្នែកខ្លះនៃដីសម្បទានសង្គមកិច្ច ដោយមានកិច្ចសន្យាលាយល័ក្ខណ៍អក្សរ រយៈពេលមិនលើសពី ៥ឆ្នាំ និងបញ្ជាក់ដោយអាជ្ញាធរឃុំសង្កាត់នៃទីតាំងដីសម្បទាន ក្នុងលក្ខខណ្ឌថាសម្បទានិកកំពុងប្រើប្រាស់ដីជាក់ស្តែងលើផ្នែកខ្លះ។ គួរចែងថា រាល់ការព្រមព្រៀងជាឯកជន ឬធ្វើទុកមុនដោយមិនទាន់ ដាក់កាលបរិច្ឆេទក្នុងអំឡុងពេល ៥ ឆ្នាំដំបូង ស្តីពីការលក់ ដូរ ផ្ទេរ ឬធ្វើអំណោយ នូវសិទ្ធិលើដីសម្បទាន សង្គមកិច្ចត្រូវទុកជាមោឃៈដាច់ខាត។ លើសពីនេះក្នុងនីតិវិធីនៃការបែងចែកប្រគល់ក្បាលដីជូនមុខសញ្ញាអ្នកទទួលដី ត្រូវផ្អែកលើគោលការណ៍សមធម៌ និងយេនឌ័រ ព្រមទាំងត្រូវមានការយកចិត្តទុកដាក់ជាពិសេសអំពីគ្រួសារដែលមានជនពិការភាព ឬនិងចាស់ជរា។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា៧០._ ការផ្ទេរសិទ្ធិសម្បទានដីសង្គមកិច្ច (មាត្រា៦៨)

ការផ្ទេរសិទ្ធិដីសម្បទានត្រូវកើតឡើងតែតាមរយៈការបង្កើតកិច្ចសន្យាថ្មីនៃសម្បទានដោយអាជ្ញាធរមានសមត្ថកិច្ចជា គុណប្រយោជន៍ដល់អ្នកទទួលសិទ្ធិសម្បទានថ្មី លើកលែងតែក្នុងករណីដែលសម្បទានិកទទួលមរណភាព សន្តតិជនទាំងឡាយរបស់មតកជនអាចបន្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរហូតដល់គ្រប់៥(ប្រាំ)ឆ្នាំ។

**យោបល់៖** មិនគួរអនុញ្ញាតឱ្យធ្វើការផ្ទេរសិទ្ធិលើដីសម្បទានសង្គមកិច្ចឡើយ សម្រាប់ករណីផ្តល់សិទ្ធិទទួលបានកម្មសិទ្ធិក្រោយអនុវត្តបាន៥ឆ្នាំ។ ការអនុញ្ញាតឱ្យផ្ទេរសិទ្ធិដីសម្បទានសង្គមកិច្ច តាមការបង្កើតកិច្ចសន្យាសម្បទានថ្មីចំពោះដីសម្បទានសង្គមកិច្ច អាចនាំឱ្យមានការអនុវត្តផ្ទុយពីគោលបំណងនៃការផ្តល់សម្បទានប្រភេទនេះ។ ក្រោយពីបំពេញលក្ខខណ្ឌប្រើប្រាស់ដីសម្បទានសង្គមកិច្ចបាន៥ឆ្នាំ ដីសម្បទានសង្គមកិច្ចគួរក្លាយជាកម្មវត្ថុនៃការកម្មសិទ្ធិឯកជន ហើយផុតពីរបបសម្បទានដីសង្គមកិច្ច។ អ្នកផ្តល់សម្បទាន គួររៀបចំការចុះបញ្ជីនូវការលុបបន្ទុកដីសម្បទាន និងការផ្ទេរសិទ្ធិ (ការចុះបញ្ជីបន្ត) ជូនសម្បទានិកដែលមានលក្ខណៈសម្បត្តិជាកម្មសិទ្ធិករនៃដីនោះ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា៧១._ សិទ្ធិរបស់សម្បទានិកនៃសម្បទានដីសេដ្ឋកិច្ច

ការផ្ទេរដីសម្បទានសេដ្ឋកិច្ចមិនអាចធ្វើឡើងតាមរយៈការផ្ទេរសិទ្ធិបានឡើយ។

រាល់ការជួលបន្ត ការផ្ទេរសិទ្ធិ ការដាក់ប្រាតិភោគដើម្បីជានាបំណុល មិនត្រូវបានអនុញ្ញាតឡើយបើគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមានសមត្ថកិច្ច។ ប៉ុន្តែទោះជាយ៉ាងណា សម្បទានិកនៃសម្បទានដីសេដ្ឋកិច្ច

មានសិទ្ធិស្នើសុំឱ្យបង្កើតកិច្ចសន្យាថ្មីដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ច ទៅឱ្យអ្នកទទួលសិទ្ធិសម្បទានថ្មីបាន។

សម្បទានិកនៃសម្បទានដីសេដ្ឋកិច្ច អាចបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍លើដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ប៉ុន្តែអ្នកជួលអចិន្ត្រៃយ៍នោះពុំអាចប្រើប្រាស់សិទ្ធិដូចជាអ្នកជួលអចិន្ត្រៃយ៍លើកម្មសិទ្ធិឯកជនឡើយ។

ការផ្ទេរសិទ្ធិដីសម្បទានសេដ្ឋកិច្ចត្រូវធ្វើឡើងតែតាមរយៈការបង្កើតកិច្ចសន្យាថ្មីនៃសម្បទានដោយអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាជាគុណប្រយោជន៍ដល់អ្នកទទួលសិទ្ធិសម្បទានថ្មី លើកលែងតែក្នុងករណីដែលសម្បទានិកទទួលមរណភាព សន្តតិជនទាំងឡាយរបស់មតកជន អាចបន្តប្រើប្រាស់សិទ្ធិទាំងនោះក្នុងរយៈពេលសម្បទានដីសេដ្ឋកិច្ចដែលនៅសល់។

**យោបល់៖** គួរបញ្ជាក់អំពីអាជ្ញាធរមានសមត្ថកិច្ច ថាជាអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច។ គួរមានកំណត់លក្ខខណ្ឌពិសេសថាត្រូវមានធនធានហិរញ្ញវត្ថុ បច្ចេកទេស ផលិតកម្ម និងជំនាញសមត្ថភាពទាញផលពីដីសម្បទានប្រកបដោយចីរភាព យ៉ាងហោច ៣០% ខ្ពស់ជាងអ្វីដែលសម្បទានិកដើមមាន ក្នុងករណី អនុញ្ញាតឱ្យមានការស្នើសុំផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ចទៅឱ្យអ្នកទទួលសិទ្ធិសម្បទានថ្មី ដើម្បីកាត់បន្ថយកត្តាលើកទឹកចិត្ត ឬឱកាសសម្រាប់សម្បទានិកដើម សុំដីសម្បទានក្នុងគោលបំណងតែទុកកេងយកចំណេញពីការផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ច។ ដើម្បីតម្លាភាព ធានាបាននូវឧត្តមប្រយោជន៍របស់កម្មសិទ្ធិករនៃដី ព្រមទាំងកាត់បន្ថយឱកាសប្រព្រឹត្តអំពើពុករលួយពាក់ព័ន្ធនឹងការស្នើសុំផ្ទេរសិទ្ធិដីសម្បទាន ច្បាប់នេះគួរចែងលក្ខខណ្ឌលម្អិតថាករណីដែលអនុញ្ញាត ឬមិនអនុញ្ញាតឱ្យអាជ្ញាធរមានសមត្ថកិច្ច (អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច) យល់ព្រមចំពោះការស្នើសុំផ្ទេរសិទ្ធិដីសម្បទានសេដ្ឋកិច្ច។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា៧២._ លក្ខខណ្ឌនៃការដកហូតសម្បទានដីសេដ្ឋកិច្ច

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ត្រូវបញ្ចប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចដោយឯកតោភាគី និងដកហូតរាល់សិទ្ធិទាំងឡាយពីសម្បទានិក ក្នុងករណីណាមួយដូចខាងក្រោម៖

១. សម្បទានិកមិនបានចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីថ្ងៃដែលសម្បទានិកត្រូវបានផ្តល់សិទ្ធិឱ្យចូលគ្រប់គ្រងនិងកាន់កាប់ដីសម្បទាន។

២. សម្បទានិកខកខានធ្វើអាជីវកម្មដោយគ្មានមូលហេតុត្រឹមត្រូវក្នុងរយៈពេលលើសពី ១២(ដប់ពីរ) ខែជាប់គ្នា។

៣. សម្បទានិកមិនបានធ្វើអាជីវកម្មដោយគ្មានមូលហេតុត្រឹមត្រូវចាប់ពី១២(ដប់ពីរ) ខែឡើងទៅគិតពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ចំពោះករណីសម្បទានដីដែលបានផ្តល់ឱ្យមុនច្បាប់នេះចូលជាធរមាន។

៤. សម្បទានិកមិនបានបំពេញកិច្ចតាមសៀវភៅបន្ទុក។

៥. ករណីផ្សេងទៀតដែលកំណត់ដោយអនុក្រឹត្យ។

ក្នុងករណីនៃការដកហូតសម្បទានទោះជាមានមូលហេតុអ្វីក៏ដោយ សម្បទានិកគ្មានសិទ្ធិទារសំណងនៃការខូចខាតណាមួយឡើយ។

**យោបល់៖** សូមមើលយោបល់ក្នុងមាត្រា ៦៥ ខាងលើ។ ការដកហូតដីសម្បទានដោយគ្មានមូលហេតុសមស្រប កំណត់ក្នុងច្បាប់ បទដ្ឋានគតិយុត្តជាធរមាន ឬនិងកិច្ចសន្យាដីសម្បទាន បើកសិទ្ធិឱ្យសម្បទានិកប្តឹងទាមទារសំណងខូចខាត។ ជាការមិនលើកទឹកចិត្តដល់អ្នកវិនិយោគពិតប្រាកដ ជាពិសេសអ្នកវិនិយោគបរទេស ក្នុងការដាក់ទុកវិនិយោគលើដីសម្បទានសេដ្ឋកិច្ចឡើយ ប្រសិនបើច្បាប់នេះ ឬនិង បទដ្ឋានគតិយុត្ត កំណត់ករណីភាគីម្ខាង (ជារដ្ឋ ឬកម្មសិទ្ធិករនៃដី) អាចបញ្ចប់កិច្ចសន្យាជាឯកតោភាគីតាមទំនើងចិត្តរបស់ខ្លួន និងដកហូតសិទ្ធិទាំងអស់របស់ភាគីម្ខាងទៀត (សម្បទានិក) ទោះដោយសារមូលហេតុអ្វីក៏ដោយ ហើយសម្បទានិកគ្មានសិទ្ធិទាមទារសំណងខូចខាតទេនោះ។ រាល់លក្ខខណ្ឌសមស្របដែលផ្តល់សិទ្ធិឱ្យភាគីម្ខាងៗសម្រេច និងជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យាដីសម្បទានជាឯកតោភាគី ហើយមិនមានកាតព្វកិច្ចទទួលខុសត្រូវចំពោះការខូចខាតរបស់ភាគីម្ខាងទៀត គួរតែមានចែងច្បាស់ក្នុងកិច្ចសន្យាដីសម្បទាន ឬកិច្ចសន្យាបំពេញបន្ថែម។ ការប្រើអំណាចឆន្ទានុសិទ្ធិរបស់រដ្ឋបាលសាធារណៈ ក្នុងទំនាក់ទំនងកិច្ចសន្យាក្រោមរបបគតិយុត្តឯកជន គួរតែជៀសវាង ឬធ្វើតែក្នុងករណីចាំបាច់ដើម្បីប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។ សូមដាក់បញ្ចូល និងពង្រីកបន្ថែមនូវលក្ខខណ្ឌនៃការត្រួតពិនិត្យឡើងវិញ ចំពោះសម្បទានដីសេដ្ឋកិច្ចដែលមានទំហំសរុបលើសពីច្បាប់ភូមិបាល ឆ្នាំ២០០១ បានអនុញ្ញាត។ សូមបញ្ជាក់អំពីអំឡុងពេលអតិបរមានៃសម្បទានដីសេដ្ឋកិច្ចផង។ លើសពីនេះលក្ខខណ្ឌតម្រូវនៃការប៉ាន់ប្រមាណហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃការប្រើប្រាស់អភិវឌ្ឍន៍ដីក្នុងគម្រោង សម្បទានដីដែលមានទំហំលើសពី ៥០០ ហិកតា ទោះជាគម្រោងសម្បទានដែលមានស្រាប់ ឬថ្មីក៏ដោយ ចាំបាច់ត្រូវតែបានធ្វើឡើងតាមបច្ចេកទេសវិជ្ជាជីវៈនៃការវាយតម្លៃហេតុប៉ះពាល់ ពិគ្រោះយោបល់ជាមួយសហគមន៍ជុំវិញ ពិនិត្យឯកភាពដោយក្រសួងបរិស្ថាន និងផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ និងផែនការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា៧៣._ លក្ខខណ្ឌតតាំងនៃការបង្កើតសិទ្ធិសម្បទានដីសេដ្ឋកិច្ច**

សម្បទានដីសេដ្ឋកិច្ចត្រូវតែចុះបញ្ជីនៅរដ្ឋបាលសុរិយោដី។ ការចុះបញ្ជីសម្បទានដីសេដ្ឋកិច្ច ជាលក្ខខណ្ឌតតាំងជាមួយតតិយជន។

**យោបល់៖** គួរតែចែងថាសិទ្ធិសម្បទានដីសេដ្ឋកិច្ចត្រូវចុះបន្ទុកក្នុងបញ្ជីអចលនវត្ថុនៅរដ្ឋបាលសុរិយោដី ហើយមិនមែនជាការចុះបញ្ជីដីលើកដំបូងទេ។ ការចុះបញ្ជីដីលើកដំបូង ជាបន្ទុក និងកាតព្វកិច្ចរបស់ម្ចាស់ដី ព្រោះច្បាប់នេះចែងថាដើម្បីអាចផ្តល់សម្បទានបានត្រូវមានការចុះបញ្ជីដីនោះថាជាដីឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈ។ ដូច្នេះប្រសិនបើដីនោះត្រូវបានចុះបញ្ជីលើកដំបូងរួចហើយ ការតម្រូវឱ្យចុះបន្ទុកដីសម្បទាន (ឬចុះបញ្ជីសិទ្ធិដីសម្បទាន) ដើម្បីបង្កើតលក្ខខណ្ឌតតាំងជាមួយតតិយជន ជាការសមស្រប និងអាចអនុវត្តបាន ផ្ទុយទៅវិញ ប្រសិនបើដីនោះមិនទាន់បានចុះបញ្ជីលើកដំបូងទេ ការតម្រូវឱ្យសម្បទានិកចុះបន្ទុកដីសម្បទានដើម្បីបង្កើតលក្ខខណ្ឌតតាំងជាមួយតតិយជន មិនសមស្រប ឬនិងមិនអាចអនុវត្តបានឡើយ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាតិកាទី៣
## បទប្បញ្ញត្តិនៃការប្រើប្រាស់ដី
## ជំពូកទី១
## វិធាននៃដី

**មាត្រា៧៤._**

សិទ្ធិនិងកាតព្វកិច្ចនៃកម្មសិទ្ធិករ ត្រូវបានកម្រិតដោយវិធានដីទាំងឡាយ សំដៅជានាការពារផលប្រយោជន៍ទូទៅដែលកំណត់ដោយច្បាប់។

**យោបល់៖** រាល់វិធានដី មិនគួរមានអានុភាពជាការដកហូត លុបចោល បដិសេធ ឬមោឃៈ មួយផ្នែក ឬទាំងស្រុង នូវសិទ្ធិប្រត្យក្សលើដី ឬអចលនវត្ថុដទៃទៀតជាធរមានស្របច្បាប់របស់បុគ្គលឯកជន ឬសមូហភាពឡើយ ប៉ុន្តែគ្រាន់តែអាចកម្រិត ឬដាក់លក្ខខណ្ឌចំពោះការប្រើប្រាស់ថ្មីលើដី ឬអចលនវត្ថុនោះក្រោយពីមានវិធានដី ដែលរៀបចំឡើងដោយមានតម្លាភាព មានការពិគ្រោះយោបល់ជាសាធារណៈ និងផ្តល់ឱកាសសមរម្យឱ្យម្ចាស់អចលនវត្ថុដែលអាចនឹងប៉ះពាល់ជាអវិជ្ជមានដោយសារវិធានដីដែលស្នើឡើងនោះ ធ្វើការតវ៉ាជំទាស់ ឬទទួលបានសេចក្តីពន្យល់អំពីគោលបំណងនៃនយោបាយសាធារណៈ តាមគោលការណ៍អភិបាលកិច្ចល្អ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

មាត្រា៧៥._

កម្មសិទ្ធិករត្រូវគោរពគោលការណ៍និងវិធាននៃការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលមានបញ្ញត្តក្នុងច្បាប់ដោយឡែក។

**យោបល់៖** សូមមើលយោបល់ក្នុងមាត្រា ៧៤។ បច្ចុប្បន្នយើងមានច្បាប់ស្តីពីសំណង់ ដែលធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់។ តើក្រសួងមានផែនការយ៉ាងណាអំពីច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម ដែលត្រូវបានកែប្រែស្ទើរអស់លើងដោយច្បាប់ និងបទដ្ឋានគតិយុត្តថ្មីៗ? ករណីមានច្បាប់ជាក់លាក់ជាធរមានរួចហើយ គួរតែចែងយោងទៅឈ្មោះច្បាប់នោះតែម្តង ដើម្បីសម្រួលដល់ការយល់ដឹងរបស់អ្នកអានច្បាប់ និងអ្នកសិក្សាច្បាប់។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា៧៦._ **សិទ្ធិបុព្វក្រៃលើអចលនវត្ថុ**

ក្នុងករណីមានតម្រូវការចាំបាច់នៃផលប្រយោជន៍សាធារណៈ រដ្ឋ នីតិបុគ្គលសាធារណៈដទៃទៀត និងបុគ្គលឯកជនអាចអនុវត្តសិទ្ធិបុព្វក្រៃលើអចលនវត្ថុជាកម្មសិទ្ធិរបស់បុគ្គលឯកជន។ សិទ្ធិបុព្វក្រៃរបស់រដ្ឋ របស់នីតិបុគ្គលសាធារណៈដទៃទៀត និងរបស់បុគ្គលឯកជនលើអចនវត្ថុជាកម្មសិទ្ធិរបស់បុគ្គលឯកជន ត្រូវកំណត់ដោយច្បាប់ដោយឡែក។

**យោបល់៖** សូមផ្តល់និយមន័យនៃសិទ្ធិបុព្វក្រៃលើអចលនវត្ថុនៅក្នុងច្បាប់នេះ (ក្នុងមាត្រា ៣)។ ម៉្យាងវិញទៀត គួរលុបមាត្រានេះចេញ ព្រោះវាគ្មានប្រយោជន៍អ្វីក្នុងការអនុវត្តច្បាប់នេះទេ មុនពេលមានច្បាប់ដោយឡែកកំណត់អំពីសិទ្ធិបុព្វក្រៃនោះ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា៧៦.១_ ការប៉ះពាល់ដល់កម្មសិទ្ធិឯកជនក្នុងស្ថានភាពប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

រដ្ឋមានសិទ្ធិដាក់ចេញវិធានការទាក់ទងនឹងកំណែន ការដកហូតជាបណ្ដោះអាសន្ន ការគ្រប់គ្រង និងការចាត់ចែង កម្មសិទ្ធិលើអចលនវត្ថុឬសិទ្ធិប្រត្យក្សលើអចលនវត្ថុជារបស់បុគ្គលឯកជនក្នុងករណីប្រទេសជាតិស្ថិតក្នុងភាពអាសន្ន មានជាអាទិ៍ គ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាមឬការឈ្លានពានពីកម្លាំងបរទេស គ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្ដាលមកពីការឆ្លងរាលដាលនៃជំងឺរាតត្បាតធ្ងន់ធ្ងរដល់សន្តិសុខជាតិនិងសណ្ដាប់ធ្នាប់សាធារណៈ គ្រោះមហន្តរាយធ្ងន់ធ្ងរ ដែលគម្រាមកំហែងឬបង្កគ្រោះថ្នាក់រីករាលដាលដល់កម្រិតទូទាំងប្រទេស។

**យោបល់៖** លក្ខខណ្ឌនៃការប្រើប្រាស់សិទ្ធិដាក់ចេញវិធានការក្នុងមាត្រានេះ គួរត្រូវបានកំណត់ក្នុងច្បាប់នេះ ឬច្បាប់ដោយឡែក ហើយគួរមានការពន្យល់ថាតើស្ថានភាព និងតម្រូវការដែលរៀបរាប់ក្នុងមាត្រានេះ ខុសគ្នាដូចម្ដេចខ្លះពីការដកហូតអចលនវត្ថុដើម្បីបម្រើប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ (ដែលត្រូវផ្ដល់សំណងសមរម្យ និងយុត្តិធម៌ ជាមុន) ក្នុងមាត្រា ៩ ការអនុវត្តសកម្មភាពការងាររបស់រដ្ឋដែលជាតម្រូវការនៃផលប្រយោជន៍សាធារណៈ ឬតម្រូវការជាបន្ទាន់របស់ជាតិ ក្នុងមាត្រា៣៩ ឬករណីបន្ទាន់ ឬតម្រូវការចាំបាច់នៃផលប្រយោជន៍សាធារណៈ ក្នុងមាត្រា៧៦-២ (ដែលមិនបាននិយាយអំពីការផ្ដល់សំណងចំពោះការខូចខាតអចលនវត្ថុ ឬនិងសិទ្ធិលើអចលនវត្ថុ)។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា៧៦.២_ ការអនុវត្តបន្ទាន់នៃវិធាននៃដី

ក្នុងករណីបន្ទាន់ឬតម្រូវការចាំបាច់នៃផលប្រយោជន៍សាធារណៈ ច្បាប់អាចបញ្ញត្តថែមទៀតនូវការអនុវត្តបន្ទាន់នៃវិធានដីដោយកម្រិតពីការប្រើប្រាស់កម្មសិទ្ធិ។

**យោបល់៖** សូមមើលយោបល់ក្នុងមាត្រា មាត្រា៧៦-១ ខាងលើ។

## ជំពូកទី២
## សេវភាពសាធារណៈ

### មាត្រា៧៧._ សញ្ញាណសេវភាពសាធារណៈ

អចលនវត្ថុជាទ្រព្យរបស់បុគ្គលឯកជន អាចទទួលរងបន្ទុកនៃសេវភាពរដ្ឋបាល។

រាល់សេវភាពរដ្ឋបាលត្រូវបានបង្កើតឡើងដោយច្បាប់ក្នុងគោលបំណងបម្រើប្រយោជន៍សាធារណៈ ហើយផលប្រយោជន៍សាធារណៈដែលកើតពីបន្ទុកនោះ ត្រូវមានតម្លៃខ្ពស់ជាងការខាតបង់របស់ម្ចាស់អចលនវត្ថុដែលទទួលរងបន្ទុកនៃសេវភាពនោះ។

សេវភាពរដ្ឋបាល ត្រូវអនុលោមតាមបញ្ញត្តិច្បាប់ដែលកម្រិតសិទ្ធិរបស់កម្មសិទ្ធិករឬម្ចាស់សិទ្ធិលើការកាន់កាប់ និងប្រើប្រាស់ដី។

រដ្ឋនិងនីតិបុគ្គលសាធារណៈដទៃទៀតដែលមានការពាក់ព័ន្ធ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវរាល់សេវភាពរដ្ឋបាលទាំងឡាយតាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

**យោបល់៖** គួរបញ្ជាក់ថាតើអចលនវត្ថុសម្ពហភាព និងអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ អាចទទួលរងបន្ទុកនៃសេវភាពសាធារណៈ ដែរឬទេ។ សូមពន្យល់តើសេវភាពសាធារណៈ ខុសពី ឬដូចគ្នានឹងសេវភាពរដ្ឋបាលឬទេ? តើមានច្បាប់ ឬបទដ្ឋានគតិយុត្តដែលកំណត់លក្ខខណ្ឌ និងនីតិវិធីជាធរមានស្តីពីការដាក់បន្ទុកសេវភាពសាធារណៈឬទេ? បើពុំទាន់មានទេ គួរចែងថា តាមលក្ខខណ្ឌ និងនីតិវិធីកំណត់ក្នុងច្បាប់ដោយឡែក។ ពាក្យថា **ច្បាប់** ដែលប្រើក្នុងច្បាប់នេះ ចាំបាច់ត្រូវពន្យល់ ឬផ្តល់និយមន័យក្នុងមាត្រា ៣។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា៧៨._ ការអនុវត្តតាមប្លង់តម្រង់ជួរ

មុននឹងធ្វើរបងឬកសាងអគារប្រភេទណាក៏ដោយដែលស្ថិតនៅជាប់នឹងផ្លូវសាធារណៈ ឆ្នេរសមុទ្រ ជ្រោះ ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក កម្មសិទ្ធិករចាំបាច់ត្រូវតែត្រួតពិនិត្យលើនូវភាពសមស្របនៃរបងឬអគារនោះជាមួយនឹងប្លង់តម្រង់ជួរឆ្នេរសមុទ្រ ជ្រោះ ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក ប្រសិនបើមាន។ រាល់លិខិតអនុញ្ញាតសាងសង់ត្រូវតែយកចិត្តទុកដាក់ដល់ខ្សែបន្ទាត់ជួរតម្រង់ផ្លូវសាធារណៈ ដែលមានរួចហើយ។

**យោបល់៖** តើប្លង់តម្រង់ជួរ និងខ្សែបន្ទាត់ជួរតម្រង់ផ្លូវសាធារណៈខុសគ្នាដូចម្តេច សូមផ្តល់និយមន័យក្នុងមាត្រា ៣។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាតិកាទី៤
## ការចុះបញ្ជីអចលនវត្ថុ

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ
## ផ្នែកទី១
## ឯកតាសុរិយោដី

### មាត្រា៧៩._ និយមន័យនៃឯកតាសុរិយោដី

ក្បាលដីឬឯកតាសុរិយោដី គ្របដណ្តប់លើផ្ទៃដីមួយជាក់លាក់ ស្ថិតនៅក្នុងភូមិតែមួយ មិនពុះបំបែកដោយព្រំដាប់មិនដាច់ ជារបស់បុគ្គលម្នាក់ឬច្រើននាក់ក្នុងករណីអវិភាគកម្ម ហើយស្ថិតក្នុងតំបន់ប្រើប្រាស់ដីតែមួយ។

ក្នុងករណីក្បាលដីមួយស្ថិតនៅក្នុងភូមិសាស្ត្រនៃភូមិលើសពីមួយ ដោយពុំមានការពុះបំបែកដោយ ព្រំដាប់មិនដាច់ ក្បាលដីនោះត្រូវចុះបញ្ជីឱ្យស្ថិតនៅក្នុងភូមិណាមួយដែលចំណែកភាគច្រើននៃក្បាលដីនោះតាំងនៅ។

ចាត់ទុកជាព្រំដាប់មិនដាច់ដែលនាំឱ្យបំបែកក្បាលដីជាច្រើនក្បាលដីនោះ គឺរបងផ្លូវសាធារណៈ ប្រឡាយសាធារណៈ និងផ្លូវទឹកធម្មជាតិដែលមានទទឹងយ៉ាងតិចពីរម៉ែត្រ។

គោលការណ៍ដែលមានចែងក្នុងមាត្រានេះ មិនអនុវត្តចំពោះដីសាធារណៈរបស់រដ្ឋ និងដីសាធារណៈរបស់នីតិបុគ្គលសាធារណៈដទៃឡើយ។

**យោបល់៖** សូមបញ្ជាក់ថាតើ នៅពេលដែលដីសាធារណៈរបស់រដ្ឋណាមួយ ឬមួយផ្នែក ត្រូវបានធ្វើអនុប្បយោគជាដីឯកជនរបស់រដ្ឋ តើគោលការណ៍ដែលចែងក្នុងមាត្រានេះ ត្រូវអនុវត្តចំពោះការចុះបញ្ជីក្បាលដីអនុប្បយោគ ឬក្បាលដីដែលត្រូវបានបំបែកចេញពីដីសាធារណៈរបស់រដ្ឋនោះដែរឬទេ?

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា៨០._ ករណីលើកលែងចំពោះដីរដ្ឋ

~~គោលការណ៍ដែលមានចែងក្នុងផ្នែកនេះ មិនអនុវត្តចំពោះដីសាធារណៈរបស់រដ្ឋនិងដីសាធារណៈរបស់នីតិបុគ្គលសាធារណៈដទៃទៀតឡើយ។~~

### មាត្រា៨១._ និយាមកានៃក្បាលដី

ប្រព័ន្ធនិយាមកានៃក្បាលដីសម្រាប់អនុវត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មន្ត្រីសុរិយោដីដែលទទួលបន្ទុកការងារវាស់វែង ត្រូវទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវជាមុនលើការងារវាស់វែងនិងការកំណត់និយាមកានៃក្បាលដីបាន។

អ្នកវិជ្ជាជីវៈវាស់វែងនិងក្រុមហ៊ុនវាស់វែងដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អាចត្រូវបានអនុញ្ញាតឱ្យអនុវត្តការងារវាស់វែងនិងកំណង់និយាមកានៃក្បាលដីបាន។ ការគ្រប់គ្រងអ្នកវិជ្ជាជីវៈវាស់វែងនិងក្រុមហ៊ុនវាស់វែង ត្រូវកំណត់ដោយច្បាប់ដោយឡែក។

**យោបល់៖** គួរបញ្ជាក់ថាតើនរណាជាអ្នកកំណត់ និងផ្តល់នូវការបណ្តុះបណ្តាលត្រឹមត្រូវលើការងារវាស់វែងដល់មន្ត្រីសុរិយោដី។ តើក្រសួងមានគម្រោងរៀបចំច្បាប់ស្តីពីការគ្រប់គ្រងអ្នកវិជ្ជាជីវៈវាស់វែង និងក្រុមហ៊ុនវាស់វែងក្នុងពេលឆាប់ៗនេះដែរឬទេ? ប្រសិនបើមិនទាន់មានគម្រោងទេជាការប្រសើរជាងដែលចែងក្នុងមាត្រានេះ ការគ្រប់គ្រងអ្នកវិជ្ជាជីវៈវាស់វែង និងក្រុមហ៊ុនវាស់វែងត្រូវអនុវត្តតាមលក្ខខណ្ឌ និងនីតិវិធីដែលមានកំណត់ក្នុងច្បាប់ ឬបទដ្ឋានគតិយុត្តជាធរមាន។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

ផ្នែកទី២

ឯកសារសុរិយោដី

### មាត្រា៨២._ **ប្លង់សុរិយោដី**

ប្លង់សុរិយោដីគ្របដណ្តប់តំបន់ដែលបានធ្វើការវិនិច្ឆ័យ ដោយមានកំណត់ព្រំប្រទល់ក្បាលដីកម្មសិទ្ធិសាធារណៈ ដីកម្មសិទ្ធិសមូហភាព និង/ឬក្បាលដីកម្មសិទ្ធិឯកជនទាំងអស់។

ក្បាលដីកម្មសិទ្ធិនីមួយៗត្រូវមានលេខក្បាលដី។

**យោបល់៖** តើនីតិវិធីចុះបញ្ជីដីរដ្ឋតម្រូវឱ្យមានប្លង់សុរិយោដីដែលកំណត់ព្រំប្រទល់ក្បាលដីកម្មសិទ្ធិសាធារណៈ ដីកម្មសិទ្ធិសមូហភាព និងឬក្បាលដីកម្មសិទ្ធិឯកជនទាំងអស់ដែរឬទេ? តើក្នុងនីតិវិធីចុះបញ្ជីដីរដ្ឋកំណត់តំបន់ធ្វើការវិនិច្ឆ័យយ៉ាងណាដែរ?

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា៨៣._ **សៀវភៅគោលបញ្ជីដីធ្លី**

សៀវភៅគោលបញ្ជីដីធ្លី មានតម្លៃពេញលេញតាមផ្លូវច្បាប់សម្រាប់កត់ត្រានូវកម្មសិទ្ធិ និងរាល់ព័ត៌មានទាក់ទងនឹងក្បាលដីនីមួយៗមានជាអាទិ៍ លេខក្បាលដី អត្តសញ្ញាណរបស់កម្មសិទ្ធិករ មធ្យោបាយនៃការធ្វើអត្ត

សញ្ញាណកម្មក្បាលដី និងការពិពណ៌នាអំពីកម្មសិទ្ធិ ទំហំក្បាលដី ប្រភេទដី ប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី ព្រមទាំងបន្ទុកលើក្បាលដី មានជាអាទិ៍ ហ៊ីប៉ូតែក ការបញ្ចាំ ផលុបភោគ សេវភាព សិទ្ធិជួលអចិន្ត្រៃយ៍។

សៀវភៅគោលបញ្ជីដីធ្លីត្រូវតម្កល់និងធ្វើបច្ចុប្បន្នកម្មនៅរដ្ឋបាលសុរិយោដីគ្រប់ថ្នាក់ដែលពាក់ព័ន្ធ។

**យោបល់៖** ក្នុងនីតិវិធីចុះបញ្ជីដីរដ្ឋ តើរាល់បន្ទុកជាសិទ្ធិប្រត្យក្សកើតឡើងតាមច្បាប់ដូចជា សិទ្ធិភោគៈ សិទ្ធិប្រើប្រាស់អាស្រ័យផល សិទ្ធិផលុបភោគ សិទ្ធិសេវភាព ឬតាមកិច្ចសន្យា (សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិសេវភាព សិទ្ធិដីសម្បទាន ព្រៃសហគមន៍) ត្រូវបានធ្វើការវិនិច្ឆ័យ និងចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី ឬនិងបញ្ជីដីរដ្ឋដែរឬទេ? ហេតុអ្វី?

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា៨៤._ សៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុ

សៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុ មានតម្លៃពេញលេញតាមផ្លូវច្បាប់សម្រាប់ចុះបញ្ជីអំពីសិទ្ធិប្រត្យក្ស ទាក់ទងនឹងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី មានជាអាទិ៍ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច សៀវភៅចុះបញ្ជីសិទ្ធិផលុបភោគ។

**យោបល់៖** គួរតែមានសៀវភៅចុះបញ្ជីសិទ្ធិសម្បទានដីសង្គមកិច្ច ដើម្បីផ្តល់នូវលក្ខខណ្ឌតតាំងចំពោះតតីយជន ដល់មុខសញ្ញាអ្នកទទួលដីសម្បទានផងដែរ។

**សំណើចែងបន្ថែម៖** សូមចែងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា៨៥._ ប្រព័ន្ធទិន្នន័យសុរិយោដីឌីជីថល

ប្រព័ន្ធទិន្នន័យសុរិយោដីឌីជីថលត្រូវកត់ត្រារាល់ព័ត៌មាននិងទិន្នន័យនៅក្នុងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លីនិងឯកសារសុរិយោដីចាំបាច់ផ្សេងទៀត។

ប្រព័ន្ធទិន្នន័យសុរិយោដីឌីជីថលត្រូវមាន៣(បី)កម្រិតអនុលោមតាមថ្នាក់នៃរដ្ឋបាលសុរិយោដី។

រដ្ឋបាលសុរិយោដីត្រូវធ្វើបច្ចុប្បន្នកម្មប្រព័ន្ធទិន្នន័យសុរិយោដីឌីជីថលជាប្រចាំតាមការវិវត្តនៃសិទ្ធិប្រត្យក្សពាក់ព័ន្ធនឹងក្បាលដីនីមួយៗ។

ការបង្កើត ការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធទិន្នន័យសុរិយោដីឌីជីថលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** គួររាប់បញ្ចូលទាំងព័ត៌មាននៅក្នុងសៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុដែលរៀបរាប់ក្នុងមាត្រា ៨៤ ផង។ ការបង្កើត ការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធទិន្នន័យសុរិយោដីឌីជីថល គួរត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយសារការផ្ទេរមុខងារពាក់ព័ន្ធមួយចំនួនជូនរដ្ឋបាលថ្នាក់ក្រោមជាតិ។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា៨៦._ អានុភាពនៃឯកសារសុរិយោដី

ឯកសារសុរិយោដី និងប្រព័ន្ធមូលដ្ឋានទិន្នន័យសុរិយោដីឌីជីថលមានតម្លៃពេញលេញតាមផ្លូវច្បាប់ និងមានអានុភាពច្បាស់លាស់។ ប្លង់សុរិយោដី សៀវភៅគោលបញ្ជីដី និងសៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុមិនត្រូវមានការឆូតលុប ការសរសេរត្រួត ការកែ លើកលែងតែមានការបញ្ជាក់ច្បាស់លាស់។

**យោបល់៖** តើប័ណ្ណសំគាល់សិទ្ធិ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិ ឬសម្គាល់ម្ចាស់ ជាផ្នែកមួយនៃឯកសារសុរិយោដីមែនទេ? បើដូច្នេះតើតម្លៃ និងអានុភាពរបស់ប័ណ្ណ ឬវិញ្ញាបនបត្រនេះ ធៀបនឹងប្លង់សុរិយោដី សៀវភៅគោលបញ្ជីដី និងសៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុយ៉ាងណាដែរ?

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា៨៧._ ការរក្សាទុកឯកសារសុរិយោដី

ប្លង់សុរិយោដី សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុ និងប្រព័ន្ធមូលដ្ឋានទិន្នន័យសុរិយោដី ត្រូវរក្សាទុកជាអចិន្ត្រៃយ៍។

បញ្ជីឈ្មោះកម្មសិទ្ធិករ ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី កំណត់ហេតុអង្កេតដី ត្រូវរក្សាទុករយៈពេល ១៥ (ដប់ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើឯកសារទាំងនេះ។

សាលកបត្របង្រួមក្បាលដី សាលកបត្របំបែកក្បាលដី លិខិតអំណោយ លិខិតលក់ផ្តាច់ និងលិខិតសន្តតិកម្មត្រូវរក្សាទុករយៈពេល១០(ដប់)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើឯកសារទាំងនេះ។

រាល់ឯកសារសុរិយោដីត្រូវរក្សាទុកក្នុងប្រព័ន្ធទិន្នន័យសុរិយោដីឌីជីថល។

រយៈពេលពេលសម្រាប់រក្សាទុកឯកសារសុរិយោដីផ្សេងទៀត ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** ដើម្បីកុំឱ្យមានមន្ទិលសង្ស័យ គួររាប់បញ្ចូលនូវប័ណ្ណសំគាល់សិទ្ធិ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិ ឬសម្គាល់ម្ចាស់ដី ឬអចលនវត្ថុ ទម្រង់ព័ត៌មានសុរិយោដីដែលបានចេញផង។ ហេតុអ្វីមិនអាចរក្សាទុក រាល់ឯកសារសុរិយោ

ដីក្នុងប្រព័ន្ធទិន្នន័យសុរិយោដីឌីជីថលជាអចិន្ត្រៃយ៍? សូមបញ្ជាក់ថាថ្ងៃចុះហត្ថលេខារបស់នរណា ព្រោះនៅលើឯកសារនីមួយៗ អាចមានហត្ថលេខាច្រើនគ្នាដែលចុះនៅថ្ងៃផ្សេងគ្នា។
**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា៨៨._ បណ្ណនិងព័ត៌មានសុរិយោដី

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ វិញ្ញាបនបត្រសម្គាល់សិទ្ធិផ្សេងទៀតពាក់ព័ន្ធនឹងអចលនវត្ថុ ត្រូវបង្ហាញព័ត៌មានទាំងឡាយមានជាអាទិ៍ លក្ខណៈរូប ប្រភេទដី ប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងបន្ទុកនៃក្បាលដី ដោយផ្អែកលើឯកសារនិងសៀវភៅគោលបញ្ជីដីធ្លី។

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ត្រូវចេញឱ្យតែកម្មសិទ្ធិករនៃអចលនវត្ថុនោះប៉ុណ្ណោះ។ វិញ្ញាបនបត្រសម្គាល់សិទ្ធិផ្សេងទៀតពាក់ព័ន្ធនឹងអចលនវត្ថុ ត្រូវចេញឱ្យអ្នកមានសិទ្ធិស្របច្បាប់លើអចលនវត្ថុនោះតែប៉ុណ្ណោះ។

ទម្រង់ដែលមានព័ត៌មានសុរិយោដីនិងចេញដោយរដ្ឋបាលសុរិយោដី គឺជាមូលដ្ឋាននៃការអះអាងជាផ្លូវការមួយនៃលិខិតគតិយុត្ត។

**យោបល់៖** បើសៀវភៅគោលបញ្ជីដីធ្លី ចុះ និងបង្ហាញរាល់ព័ត៌មានទាំងឡាយនៃក្បាលដី តើហេតុអ្វីចាំបាច់ត្រូវមានសៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុ បន្ថែមលើសៀវភៅគោលបញ្ជីដីធ្លី? តើចាំបាច់ទេ ជាពិសេសក្នុងបរិបទរៀបចំប្រព័ន្ធព័ត៌មានទិន្នន័យសុរិយោដីឌីជីថល? គួរមានការចែងពន្យល់បន្ថែមអំពីអត្ថន័យ ឬអានុភាពនៃទម្រង់ព័ត៌មានសុរិយោដីចេញដោយរដ្ឋបាលសុរិយោដីថាជាមូលដ្ឋាននៃការអះអាងជាផ្លូវការមួយនៃលិខិតគតិយុត្ត។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា៨៩._ ការហាមឃាត់ការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

ត្រូវហាមឃាត់ការចុះបញ្ជីអចលនវត្ថុដែលមិនអាចយកធ្វើជារបស់ឯកជនបាន ឬដែលមិនបានកាន់កាប់តាមលក្ខខណ្ឌនៃច្បាប់ និងការចុះបញ្ជីអចលនវត្ថុទៅឱ្យបុគ្គលដែលពុំបានទទួលសិទ្ធិនោះតាមលក្ខខណ្ឌនិងនីតិវិធីនៃច្បាប់។

**យោបល់៖** ការចែងបែបនេះជាឧបសគ្គក្នុងការចុះបញ្ជី ទោះជាបានអនុវត្តត្រឹមត្រូវតាមនីតិវិធីនៃការវិនិច្ឆ័យកំណត់ព្រំប្រទល់ វាស់វែង បិទផ្សាយជាសាធារណៈពេញលេញរួចហើយ តើរដ្ឋបាលសុរិយោដីត្រូវធ្វើយ៉ាងម៉េចទៀតដើម្បីគោរពតាមការហាមឃាត់នេះ? វាក៏អាចនាំឱ្យខ្វះភាពប្រាកដអាចទុកចិត្តលើតម្លៃនៃការចុះបញ្ជីសុរិយោដី ចំពោះតតិយជន ក៏ដូចជាអ្នកវិនិយោគលើអចលនទ្រព្យ។ គួរមានចែងបញ្ញត្តិលម្អិតគ្រប់គ្រាន់ដើម្បីការពារតតិយជន និងអ្នក

វិនិយោគិនសុចរិត និងឥតកំហុស។ ការធានារបស់រដ្ឋ និងកិច្ចគាំពារដោយច្បាប់ចំពោះកម្មសិទ្ធិ និងសិទ្ធិប្រត្យក្សដែលបានចុះបញ្ជី ទាមទារឱ្យមានការកំណត់ឱ្យបានច្បាស់អំពីអានុភាពនៃការចុះបញ្ជីចំពោះភាគី សុចរិតឥតកំហុស។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## ផ្នែកទី៣
## រដ្ឋបាលសុរិយោដី

### មាត្រា៩០._ រចនាសម្ព័ន្ធរបស់រដ្ឋបាលសុរិយោដី

ត្រូវបានបង្កើតរដ្ឋបាលសុរិយោដី ក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋបាលសុរិយោដី មានរចនាសម្ព័ន្ធដូចខាងក្រោម៖

1. រដ្ឋបាលសុរិយោដីថ្នាក់កណ្តាល។
2. រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត។
3. រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុរិយោដី ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** មិនមានយោបល់

### មាត្រា៩១._ លក្ខន្តិកៈគតិយុត្តរបស់មន្ត្រីសុរិយោដី

ការរៀបចំនិងការគ្រប់គ្រងមន្ត្រីសុរិយោដីដែលជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលសុរិយោដី ត្រូវអនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីសុរិយោដីនៃរដ្ឋបាលសុរិយោដី ត្រូវស្ថិតក្នុងអង្គ ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ដែលត្រូវអនុវត្តទាំងថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ។

លក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីសុរិយោដី ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**យោបល់៖** មិនមានយោបល់

### មាត្រា៩២._ ក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីសុរិយោដី

មន្ត្រីសុរិយោដីត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈ។

ក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីសុរិយោដី ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** មិនមានយោបល់

### មាត្រា៩៣._ ការគ្រប់គ្រងមុខជំនាញរបស់មន្ត្រីសុរិយោដី

មន្ត្រីសុរិយោដីត្រូវមានជំនាញផ្នែកសុរិយោដី ផ្នែកភូមិសាស្ត្រ ឬផ្នែកនីតិសាស្ត្រ។

មន្ត្រីសុរិយោដីត្រូវទទួលការបណ្តុះបណ្តាលសុក្រឹត្យការឬវិក្រឹត្យការលើមុខជំនាញវិជ្ជាជីវៈដើម្បីបំពេញមុខងាររបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។

**យោបល់៖** គួរចែងបញ្ជាក់ថានរណាជាអ្នកផ្តល់ការបណ្តុះបណ្តាលសុក្រឹត្យការ ឬវិក្រឹត្យការលើមុខជំនាញវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជំនាញអង្កេតវាស់វែងក្នុងមាត្រា ៨១ ដល់ មន្ត្រីសុរិយោដី។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា៩៤._ ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីសុរិយោដី

ក្នុងពេលប្រតិបត្តិការការងារ មន្ត្រីសុរិយោដីត្រូវស្លៀកពាក់ឯកសណ្ឋាន និងមានសញ្ញាសម្គាល់។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីសុរិយោដីត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** មិនមានយោបល់

### មាត្រា៩៥._ សមត្ថកិច្ចរបស់រដ្ឋបាលសុរិយោដី

រដ្ឋបាលសុរិយោដីមានសមត្ថកិច្ចដូចខាងក្រោម៖

- កសាង អភិរក្ស និងធ្វើបច្ចុប្បន្នកម្មប្លង់សុរិយោដី សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជី និងប្រព័ន្ធមូលដ្ឋានទិន្នន័យសុរិយោដី
- ចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុឬសិទ្ធិផ្សេងទៀតពាក់ព័ន្ធនឹងអចលនវត្ថុ
- ចេញសលាកបត្រក្បាលដី សម្រាប់ប្រើប្រាស់ក្នុងការងារសិក្សាគម្រោងប្លង់ និងការងារសាងសង់នៅលើក្បាលដី
- ចេញលិខិតបញ្ជាក់ព័ត៌មានសុរិយោដីអំពីស្ថានភាពអចលនវត្ថុឬសិទ្ធិដែលពាក់ព័ន្ធ មានជាអាទិ៍ លក្ខណៈរូបស្ថានភាពគតិយុត្ត បន្ទុកផ្សេងៗដែលអាចមានលើអចលនវត្ថុនោះ ដោយផ្អែកលើសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជី និងប្រព័ន្ធមូលដ្ឋានទិន្នន័យសុរិយោដី។

សមត្ថកិច្ចផ្សេងទៀតរបស់រដ្ឋបាលសុរិយោដី ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** មិនមានយោបល់

## មាត្រា៩៦._ ភារកិច្ចរបស់រដ្ឋបាលសុរិយោដី

រដ្ឋបាលសុរិយោដីមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ធ្វើសម្រង់សុរិយោដីដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែលពាក់ព័ន្ធ តាមរយៈការអង្កេតវាស់វែងសុរិយោដី និងធ្វើអត្តសញ្ញាណកម្មអចលនវត្ថុ
- ធ្វើលេខាចារិកឈ្មោះកម្មសិទ្ធិករនិងរាល់ទិន្នន័យដែលប្រមូលបានទាក់ទងទៅនឹងលក្ខណៈរូប ទំហំ និងអត្តសញ្ញាណនៃអចលនវត្ថុ និងរាល់បន្ទុក មានជាអាទិ៍ ហ៊ីប៉ូតែក ការបញ្ចាំ ផលុបភោគ សិទ្ធិជួលអចិន្ត្រៃយ៍ សេវភាព ដែលបានបង្កើតឡើងលើអចលនវត្ថុ
- ធ្វើចរន្តការនូវរាល់ការផ្លាស់ប្តូរប្រែប្រួលទាក់ទងទៅនឹងសិទ្ធិដែលកើតឡើងដោយកិច្ចសន្យាផ្ទេរ មានជាអាទិ៍ ការលក់ ការឱ្យ ការដូរ សន្តតិកម្ម ឬពាក់ព័ន្ធនឹងការដូរប្រភេទដី ប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី ឬស្ថានភាពនៃដី មានជាអាទិ៍ ការសាងសង់ ការចាក់បំពេញដី ការជីកកកាយយកដី
- អភិរក្សនូវរាល់ឯកសារសុរិយោដីដែលមានប្លង់សុរិយោដី បញ្ជីឈ្មោះកម្មសិទ្ធិករ សៀវភៅគោលបញ្ជីដី សៀវភៅចុះបញ្ជី និងរាល់ឯកសារគតិយុត្តទាក់ទងទៅនឹងក្បាលដីនីមួយៗ
- ផ្តល់សេវាព័ត៌មានសុរិយោដី មានជាអាទិ៍ ការចេញសលាកបត្រក្បាលដី លិខិតបញ្ជាក់ព័ត៌មានសុរិយោដី សេវាថតចម្លងឯកសារឬប្លង់សុរិយោដី
- ធ្វើច្បាប់ចម្លងនៃសម្រង់ឯកសារសុរិយោដីជូលរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលពាក់ព័ន្ធ
- កត់ត្រានូវរាល់ការផ្លាស់ប្តូរដែលទាក់ទងទៅនឹងស្ថានភាពនៃកម្មសិទ្ធិ កម្មសិទ្ធិករ សិទ្ធិ និងម្ចាស់សិទ្ធិពាក់ព័ន្ធនឹងអចលនវត្ថុក្នុងមូលដ្ឋានរបស់ខ្លួន។

តួនាទីនិងភារកិច្ចផ្សេងទៀតរបស់រដ្ឋបាលសុរិយោដី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** មិនមានយោបល់

## មាត្រា៩៧._ សិទ្ធិអំណាចរបស់រដ្ឋបាលសុរិយោដី

មានតែរដ្ឋបាលសុរិយោដីតែមួយគត់ដែលមានសមត្ថកិច្ចកំណត់និយាមកានៃក្បាលដីជាផ្លូវការ។

មន្ត្រីទទួលបន្ទុកកំណត់ព្រំដី អ្នកវាស់វែង និងមន្ត្រីវិនិច្ឆ័យ មានសិទ្ធិចូលក្នុងបរិវេណក្បាលដីដែលជាកម្មវត្ថុនៃការចុះបញ្ជីដាច់ដោយដុំនិងក្បាលដីនៅជាប់ព្រំនៅពេលធ្វើការអង្កេតវាស់វែង។

ក្នុងករណីចាំបាច់ រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬកងកម្លាំងប្រដាប់អាវុធឱ្យជួយជ្រោមជ្រែងក្នុងការអនុវត្តការងារវាស់វែង។

**យោបល់៖** មិនមានយោបល់

## មាត្រា៩៨._ ការទទួលខុសត្រូវរបស់រដ្ឋបាលសុរិយោដី

រដ្ឋបាលសុរិយោដីគ្រប់លំដាប់ថ្នាក់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការកាន់កាប់ប្លង់សុរិយោដី សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជី ប្រព័ន្ធមូលដ្ឋានទិន្នន័យសុរិយោដី និងកិច្ចការអភិរក្សឯកសារ។

រដ្ឋបាលសុរិយោដីត្រូវទទួលខុសត្រូវលើភាពជាក់លាក់នៃព័ត៌មាននិងទិន្នន័យដែលទទួលបានពីក្នុងដំណើរការនៃការធ្វើសម្រង់សុរិយោដី។

រដ្ឋបាលសុរិយោដីត្រូវធានាថា ប្លង់សុរិយោដី សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជី និងប្រព័ន្ធមូលដ្ឋានទិន្នន័យសុរិយោដីនៅគ្រប់ថ្នាក់ដែលពាក់ព័ន្ធ មានទិន្នន័យដូចគ្នានិងធ្វើបច្ចុប្បន្នកម្មដំណាលគ្នា។

**យោបល់៖** គួរមានការចែងជាអន្តរកាលអំពីការកំណត់ឱ្យធ្វើបច្ចុប្បន្នកម្មដំណាលគ្នា ក្នុងពេលមិនទាន់ប្រព័ន្ធទិន្នន័យសុរិយោដីឌីជីថល។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា៩៩._ លក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់សេវាសាធារណៈដោយរដ្ឋបាលសុរិយោដី

បុគ្គលដែលមានផលប្រយោជន៍អាចស្នើសុំព័ត៌មានសុរិយោដីពីរដ្ឋបាលសុរិយោដី។

មន្ត្រីសុរិយោដីត្រូវផ្ដល់ព័ត៌មាននិងទិន្នន័យសុរិយោដីឱ្យបានត្រឹមត្រូវដល់អ្នកស្នើសុំ។

ការប្រើប្រាស់ព័ត៌មាននិងទិន្នន័យសុរិយោដីដែលផ្ដល់ដោយរដ្ឋបាលសុរិយោដី មិននាំឱ្យជាប់ការទទួលខុសត្រូវរបស់រដ្ឋបាលសុរិយោដីឡើយ។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់សេវាសាធារណៈដោយរដ្ឋបាលសុរិយោដី ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** អនុក្រឹត្យគួរកំណត់អំពីមូលដ្ឋាននៃការកំណត់ថាបុគ្គលមួយមានផលប្រយោជន៍ ឬមិនមានប្រយោជន៍ក្នុងការសុំព័ត៌មានសុរិយោដី និងទម្រង់នៃការផ្តល់ព័ត៌មានសុរិយោដី។ តាមការចែងក្នុងកថាខណ្ឌចុងក្រោយនៃមាត្រា ៨៨ ព័ត៌មានសុរិយោដីដែលផ្តល់ដោយរដ្ឋបាលសុរិយោដីចំពោះក្បាលដីណាមួយ ដល់បុគ្គលមានផលប្រយោជន៍ពាក់ព័ន្ធនឹងក្បាលដី ច្បាប់គួរតែចែងតម្រូវឱ្យរដ្ឋបាលសុរិយោដីទទួលខុសត្រូវចំពោះការខូចខាតជាក់ស្តែងណាមួយដែលបណ្តាលមកពីការសម្អាងលើព័ត៌មានដែលមានក្នុងឯកសារសុរិយោដី។ ដើម្បីសម្រេចបាននូវការធានារបស់រដ្ឋចំពោះកម្មសិទ្ធិ និងសិទ្ធិប្រត្យក្សដែលបានចុះបញ្ជីសុរិយោដី និងពង្រឹង គណនេយ្យភាពសាធារណៈរបស់រដ្ឋបាលសុរិយោដី ច្បាប់នេះគួរចែងកំណត់ឱ្យរដ្ឋបាលសុរិយោដីទទួលខុសត្រូវ ចំពោះព្យុះសនកម្ម ដែលបង្កឡើងដោយការសម្អាងដោយសុចរិតលើព័ត៌មានសុរិយោដីអំពីក្បាលដីជាក់លាក់ណាមួយ ដែលផ្តល់ឱ្យជាផ្លូវការដោយរដ្ឋបាលសុរិយោដី។ ដូច្នេះ កថាខណ្ឌទី៣ នៃមាត្រានេះ គួរមានការកែសម្រួល ស្របតាមយោបល់នេះ។
**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១០០._ កម្រៃសេវាសាធារណៈផ្តល់ដោយរដ្ឋបាលសុរិយោដី

ការស្នើសុំសេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលសុរិយោដី ត្រូវបង់កម្រៃសេវា។

កម្រៃសេវាសាធារណៈផ្តល់ដោយរដ្ឋបាលសុរិយោដី ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កម្រៃសេវាសាធារណៈផ្តល់ដោយរដ្ឋបាលសុរិយោដី ត្រូវបានជាប្រយោជន៍ដល់ថវិកាជាតិនិងថវិកាថ្នាក់ក្រោមជាតិ។

**យោបល់៖** មិនមានយោបល់

### មាត្រា១០១._ ឌីជីថលភាវូបនីយកម្មនៃការផ្តល់សេវាសាធារណៈ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវជំរុញកសាងប្រព័ន្ធទិន្នន័យសុរិយោដីជាឌីជីថល និងធ្វើបរិវត្តកម្មឌីជីថលកក្នុងវិស័យសុរិយោដីដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព និងជំរុញការផ្តល់សេវាសាធារណៈក្នុងវិស័យដីធ្លីកាន់តែប្រសើរឡើង។

បែបបទនិងនីតិវិធីនៃការផ្តល់សេវាសាធារណៈតាមប្រព័ន្ធឌីជីថលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** មិនមានយោបល់

## ផ្នែកទី៤

សិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលដែលពាក់ព័ន្ធក្នុងដំណើរការចុះបញ្ជីអចលនវត្ថុ

**មាត្រា១០២._ ការចូលរួមក្នុងដំណើរការនៃការធ្វើសម្រង់សុរិយោដី**

បុគ្គលទាំងឡាយ ជាពិសេសម្ចាស់អចលនវត្ថុ អ្នកកាន់កាប់អចលនវត្ថុ និងបុគ្គលដែលមានការពាក់ព័ន្ធ មានកាតព្វកិច្ចចូលរួមនិងសហការក្នុងដំណើរការនៃការធ្វើសម្រង់សុរិយោដី។
បុគ្គលទាំងនោះត្រូវជួយសម្រួលដល់កិច្ចប្រតិបត្តិការវាស់វែងសុរិយោដី និងការធ្វើអត្តសញ្ញាណកម្មអ្នកកាន់កាប់ ឬកម្មសិទ្ធិករ ហើយត្រូវរាយការណ៍អំពីការផ្លាស់ប្តូរទាំងអស់ដែលកើតមានទាក់ទងនឹងក្បាលដីរបស់ខ្លួន និងស្ថានភាពនៃដី។

**យោបល់៖** គួរថែងបញ្ចូលផងនូវការតម្រូវឱ្យតំណាងរបស់អាជ្ញាធរកាន់កាប់ដីរដ្ឋពាក់ព័ន្ធ ចូលរួមក្នុងដំណើរការធ្វើសម្រង់សុរិយោដី។
**សំណើថែងបញ្ជាក់៖** សូមថែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១០៣._ កាតព្វកិច្ចរបស់អ្នកកាន់កាប់ដីឬអ្នកតំណាងស្របច្បាប់របស់ខ្លួន**

អ្នកកាន់កាប់ដីឬអ្នកតំណាងស្របច្បាប់របស់ខ្លួន មានកាតព្វកិច្ចចូលរួមនិងសហការក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ តាមរយៈការផ្តល់នូវព័ត៌មានពិត ដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬភស្តុតាងផ្សេងៗទាក់ទងនឹងក្បាលដីរបស់ខ្លួន ឬក្បាលដីដែលខ្លួនឈរឈ្មោះជាតំណាង ឬក្បាលដីអ្នកជាប់ព្រំដល់មន្ត្រីជំនាញដែលមានសមត្ថកិច្ច។

បុគ្គលដែលបង្ហាញឬប្រគល់ភស្តុតាងឬឯកសារណាមួយដល់មន្ត្រីជំនាញដែលមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីភស្តុតាងឬឯកសារនោះ។

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីអចលនវត្ថុ មានកាតព្វកិច្ចចូលរួមនិងសហការក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យតាមសេចក្តីជូនដំណឹងរបស់មន្ត្រីទទួលបន្ទុក។

បុគ្គលដែលមានការពាក់ព័ន្ធមានកាតព្វកិច្ចចូលរួមនិងសហការក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យដោយផ្តល់ព័ត៌មានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាងផ្សេងៗតាមសំណូមពររបស់មន្ត្រីទទួលបន្ទុក។

**យោបល់៖** ដូចយោបល់សម្រាប់ មាត្រា ១០២។

## មាត្រា១០៤._ សិទ្ធិរបស់បុគ្គលដែលពាក់ព័ន្ធ

បុគ្គលគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យនិងផ្តល់យោបល់ក្នុងរយៈពេលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងមានសិទ្ធិស្នើសុំឱ្យមន្រ្តីជំនាញពន្យល់បំភ្លឺអំពីខ្លឹមសារនៃទិន្នន័យដែលពាក់ព័ន្ធនឹងតំបន់ធ្វើការវិនិច្ឆ័យ។

ក្នុងកំលុងពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ បុគ្គលដែលមានឈ្មោះក្នុងបញ្ជី ឬអ្នកដែលមានផលប្រយោជន៍លើក្បាលដីណាមួយដែលបានចាត់ទុកថាឯកសារនៃការវិនិច្ឆ័យមិនជាក់លាក់ឬមិនពេញលេញ អាចផ្តល់ដំណឹងដល់មន្រ្តីគ្រប់គ្រងតំបន់វិនិច្ឆ័យនូវការជំទាស់របស់ខ្លួន។

ក្នុងរយៈពេលប្រតិបត្តិការរបស់មន្រ្តីជំនាញ អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ខ្លួន ឬបុគ្គលដែលពាក់ព័ន្ធ មានសិទ្ធិជំទាស់ឬតវ៉ា ប្រសិនបើខ្លួនយល់ថា ទិន្នន័យដែលមន្រ្តីជំនាញបានកត់ត្រាចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យនោះ មិនត្រឹមត្រូវឬខុសពីចម្លើយរបស់ខ្លួន។

**យោបល់៖** បន្ថែមពីលើការមានសិទ្ធិចូលរួម ច្បាប់នេះគួរចែងអំពីកាតព្វកិច្ចរបស់ម្ចាស់សិទ្ធិ រួមទាំងតំណាងរបស់អាជ្ញាធរកាន់កាប់ដីរដ្ឋ ថាចាំបាច់ត្រូវចូលរួមពិនិត្យ ផ្តល់យោបល់ និងដាក់ពាក្យជំទាស់ ឬតវ៉ា អំពីភាពមិនជាក់លាក់ ឬមិនពេញលេញនៃឯកសារវិនិច្ឆ័យ ឬភាពមិនត្រឹមត្រូវនៃព័ត៌មានណាមួយ ឬនៃការវិនិច្ឆ័យលើផ្នែកណាមួយនៃដីក្នុងប្លង់បង្ហាញក្បាលដី ឬនិងក្នុងបញ្ជីឈ្មោះម្ចាស់ដី និងម្ចាស់សិទ្ធិ ក្នុងអំឡុងពេលប្រតិបត្តិការរបស់មន្ត្រីជំនាញសុរិយោដី រួមទាំងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈ។ គួរតម្រូវឱ្យរដ្ឋបាលសុរិយោដីជូនដំណឹងដល់ភ្នាក់ងារ ឬតំណាងរបស់អាជ្ញាធរកាន់កាប់ដីរដ្ឋ ករណីមានព័ត៌មានបង្ហាញថាប្រហែលជាអាជ្ញាធរកាន់កាប់ដីរដ្ឋនោះ មានការពាក់ព័ន្ធនឹងក្បាលដីណាមួយនៅក្នុងតំបន់ដែលធ្វើការវិនិច្ឆ័យ មុននឹងធ្វើការបិទផ្សាយជាសាធារណៈនូវឯកសារវិនិច្ឆ័យ។

**សំណើកែសម្រួល និងចែងបន្ថែម៖** សូមកែសម្រួល និងចែងក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១០៥._ ការចូលរួមរបស់អាជ្ញាធរដែនដី និងកងកម្លាំងប្រដាប់អាវុធ

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កលក្ខណៈសម្បត្តិងាយស្រួល សហការឱ្យបានល្អ និងផ្តល់សុវត្ថិភាពដល់កិច្ចប្រតិបត្តិការទាំងឡាយ មានប្រតិបត្តិការបច្ចេកទេស រដ្ឋបាល គតិយុត្ត ដើម្បីធ្វើឱ្យសម្រេចនូវការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យដែលប្រព្រឹត្តទៅនៅក្នុងដែនដីដែលខ្លួនទទួលខុសត្រូវ។

ក្នុងករណីចាំបាច់ រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬកងកម្លាំងប្រដាប់អាវុធ ឱ្យជួយជ្រោមជ្រែងដល់កិច្ចប្រតិបត្តិការនៃការធ្វើសម្រង់សុរិយោដីនៅនឹងកន្លែង។

ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យក្នុងឃុំ សង្កាត់ណាមួយ មេឃុំ ចៅសង្កាត់ ឬតំណាងស្របច្បាប់របស់ខ្លួន ត្រូវមានវត្តមានតាមកាលកំណត់ និងតាមតម្រូវការជាក់ស្តែងនៃការងារ។

តួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ក្នុងការចុះបញ្ជីដីធ្លី ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ។

**យោបល់៖** មិនមានយោបល់លើមាត្រានេះទេ។

**យោបល់សម្រាប់សំណើបន្ថែមមាត្រា ៖** គួរបញ្ចូលបញ្ញត្តិពិសេសដើម្បីលើកកម្ពស់សមភាពយេនឌ័រ សិទ្ធិសេរីភាពបុគ្គលក្នុងជីវិតឯកជន សម្រួល និងលើកទឹកចិត្តដល់ការចុះបញ្ជីជាទ្រព្យរួមប្តីប្រពន្ធ ឬទ្រព្យអវិភាគរបស់គ្រួសារដែលរួមរស់ជាមួយគ្នាដោយមានអាពាហ៍ពិពាហ៍តាមបែបប្រពៃណី ឬរស់នៅជាមួយគ្នាដោយគ្មានអាពាហ៍ពិពាហ៍អ្វីទាំងអស់ ឬរស់នៅជាមួយគ្នាតាមបែបមនុស្សស្រលាញ់ភេទដូចគ្នា ក្នុងនីតិវិធីចុះបញ្ជីដីធ្លីលើកដំបូង ព្រមទាំងបញ្ញត្តិពិសេសសម្រាប់ការប្រើប្រាស់សិទ្ធិចាត់ចែងទ្រព្យរួម ឬទ្រព្យអវិភាគប្រកបដោយភាពវិជ្ជមាន ដោយភាគីដែលនៅកាន់កាប់ប្រើប្រាស់ ឬគ្រប់គ្រងជាក់ស្តែងលើអចលនវត្ថុ ក្នុងករណីចាំបាច់ ឬនិងករណីចុះចោលគ្នា បែកបាក់បោះបង់គ្រួសារបាត់ខ្លួន ឬលែងលះតាមបែបប្រពៃណី ឬដោយគ្មានអាពាហ៍ពិពាហ៍ស្របច្បាប់ ដោយមិនចាំបាច់តម្រូវមានសាលក្រមឬដីកាសម្រេចរបស់តុលាការឡើយ។ ច្បាប់នេះគួរមានចែងអនុគ្រោះពន្ធប្រថាប់ត្រាក្នុងករណីមានការយល់ព្រមយកទ្រព្យដែលបានចូលកាន់កាប់ជាភោគៈ ទិញ ទទួលមរតក ឬបានធ្វើលទ្ធកម្មតាមមធ្យោបាយផ្សេងទៀតក្នុងជាលក្ខណៈបុគ្គល ទោះក្នុងពេលនៅលីវ ពេលរស់នៅម្នាក់ឯង ឬពេលរស់នៅជាគ្រួសារ មកចុះបញ្ជីលើកដំបូងជាទ្រព្យរួមប្តីប្រពន្ធ ឬទ្រព្យអវិភាគរបស់គ្រួសារដែលរួមរស់ជាមួយគ្នា។

**សំណើបន្ថែមមាត្រាថ្មី ៖** ការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិសេរីភាពបុគ្គលក្នុងជីវិតឯកជននៃគ្រួសារ

ត្រូវបានអនុគ្រោះពន្ធប្រថាប់ត្រាក្នុងករណីមានការយល់ព្រម ឬសុខចិត្តយកទ្រព្យដែលបានចូលកាន់កាប់ជាភោគៈ ទិញ ទទួលមរតក ឬបានធ្វើលទ្ធកម្មតាមមធ្យោបាយផ្សេងទៀតក្នុងជាលក្ខណៈបុគ្គល ទោះក្នុងពេលនៅលីវ ពេលរស់នៅម្នាក់ឯង ឬពេលរស់នៅជាគ្រួសារ មកចុះបញ្ជីលើកដំបូងជា ទ្រព្យរួមប្តីប្រពន្ធ ឬទ្រព្យអវិភាគរបស់គ្រួសារដែលរួមរស់ជាមួយគ្នា។

ក្នុងករណីដូចចែងក្នុងកថាខណ្ឌទី១ មិនតម្រូវឱ្យធ្វើលិខិតផ្ទេរសិទ្ធិ ឬលិខិតធ្វើអំណោយលើចំណែកដីដែលបុគ្គលនោះយល់ព្រមជាលាយល័ក្ខណ៍អក្សរចំពោះមុខសាការី ឬចំពោះមុខមេឃុំ ចៅសង្កាត់នៃទីតាំងដី ប្រគល់ឱ្យសហព័ទ្ធ ឬសមាជិកនៃគ្រួសារដែលរួមរស់ជាមួយគ្នាឡើយ។

បទប្បញ្ញត្តិក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រានេះ ត្រូវអនុវត្តផងដែរចំពោះក្បាលដីដែលបានវាស់វែងរួចមុនពេលចាប់ផ្តើមអនុវត្តច្បាប់នេះ ហើយម្ចាស់ដីបានសុខចិត្តដាក់អចលនវត្ថុរបស់ខ្លួនចុះបញ្ជីជាទ្រព្យរួម ឬទ្រព្យអវិភាគ ប៉ុន្តែមិនទាន់បានបង់ពន្ធប្រថាប់ត្រាសម្រាប់ការផ្ទេរភាគចំណែកនៃទ្រព្យជូនសហព័ទ្ធ ឬសមាជិកនៃគ្រួសារដែលរួមរស់ជាមួយគ្នានៅឡើយ ទោះជាបាន ឬមិនបានធ្វើលិខិតផ្ទេរសិទ្ធិ ឬលិខិតធ្វើអំណោយក៏ដោយ។

ដើម្បីសម្រួលដល់ការប្រើប្រាស់សិទ្ធិចាត់ចែងទ្រព្យរួម ឬទ្រព្យអវិភាគប្រកបដោយភាពវិជ្ជមាន ក្នុងករណីចាំបាច់ ឬនិង ករណីចុះចោលគ្នា បែកបាក់បោះបង់គ្រួសារ បាត់ខ្លួនរបស់ភាគីណាមួយនៃម្ចាស់សិទ្ធិលើទ្រព្យរួម ឬទ្រព្យអវិភាគ ឬ លែងលះគ្នាតាមបែបប្រពៃណី ឬ ដោយគ្មានអាពាហ៍ពិពាហ៍ស្របច្បាប់ ភាគីដែលនៅកាន់កាប់ប្រើប្រាស់ ឬ គ្រប់គ្រងជាក់ស្តែងលើអចលនវត្ថុ អាចសម្រេចចាត់ចែងលក់ ឬបង្កើតសិទ្ធិប្រត្យក្សលើអចលនវត្ថុនោះ ដោយមិនចាំបាច់មានការយល់ព្រមពីភាគីដែលបានចុះចោល បែកបាក់បោះបង់គ្រួសារ បាត់ខ្លួន ឬលែងលះគ្នា តាមបែបប្រពៃណី ឬ ដោយគ្មានអាពាហ៍ពិពាហ៍ស្របច្បាប់ រួចមិនអើពើចំពោះការថែទាំគ្រប់គ្រងអចលនវត្ថុនោះ ឬដោយមិនតម្រូវមានសាលក្រម ឬដីកាសម្រេចរបស់តុលាការឡើយ ក្នុងករណីបំពេញលក្ខខណ្ឌទាំងអស់ ដូចខាងក្រោម ៖

១- បានដាក់ជូនរដ្ឋបាលសុរិយោដីនៃទីតាំងដី នូវលិខិតសម្រេចចាត់ចែងលក់ ឬបង្កើតសិទ្ធិប្រត្យក្សលើអចលនវត្ថុនោះ

២- រដ្ឋបាលសុរិយោដីបានចាត់ចែងឱ្យមានការបិទផ្សាយជាសាធារណៈ រយៈពេល ៩០ ថ្ងៃប្រតិទិន នូវលិខិតជូនដំណឹងអំពីការសម្រេចរបស់ភាគីស្នើសុំចាត់ចែងលក់ ឬបង្កើតសិទ្ធិប្រត្យក្សលើអចលនវត្ថុនោះ នៅសាលាឃុំ សង្កាត់នៃទីតាំងដី និងនៃទីលំនៅរបស់គ្រួសារនោះ

៣- (ក) មេឃុំ ចៅសង្កាត់នៃទីលំនៅរបស់គ្រួសារនោះ បានចេញលិខិតបញ្ជាក់ ក្រោយពីមានការសាកសួរអ្នកជិតខាង អំពីហេតុនៃការចុះចោល បែកបាក់បោះបង់គ្រួសារ បាត់ខ្លួន ឬលែងលះគ្នាតាមបែបប្រពៃណី ឬដោយគ្មានអាពាហ៍ពិពាហ៍ស្របច្បាប់ នោះ ថាបានកើតឡើងយ៉ាងតិច ៣(បី) ឆ្នាំប្រតិទិនមកហើយ ឬ (ខ) ភាគីស្នើសុំនោះបង្ហាញហេតុយ៉ាងច្បាស់គួរឱ្យទុកចិត្តបានអំពីតម្រូវការចាំបាច់ក្នុងលក់ ឬបង្កើតសិទ្ធិប្រត្យក្ស ដើម្បីបានថវិកាមកបង់ថ្លៃព្យាបាលសុខភាពផ្ទាល់ខ្លួន ឬ របស់សមាជិកគ្រួសារដែលរួមរស់ជាមួយគ្នា ឬ សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅចាំបាច់ដល់សមាជិកក្នុងបន្ទុកដែលពុំមានលទ្ធភាពរកប្រាក់ចំណូលបាន

៤-

ម្ចាស់ភាគចំណែកអវិភាគផ្សេងទៀតទាំងអស់នៃទ្រព្យអវិភាគដែលនៅរួមរស់ជាមួយគ្នាបានបង្ហាញការយល់ព្រម ចំពោះការសម្រេចចាត់ចែងលក់ ឬបង្កើតសិទ្ធិប្រត្យក្សលើអចលនវត្ថុនោះ

៥- ភាគីដែលបានចុះចោល បែកបាក់បោះបង់គ្រួសារ បាត់ខ្លួន ឬ លែងលះគ្នាតាមបែបប្រពៃណី ឬដោយគ្មានអាពាហ៍ពិពាហ៍ស្របច្បាប់ មិនបានចេញមុខតវ៉ា ឬជំទាស់ជាលាយល័ក្ខណ៍អក្សរចំពោះសេចក្តីសម្រេចចាត់ចែងមុនពេលដែលការលក់ ឬការបង្កើតសិទ្ធិប្រត្យក្សលើអចលនវត្ថុនោះ ត្រូវបានចុះបញ្ជីរួចរាល់ក្រោយពីផុតអំឡុងពេលដែលចែងក្នុងចំនុចលេខ ១ នៃកថាខណ្ឌនេះ និង

៦- ភាគីដែលធ្វើសេចក្តីសម្រេចចាត់ចែងអចលនវត្ថុនោះសន្យាសងជាប្រាក់តាមសមាមាត្រនៃភាគចំណែកសិទ្ធិ និងផលទុនសុទ្ធដែលបានមកពីការលក់អចលនវត្ថុនោះ ដោយពុំមានជាប់ការប្រាក់ ប្រសិនបើភាគីដែលបានចុះចោល បែកបាក់បោះបង់គ្រួសារ បាត់ខ្លួន ឬលែងលះគ្នាតាមបែបប្រពៃណី ឬ ដោយគ្មានអាពាហ៍ពិពាហ៍ស្របច្បាប់ នោះបែរជាក្រោយមកបង្ហាញខ្លួន និងបង្ហាញឆន្ទៈទាមទារចំណែកប្រាក់ផលទុនសុទ្ធដែលបានមកពីការលក់អចលនវត្ថុនោះតាមសមាមាត្រនៃចំណែកសិទ្ធិរបស់ខ្លួន ដោយប្តឹងទៅតុលាការមាន

សមត្ថកិច្ចក្នុងអំឡុងអាជ្ញាយុកាលនៃសិទ្ធិទាមទារ ហើយមានសេចក្តីសម្រេចស្ថាពររបស់តុលាការទទួលស្គាល់ការទាមទារនោះ។

ផ្នែកទី៥
គណៈកម្មការសុរិយោដី

## មាត្រា១០៦._ ការបង្កើតគណៈកម្មការសុរិយោដី

ត្រូវបានបង្កើតគណៈកម្មការសុរិយោដីដើម្បីដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ទាំងវិវាទដែលកើតនៅក្រៅតំបន់វិនិច្ឆ័យ
ទាំងវិវាទដែលកើតនៅក្នុងតំបន់វិនិច្ឆ័យនិងដែលមិនអាចសម្រុះសម្រួលបានដោយមន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យ។

## មាត្រា១០៧._ រចនាសម្ព័ន្ធនៃគណៈកម្មការសុរិយោដី

គណៈកម្មការសុរិយោដីមានរចនាសម្ព័ន្ធដូចខាងក្រោម៖

1. គណៈកម្មការសុរិយោដីថ្នាក់ជាតិ
2. គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត
3. គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា១០៨._ សមត្ថកិច្ចដោះស្រាយបណ្តឹង

ក្នុងករណីដែលរដ្ឋបាលសុរិយោដីមិនព្រមចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ អ្នកកាន់កាប់អចលនវត្ថុនោះមានសិទ្ធិប្តឹងតវ៉ាទៅស្ថាប័នដូចខាងក្រោម៖

1. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះបណ្តឹងពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីចុះបញ្ជីរបស់មន្ត្រីសុរិយោដី។
2. គណៈកម្មការសុរិយោដី ចំពោះបណ្តឹងទាមទារសិទ្ធិលើដី។

មាត្រា១០៩._

~~ក្នុងករណីមានបណ្ដឹងទាមទារសិទ្ធិលើដីសាធារណៈរបស់រដ្ឋឬនីតិបុគ្គលសាធារណៈដទៃទៀត គណៈកម្មការសុរិយោដីត្រូវបដិសេធសិទ្ធិកាន់កាប់ដីនោះ។~~

~~ក្នុងករណីភាគីម្ខាងជារដ្ឋឬនីតិបុគ្គលសាធារណៈដទៃទៀត គណៈកម្មការសុរិយោដីត្រូវសម្រេចទទួលស្គាល់ជាកម្មសិទ្ធិរបស់រដ្ឋឬនីតិបុគ្គលសាធារណៈដទៃទៀត ហើយអាជ្ញាធរសាធារណៈត្រូវគ្រប់គ្រងថែរក្សាដីនោះ។~~

មាត្រា១១០._

~~វិវាទរវាងភាគីចំពោះអចលនវត្ថុមួយដែលត្រូវបានចុះបញ្ជីនិងមិនទាន់ត្រូវបានចុះបញ្ជី ត្រូវដាក់ឱ្យធ្វើការស៊ើបអង្កេតនិងដោះស្រាយដោយគណៈកម្មការសុរិយោដី។~~

## ផ្នែកទី៦
## អធិការកិច្ចភូមិបាល

**មាត្រា១១១._**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តែងតាំងមន្ត្រីអធិការកិច្ចភូមិបាល ដើម្បីចុះតាមដាន អង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ចភូមិបាលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដូចមានចែងក្នុង ច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្ដល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចភូមិបាលត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** មិនមានយោបល់

មាត្រា១១២._

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចភូមិបាលត្រូវស្លៀកពាក់ឯកសណ្ឋាន មានសញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចភូមិបាលត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** មិនមានយោបល់

### មាត្រា១១៣._ ភារកិច្ចនិងសិទ្ធិរបស់មន្ត្រីអធិការកិច្ចសុរិយោដី

មន្ត្រីអធិការកិច្ចភូមិបាលមានភារកិច្ចនិងសិទ្ធិដូចខាងក្រោម៖

- ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្តោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះ
- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតឬអាជ្ញាបណ្ណពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ
- ចាប់យកវត្ថុតាងនិងកសាងសំណុំរឿងនៃបទល្មើសនឹងច្បាប់នេះ
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់នេះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចភូមិបាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** មិនមានយោបល់

### មាត្រា១១៤._ សិទ្ធិរបស់មន្ត្រីអធិការកិច្ចសុរិយោដីចូលទៅក្នុងបរិវេណក្បាលដីនិងអចលនវត្ថុដទៃទៀត

មន្ត្រីអធិការកិច្ចភូមិបាលអាចចូលទៅក្នុងបរិវេណក្បាលដី និងអចលនវត្ថុដទៃទៀតគ្រប់ពេលវេលានៅក្នុងម៉ោងធ្វើការដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

**យោបល់៖** ការចូលទៅក្នុងអចលនវត្ថុជាលំនៅដ្ឋាន ចាំបាច់ត្រូវគោរពវិធានពិសេសដែលការពារចំពោះការបំពានភាពឯកជននៃលំនៅដ្ឋាន។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១១៥._ ការអនុវត្តនីតិវិធីព្រហ្មទណ្ឌដោយមន្ត្រីអធិការកិច្ចសុរិយោដី

រាល់ប្រតិបត្តិការអធិការកិច្ចភូមិបាលក្នុងការពិនិត្យបទល្មើសត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចភូមិបាលអាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

ក្នុងករណីបទល្មើសជាក់ស្តែង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចភូមិបាលមានសមត្ថកិច្ចដែលនៅជិតបំផុតដើម្បីចាត់ការតាមនីតិវិធី។

**យោបល់៖** មិនមានយោបល់

## ជំពូកទី២
## ការចុះបញ្ជីដីធ្លីលើកដំបូង
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១១៥.១_ គោលការណ៍នៃការចុះបញ្ជីអចលនវត្ថុលើកដំបូង

ការចុះបញ្ជីអចលនវត្ថុលើកដំបូង ត្រូវមានគោលការណ៍ដូចខាងក្រោម៖
- វិជ្ជាជីវៈ
- ការចូលរួម
- ការពិគ្រោះយោបល់
- សមធម៌
- ការឆ្លើយតប
- តម្លាភាព។

**យោបល់៖** គួរបន្ថែមនូវគោលការណ៍ ភាពច្បាស់លាស់ ពេញលេញ និងស្ថាពរនៃការវិនិច្ឆ័យក្បាលដីនីមួយៗផង។ គួរបញ្ជាក់ថាការចុះបញ្ជីលើកដំបូង អនុវត្តចំពោះទាំងអចលនវត្ថុរបស់រដ្ឋរបស់នីតិបុគ្គលសាធារណៈផ្សេងទៀត និងរបស់សមូហភាព និងរបស់បុគ្គលឯកជនដែលកំពុងកាន់កាប់ប្រើប្រាស់ដី ឬអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីកម្មសិទ្ធិស្ថាពរ រួមទាំង ដីដែលមានប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាស្រ័យផល ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ប័ណ្ណសម្គាល់សិទ្ធិភោគៈ ឬវិញ្ញាបនបត្រដែលមានតម្លៃគតិយុត្ត ទាបជាងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬសម្គាល់កម្មសិទ្ធិលើអចលនវត្ថុ និងអចលនវត្ថុដែលមិនធ្លាប់មានការចុះបញ្ជីសុរិយោដីសោះ។

**សំណើបែងបន្ថែម៖** សូមបែងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**យោបល់៖** ចំពោះមាត្រា ១១៦ ដល់មាត្រា ១២៣ ដែលចែងអំពីភោគៈ និងការកាន់កាប់ដីក្នុងបំណងធ្វើលទ្ធកម្មកម្មសិទ្ធិ គួរលើកយកទៅដាក់ក្នុងមាតិកាទី២ ក្នុងជំពូកថ្មីមួយ មុនជំពូកស្តីពីសម្បទាន និងបន្ទាប់ពី មាត្រា ៥៨ ដើម្បីងាយស្រួលដល់អ្នកអានច្បាប់នេះ ហើយម្យ៉ាងវិញទៀតការចែងអំពីសិទ្ធិលើដីធ្លី ខុសពីការចែងអំពីការចុះបញ្ជីអចលនវត្ថុ។

## មាត្រា១១៦._ លក្ខខណ្ឌនៃភោគៈស្របច្បាប់

ក្នុងក្របខណ្ឌនៃការបង្កើតឡើងវិញនូវកម្មសិទ្ធិលើអចលនវត្ថុនៅកម្ពុជាក្រោយមានវិបត្តិពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

ដោយមិនចំណុះទៅនឹងវិធានទូទៅនៃអាជ្ញាយុកាលស្តីពីកម្មសិទ្ធិលើអចលនវត្ថុដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ភោគៈនៃអចលនវត្ថុដែលត្រូវបានទទួលស្គាល់ចាប់ពីឆ្នាំ១៩៨៩ អាចបង្កើតជាពិសេសនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ នឹងនាំទៅដល់លទ្ធកម្មនៃកម្មសិទ្ធិដោយអ្នកកាន់កាប់អចលនវត្ថុក្នុងលក្ខខណ្ឌដូចខាងក្រោម៖

១. ការកាន់កាប់អចលនវត្ថុត្រូវបានចាប់ផ្តើមនៅមុនថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ និង

២. ការកាន់កាប់អចលនវត្ថុត្រូវបានធ្វើដោយពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយពិតប្រាកដគឺថា ភោគីទោះកាន់កាប់ដោយខ្លួនឯងក្តី ឱ្យអ្នកដទៃធ្វើឱ្យក្តី ត្រូវកាន់កាប់ឱ្យឃើញថា ការកាន់កាប់នោះប្រាកដជាធ្វើដើម្បីខ្លួនក្នុងគោលបំណងឱ្យខ្លួនជាភោគីយ៉ាងផ្តាច់មុខ កុំឱ្យឃើញថា ការដែលធ្វើនោះគឺធ្វើដោយសារសិទ្ធិណាមួយផ្សេងទៅវិញ។ ប្រសិនបើភោគីពិតប្រាកដមិនចេញមុខនៅពីក្រោយភោគីមិនពិតប្រាកដ ភោគីនោះមិនអាចទាមទារធ្វើលទ្ធកម្មកម្មសិទ្ធិបានឡើយ។ ភោគៈដោយភោគីមិនចេញមុខនោះ ត្រូវចាត់ទុកជាមោឃៈ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយគ្មានហិង្សា គឺថាភោគៈដែលបានមកដោយហិង្សាមិនទុកជាភោគៈត្រឹមត្រូវតាមច្បាប់ឡើយ។ ក៏ប៉ុន្តែបើកាលណាគេប្រើហិង្សាក្នុងពេលមានតតិយជនឥតសិទ្ធិសោះមកដណ្តើមនោះ ហិង្សានេះគ្មានឥទ្ធិពលអ្វីទៅលើភោគៈដែលគេបានមកដោយសន្តិភាពតាំងពីដើមមកនោះទេ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយមានការដឹងឮជាសាធារណៈ គឺថាភោគីត្រូវកាន់កាប់ដោយឥតលាក់ឬបិទបាំងពីអ្នកទាំងពួងដែលចង់តវ៉ាអំពីសិទ្ធិរបស់ខ្លួនលើអចលនវត្ថុនោះ នឹងបានដឹងឮឬឃើញមិនខាន។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយគ្មានអាក់ខាន គឺថាភោគីត្រូវធ្វើនូវកិច្ចការផងទាំងពួងតាមធម្មតាជាប្រក្រតីក្នុងរយៈពេលចាំបាច់នៃការទាមទារលទ្ធកម្មនៃកម្មសិទ្ធិ។ ការអាក់ខានក្នុងរយៈពេលខ្លី ឬបោះបង់ទុកឱ្យនៅទំនេរដើម្បីឱ្យមានដីជាតិឡើងវិញ មិនមែនជាឧបសគ្គដល់លទ្ធកម្មកម្មសិទ្ធិនោះទេ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយសុចរិត គឺថាភោគីមិនដឹងពីសិទ្ធិជាយថាហេតុរបស់តតិយជនលើអចលនវត្ថុដែលខ្លួនកំពុងកាន់កាប់នោះសោះ។

**យោបល់៖** គួរចែងបញ្ជាក់ថាការកាន់កាប់ជាភោគៈអាចស្របច្បាប់តែក្នុងករណីដែលក្បាលដី ឬអចលនវត្ថុដទៃទៀត ជាកម្មវត្ថុនៃការទាមទារសិទ្ធិភោគៈ (សិទ្ធិកាន់កាប់ផ្តាច់មុខដែលមានឆន្ទៈយកធ្វើជាកម្មសិទ្ធិនោះ) មិនមែនជា ឬ មិនត្រូវបានកំណត់និយាមការ និងព្រំប្រទល់ច្បាស់លាស់ឥតប្រកែកតវ៉ាបានថាជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មុនពេលមានការចាប់ផ្តើម និងបន្តកាន់កាប់ជាប់លាប់ឥតអាក់ខានហួសពី ៣ ឆ្នាំជាប់ៗគ្នាផង។ ការចែងថា ការអាក់ខានក្នុងរយៈពេលខ្លី ឬបោះបង់ទុកឱ្យនៅទំនេរដើម្បីមានដីជាតិឡើងវិញមានភាពមិនច្បាស់នាំឱ្យពិបាក បកស្រាយ និងអនុវត្ត។ គួរលើកមាត្រា ២៦ មកដាក់បន្ទាប់ពីមាត្រា ១១៦ នេះ។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១១៧._ ការការពារភោគីស្របច្បាប់**

មានតែអាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋនិងក្នុងនាមនីតិបុគ្គលសាធារណៈដទៃទៀតប៉ុណ្ណោះ ដែលអាចឱ្យអ្នកកាន់កាប់អចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ឬដែលចុះបញ្ជីមិនបានត្រឹមត្រូវចាកចេញពីទីតាំងអចលនវត្ថុនោះ។

បុគ្គលឯកជន មន្ត្រីសាធារណៈ ឬអាជ្ញាធរដែលមិនបានទទួលអាណត្តិពីរដ្ឋ ឬពីនីតិបុគ្គលសាធារណៈដទៃទៀត គ្មានសមត្ថកិច្ចដេញដោយបង្ខំនូវអ្នកកាន់កាប់ដោយសន្តិភាពនូវដីដែលបានចុះបញ្ជីភោគៈ និងចេញបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីត្រឹមត្រូវបានឡើយ។ ការដេញអាចធ្វើបានតែតាមការបង្គាប់របស់តុលាការ យោងតាមបណ្តឹងរបស់បុគ្គលដែលបានប្តឹងទាមទារទ្រព្យ។

តុលាការត្រូវពិនិត្យបញ្ជាក់រូបភាព ប្រភព កាលបរិច្ឆេទ និងលក្ខខណ្ឌទាំងឡាយនៃបណ្ណដែលបានបង្ហាញ។ តុលាការមិនអាចប្រកែកក្នុងការបង្គាប់ឱ្យចាកចេញដើម្បីជាប្រយោជន៍ដល់បុគ្គលដែលបង្ហាញឯកសារត្រឹមត្រូវនិងពេញលេញរបស់រដ្ឋបាលសុរិយោដីបានឡើយ។

បើវិធានការបណ្តេញចេញបង្គាប់ដោយតុលាការ អាចបណ្តាលឱ្យមានភាពវឹកវរឬមានផលវិបាកធ្ងន់ធ្ងរដល់សង្គម អាជ្ញាធរមានសមត្ថកិច្ចអាចសុំពន្យារការអនុវត្តជាបណ្តោះអាសន្នបាន។

**យោបល់៖** ដើម្បីឱ្យមានអភិបាលកិច្ចដីធ្លីល្អ គួរមានការកំណត់ឱ្យច្បាស់អំពីការចាត់តាំង ឬការកំណត់អាណត្តិ និងការសម្គាល់អាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋ ឬក្នុងនាមនីតិបុគ្គលសាធារណៈដទៃទៀត ដែលមានសមត្ថកិច្ច កំណត់ក្នុងមាត្រា ១១៧ នេះ។ លើសពីនេះ ដើម្បីកុំឱ្យមានការយល់ច្រលំ ឬអនុវត្តខុស គួរលុបចោលឃ្លាថា នូវដីដែលបានចុះបញ្ជីភោគៈ និងចេញបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់

ដីធ្លីត្រឹមត្រូវ ក្នុងកថាខណ្ឌទី១ នៃមាត្រា ១១៧ នេះចេញ។ ការលុបចោលនេះ វានឹងធ្វើឱ្យមាត្រានេះស្របគ្នាជាមួយការចែងក្នុងមាត្រា ១២០។ រាល់អ្នកកាន់កាប់ប្រើប្រាស់ដីជាក់ស្តែងដោយសន្តិភាពត្រូវទទួលបានការប្រព្រឹត្តដូចគ្នា ហើយរាល់ការចាត់វិធានការបណ្តេញចេញក្រៅពីការប្រាប់ ការទាមទារ ឬការជូនដំណឹងដោយផ្ទាល់មាត់ ឬនិង លាយល័ក្ខណ៍អក្សរ ដោយសន្តិវិធី គួរអាចធ្វើបានតែតាមបង្គាប់របស់តុលាការ ផ្អែកលើបណ្តឹងរបស់បុគ្គលដែលប្តឹងទាមទារទ្រព្យ ឬប្តឹងការពារទ្រព្យ ឬរបស់អធិការសុរិយោដី អាជ្ញាធរកាន់កាប់ដីរដ្ឋ ឬសហគមន៍ដែលមានសិទ្ធិ ឬផលប្រយោជន៍លើដីនោះ។

## មាត្រា១១៨._ សិទ្ធិដែលត្រូវបានបង្កើតលើអចលនវត្ថុមុនពេលធ្វើលទ្ធកម្មកម្មសិទ្ធិដោយភោគៈ

ក្នុងករណីភោគីបានធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ សិទ្ធិដែលត្រូវបានបង្កើតលើអចលនវត្ថុនោះមុនពេលធ្វើលទ្ធកម្ម ត្រូវក្លាយជាសិទ្ធិដែលយកអចលនវត្ថុឬកម្មសិទ្ធិលើអចលនវត្ថុដដែលនោះមកធ្វើជាកម្មវត្ថុដោយស្វ័យប្រវត្តិ។

ក្នុងករណីបញ្ហាអំពីអំឡុងពេលបានកើតឡើងចំពោះសិទ្ធិដែលត្រូវបានបង្កើតលើអចលនវត្ថុនោះមុនពេលធ្វើលទ្ធកម្ម អំឡុងពេលត្រូវគណនាចាប់ពីពេលដែលសិទ្ធិនោះត្រូវបានបង្កើតជាដំបូង។

**យោបល់៖** គួរដាក់មាត្រានេះ នៅខាងក្រោយ បន្ទាប់ពីមាត្រា ១២៣ ដើម្បីកុំឱ្យដាច់លំហូរនៃវិធានអំពីភោគៈ។

**សំណើប្តូរទីតាំង៖** សូមប្តូរទីតាំងនៃមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១១៩._ វិធានចំពោះភោគៈមិនស្របច្បាប់

រដ្ឋមិនទទួលស្គាល់រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដទៃទៀត និងរាល់ការបំប្លែងការកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដទៃទៀត ទៅជាកម្មសិទ្ធិរបស់បុគ្គលឯកជន ទោះបីការកាន់កាប់និងការបំប្លែងនេះកើតមាននៅពេលណាក៏ដោយដែលមិនស្របនឹងលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីដែលមានជាធរមាននៅមុនច្បាប់នេះចូលជាធរមាន។

លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុដោយភោគៈ អាចសម្រេចបានចំពោះតែគុណប្រយោជន៍ដល់ភោគីស្របច្បាប់។ លទ្ធកម្មនេះមិនអាចជាគុណប្រយោជន៍ដល់ភោគីដែលកេងបន្លំឡើយ។

ការទទួលស្គាល់ដោយរំលោភដោយអាជ្ញាធរមានសមត្ថកិច្ច នូវភោគៈដែលមិនបំពេញលក្ខខណ្ឌនៃច្បាប់ត្រូវចាត់ទុកជាមោឃៈនិងគ្មានអានុភាព។ អាជ្ញាធរឬមន្ត្រីសាធារណៈដែលបានទទួលស្គាល់ដោយរំលោភនេះត្រូវទទួលខុសត្រូវដោយផ្ទាល់ខ្លួនចំពោះមុខច្បាប់។

អចលនវត្ថុទាំងឡាយដែលមិនអាចក្លាយជាកម្មសិទ្ធិនៃអ្នកកាន់កាប់ ដោយហេតុមកពីលក្ខណសម្បត្តិរបស់អ្នកកាន់កាប់នោះជាភោគីមិនស្របច្បាប់ ត្រូវទុកជាទ្រព្យសម្បត្តិរដ្ឋ ហើយមិនអាចឱ្យបុគ្គលឯកជនណាកាន់កាប់ជាភោគីថ្មីសម្រាប់លទ្ធកម្មនៃកម្មសិទ្ធិបានឡើយ។

**យោបល់៖** គួរចែងបញ្ជាក់ថានរណាជាអាជ្ញាធរ ឬ មន្ត្រីសាធារណៈ មានសមត្ថកិច្ចទទួលស្គាល់នូវភោគៈតាមការចែងក្នុងច្បាប់នេះ។ លិខិតបញ្ជាក់នូវការកាន់កាប់ដី ដែលចេញដោយរដ្ឋបាលភូមិ ឃុំសង្កាត់ ឬនិងក្រុងស្រុកខណ្ឌ មិនមែនជាការទទួលស្គាល់នូវភោគៈដែលបំពេញរាល់លក្ខខណ្ឌនៃច្បាប់ឡើយ។ ដូច្នេះគួរមានការកែសម្រួល និងចែងបញ្ជាក់ចំពោះកថាខណ្ឌទី៣ នៃមាត្រានេះ។ កថាខណ្ឌទី៤ នៃមាត្រានេះហាក់ដូចជាមិនចាំបាច់មានទៀតទេព្រោះច្បាប់នេះ ក៏ដូចជាច្បាប់ភូមិបាល ឆ្នាំ២០០១ លែងអនុញ្ញាតឱ្យមានការចូលកាន់កាប់ជាភោគៈថ្មីក្រោយថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ ទៀតឡើយ ដូចនេះគួរលុបកថាខណ្ឌនេះចោល ដើម្បីកុំឱ្យពិបាកបកស្រាយបទប្បញ្ញត្តិដែលចែងក្នុងកថាខណ្ឌនេះ។

**សំណើលុបចោល៖** សូមលុបចោលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១២០._ សិទ្ធិរបស់ភោគីស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

ក្នុងការរង់ចាំការចុះបញ្ជីដើម្បីឱ្យបានទៅជាកម្មសិទ្ធិពេញលេញ ភោគៈដែលស្របតាមបញ្ញត្តិនៃច្បាប់នេះបង្កើតបានជាសិទ្ធិប្រត្យក្សលើអចលនវត្ថុ។

ភោគីស្របច្បាប់នៃអចលនវត្ថុមានសិទ្ធិស្នើសុំទៅរដ្ឋបាលសុរិយោដីដើម្បីចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនោះ។ ក្នុងករណីមានការជំទាស់នឹងការចុះបញ្ជីនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថាខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈ។

ការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុទៅឱ្យបុគ្គលក្រៅពីភោគីពិតប្រាកដដែលបានកាន់កាប់អចលនវត្ថុនោះ ត្រូវបានហាមឃាត់។

បុគ្គលទាំងឡាយដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់នៃអចលនវត្ថុរបស់ខ្លួន ដោយហេតុមិនបានដឹង ឬដោយធ្វេសប្រហែស បុគ្គលនោះនៅតែមានសិទ្ធិត្រូវបានការពារជាភោគីស្របច្បាប់តាមអំណាចនៃច្បាប់នេះ។

**យោបល់៖** តាមការចែងនេះ ចំពោះករណីដែលជនបរទេស ឬនីតិបុគ្គលបរទេស ធ្វើកិច្ចព្រមព្រៀងបរធនបាលជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលខ្មែរដើម្បីទិញ និងកាន់កាប់ដីភោគៈដែលមិនទាន់បានចុះបញ្ជី សម្រាប់ជាប្រយោជន៍របស់ជនបរទេស ឬនីតិបុគ្គលបរទេស តើត្រូវអនុវត្តបែបណានៅក្នុងការចុះបញ្ជីដីនោះ ព្រោះថាតាមភាពជាក់ស្តែង

គឺជាការចុះបញ្ជីឱ្យផលប្រយោជន៍ទៅជនបរទេស ឬនីតិបុគ្គលបរទេស ដែលមិនមែនជាភោគីពិតប្រាកដ។ គួរចែងបញ្ជាក់ខ្លឹមសារសម្រាប់អនុវត្ត កថាខណ្ឌទី១ នៃមាត្រានេះ។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១២១._ ភស្តុតាងនៃសិទ្ធិកាន់កាប់

បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ និងបណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដែលត្រូវបានចេញដោយរដ្ឋបាលសុរិយោដីមុនច្បាប់នេះចូលជាធរមាន ជាវត្ថុតាងនៃសិទ្ធិកាន់កាប់ ប៉ុន្តែមិនមែនជាឯកសារសម្គាល់កម្មសិទ្ធិទេ ហើយក៏មិនមែនជាលិខិតដែលតវ៉ាមិនបាននោះដែរ។

បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ និងបណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី អាចនឹងយកទៅប្រើជាលិខិតដែលមានលក្ខណៈមិនអាចតវ៉ាបាន លុះត្រាតែគ្មានការជំទាស់នៅពេលបង្កើតសៀវភៅគោលបញ្ជីដីធ្លី។

បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុគឺជាភស្តុតាងមួយ ប៉ុន្តែមិនអាចកំណត់តែឯកឯងបានទេ

**យោបល់៖** កន្លងមកសង្កេតឃើញថាមានការចេញបណ្ណសម្គាល់សិទ្ធិភោគៈលើអចនវត្ថុផងដែរ។ ដូច្នេះការរៀបរាប់ប្រភេទបណ្ណក្នុងមាត្រាទេនេះមិនពេញលេញទេគួរតែពិនិត្យឡើងវិញ។ រីឯកថាខណ្ឌទី៣ នៃមាត្រានេះ យោងតែលើបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ដូច្នេះនាំឱ្យមានសំណួរអំពីអានុភាពនៃបណ្ណសម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី និងបណ្ណសម្គាល់សិទ្ធិភោគៈលើអចនវត្ថុ។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១២២._ សិទ្ធិស្នើសុំចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

អ្នកកាន់កាប់អចលនវត្ថុដែលយល់ថាខ្លួនអាចទទួលបានលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុដោយភោគៈ មានសិទ្ធិស្នើសុំទៅរដ្ឋបាលសុរិយោដីដើម្បីចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំពោះអចលនវត្ថុនោះ។ ក្នុងករណីនេះ រដ្ឋបាលសុរិយោដីមានសិទ្ធិសម្រេចបដិសេធការស្នើសុំ ឬធ្វើការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ឬស្នើសុំឱ្យម្ចាស់សំណើរង់ចាំការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។

ទោះក្នុងករណីណាក៏ដោយ រដ្ឋបាលសុរិយោដីត្រូវចេញលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចនោះដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។ ការមិនឆ្លើយតបក្នុងរយៈពេលលើសពី១(មួយ)ខែគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ ត្រូវចាត់ទុកជាកំហុសរបស់រដ្ឋបាលសុរិយោដីដែលទទួលសំណើ។

~~ក្នុងករណីរដ្ឋបាលសុរិយោដីបដិសេធចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ អ្នកកាន់កាប់អចលនវត្ថុនោះមានសិទ្ធិប្តឹងតវ៉ាទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងស្តីពីការបដិសេធ។~~

**យោបល់៖** គួរមានចែងអំពីឧបាស្រ័យ (ដូចជា ទណ្ឌកម្មរដ្ឋបាលចំពោះមន្ត្រីទទួលបន្ទុកពិនិត្យសម្រេច លើពាក្យសុំចុះបញ្ជី និងសំណងការខូចខាតជាក់ស្តែងដល់ភាគី តាមការប្តឹងទាមទាររបស់ភាគី) ចំពោះកំហុសរបស់រដ្ឋបាលសុរិយោដី ដែលចែងក្នុងមាត្រានេះ ដើម្បីធានាឱ្យមានប្រសិទ្ធភាពអនុវត្តបទប្បញ្ញត្តនេះ។

**សំណើចែងបន្ថែម៖** សូមចែងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១២៣._ ការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដោយរដ្ឋបាលសុរិយោដី ឱ្យបុគ្គលក្រៅពីភាគីពិតប្រាកដដែលបានកាន់កាប់អចលនវត្ថុ**

ការចុះបញ្ជីអចលនវត្ថុដោយរដ្ឋបាលសុរិយោដី ឱ្យបុគ្គលក្រៅពីភាគីពិតប្រាកដដែលបានកាន់កាប់អចលនវត្ថុ គឺជាបទល្មើសដែលត្រូវទទួលទោសតាមបញ្ញត្តិនៃច្បាប់ជាធរមាន។

**យោបល់៖** ក្នុងករណីនេះតើនរណាជាអ្នកទទួលខុសត្រូវចំពោះបទល្មើសនេះ ព្រោះដំណើរការចុះបញ្ជីដីពាក់ព័ន្ធមនុស្សជាច្រើនដែលចូលរួមអនុវត្ត ឬពិនិត្យលើឯកសារវិនិច្ឆ័យក្នុងកម្រិតទទួលខុសត្រូវខុសៗគ្នា? ម្យ៉ាងទៀត តើច្បាប់ជាធរមានណា (ក្រៅពីច្បាប់ភូមិបាល ២០០១ ដែលត្រូវជំនួសដោយច្បាប់នេះ) ចែងកំណត់បទល្មើស និង ទោសទណ្ឌសម្រាប់អំពើនេះ? សូមមើលយោបល់ក្នុងមាត្រា ១២០ ផង។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## ផ្នែកទី២
## ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

**មាត្រា១២៤._ បន្ទុកក្នុងការចំណាយលើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ**

~~រដ្ឋទទួលបន្ទុកចំណាយលើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស។~~

### មាត្រា១២៥._ គោលការណ៍នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

~~ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ត្រូវមានគោលការណ៍ដូចខាងក្រោម៖~~

~~- វិជ្ជាជីវៈ~~

~~- ការចូលរួម~~

~~- ការពិគ្រោះយោបល់~~

~~- សមធម៌~~

~~- ការឆ្លើយតប~~

~~- តម្លាភាព។~~

### មាត្រា១២៦._ ការកំណត់តំបន់វិនិច្ឆ័យ

រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្តមានសមត្ថកិច្ចធ្វើការកំណត់តំបន់វិនិច្ឆ័យសម្រាប់ការចុះបញ្ជីដីធ្លីក្នុងដែនភូមិសាស្ត្ររបស់ខ្លួន ទៅតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ឬតាមសំណើរបស់រដ្ឋបាលឃុំ សង្កាត់ដែលពាក់ព័ន្ធ។

តំបន់វិនិច្ឆ័យសម្រាប់អនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ត្រូវកំណត់តូចបំផុតត្រឹមព្រំប្រទល់ភូមិសាស្ត្រនៃភូមិ។

**យោបល់៖** មិនមានយោបល់

### មាត្រា១២៧._ ការកំណត់ព្រំដី

ការកំណត់ព្រំដីជាសមត្ថកិច្ចរបស់មន្ត្រីទទួលបន្ទុកកំណត់ព្រំដី។

មន្ត្រីទទួលបន្ទុកកំណត់ព្រំដីមានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុ ដើម្បីកំណត់ព្រំដីនិងវាស់វែង ហើយអាចអញ្ជើញបុគ្គលពាក់ព័ន្ធឱ្យផ្តល់ចម្លើយផ្ទាល់មាត់ ឯកសារ ឬបង្ហាញភស្តុតាងផ្សេងៗទាក់ទងនឹងព្រំដីដែលកំពុងធ្វើការកំណត់។

ក្នុងការកំណត់ព្រំដី មន្ត្រីទទួលបន្ទុកកំណត់ព្រំដីត្រូវគោរពគោលការណ៍ណាមួយដូចខាងក្រោម៖

ក-ការព្រមព្រៀងរវាងម្ចាស់ដីឬអ្នកកាន់កាប់ដីដែលមានព្រំនៅជាប់គ្នា។

ខ-ការផ្អែកតាមឯកសារដែលមាននិងភស្តុតាងជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ទាក់ទងនឹងព្រំដី។

វិវាទអំពីព្រំដីដែលទទួលបាននៅពេលកំណត់ព្រំដីហើយមិនអាចសម្រុះសម្រួលបាន ត្រូវបញ្ជូនទៅមន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យ ឱ្យធ្វើការសម្រុះសម្រួលនិងដោះស្រាយ នៅពេលបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ។

**យោបល់៖** គួរចែងបញ្ជាក់ថានរណាមានភារកិច្ចសម្រុះសម្រួលវិវាទអំពីព្រំដី ដែលទទួលបាននៅពេលកំណត់ព្រំដីមុននឹងបញ្ជូនទៅមន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យ ហើយគួរបញ្ជាក់ផងដែរថាការសម្រុះសម្រួល និងដោះស្រាយវិវាទនោះចាំបាច់ត្រូវមានការដាក់ពាក្យប្តឹងជំទាស់ ឬតវ៉ាដោយភាគីណាមួយនៃវិវាទ ក្នុងអំឡុងពេលបិទផ្សាយជាសាធារណៈនូវឯកសារ វិនិច្ឆ័យទៀតឬអត់។ លើសពីនេះការប្រើពាក្យថា ដោះស្រាយនៅពេលបិទផ្សាយជាសាធារណៈតើមានន័យកម្រិតត្រឹមតែក្នុងអំឡុងពេលបិទផ្សាយជាសាធារណៈ ឬអាចបន្តធ្វើក្រោយបញ្ចប់អំឡុងពេលបិទផ្សាយផងដែរ ប្រសិនបើវិវាទនោះមិនទាន់បានដោះស្រាយ។ ករណីដែលគូភាគីវិវាទបានឯកភាពព្រមព្រៀងអំពីព្រំដីក្រោយពីការវាស់វែង និងបញ្ចប់នូវអំឡុងពេលបិទផ្សាយជាសាធារណៈ ហើយបានជូនដំណឹងទៅមន្ត្រីវាស់វែងអំពីការព្រមព្រៀងនោះ តើរដ្ឋបាលសុរិយោដីត្រូវធ្វើបែបណា។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១២៨._ ការងារវាស់វែង

ការងារវាស់វែងត្រូវអនុវត្តបន្ទាប់ពីបានកំណត់ព្រំដីរួច។

អ្នកវាស់វែងត្រូវអនុវត្តការងារវាស់វែងដែលជាតម្រូវការក្នុងការកសាងប្លង់សុរិយោដី និងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ។

**យោបល់៖** មិនមានយោបល់

### មាត្រា១២៩._ ការងារវិនិច្ឆ័យ

មន្ត្រីវិនិច្ឆ័យមានសិទ្ធិដូចខាងក្រោម៖

- អាចអញ្ជើញបុគ្គលពាក់ព័ន្ធឱ្យផ្តល់ចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗដែលទាក់ទងនឹងការវិនិច្ឆ័យ
- សាកសួរយកព័ត៌មានចាំបាច់សម្រាប់អនុវត្តការងារវិនិច្ឆ័យ

- ប្រមូលរាល់ឯកសារ ភស្តុតាង និងព័ត៌មានផ្សេងៗទាក់ទងនឹងសិទ្ធិលើក្បាលដីនីមួយៗ ក្នុងតំបន់វិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនោះចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី រួចឱ្យអ្នកកាន់កាប់ដីផ្ដិតស្នាមមេដៃ។

មន្ត្រីវិនិច្ឆ័យមានកាតព្វកិច្ចចុះហត្ថលេខា និងសរសេរឈ្មោះរបស់ខ្លួនទទួលខុសត្រូវលើទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីផងដែរ។

**យោបល់៖** មិនមានយោបល់

## មាត្រា១៣០._ ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

ឯកសារនៃការវិនិច្ឆ័យត្រូវបិទផ្សាយជាសាធារណៈនៅតាមទីកន្លែងដែលងាយមើលឃើញនៅក្នុងភូមិដែលត្រូវបានប្រកាសជាតំបន់វិនិច្ឆ័យ មានជាអាទិ៍ ទីវត្តអារាម ទីសាធារណៈ សាលារៀន សាលាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ។

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ជាភារកិច្ចរបស់រដ្ឋបាលសុរិយោដីដែលទទួលបន្ទុកប្រកាសតំបន់វិនិច្ឆ័យ។

រដ្ឋបាលសុរិយោដីដែលទទួលបន្ទុកប្រកាសតំបន់វិនិច្ឆ័យ ត្រូវជូនដំណឹងជាមុនអំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ។

បុគ្គលដែលមានផលប្រយោជន៍ មានសិទ្ធិប្ដឹងតវ៉ាអំពីវិការៈនៃនីតិវិធីចុះបញ្ជីដីធ្លីនិងអំពីការទទួលបានកម្មសិទ្ធិលើដី តែក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យប៉ុណ្ណោះ។

រយៈពេលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** គួរចែងបញ្ជាក់អំពីបុគ្គលមានផលប្រយោជន៍ ដែលមានសិទ្ធិ និងកាតព្វកិច្ចប្ដឹងតវ៉ាអំពីវិការៈនៃនីតិវិធីចុះបញ្ជី ហើយក្រៅពីវិការៈនៃនីតិវិធី គួរបញ្ជាក់អំពីការប្ដឹងតវ៉ាអំពីភាពមិនសុក្រឹត ឬកំហុសខ្លឹមសារក្នុងឯកសារវិនិច្ឆ័យ។ ជាការចាំបាច់ដែលត្រូវតែតម្រូវឱ្យភ្នាក់ងារ ឬតំណាងរបស់អាជ្ញាធរកាន់កាប់ដីរដ្ឋចូលរួមពិនិត្យឯកសារវិនិច្ឆ័យ ឬអញ្ជើញអាជ្ញាធរកាន់កាប់ដីរដ្ឋពាក់ព័ន្ធដែលរដ្ឋបាលសុរិយោដីរកឃើញក្នុងដំណើរការវិនិច្ឆ័យក្បាលដីឱ្យមកពិនិត្យ និងដាក់ពាក្យតវ៉ាមុនពេលចាប់ផ្ដើមបិទផ្សាយជាសាធារណៈ។ គួរតែចែងផងដែរថា ការខកខានមិនបានពិនិត្យ ឬនិងតវ៉ាចំពោះឯកសារវិនិច្ឆ័យក្នុងអំឡុងពេល ៣០ថ្ងៃ ប្រតិទិនគិតចាប់ពីថ្ងៃបញ្ចប់នូវការបិទផ្សាយជាសាធារណៈ នាំឱ្យបុគ្គលសហគមន៍ ឬអាជ្ញាធរកាន់កាប់ដីរដ្ឋពាក់ព័ន្ធ ថ្លោះសិទ្ធិក្នុងការទាមទារដី ឬអចលនវត្ថុនោះ ឬបើកផ្លូវឱ្យរដ្ឋបាលសុរិយោដីបញ្ចប់ការចុះបញ្ជី និងចេញបណ្ណដោយស្របច្បាប់លើដីពាក់ព័ន្ធ ហើយមានតែករណីដែល អ្នកទទួលបានការចុះបញ្ជី ឬភ្នាក់ងាររបស់ខ្លួនបានប្រើឧបាយកលទុច្ចរិត ឬខុសច្បាប់ក្នុងការលាក់កំបាំងការពិតចំពោះ រដ្ឋបាលសុរិយោដី ហើយទ្រព្យនោះមិនទាន់ត្រូវបានផ្ទេរទៅឱ្យតតីយជនសុចរិតឥតកំហុស ភាគីដែលរងផលប៉ះពាល់ ដោយសារការចុះបញ្ជី

មានសិទ្ធិប្ដឹងទៅតុលាការឱ្យ សម្រេចអំពីអានុភាពនៃការចុះបញ្ជីចេញបណ្ណនោះ ចំពោះអ្នកទទួលបានការចុះបញ្ជីរួមទាំងអាចបង្គាប់ឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិលើទ្រព្យនោះដោយបង្ខំទៅឱ្យ ម្ចាស់ទ្រព្យស្របច្បាប់វិញ។

**សំណើចែងបញ្ជាក់ និងបន្ថែម៖** សូមចែងបញ្ជាក់ និងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៣១._ ការសម្រុះសម្រួល

ក្នុងករណីមានវិវាទអំពីទំហំនៃក្បាលដី ឬឈ្មោះនៃកម្មសិទ្ធិករកើតឡើងក្នុងពេលប្រតិបត្តិការធ្វើសម្រង់សុរិយោដី មន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យត្រូវអញ្ជើញសាមីខ្លួនឬអ្នកតំណាងមកសម្រុះសម្រួល ប៉ុន្តែមន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យពុំមានសមត្ថកិច្ចធ្វើការសម្រេចទេ។

ការដោះស្រាយតាមការព្រមព្រៀងនេះត្រូវធ្វើក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យបណ្ដឹងតវ៉ា។ ផុតរយៈពេលនេះ មន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យត្រូវបញ្ជូនបណ្ដឹងតវ៉ាដែលមិនអាចដោះស្រាយបានទៅ គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌនៃតំបន់វិនិច្ឆ័យនោះ។ មន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យត្រូវបន្តធ្វើអង្កេតវាស់វែងសុរិយោដីទោះបីជាភាគីវិវាទមិនព្រមព្រៀងគ្នាក៏ដោយ។ ក្នុងករណីនេះ មន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យត្រូវកសាងកំណត់ហេតុ និងបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌនៃទីតាំងដីវិវាទនោះ។ មន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យមានសិទ្ធិប្រានចោលការទាមទារណាមួយដែលមិនត្រឹមត្រូវ
ឬមិនមែនជាសមត្ថកិច្ចដោះស្រាយដែលអនុញ្ញាតដោយច្បាប់នេះ។

ក្នុងកំលុងពេលបិទផ្សាយជាសាធារណៈ ជនណាដែលមានប្រយោជន៍លើក្បាលដីណាមួយដែលបានចាត់ទុកថាឯកសារនៃការវិនិច្ឆ័យមិនជាក់លាក់ឬមិនពេញលេញ អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មការរដ្ឋបាល។

គណៈកម្មការរដ្ឋបាលត្រូវសម្រុះសម្រួលដោះស្រាយរាល់វិវាទទាំងអស់ក្នុងកំលុងពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ។

ការជំទាស់ឬវិវាទណាមួយដែលមិនអាចដោះស្រាយបានដោយគណៈកម្មការរដ្ឋបាលនៅក្នុងកំលុងពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិស្របតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងក្នុងច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ផុតអំលុងពេលបិទផ្សាយជាសាធារណៈ ក្បាលដីទាំងឡាយដែលមិនអាចសម្រុះសម្រួលដោះស្រាយបានត្រូវដកចេញពីបញ្ជីក្បាលដីនៃតំបន់វិនិច្ឆ័យ សម្រាប់ទុកអនុវត្តនីតិវិធីចុះបញ្ជីដីបំពេញបន្ថែមនៅពេលក្រោយ។

**យោបល់៖** ការចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ មិនស្របគ្នាជាមួយការចែងក្នុងកថាខណ្ឌចុងក្រោយ នៃមាត្រា១២៧ ទេ។ តើវិវាទចែងក្នុងកថាខណ្ឌចុងក្រោយនៃមាត្រា១២៧ ត្រូវសម្រុះសម្រួលដោយ មន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យ ឬ

ដោយគណៈកម្មការរដ្ឋបាលនៅអំឡុងពេលនៃការបិទផ្សាយជាសាធារណៈ? គួរតែទុករយៈពេល ៤៥ ថ្ងៃប្រតិទិនទៀតក្រោយពីផុតអំឡុងពេលបិទផ្សាយជាសាធារណៈ ឱ្យគណៈកម្មការរដ្ឋបាលព្យាយាមសម្រុះសម្រួលវិវាទ ឬការតវ៉ានានាអំពីការវាស់វែងមិនត្រឹមត្រូវ ដែលនៅសេសសល់ទាំងអស់ មុននឹងអនុវត្តកថាខណ្ឌចុងក្រោយនៃ មាត្រានេះ ដើម្បីសម្រួលបន្ទុកការងាររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ព្រោះការតវ៉ាអំពីឯកសារវិនិច្ឆ័យ ឬព្រំដីដែលបង្ហាញក្នុងប្លង់បង្ហាញក្បាលដី ទំនងជាធ្វើឡើងយឺតដោយមូលហេតុផ្សេងៗ នៅថ្ងៃចុងក្រោយនៃអំឡុងពេលបិទផ្សាយជាសាធារណៈ។ លើសពីនេះ ការដាក់ពាក្យប្តឹងតវ៉ា ឬជំទាស់ចំពោះឯកសារវិនិច្ឆ័យ គួរតែបើកថែមជូន ៣០ ថ្ងៃប្រតិទិនក្រោយពីបញ្ចប់អំឡុងពេលបិទផ្សាយជាសាធារណៈ ដើម្បីផ្តល់ឱកាសសមស្របឱ្យម្ចាស់ដី ឬអាជ្ញាធរកាន់កាប់ដីរដ្ឋដែលនៅឆ្ងាយ ឬមានធុរៈ ឬត្រូវឆ្លងយោបល់របស់ថ្នាក់ដឹកនាំតាមឋានានុក្រមមិនអាចមកដាក់ពាក្យតវ៉ា ឬជំទាស់ទាន់ក្នុងអំឡុងពេលបិទផ្សាយជាសាធារណៈ។

**សំណើចែងបញ្ជាក់ និងបន្ថែម៖** សូមចែងបញ្ជាក់ និងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

មាត្រា១៣១.១_

ក្នុងករណីម្ចាស់ដីណាមួយមិនបានចូលរួមក្នុងដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ម្ចាស់ដីនោះអាចដាក់ពាក្យស្នើសុំចុះបញ្ជីដីបំពេញបន្ថែមនៅក្រោយពេលដែលការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវបានបញ្ចប់។

លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជិដីបំពេញបន្ថែម ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** គួរមានការចែងបញ្ជាក់ថាបទប្បញ្ញត្តិនៃមាត្រានេះ មិនអនុវត្តចំពោះក្បាលដីដែលបុគ្គលផ្សេងបានចូលរួមពេញលេញក្នុងនីតិវិធីចុះបញ្ជី ហើយក្បាលដីនោះត្រូវបានចុះបញ្ជី និងចេញបណ្ណជូនបុគ្គលផ្សេងដែលបានចូលរួមនោះទេ។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៣២._ លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ**

លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** គួរពិនិត្យកែសម្រួលអនុក្រឹត្យជាធរមានដើម្បីដោះស្រាយបញ្ហានានា ឬដាក់បញ្ចូលយោបល់ពាក់ព័ន្ធមួយចំនួន ដើម្បីធ្វើឱ្យនីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធកាន់តែល្អប្រសើរ ច្បាស់លាស់ ពេញលេញ មានសមធម៌ និងប្រសិទ្ធភាពជាងមុន។

**សំណើកែសម្រួលអនុក្រឹត្យ៖** សូមកែសម្រួលអនុក្រឹត្យពាក់ព័ន្ធ ស្របតាមយោបល់ខាងលើ។

## ផ្នែកទី៣
## ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

### មាត្រា១៣៣._ សិទ្ធិស្នើសុំចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

ក្នុងការរង់ចាំការចុះបញ្ជីដើម្បីឱ្យបានទៅជាកម្មសិទ្ធិពេញលេញ ភោគៈដែលស្របតាមបញ្ញត្តិនៃច្បាប់នេះ បង្កើតបានជាសិទ្ធិប្រត្យក្សលើអចលនវត្ថុ។

ម្ចាស់ដីឬអ្នកកាន់កាប់ដីដែលស្នើសុំចុះបញ្ជីដីរបស់ខ្លួននៅក្រៅតំបន់វិនិច្ឆ័យ មានសិទ្ធិស្នើសុំមករដ្ឋបាលសុរិយោដីដើម្បីអនុវត្តនីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

**យោបល់៖** មិនមានយោបល់

### មាត្រា១៣៤._ លក្ខខណ្ឌនៃក្បាលដីសម្រាប់ធ្វើការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ

ក្បាលដីដែលអាចធ្វើការចុះបញ្ជីតាមនីតិវិធីមានលក្ខណៈដាច់ដោយដុំ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ក្បាលដីត្រូវបានកាន់កាប់ជាភោគៈដែលស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- ក្បាលដីពុំមានជាប់ព្រំជាមួយក្បាលដីរដ្ឋឬស្ថិតក្នុងតំបន់ដែលអាជ្ញាធរមានសមត្ថកិច្ចអាចកំណត់ព្រំប្រទល់ដីរដ្ឋបាន។

**យោបល់៖** សូមចែងបញ្ជាក់ថាតើក្បាលដីជាប់ផ្លូវថ្នល់ ផ្លូវរថភ្លើង ទន្លេ ស្ទឹង ព្រែក បឹងបួរ អូរ ឆ្នេរសមុទ្រ ត្រើយសមុទ្រ ដីលិចទឹកអចិន្ត្រៃយ៍ អាចស្នើសុំចុះបញ្ជីបានទេ? តើនរណាជាអាជ្ញាធរមានសមត្ថកិច្ចកំណត់ព្រំប្រទល់ដីរដ្ឋ? ការចែងបញ្ជាក់ច្បាស់អំពីសំណួរទាំងនេះនឹងសម្រួលដល់ការងាររបស់រដ្ឋបាលសុរិយោដី ដើម្បីដឹងច្បាស់ថាពេលណាអាចអនុវត្តនីតិវិធីចុះបញ្ជីដាច់ដោយដុំបាន។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៣៥._ ប្រភេទនៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ**

នៅក្នុងការអនុវត្តនីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ រដ្ឋបាលសុរិយោដីត្រូវចុះបញ្ជីអចលនវត្ថុនៅក្នុងសៀវភៅគោលបញ្ជិដីធ្លី។

**យោបល់៖** តើនេះមានន័យថាត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុមែនទេ?

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៣៦._ ការបញ្ចូលក្បាលដីដែលត្រូវបានចុះបញ្ជីមានលក្ខណៈដាច់ដោយដុំរួចហើយ**

ពេលចុះអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ រដ្ឋបាលសុរិយោដីត្រូវបញ្ចូលក្បាលដីដែលត្រូវបានចុះបញ្ជីមានលក្ខណៈដាច់ដោយដុំរួចហើយ ទៅក្នុងទិន្នន័យក្បាលដីនិងផែនទីនៃតំបន់វិនិច្ឆ័យដោយស្វ័យប្រវត្តិ និងចេញវិញ្ញាបណ្ណបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មីជូនកម្មសិទ្ធិករ។ ក្នុងករណីនេះ រដ្ឋបាលសុរិយោដីពុំមានអាចកែសម្រួលរូបរាងឬទំហំនៃក្បាលដីដែលត្រូវបានចុះបញ្ជីមានលក្ខណៈដាច់ដោយដុំរួចហើយ ដោយការយល់ព្រមជាលាយលក្ខណ៍អក្សរពីកម្មសិទ្ធិករនៃក្បាលដីបានឡើយ។

**យោបល់៖** សូមបញ្ជាក់ថាក្នុងករណីនេះ តើម្ចាស់ដីចាំបាច់ត្រូវចូលរួមបំពេញទម្រង់ទិន្នន័យក្បាលដីសម្រាប់នីតិវិធីចុះបញ្ជីជាប្រព័ន្ធដែរឬទេ? តើពាក្យថា ដោយស្វ័យប្រវត្តិ មានន័យយ៉ាងណាក្នុងការអនុវត្តរបស់រដ្ឋបាលសុរិយោដី? តើបទប្បញ្ញត្តិនេះ អនុវត្តចំពោះក្បាលដីដែលបានចុះបញ្ជីដាច់ដោយដុំកន្លងមក មុនពេលចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីដីធ្លីស្របតាមការចែងក្នុងច្បាប់នេះដែរឬទេ? បើអនុវត្ត តើអនុវត្តចាប់ពីត្រឹមណា? បើមិនអនុវត្ត តើរដ្ឋបាលសុរិយោដីត្រូវធ្វើយ៉ាងដូចម្តេចចំពោះក្បាលដី និងអចលនវត្ថុដែលបានចុះបញ្ជីដាច់ដោយដុំកន្លងមក ?

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៣៧._ លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ**

ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំត្រូវធ្វើការបិទផ្សាយជាសាធារណៈ។

លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** គួរមានបញ្ញត្តិចែងស្រដៀងគ្នានឹងមាត្រា ១៣០ ហើយបញ្ចូលយោបល់ក្នុងមាត្រា ១៣០ ផង។ លើសពីនេះគួរពិនិត្យកែសម្រួលអនុក្រឹត្យជាធរមានដើម្បីដោះស្រាយបញ្ហានានា ឬដាក់បញ្ចូលយោបល់ពាក់ព័ន្ធមួយចំនួន ដើម្បីធ្វើឱ្យនីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ កាន់តែល្អប្រសើរ ច្បាស់លាស់ ពេញលេញ មានសមធម៌ និងប្រសិទ្ធភាពជាងមុន។

**សំណើចែងបន្ថែម និងកែសម្រួលអនុក្រឹត្យ៖** សូមចែងបន្ថែមក្នុងមាត្រានេះ និងកែសម្រួលអនុក្រឹត្យពាក់ព័ន្ធស្របតាមយោបល់ខាងលើ។

## ផ្នែកទី៣-១
## ការចុះបញ្ជីដីរដ្ឋ

### មាត្រា១៣៧.១_

អាជ្ញាធរកាន់កាប់ដីរដ្ឋគ្រប់ថ្នាក់មានករណីកិច្ចជំរុញនិងចូលរួមអនុវត្តនីតិវិធីចុះបញ្ជីដីរដ្ឋស្ថិតក្រោមការកាន់កាប់របស់ខ្លួន។

**យោបល់៖** មិនមានយោបល់

### មាត្រា១៣៧.២_

ការចុះបញ្ជិដីរដ្ឋត្រូវធ្វើឡើងតាមរយៈការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធឬមានលក្ខណៈដាច់ដោយដុំដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវបំពេញតួនាទីក្នុងមានរដ្ឋដែលជាកម្មសិទ្ធិករនៃដីរដ្ឋ និងនីតិបុគ្គលសាធារណៈដែលជាម្ចាស់ដីរដ្ឋដទៃទៀត ចូលរួមក្នុងដំណើរការនៃការចុះបញ្ជិដីធ្លីមានលក្ខណៈជាប្រព័ន្ធឬបំពេញបែបបទស្នើសុំចុះបញ្ជីដីរដ្ឋមានលក្ខណៈដាច់ដោយដុំទៅរដ្ឋបាលសុរិយោដី។

**យោបល់៖** សូមមើលយោបល់សម្រាប់មាត្រា ១៣០។

### មាត្រា១៣៧.៣_

ដីរដ្ឋត្រូវចុះបញ្ជិនៅក្នុងសៀវភៅគោលបញ្ជិដីធ្លី ជាដីសាធារណៈរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ឬជាដីឯកជនរដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត។

ការធ្វើចំណាត់ថ្នាក់ដីរដ្ឋជាប្រភេទដីសាធារណៈរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ឬជាប្រភេទដីឯកជនរដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ជាសមត្ថកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្រោមការត្រួតពិនិត្យរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្នុងករណីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនអាចសម្រេចអំពីប្រភេទដីរដ្ឋណាមួយ ក្រសួងត្រូវស្នើសុំសម្រេចពីនាយករដ្ឋមន្ត្រី។

**យោបល់៖** មិនមានយោបល់

**មាត្រា១៣៧.៤_**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបង្កើតនិងគ្រប់គ្រងប្រព័ន្ធទិន្នន័យនិងផែនទីរដ្ឋ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តមានភារកិច្ចថែរក្សា និងធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនដីរដ្ឋប្រចាំរាជធានី ខេត្តរបស់ខ្លួន។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលសាធារណៈដទៃទៀតដែលជាអាជ្ញាធរកាន់កាប់ដីរដ្ឋណាមួយ ឬអះអាងថាក្បាលដីណាមួយស្ថិតនៅក្រោមអាណត្តិកាន់កាប់របស់ខ្លួន មានកាតព្វកិច្ចប្រគល់មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នូវរាល់ព័ត៌មាន និងឯកសារចាំបាច់ដើម្បីគាំទ្រនូវអំណះអំណាងរបស់ខ្លួន។

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តល់នូវរាល់ព័ត៌មាន និងឯកសារទាក់ទងនឹងដីរដ្ឋទាំងអស់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទោះបីជាដីទាំងអស់នោះមិនស្ថិតនៅក្រោមអាណត្តិកាន់កាប់របស់ខ្លួនក៏ដោយ។

**យោបល់៖** មិនមានយោបល់

**មាត្រា១៣៧.៥_**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចចាត់ចែងធ្វើការចុះបញ្ជីដីរដ្ឋដោយផ្ទាល់តាមនីតិវិធីពិសេសក្នុងលក្ខខណ្ឌដូចខាងក្រោម៖

១- ដីរដ្ឋត្រូវបានកំណត់ទំហំ ប្រភេទ ប្រភេទប្រើប្រាស់ និងមានព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការចុះបញ្ជីត្រឹមត្រូវរួចហើយ។

២- អាជ្ញាធរកាន់កាប់ដីរដ្ឋបានស្នើសុំមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេស។

**យោបល់៖** តើក្រសួងរៀបចំដែនដី កំណត់អំពីភាពត្រឹមត្រូវនៃដីរដ្ឋសម្រាប់ការចុះបញ្ជី ដោយផ្អែកលើអ្វី? តើក្រសួងនេះត្រូវតែកំណត់ថាមានបន្ទុកភោគៈស្របច្បាប់ ឬសិទ្ធិប្រត្យក្សផ្សេងទៀតផងដែរឬទេ មុននឹងអនុវត្តនីតិវិធីពិសេសនោះ? មានការព្រួយបារម្ភខ្លាំងថាការអនុវត្តនីតិវិធីពិសេស អាចលម្អៀងទៅខាងភាគីរដ្ឋ និងខ្វះតម្លាភាព ហើយធ្វើឱ្យប៉ះពាល់ដល់សិទ្ធិភោគៈស្របច្បាប់ និងសិទ្ធិប្រត្យក្សផ្សេងទៀតដែលមានលើដីដែលស្នើសុំដោយអាជ្ញាធរកាន់កាប់ដីរដ្ឋ។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

មាត្រា១៣៧.៦_

លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** សូមពិចារណាយោបល់ក្នុង មាត្រា ១៣៧-២ និង មាត្រា ១៣៧-៥ ខាងលើ។

## ផ្នែកទី៤
## ការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិ

### មាត្រា១៣៨._ ការចាប់ផ្តើមធ្វើការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិ

សម្រាប់សហកម្មសិទ្ធិដែលមានស្រាប់ ការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិត្រូវអនុវត្តក្រោយការចុះបញ្ជីដីដែលសហកម្មសិទ្ធិនោះតាំងនៅជាដីសហកម្មសិទ្ធិ។

សម្រាប់សហកម្មសិទ្ធិដែលទើបអភិវឌ្ឍថ្មី ការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិអាចអនុវត្តដំណាលគ្នាឬក្រោយការចុះបញ្ជីដីសហកម្មសិទ្ធិ ប៉ុន្តែត្រូវធ្វើមុនពេលចំណែកឯកជនដំបូងត្រូវបានលក់ចេញ។ ក្នុងករណីនេះ រដ្ឋបាលសុរិយោដីអាចអនុវត្តការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិនោះ ដោយដាក់អ្នកអភិវឌ្ឍសហកម្មសិទ្ធិនោះជាម្ចាស់នៃចំណែកឯកជនបាន។

**យោបល់៖** មិនមានយោបល់

## មាត្រា១៣៩._ ក្បាលដីសហកម្មសិទ្ធិ

ដើម្បីធ្វើការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិ ក្បាលដីដែលសហកម្មសិទ្ធិនោះតាំងនៅត្រូវតែបានចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ជាទ្រព្យអវិភាគរបស់សហកម្មសិទ្ធិករទាំងអស់ជាមុនសិន។

សម្រាប់សហកម្មសិទ្ធិដែលមានស្រាប់ រដ្ឋបាលសុរិយោដីត្រូវធ្វើការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ជាទ្រព្យអវិភាគរបស់សហកម្មសិទ្ធិករទាំងអស់ មុននឹងធ្វើការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិនោះ។

សម្រាប់សហកម្មសិទ្ធិដែលទើបអភិវឌ្ឍថ្មី រដ្ឋបាលសុរិយោដីត្រូវធ្វើការចុះបញ្ជីអំពីការប្តូរក្បាលដីដើមដែលសហកម្មសិទ្ធិនោះតាំងនៅ ជាទ្រព្យអវិភាគរបស់សហកម្មសិទ្ធិករទាំងអស់នៃសហកម្មសិទ្ធិដែលតាំងនៅលើដីនោះ មុននឹងធ្វើការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិនោះ។

រាល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៃក្បាលដីសហកម្មសិទ្ធិ ត្រូវតម្កល់ទុកនៅរដ្ឋបាលសុរិយោដី។

**យោបល់៖** មិនមានយោបល់

## មាត្រា១៤០._ ទំហំ ព្រំប្រទល់ និងមុខងារប្រើប្រាស់នៃចំណែកឯកជននៃសហកម្មសិទ្ធិ

ការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិអាចអនុវត្តទៅបានលុះត្រាតែចំណែករួមនិងចំណែកឯកជនទាំងអស់នៃសហកម្មសិទ្ធិនោះត្រូវបានកំណត់ទំហំ ព្រំប្រទល់ និងមុខងារប្រើប្រាស់ច្បាស់លាស់រួចហើយ។

សម្រាប់សហកម្មសិទ្ធិដែលមានស្រាប់ ទំហំ និងព្រំប្រទល់នៃចំណែកឯកជននៃសហកម្មសិទ្ធិត្រូវកំណត់ក្នុងបទបញ្ញាផ្ទៃក្នុងនៃសហកម្មសិទ្ធិនោះ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចអំពីទំហំ និងព្រំប្រទល់នៃចំណែកឯកជននៃសហកម្មសិទ្ធិដែលមានស្រាប់ ក្នុងករណីសហកម្មសិទ្ធិករមិនអាចរកឃើញការឯកភាពគ្នា។

ទំហំ ព្រំប្រទល់ និងមុខងារប្រើប្រាស់នៃចំណែកឯកជននៃសហកម្មសិទ្ធិត្រូវកំណត់តាមគម្រោងប្លង់ស្ថាបត្យកម្ម និង/ឬគម្រោងប្លង់អភិវឌ្ឍនគរូបនីយកម្មដែលបានទទួលការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច។

វិធីសាស្ត្រនៃការវាស់វែងនិងកំណត់ទំហំនិងព្រំប្រទល់នៃចំណែកឯកជននៃសហកម្មសិទ្ធិត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** មិនមានយោបល់

### មាត្រា១៤១._ វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃសហកម្មសិទ្ធិ

វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃសហកម្មសិទ្ធិ ត្រូវកំណត់អំពីប្រភេទ ទំហំ និងមុខងារប្រើប្រាស់នៃចំណែកឯកជននោះ។

**យោបល់៖** មិនមានយោបល់

### មាត្រា១៤២._ ការបំបែកក្បាលដីសហកម្មសិទ្ធិ

សហកម្មសិទ្ធិករអាចបំបែកក្បាលដីសហកម្មសិទ្ធិបានស្របតាមលក្ខខណ្ឌនិងនីតិវិធីដូចមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃសហកម្មសិទ្ធិ ប៉ុន្តែមិនត្រូវបំពានសិទ្ធិរបស់តតិយជនឡើយ។ ការបំបែកក្បាលដីសហកម្មសិទ្ធិនេះត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច និងអនុលោមតាមបទប្បញ្ញត្តិស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**យោបល់៖** គួរចែងបញ្ជាក់ថានរណាជាអាជ្ញាធរមានសមត្ថកិច្ច សម្រាប់កិច្ចការនេះ។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៤៣._ ការបំបែកក្បាលដីសហកម្មសិទ្ធិក្នុងករណីមានការដកហូតដើម្បីផលប្រយោជន៍សាធារណៈ

ក្នុងករណីមានការដកហូតកម្មសិទ្ធិមួយផ្នែកលើដីសហកម្មសិទ្ធិដើម្បីផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ សហកម្មសិទ្ធិករត្រូវស្នើសុំបំបែកក្បាលដីសហកម្មសិទ្ធិមួយផ្នែក ហើយធ្វើអនុប្បទានក្បាលដីថ្មីនោះឱ្យរដ្ឋឬនីតិបុគ្គលសាធារណៈដទៃទៀតដាច់ដោយឡែកពីចំណែកឯកជន។

លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិ ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** ជំនួសឱ្យការស្នើសុំបំបែកក្បាលដីដោយសហកម្មសិទ្ធិករ គួរតែឱ្យរដ្ឋជាអ្នកស្នើសុំ ចេញរាល់ចំណាយ និងតម្រូវឱ្យសហកម្មសិទ្ធិករត្រូវតែយល់ព្រមចំពោះការស្នើសុំបំបែកក្បាលដីនោះ ឬអាចសុំឱ្យតុលាការបង្គាប់ឱ្យបំបែកក្បាលដីដោយបង្ខំករណីមិនអាចទទួលបានការយល់ព្រមពីរាល់សហកម្មសិទ្ធិករទាំងអស់ក្នុងរយៈពេលសមស្រប។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## ផ្នែកទី៥
## ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

**មាត្រា១៤៤._ សិទ្ធិស្នើសុំចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច**

មានតែសហគមន៍ជនជាតិដើមភាគតិចដែលត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការជានីតិបុគ្គលរួចរាល់ ទើបអាចដាក់ពាក្យសុំចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាពបាន។

**យោបល់៖** សូមមើលយោបល់ក្នុងមាត្រា ១២ មាត្រា ៣៦ និងមាត្រា ៣៧។

**មាត្រា១៤៥._ គោលការណ៍នៃការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច**

ដីសហគមន៍ជនជាតិដើមភាគតិច ត្រូវចុះបញ្ជីដីទាំងអស់របស់សហគមន៍មួយជាកម្មសិទ្ធិសមូហភាពទៅក្នុងប្លង់រួមតែមួយ ទោះបីក្បាលដីទាំងនោះស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលខុសគ្នាក៏ដោយ។

វិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពដែលត្រូវចេញជូនសហគមន៍ ត្រូវបញ្ជាក់ឈ្មោះសហគមន៍ ទីតាំងសហគមន៍ លេខយោងទៅរកប្លង់រួមដែលចង្អុលបង្ហាញនូវទីតាំង ទំហំ ព្រំប្រទល់ និយាមកានៃចំណែកដីដែលជាកម្មសិទ្ធិសមូហភាព និងមានបញ្ជាក់ប្រភេទដី ប្រភេទនៃការប្រើប្រាស់ដី និងកំណត់សម្គាល់ផ្សេងៗ។

**យោបល់៖** ក្នុងកថាខណ្ឌទី១ គួរលុបពាក្យថា ដីទាំងអស់ ហើយជំនួសដោយពាក្យ ដីនីមួយៗ ហើយ ប្លង់រួមនៃក្បាលដីទាំងឡាយរបស់សហគមន៍ជនជាតិដើមភាគតិច មួយត្រូវកសាងជាដំណាក់កាលស្របតាមលទ្ធផលនៃការចុះ បញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិចនោះ។ សូមមើលយោបល់ក្នុងមាត្រា ៣៦ មាត្រា ៣៧ និងមាត្រា ៤០ ផង។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៤៦._ ដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច**

ដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចមាន៖

១. ដីឯកជនរបស់រដ្ឋ ដូចជា៖

- ដីលំនៅឋានឬដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន
- ដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណីមានដីដាំដុះដាក់ស្លែងនិងដីស្រែចម្ការ។

២. ដីសាធារណៈរបស់រដ្ឋដែលបានចុះបញ្ជីរួចហើយ ដូចជា៖

- ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ ដែលបានទទួលស្គាល់ដោយអាជ្ញាធរដែនដី និងមានការព្រមព្រៀងពីអ្នកជិតខាងច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ
- ដីព្រៃអារក្សដែលអាចមានមួយកន្លែងឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ
- ដីកប់សពដែលអាចមានមួយកន្លែងឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ។

ទំហំសរុបអតិបរិមានៃដីព្រៃអារក្សនិងដីកប់សពដែលអាចចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** គួរជំនួសពាក្យ កសិកម្មប្រពៃណី ដោយ កសិកម្ម ព្រោះគោលដៅសំខាន់នៃការរក្សាកម្មសិទ្ធិសមូហភាពមិនមែនដើមចងខ្លួនភ្ជាប់ទៅនឹងរបៀបធ្វើកសិកម្មបែបប្រពៃណី ដោយកម្លាំងមនុស្ស និងការដុះព្រៃដើម្បីដាំដំណាំនោះទេ។ គួរបញ្ចូលផងដែរនូវ ដីសម្រាប់ដូរវេនដំណាំចំការវិលជុំ ដីបម្រុងទុកយ៉ាងតិច ១០% នៃដីលំនៅដ្ឋាន និងដីដាំដុះអចិន្ត្រៃយ៍ ប្រភេទដីបេតិកភណ្ឌវប្បធម៌ និងធម្មជាតិរបស់ជនជាតិដើមភាគតិច ដីព្រៃឈើសហគមន៍ កន្លែងប្រើប្រាស់ទឹក វាលស្មៅចិញ្ចឹមសត្វ កន្លែងផ្តល់សេវាសហគមន៍ ដីផ្លូវក្នុងសហគមន៍ដែលទុកសម្រាប់តែការប្រើប្រាស់សមាជិកសហគមន៍ និងអាជ្ញាធរមានសមត្ថកិច្ចដែលមានសិទ្ធិ ឬទទួលបានការអនុញ្ញាតឱ្យចេញចូលសហគមន៍។ លើសពីនេះទំហំដីប្រភេទនីមួយៗ ត្រូវកំណត់តាមស្ថានភាពប្រើប្រាស់ និងតម្រូវការជាក់ស្តែង និងតម្រូវការរបស់សហគមន៍ក្នុងអំឡុង ២០ឆ្នាំខាងមុខ ហើយមិនត្រូវមានការចេញបទដ្ឋានគតិយុត្តិកម្រិតទំហំដីណាមួយឡើយ។ រាល់បទដ្ឋានគតិយុត្តដែលកម្រិតទំហំដីរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវអស់សុពលភាពអនុវត្ត។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៤៧._ **បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍**ជនជាតិដើមភាគតិច

សហគមន៍ជនជាតិដើមភាគតិចដែលដាក់ពាក្យសុំចុះបញ្ជីដីសហគមន៍ ត្រូវមានបទបញ្ជាផ្ទៃក្នុងដែលចែងអំពីការគ្រប់គ្រងនិងការប្រើប្រាស់ដីជាសមូហភាព ព្រមទាំងការកំណត់នូវលក្ខខណ្ឌមួយចំនួន មានជាអាទិ៍ ការចាត់ចែងដីជាសមូហភាព ការប្រើប្រាស់ដីទៅតាមប្រភេទដី និងការសម្រុះសម្រួលកម្រិតសហគមន៍ក្នុងករណីវិវាទលើការប្រើប្រាស់ដីតាមបែបប្រពៃណី។

គំរូបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិចដែលដាក់ពាក្យសុំចុះបញ្ជីដីសហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** គួរចែងថាជនជាតិដើមភាគតិច មានសិទ្ធិរៀបចំចងក្រងសហគមន៍ជនជាតិដើមភាគតិច ដោយមិនចំណុះឱ្យតំបន់រដ្ឋបាលណាមួយឡើយ ហើយត្រូវរៀបចំលក្ខន្តិកៈសហគមន៍ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ ជាភាសាជនជាតិដើមភាគតិច ឬភាសាខ្មែរ តាមឆន្ទៈ និងស្វ័យភាពរបស់ពួកគេ ដោយមិនចំណុះលក្ខខណ្ឌទម្រង់ និងភាសាដែលកំណត់ដាក់ចេញ ឬណែនាំដោយក្រសួងស្ថាប័នណាមួយឡើយ ប៉ុន្តែដើម្បីអាចចុះបញ្ជីជានីតិបុគ្គល និងមានការទទួលស្គាល់នូវសញ្ញាតិរបស់សហគមន៍ជនជាតិដើមភាគតិចបាន លក្ខន្តិកៈសហគមន៍ត្រូវមានខ្លឹមសារតម្រូវជាអប្បបរមាកំណត់ដោយក្រសួងមហាផ្ទៃ ហើយមានការបកប្រែជាភាសាខ្មែរសម្រាប់កិច្ចសម្របសម្រួលផ្នែករដ្ឋបាល។ គួរកំណត់ថា ហើយការបែងចែកឱ្យប្រើប្រាស់ ការកែប្រែ ឬការដកយកមកវិញនូវដី ឬអចលនវត្ថុណាដែលគ្រប់គ្រងដោយសហគមន៍ ព្រមទាំងការផ្តល់សំណងចំពោះការវិនិយោគលើដី ឬអចលនវត្ថុដែលគ្រប់គ្រងដោយសហគមន៍ ត្រូវអនុវត្តតាមការកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងច្បាប់ដើមរបស់សហគមន៍។ ការចុះបញ្ជីដី និងអចលនវត្ថុដទៃទៀតរបស់សហគមន៍ គឺដើម្បីបង្កើនសុវត្ថិភាពនៃការកាន់កាប់ និងមានអានុភាពតតាំងជាមួយតតីយជន និងជាមួយរដ្ឋបាលសាធារណៈ រួមទាំងអាជ្ញាធរកាន់កាប់ទ្រព្យរដ្ឋផងដែរ ប៉ុន្តែការមិនទាន់បានចុះបញ្ជីដី ឬអចលនវត្ថុណាដែលគ្រប់គ្រងដោយសហគមន៍ មិនប៉ះពាល់ដល់សិទ្ធិរបស់សហគមន៍ក្នុងការគ្រប់គ្រង កិច្ចការផ្ទៃក្នុងរបស់សហគមន៍ឡើយ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៤៨._ លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីសហគមន៍**ជនជាតិដើមភាគតិច

ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ត្រូវធ្វើឡើងនៅរដ្ឋបាលសុរិយោដី តាមសំណើរបស់ប្រធានគណៈកម្មការឬអាជ្ញាធរប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច។

ការវាស់វែងនិងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែងដូចដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាង។

លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** សូមលុបឃ្លា ដោយមានការព្រមព្រៀងពីអ្នកជិតខាង ក្នុងកថាខណ្ឌទី២ ចេញ ព្រោះវាអាចនាំឱ្យជាប់គាំងរហូត ប្រសិនបើអ្នកជិតខាងមិនយល់ព្រម។ ក្នុងករណីមានវិវាទជាមួយអ្នកជិតខាង ឬអាជ្ញាធរកាន់កាប់ដីរដ្ឋក្នុងតំបន់សហគមន៍ គួរប្រើយន្តការដែលផ្តល់យោបល់ក្នុងមាត្រា ៣៦។ គួរកំណត់ថា ការចុះបញ្ជីដី និងអចលនវត្ថុដទៃទៀតរបស់សហគមន៍ គឺដើម្បីបង្កើនសុវត្ថិភាពនៃការកាន់កាប់ និងមានអានុភាពតតាំងជាមួយតតីយជន និងជាមួយរដ្ឋបាលសាធារណៈ រួមទាំងអាជ្ញាធរកាន់កាប់ទ្រព្យរដ្ឋផងដែរ ប៉ុន្តែការមិនទាន់បានចុះបញ្ជីដី ឬអចលនវត្ថុណាដែលគ្រប់គ្រងដោយសហគមន៍ មិនប៉ះពាល់ដល់សិទ្ធិរបស់

សហគមន៍ក្នុងការគ្រប់គ្រងកិច្ចការផ្ទៃក្នុងរបស់សហគមន៍ឡើយ។ គួរចែងឱ្យមាននីតិវិធីទន់ភ្លន់ និងឆាប់រហ័សសម្រាប់កំណត់ព្រំប្រទល់ វាស់វែង វិនិច្ឆ័យ និងចុះបញ្ជីដីដែលទាមទារដោយសហគមន៍ជនជាតិដើមភាគតិច ដោយអនុវត្តតាមអភិក្រមដែលថា ក្បាលដីដែលគ្មានវិវាទ ឬដែលបានដោះស្រាយវិវាទចប់ជាស្ថាពរ ចុះបញ្ជីក្បាលដីនោះ និងចេញបណ្ណឱ្យភ្លាម។ ប្លង់រួមក្បាលដីរបស់សហគមន៍អាចកសាងជាសន្សឹមៗ ហើយមិនចាំបាច់ចំណុះឱ្យភូមិសាស្ត្រ រដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

ផ្នែកទី៦

អានុភាពនៃការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

**មាត្រា១៤៩. អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិប្តឹងតវ៉ាចំពោះការចុះបញ្ជី**

អាជ្ញាយុកាលនៃការរំលត់សិទ្ធិប្តឹងតវ៉ាចំពោះការចុះបញ្ជីមានអំឡុងពេល ១០(ដប់)ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជី។

បញ្ញត្តិនៃកថាខណ្ឌខាងលើ មិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីដែលការចុះបញ្ជីរំលោភបំពានលើដីសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត។

**យោបល់៖** តាមគោលការណ៍កម្មសិទ្ធិធានាដោយរដ្ឋ ការទទួលបានកម្មសិទ្ធិតាមរយៈការចុះបញ្ជី និងការការពារតតីយជនសុចរិតឥតកំហុស គួរតែកម្រិតនូវការបើកសិទ្ធិឱ្យប្តឹងតវ៉ាទាមទារកម្មសិទ្ធិក្រោយពីបញ្ចប់យ៉ាងត្រឹមត្រូវនូវនីតិវិធីចុះបញ្ជីដីធ្លីដែលមានតម្លាភាព ការចូលរួមច្បាស់លាស់ ពេញលេញ សមធម៌ និងប្រសិទ្ធភាព។ ទាំងភាគីរដ្ឋនិងភាគីឯកជន គួរតែគោរពគោលការណ៍ដូចគ្នា ហើយអ្នកដែលបាត់បង់សិទ្ធិដោយសារកំហុសចេតនារបស់ភាគីផ្សេងទៀតអាចប្តឹងទាមទារសំណងការខូចខាតពីភាគីប្រព្រឹត្តកំហុស ហើយមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់តតីយជនសុចរិតឥតកំហុសឡើយ។ ដូច្នេះគួរលុបចោលមាត្រា ១៤៩ នេះ ឬចែងអំឡុងពេលអាជ្ញាយុកាលឱ្យដូចគ្នា ប៉ុន្តែមិនត្រូវវែងជាងអំឡុងពេលសម្រាប់លទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាល ដែលស្នើឱ្យអនុវត្តដូចគ្នាចំពោះកម្មសិទ្ធិឯកជន និងកម្មសិទ្ធិសាធារណៈលើអចលនវត្ថុដែលបានចុះបញ្ជីកម្មសិទ្ធិរួចហើយ។ រាល់ការប្តឹងតវ៉ា ឬជំទាស់ចំពោះការចុះបញ្ជីអចលនវត្ថុណាមួយ ត្រូវតែធ្វើក្នុងអំឡុងពេលដែលបើកឱ្យប្តឹងតវ៉ា ឬជំទាស់ កំណត់ក្នុងនីតិវិធីចុះបញ្ជីដីធ្លី។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១៥០._ ការកាន់កាប់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

~~មានតែម្ចាស់អចលនវត្ថុប៉ុណ្ណោះទើបមានសិទ្ធិកាប់កាប់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ខ្លួន។~~

~~រដ្ឋបាលសុរិយោដីទទួលបន្ទុករក្សាទុកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ តាមការកំណត់របស់ច្បាប់នេះ និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ។~~

~~តាមសំណើរបស់ម្ចាស់អចលនវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសិទ្ធិបង្គាប់ឱ្យអ្នកកាន់កាប់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ខ្លួនឱ្យប្រគល់មករដ្ឋបាលសុរិយោដី។ ក្នុងករណីអ្នកកាន់កាប់មិនប្រគល់ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតបង្គាប់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវប្រកាសថាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុបានបាត់និងបញ្ជាឱ្យរដ្ឋបាលសុរិយោដីអនុវត្តនីតិវិធីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មីជូនម្ចាស់អចលនវត្ថុ។~~

## មាត្រា១៥១._ ការកែតម្រូវការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

បន្ទាប់ពីទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ម្ចាស់អចលនវត្ថុអាចស្នើសុំមករដ្ឋបាលសុរិយោដីដើម្បីធ្វើការកែតម្រូវចំណុចដែលបានចុះបញ្ជីក្នុងពេលអនុវត្តនីតិវិធីចុះបញ្ជីដីធ្លីដំបូង។

រដ្ឋបាលសុរិយោដីត្រូវធ្វើការកែតម្រូវការចុះបញ្ជីតាមសំណើរបស់ម្ចាស់អចលនវត្ថុក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

លក្ខខណ្ឌនិងនិតិវិធីនៃការកែតម្រូវការចុះបញ្ជីដីធ្លីដំបូង ត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** គួរចែងថារាល់ការកែតម្រូវ មិនត្រូវប៉ះពាល់ដល់សិទ្ធិរបស់តតីយជនឡើយ លើកលែងតែផ្អែកតាមសេចក្តីសម្រេចស្ថាពររបស់តុលាការមានសមត្ថកិច្ច។ សូមមើលយោបល់ ក្នុងមាត្រា ១៤៩ ផង។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១៥២._ ការដកហូតវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

~~ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃដែលម្ចាស់អចលនវត្ថុបានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុពីរដ្ឋបាលសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចសម្រេចដកហូតវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រឡប់មកវិញក្នុងករណីដែលនីតិវិធីនៃចុះបញ្ជីនិ~~

~~ងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ត្រូវបានរំលោភធ្ងន់ធ្ងរ។ ក្នុងករណីនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបង្គាប់ឱ្យអ្នកកាន់កាប់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលត្រូវបានប្រកាសដកហូតប្រគល់មករដ្ឋបាលសុរិយោដីដើម្បីបោះត្រាទុកជាមោឃៈ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចាត់ចែងរដ្ឋបាលសុរិយោដីរាជធានី ខេត្តដែលពាក់ព័ន្ធ ឱ្យចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មីតាមការសម្រេចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។~~

~~ក្នុងករណីអ្នកកាន់កាប់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុមិនប្រគល់ត្រឡប់មករដ្ឋបាលសុរិយោដីរាជធានី ខេត្តដែលពាក់ព័ន្ធ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹងអំពីការប្រកាសដកហូតដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋបាលសុរិយោដីរាជធានី ខេត្តដែលពាក់ព័ន្ធត្រូវចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មីតាមការសម្រេចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្សព្វផ្សាយនៅទូទាំងប្រទេសអំពីការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មីនោះ។~~

### មាត្រា១៥២._ ការបង្កើតនិងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី (មាត្រា១០៦)

ត្រូវបានបង្កើតគណៈកម្មការសុរិយោដីដើម្បីដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ទាំងវិវាទដែលកើតនៅក្រៅតំបន់វិនិច្ឆ័យ ទាំងវិវាទដែលកើតនៅក្នុងតំបន់វិនិច្ឆ័យនិងដែលមិនអាចសម្រុះសម្រួលបានដោយមន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យ។

**យោបល់៖** គួរបញ្ចូល គណៈកម្មការរដ្ឋបាល នៃតំបន់វិនិច្ឆ័យ ដែលមានភារកិច្ចសម្រុះសម្រួលវិវាទក្នុងពេលបិទផ្សាយជាសាធារណៈនូវឯកសារវិនិច្ឆ័យផង។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៥២.១_ រចនាសម្ព័ន្ធនៃគណៈកម្មការសុរិយោដី (មាត្រា១០៧)

គណៈកម្មការសុរិយោដីមានរចនាសម្ព័ន្ធដូចខាងក្រោម៖

១- គណៈកម្មការសុរិយោដីថ្នាក់ជាតិ

២- គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត

៣- គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីត្រូវកំណត់ដោយអនុក្រឹត្យ។

**យោបល់៖** មិនមានយោបល់

### មាត្រា១៥២.២_ ការទាមទារសិទ្ធិលើដីសាធារណៈរបស់រដ្ឋឬនីតិបុគ្គលសាធារណៈដទៃទៀត (១០៩)

ក្នុងករណីមានបណ្តឹងទាមទារសិទ្ធិលើដីសាធារណៈរបស់រដ្ឋឬនីតិបុគ្គលសាធារណៈដទៃទៀតគណៈកម្មការសុរិយោដីត្រូវបដិសេធសិទ្ធិកាន់កាប់ដីនោះ។

ក្នុងករណីភាគីម្ខាងជារដ្ឋឬនីតិបុគ្គលសាធារណៈដទៃទៀត គណៈកម្មការសុរិយោដីត្រូវសម្រេចទទួលស្គាល់ជាកម្មសិទ្ធិរបស់រដ្ឋឬនីតិបុគ្គលសាធារណៈដទៃទៀត ហើយអាជ្ញាធរសាធារណៈត្រូវគ្រប់គ្រងថែរក្សាដីនោះ។

**យោបល់៖** គួរលុបមាត្រានេះចោល ព្រោះកាលណាដីមិនទាន់ចុះបញ្ជីកម្មសិទ្ធិ មិនអាចសន្និដ្ឋានថាដីនោះពិតជាដីរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈ ដែលគ្មានបន្ទុកភោគៈស្របច្បាប់ ឬបន្ទុកសិទ្ធិប្រត្យក្សផ្សេងទៀតបានឡើយ។ ការចែងយ៉ាងលម្អៀងបែបនេះ មិនគួរផ្តល់សមត្ថកិច្ចឱ្យគណៈកម្មការសុរិយោដី ដោះស្រាយវិវាទពាក់ព័ន្ធដីដែលគ្រប់គ្រង ឬអះអាងទាមទារដោយអាជ្ញាធរកាន់កាប់ដីរដ្ឋឡើយ ហើយគួរតែទុកវិវាទប្រភេទនេះជូនតុលាការសម្រេចដោយ ឯករាជ្យផ្អែកតាមច្បាប់ និងនីតិវិធីជាធរមាន។

**សំណើលុបចោល៖** សូមលុបចោលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៥២.៣_ វិវាទរវាងភោគីចំពោះអចលនវត្ថុដែលមិនទាន់ត្រូវបានចុះបញ្ជី (មាត្រា ១១០)

វិវាទរវាងភោគីចំពោះអចលនវត្ថុដែលមិនទាន់ត្រូវបានចុះបញ្ជី ត្រូវដាក់ឱ្យធ្វើការស៊ើបអង្កេតនិងដោះស្រាយដោយគណៈកម្មការសុរិយោដី។

**យោបល់៖** មិនមានយោបល់

### មាត្រា១៥២.៤_ ការដោះស្រាយវិវាទនៅក្នុងតំបន់វិនិច្ឆ័យ

គណៈកម្មការសុរិយោដីថ្នាក់ជាតិមានរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារវិវាទដែលមិនអាចដោះស្រាយពីគណៈកម្មការរដ្ឋបាលសម្រេចទទួលស្គាល់ភោគីឬកម្មសិទ្ធិករស្របច្បាប់។

ក្នុងការធ្វើសេចក្តីបុគ្គលដែលមិនយល់ព្រមតាមសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទមានសិទ្ធិប្តឹងទៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញ/
តុលាការកំពូលក្នុងរយៈពេល៣០(សាមសិបថ្ងៃ)គិតចាប់ថ្ងៃទទួលបានសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។

**យោបល់៖** គួរលុបតុលាការកំពូលចេញពីក្នុងកថាខណ្ឌទី២នៃមាត្រានេះ ហើយអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី។ មិនអាចចែងឱ្យប្តឹងទៅតុលាការកំពូលដោយផ្ទាល់ ដោយមិនឆ្លងកាត់សាលាឧទ្ធរណ៍ទេ។ ដំណើរការបែបនេះធាប់ហ័សដោយមិនចាំបាច់ទៅសាលាតំបូង គឺប្តឹងទៅសាលាឧទ្ធរណ៍ រួចអាចបន្តទៅតុលាការកំពូល។ សូមលុបរាជធានីភ្នំពេញចេញ ដោយហេតុថា បច្ចុប្បន្ននេះមានសាលាឧទ្ធរណ៍បួនហើយដែលទទួលការប្តឹងតវ៉ាតាមខេត្តផ្សេងៗតាមតំបន់ និងស្នើលុបចេញ ដោយដាក់ថា អាចបន្តទៅតុលាការកំពូល។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៥២.៥_ ការដោះស្រាយវិវាទនៅក្រៅតំបន់វិនិច្ឆ័យ

គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើ ការគិតចាប់ពីថ្ងៃទទួលពាក្យសុំតវ៉ាពីបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធនឹងក្បាលដីនៅក្រៅតំបន់វិនិច្ឆ័យដើម្បីធ្វើការសម្របសម្រួលរវាងរាល់ភាគីដែលមានការពាក់ព័ន្ធ។ ក្នុងករណីអាចសម្រុះសម្រួល គ្នាបាន គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវធ្វើកំណត់ហេតុបញ្ចប់វិវាទនិងបញ្ជូនទៅរដ្ឋបាល សុរិយោដីដើម្បីចុះបញ្ជីដីដែលលែងជាកម្មវត្ថុនៃវិវាទ។ ក្នុងករណីមិនអាចសម្រុះសម្រួលគ្នាបាន និង ផុតរយៈពេលនេះ គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបញ្ជូនសំណុំឯកសារនៃការដាក់ ពាក្យសុំតវ៉ាទៅគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត។

គណៈកម្មការសុរិយោដីថ្នាក់រាជធានី
ខេត្តមានរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលសំណុំឯកសារនៃការដាក់ពាក្យសុំតវ៉ាពីគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការសម្របសម្រួលរវាងរាល់ភាគីដែលមានការពាក់ព័ន្ធ។ ក្នុងករណីអាចសម្រុះសម្រួលគ្នាបាន គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវធ្វើកំណត់ ហេតុបញ្ចប់វិវាទនិងបញ្ជូនទៅរដ្ឋបាល សុរិយោដីដើម្បីចុះបញ្ជីដីដែលលែងជាកម្មវត្ថុនៃវិវាទ។ ក្នុងករណីមិនអាចសម្រុះសម្រួលគ្នាបាន និង ផុតរយៈពេលនេះ គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្តត្រូវបញ្ជូនសំណុំឯកសារនៃការដាក់ពាក្យសុំតវ៉ាទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិមានរយៈពេលយ៉ាងយូរ៦០(ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពី ថ្ងៃទទួលសំណុំឯកសារនៃការដាក់ពាក្យសុំតវ៉ាពីគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចទទួលស្គាល់ភោគីឬកម្មសិទ្ធិករស្របច្បាប់។

បុគ្គលដែលមិនយល់ព្រមតាមសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទ មានសិទ្ធិប្តឹងទៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញ/ តុលាការកំពូលក្នុងរយៈពេល ៣០(សាមសិបថ្ងៃ)គិតចាប់ថ្ងៃទទួលបានសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។

**យោបល់៖** គួរលុបតុលាការកំពូលចេញពីក្នុងកថាខណ្ឌទី៤ នៃមាត្រានេះ ហើយអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី។ មិនអាចថែងឱ្យប្តឹងទៅតុលាការកំពូលដោយផ្ទាល់ ដោយមិនឆ្លងកាត់សាលាឧទ្ធរណ៍ទេ។ ដំណើរការបែបនេះអាចធាប់រហ័សជាង ដោយមិនចាំបាច់ទៅសាលាដំបូង គឺប្តឹងទៅសាលាឧទ្ធរណ៍ រួចអាចបន្តទៅតុលាការកំពូល។ សូមលុបរាជធានីភ្នំពេញចេញ ដោយហេតុថា បច្ចុប្បន្ននេះមានសាលាឧទ្ធរណ៍បួនហើយដែលទទួលការប្តឹងតវ៉ាតាមខេត្តផ្សេងៗដែលបែងចែកតាមតំបន់ និងស្នើលុបចេញដោយដាក់ថា អាចបន្តទៅតុលាការកំពូល។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

# ជំពូកទី៣
# ការចុះបញ្ជីបន្ត
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១៥៣._ គោលបំណង

ជំពូកនេះបញ្ញត្តអំពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិលើអចលនវត្ថុដែលត្រូវបានចុះបញ្ជីរួចហើយ។

**យោបល់៖** មិនមានយោបល់

### មាត្រា១៥៤._ វិសាលភាព

ជំពូកនេះ មានវិសាលភាពអនុវត្តចំពោះការចុះបញ្ជីដូចខាងក្រោម៖

- ការផ្ទេរ ការផ្លាស់ប្តូរ ការកម្រិតការចាត់ចែង និងការរលត់កម្មសិទ្ធិ
- ការបង្កើត ការផ្ទេរ ការផ្លាស់ប្តូរ ការកម្រិតការចាត់ចែង និងការរលត់សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិលើការបញ្ចាំ និងហ៊ីប៉ូតែក
- ការបង្កើត ការផ្លាស់ប្តូរ ការកម្រិតការចាត់ចែង និងការរលត់សេវភាព
- ការរក្សាទុក ការផ្ទេរ ការផ្លាស់ប្តូរ ការកម្រិតការចាត់ចែង និងការរលត់ឯកសិទ្ធិ

- ការបង្កើត ការផ្ទេរ ការផ្លាស់ប្តូរ ការកម្រិតការចាត់ចែង និងការរលត់សិទ្ធិសម្បទានដី។

**យោបល់៖** មិនមានយោបល់

## មាត្រា១៥៥._ ស្ថាប័នមានសមត្ថកិច្ច

រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្តដែលអចលនវត្ថុតាំងនៅ ជាស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីអចលនវត្ថុដែលត្រូវបានចុះបញ្ជីរួចហើយ។

**យោបល់៖** គួរថា ជាស្ថាប័នសមត្ថកិច្ច ចុះបញ្ជី**បន្ត** ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី**លើកដំបូង**រួចហើយ។
**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១៥៦._ លំដាប់នៃការធ្វើនីតិវិធីចុះបញ្ជី

នៅពេលរដ្ឋបាលសុរិយោដីទទួលការស្នើសុំចុះបញ្ជី ការផ្ទុកផ្តាក់ឱ្យចុះបញ្ជី ឬការជូនដំណឹងឱ្យចុះបញ្ជី រដ្ឋបាលសុរិយោដីនោះត្រូវចុះលេខរៀងនៃការទទួលការស្នើសុំ។

លេខរៀងនៃការទទួលការស្នើសុំដែលបានកំណត់នៅក្នុងកថាខណ្ឌខាងលើនេះ ត្រូវកំណត់ដោយអនុលោមតាមលំដាប់នៃការទទួលការស្នើសុំចុះបញ្ជី ការផ្ទុកផ្តាក់ឱ្យចុះបញ្ជី និងការជូនដំណឹងឱ្យចុះបញ្ជីនៅរដ្ឋបាលសុរិយោដី។

ក្នុងករណីដែលមានការស្នើសុំចុះបញ្ជីទៅលើអចលនវត្ថុតែមួយ ការផ្ទុកផ្តាក់ច្រើនឱ្យចុះបញ្ជីទៅលើអចលនវត្ថុតែមួយ ឬការជូនដំណឹងច្រើនឱ្យចុះបញ្ជីទៅលើអចលនវត្ថុតែមួយ រដ្ឋបាលសុរិយោដីត្រូវធ្វើនីតិវិធីចុះបញ្ជីទៅតាមលំដាប់លេខរៀងនៃការទទួលការស្នើសុំចុះបញ្ជី ការផ្ទុកផ្តាក់ឱ្យចុះបញ្ជី និងការជូនដំណឹងឱ្យចុះបញ្ជីនោះ។

**យោបល់៖** មិនមានយោបល់

## មាត្រា១៥៧._ លំដាប់អាទិភាពនៃសិទ្ធិ

លំដាប់អាទិភាពនៃសិទ្ធិលើអចលនវត្ថុតែមួយត្រូវអនុលោមតាមលំដាប់នៃការចុះបញ្ជី លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ផ្សេងទៀត។

លំដាប់អាទិភាពនៃការចុះបញ្ជីបន្ថែម ត្រូវអនុលោមតាមលំដាប់នៃការចុះបញ្ជីចម្បង។

លំដាប់អាទិភាពនៃការចុះបញ្ជីបន្ថែមនីមួយៗ ហើយដែលស្ថិតនៅក្នុងការចុះបញ្ជីចម្បងតែមួយ ត្រូវអនុលោមតាមលំដាប់នៃការចុះបញ្ជីបន្ថែមនោះ។

**យោបល់៖** គួរលុបពាក្យ ហើយ ក្នុងកថាខណ្ឌទី៣ នៃមាត្រានេះ។
**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៥៨._ ការផ្តល់អាណត្តិឱ្យទៅលិខិតបទដ្ឋានគិយុត្ត

ក្រៅពីចំណុចដែលមានកំណត់ក្នុងផ្នែកនេះ ចំណុចដែលចាំបាច់ផ្សេងទៀតពាក់ព័ន្ធនឹងកិច្ចការចុះបញ្ជីបន្ត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** គួរកែសម្រួលចំណងជើងនៃមាត្រានេះ ទៅជា ការផ្តល់អាណត្តិឱ្យចេញបទដ្ឋានគតិយុត្ត។
**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៥៩._ សិទ្ធិក្នុងការចុះបញ្ជីអំពីការកែប្រែព័ត៌មាននិងទិន្នន័យនៃក្បាលដី

រដ្ឋបាលសុរិយោដីអាចចុះបញ្ជីអំពីការកែប្រែព័ត៌មាននិងទិន្នន័យនៃក្បាលដីក្នុងករណីដូចខាងក្រោម៖

១. មានសំណើសុំចុះបញ្ជីរបស់ម្ចាស់សិទ្ធិ អ្នកមានសិទ្ធិចុះបញ្ជី និងអ្នកមានកាតព្វកិច្ចចុះបញ្ជីដោយមានភស្តុតាងច្បាស់លាស់បញ្ជាក់អំពីមូលហេតុដែលនាំឱ្យមានការកែប្រែព័ត៌មាននិងទិន្នន័យក្បាលដី។

២. មានការសម្រេចនិងសំណើសុំចុះបញ្ជីរបស់អាជ្ញាធរឬស្ថាប័នមានសមត្ថកិច្ច។

៣. ករណីមានបញ្ញត្តក្នុងច្បាប់នេះតម្រូវឱ្យរដ្ឋបាលសុរិយោដីចុះបញ្ជីអំពីការកែតម្រូវ។

**យោបល់៖** គួរបញ្ជាក់ ឬយោងទៅបទប្បញ្ញត្តិ ឬច្បាប់ដែលផ្តល់មូលដ្ឋានគតិយុត្តសម្រាប់ចំនុចលេខ ២ នៃមាត្រានេះ។
**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៦០._ ការហាមឃាត់ការកែប្រែព័ត៌មាននិងទិន្នន័យនៃក្បាលដី

ការចុះបញ្ជីអំពីការកែប្រែព័ត៌មាននិងទិន្នន័យនៃក្បាលដីត្រូវបានហាមឃាត់ក្នុងករណីដូចខាងក្រោម៖

១. មានកិច្ចសន្យាពិសេសដែលហាមឃាត់ការកែប្រែព័ត៌មាននិងទិន្នន័យនៃក្បាលដី។

២. មានការហាមឃាត់របស់អាជ្ញាធរឬស្ថាប័នមានសមត្ថកិច្ច។

៣. ពុំមានភស្តុតាងដែលបង្ហាញថារាល់ពន្ធដារលើទ្រព្យនោះត្រូវបានបង់រួច។

៤. ពុំមានភស្តុតាងច្បាស់លាស់បញ្ជាក់អំពីមូលហេតុដែលនាំឱ្យមានការកែតម្រូវព័ត៌មាននិងទិន្នន័យក្បាលដីក្នុងពាក្យស្នើសុំ និងការសម្រេចរបស់អាជ្ញាធរឬស្ថាប័នមានសមត្ថកិច្ច។

**យោបល់៖** គួរបញ្ជាក់ ឬយោងទៅបទប្បញ្ញត្តិ ឬច្បាប់ដែលផ្តល់មូលដ្ឋានគតិយុត្តសម្រាប់ចំនុចលេខ ២ នៃមាត្រានេះ។ ទំនាក់ទំនងរវាងកាតព្វពន្ធលើទ្រព្យ និងការកែតម្រូវព័ត៌មាន និងទិន្នន័យក្បាលដី គួរតែញែកឱ្យដាច់ពីគ្នា ព្រោះភាពសុក្រិតនៃព័ត៌មាន និងទិន្នន័យក្បាលសំខាន់ខ្លាំងណាស់សម្រាប់ប្រព័ន្ធចុះបញ្ជីដីធ្លី និងសៀវភៅគោលបញ្ជីដីធ្លី ដូច្នេះគួរលុបចោលចំនុចលេខ ៣ នៃមាត្រានេះ។ ការហាមឃាត់មិនឱ្យចុះបញ្ជីនូវការផ្ទេរសិទ្ធិ ករណីមិនទាន់បានបង់ពន្ធលើទ្រព្យ និងពន្ធប្រថាប់ត្រា ជាការសមស្រប ប៉ុន្តែមិនសមស្របឡើយចំពោះការស្នើកែតម្រូវព័ត៌មាន និងទិន្នន័យក្បាលដី។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៦១._ ការចុះបញ្ជីដោយផ្អែកលើការស្នើសុំចុះបញ្ជីឬការផ្ទុកផ្តាក់ឱ្យចុះបញ្ជី ឬការជូនដំណឹង**

រដ្ឋបាលសុរិយោដីអាចចុះបញ្ជីបានតាមការស្នើសុំចុះបញ្ជី ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីពីតុលាការ ឬការជូនដំណឹងរបស់ស្ថាប័នសាធារណៈផ្សេងទៀតស្របតាមច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ការចុះបញ្ជីដោយគ្មានការស្នើសុំចុះបញ្ជី ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីពីតុលាការ និងការជូនដំណឹងរបស់ស្ថាប័នសាធារណៈផ្សេងទៀតត្រូវហាមឃាត់លើកលែងតែមានបញ្ញត្តិផ្សេង។

**យោបល់៖** គួរបញ្ជាក់ ឬយោងទៅបទប្បញ្ញត្តិ ឬច្បាប់ដែលផ្តល់មូលដ្ឋានគតិយុត្តសម្រាប់ការចុះបញ្ជីតាមការជូនដំណឹងរបស់ស្ថាប័នសាធារណៈផ្សេងទៀត។ លើសពីនេះគួរញែក ការជូនដំណឹងឱ្យដាច់ពីសេចក្តីបង្គាប់ឱ្យចុះបញ្ជីផ្អែកតាមបទប្បញ្ញត្តិច្បាប់ជាក់លាក់ជាធរមាន (ប៉ុន្តែមិនមែនផ្អែកតាមបទដ្ឋានគតិយុត្ត ឬ សេចក្តីសម្រេចរដ្ឋបាល ដែលគ្មានមូលដ្ឋានច្បាប់ទេ)។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

ផ្នែកទី២

ការចុះបញ្ជីតាមរយៈការដាក់ពាក្យស្នើសុំចុះបញ្ជីបន្ត

## មាត្រា១៦២._ ការធ្វើនិងដាក់ពាក្យស្នើសុំចុះបញ្ជីរួមគ្នា

ចំពោះការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ បុគ្គលមានសិទ្ធិចុះបញ្ជីនិងបុគ្គលមានកាតព្វកិច្ចចុះបញ្ជីត្រូវធ្វើនិងដាក់ពាក្យស្នើសុំចុះបញ្ជីរួមគ្នា លើកលែងតែមានបញ្ញត្តិផ្សេង។

**យោបល់៖** មិនមានយោបល់

## មាត្រា១៦៣._ ការស្នើសុំចុះបញ្ជីអំពីកិច្ចសន្យាហាមឃាត់មិនឱ្យបែងចែកអចលនវត្ថុអវិភាគ

ចំពោះការចុះបញ្ជីអំពីកិច្ចសន្យាហាមឃាត់មិនឱ្យបែងចែកអចលនវត្ថុអវិភាគ បុគ្គលដែលបានទទួលការចុះបញ្ជីជាម្ចាស់សិទ្ធិអវិភាគទាំងអស់ ត្រូវស្នើសុំចុះបញ្ជីរួមគ្នា។

បញ្ញត្តិនៃកថាខណ្ឌខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះឧបកម្មសិទ្ធិអវិភាគ។

**យោបល់៖** មិនមានយោបល់

## មាត្រា១៦៤._ ការស្នើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែកនិងសិទ្ធិដទៃទៀត

ចំពោះការចុះបញ្ជីអំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក បុគ្គលដែលទទួលបានការចុះបញ្ជីជាម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលត្រូវផ្លាស់ប្តូរលំដាប់ ត្រូវស្នើសុំចុះបញ្ជីរួមគ្នា។

បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះ៖

១. ការស្នើសុំចុះបញ្ជីផ្លាស់ប្តូរលំដាប់ឯកសិទ្ធិ និងសិទ្ធិលើការបញ្ចាំ។

២. ការស្នើសុំចុះបញ្ជីអំពីហេតុដែលម្ចាស់សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតទទួលការសងតាមសមាមាត្រដែលខុសពីសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ឬការស្នើសុំចុះបញ្ជីក្នុងករណីមានការចែងថាម្ចាស់សិទ្ធិរួមមួយផ្នែកទទួលការសងដោយមានអាទិភាពជាងម្ចាស់សិទ្ធិរួមផ្សេងទៀត ដូចមានចែងក្នុងក្រមរដ្ឋប្បវេណី។

**យោបល់៖** មិនមានយោបល់

**មាត្រា១៦៥._ ការស្នើសុំចុះបញ្ជីដោយឯកតោភាគី**

ទោះបីជាមានបញ្ញត្តិស្តីពីការស្នើសុំចុះបញ្ជីរួមគ្នា បញ្ញត្តិស្តីពីការស្នើសុំចុះបញ្ជីអំពីកិច្ចសន្យាហាមឃាត់មិនឱ្យបែងចែកអចលនវត្ថុអវិភាគ និងបញ្ញត្តិស្តីពីការស្នើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែកនិងសិទ្ធិដទៃទៀតដូចមានចែងក្នុងច្បាប់នេះក៏ដោយ ក៏បុគ្គលមានសិទ្ធិចុះបញ្ជីអាចដាក់ពាក្យសុំតែម្នាក់ឯងបានចំពោះករណីដូចខាងក្រោម៖

- ការផ្ទេរសិទ្ធិដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គល
- ការលុបការចុះបញ្ជីផលុបភោគដោយសារមរណភាពរបស់ផលុបភោគីដើម
- ការផ្ទេរសិទ្ធិដោយសារសន្តតិកម្ម លើកលែងតែអច្ច័យទាន
- ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធទៅជាកម្មសិទ្ធិអវិភាគដោយមូលហេតុមរណភាពរបស់សហព័ន្ធណាម្ខាង ដោយអនុលោមតាមសន្តតិកម្មតាមច្បាប់
- សាលក្រម សាលដីកា ឬដីកាសម្រេច ដែលបានចូលជាស្ថាពរ ឬលិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សារ ឬការទទួលស្គាល់នូវការទាមទារ ដែលលិខិតអនុវត្តទាំងអស់នោះបង្គាប់ឱ្យមាននីតិវិធីចុះបញ្ជី
- បញ្ញត្តិក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

**យោបល់៖** គួរប្តូរឃ្លាថា ផលុបភោគីដើម ក្នុងចំនុចទ្រទី២ ទៅជា ផលុបភោគីដែលមានឈ្មោះក្នុងបញ្ជីសុរិយោដី។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៦៦._ ការស្នើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬកែតម្រូវឈ្មោះរបស់បុគ្គលមានឈ្មោះក្នុងបញ្ជី**

បុគ្គលមានឈ្មោះក្នុងបញ្ជីអាចស្នើសុំចុះបញ្ជីផ្លាស់ប្តូរ ឬកែតម្រូវឈ្មោះឬនាមករណ៍ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើតរបស់ខ្លួន ឬឈ្មោះឪពុកម្តាយដោយឯកតោភាគីបាន។

**យោបល់៖** គួររួមបញ្ចូលទាំង ឈ្មោះ សញ្ជាតិ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត តួនាទី របស់អ្នកតំណាងស្របច្បាប់សម្រាប់ការចុះបញ្ជីផង។ អ្នកតំណាងរបស់នីតិបុគ្គលខ្មែរ មិនចាំបាច់ត្រូវតែមានសញ្ជាតិខ្មែរដែរទេ។
**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៦៧._ ការស្នើសុំចុះបញ្ជីដោយប្រតិសិទ្ធិសាកល**

ចំពោះបុគ្គលមានសិទ្ធិចុះបញ្ជី បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ឬបុគ្គលមានឈ្មោះក្នុងបញ្ជីដែលអាចស្នើសុំចុះបញ្ជីអំពីសិទ្ធិបាន

ហើយប្រសិនបើមានការទទួលបន្តនៃសិទ្ធិនិងករណីយកិច្ចទាំងស្រុងពីបុគ្គលនោះដោយសន្តតិកម្ម ឬមូលហេតុផ្សេងទៀត សន្តតិជន ឬប្រតិសិទ្ធិសាកលផ្សេងទៀតរបស់បុគ្គលនោះ អាចស្នើសុំចុះបញ្ជីអំពីសិទ្ធិនោះបាន។

**យោបល់៖** មិនមានយោបល់

### មាត្រា១៦៨._ **ការស្នើសុំចុះបញ្ជីដោយអ្នកតំណាង**

ការស្នើសុំចុះបញ្ជីដែលកំណត់នៅក្នុងផ្នែកនេះអាចធ្វើដោយអ្នកតំណាងបាន។

ក្នុងកំលុងពេលដំណើរការចុះបញ្ជី សិទ្ធិតំណាងដោយអាណត្តិរបស់អ្នកស្នើសុំចុះបញ្ជីមិនត្រូវរលត់ដោយមូលហេតុដូចខាងក្រោម៖

- មរណភាពរបស់ម្ចាស់សិទ្ធិ
- ការរលត់ដោយការរួមបញ្ចូលរបស់នីតិបុគ្គលដែលជាម្ចាស់សិទ្ធិ
- ការបញ្ចប់ភារកិច្ចទាក់ទងនឹងបរធនបាលកិច្ចរបស់បរធនបាលដែលជាម្ចាស់សិទ្ធិ
- មរណភាពរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬការរលត់ឬការផ្លាស់ប្តូរសិទ្ធិតំណាងរបស់អ្នកនោះ។

**យោបល់៖** មិនមានយោបល់

### មាត្រា១៦៩._ **ការផ្តល់អាណត្តិឱ្យទៅលិខិតបទដ្ឋានគតិយុត្ត**

ក្រៅពីចំណុចដែលមានកំណត់ក្នុងផ្នែកនេះ (ការចុះបញ្ជីតាមរយៈការស្នើសុំចុះបញ្ជី) ចំណុចដែលចាំបាច់ផ្សេងទៀតពាក់ព័ន្ធនឹងកិច្ចការចុះបញ្ជីបន្តដែលកំណត់ក្នុងផ្នែកនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**យោបល់៖** គួរកែសម្រួលចំណងជើងនៃមាត្រានេះ ទៅជា ការផ្តល់អាណត្តិឱ្យចេញបទដ្ឋានគតិយុត្ត។
**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## ផ្នែកទី៣
## ការពិនិត្យការស្នើសុំចុះបញ្ជី

## មាត្រា១៧០._ ការបង្គាប់ឱ្យកែតម្រូវការស្នើសុំចុះបញ្ជី

រដ្ឋបាលសុរិយោដីត្រូវបង្គាប់បុគ្គលដែលស្នើសុំចុះបញ្ជីឱ្យធ្វើការកែតម្រូវដោយកំណត់កំលុងពេលឱ្យបានសមរម្យ ក្នុងករណីដែលការស្នើសុំចុះបញ្ជីមានចំណុចខ្វះខាតដូចក្រោម៖

១. ករណីដែលពាក្យសុំស្នើចុះបញ្ជីមិនត្រឹមត្រូវតាមទម្រង់ដែលបានកំណត់ក្នុងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

២.
ករណីដែលអត្តសញ្ញាណនៃអចលនវត្ថុឬសិទ្ធិដែលជាគោលបំណងនៃការចុះបញ្ជីដែលបានសរសេរនៅក្នុងពាក្យសុំចុះបញ្ជីមិនស្របគ្នានឹងសៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុ។

៣. ករណីពុំបានផ្តល់ឯកសារដែលចាំបាច់។

៤. ករណីខ្លឹមសារនៃពាក្យសុំចុះបញ្ជីនិងឯកសារភ្ជាប់មិនស្របគ្នា។

៥. ករណីដែលបុគ្គលគ្មានសិទ្ធិស្នើសុំចុះបញ្ជីបានស្នើសុំចុះបញ្ជី។

៦. ករណីព័ត៌មានអំពីអត្តសញ្ញាណរបស់បុគ្គលមានកាតព្វកិច្ចចុះបញ្ជីឬបុគ្គលមានឈ្មោះក្នុងបញ្ជី មិនដូចគ្នានឹងសៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុ។

៧. ករណីពុំបានបង់សោហ៊ុយសេវាសម្រាប់ចុះបញ្ជីនិងពន្ធប្រថាប់ត្រាលើការផ្ទេរអចលនវត្ថុ។

៨. ករណីដែលមានកំណត់ក្នុងច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតថាជាករណីដែលមិនត្រូវចុះបញ្ជី។

**យោបល់៖** ឃ្លាថា លិខិតបទដ្ឋានគតិយុត្ត ជំនួសដោយ បទដ្ឋានគតិយុត្ត។ សូមមើលយោបល់ពីខាងដើមអំពី ការប្រើពាក្យបទដ្ឋានគតិយុត្ត។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១៧១._ ការបដិសេធការស្នើសុំចុះបញ្ជី

រដ្ឋបាលសុរិយោដីត្រូវបដិសេធការស្នើសុំចុះបញ្ជីបន្ត ក្នុងករណីដូចខាងក្រោម៖

១. បុគ្គលដែលស្នើសុំចុះបញ្ជីមិនធ្វើកែតម្រូវការស្នើសុំចុះបញ្ជី តាមការបង្គាប់របស់រដ្ឋបាលសុរិយោដី។

២. អចលនវត្ថុដែលបានសរសេរក្នុងពាក្យស្នើសុំចុះបញ្ជី មិនស្ថិតនៅក្នុងសមត្ថកិច្ចនៃរដ្ឋបាលសុរិយោដីដែលបានទទួលពាក្យស្នើសុំចុះបញ្ជីនោះ។

៣. គោលបំណងនៃការស្នើសុំចុះបញ្ជីគឺជាចំណុចក្រៅពីចំណុចចុះបញ្ជីដែលមានកំណត់ក្នុងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

៤. គោលបំណងនៃការស្នើសុំចុះបញ្ជីគឺជាចំណុចដែលត្រូវបានចុះបញ្ជីរួចហើយ។

រដ្ឋបាលសុរិយោដីត្រូវធ្វើលិខិតបដិសេធជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់អំពីមូលហេតុ ហើយត្រូវជូនដំណឹងអំពីការបដិសេធនោះទៅបុគ្គលដែលបានស្នើសុំចុះបញ្ជីនោះទាំងអស់ ដោយគ្មានការយឺតយ៉ាវ និងត្រូវប្រគល់ឯកសារភ្ជាប់ទាំងអស់ឱ្យទៅបុគ្គលដែលបានស្នើសុំចុះបញ្ជីនោះ។ ប៉ុន្តែរដ្ឋបាលសុរិយោដីមិនត្រូវប្រគល់ឯកសារដែលខ្លួនសង្ស័យថាជាឯកសារដែលបានក្លែងបន្លំ ឬជាឯកសារមិនត្រឹមត្រូវផ្សេងទៀតឡើយ ហើយត្រូវស្នើសុំការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងករណីនេះ។

**យោបល់៖** តើឯកសារមិនត្រឹមត្រូវ មានន័យដូចម្ដេច? ហេតុអ្វីចាំបាច់ត្រូវស្នើសុំការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធបើរដ្ឋបាលសុរិយោដីបានចេញលិខិតបដិសេធនូវការចុះបញ្ជីដោយបញ្ជាក់មូលហេតុ? ការស្នើសុំសេចក្ដីបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចគួរតែជាសិទ្ធិរបស់អ្នកស្នើសុំចុះបញ្ជី។ ឯកសារមិនត្រឹមត្រូវ ខុសពីឯកសារក្លែងបន្លំ ឬក្លែងក្លាយដូចម្ដេចដែរ។ ដូច្នេះគួរលុបឃ្លា ឬជាឯកសារមិនត្រឹមត្រូវផ្សេងទៀតចេញពីវាក្យខណ្ឌចុងក្រោយនៃកថាខណ្ឌចុងក្រោយ។

**សំណើលុប និងថែងបញ្ជាក់៖** សូមលុបចោល និងថែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៧២._ ការស្រាវជ្រាវដោយរដ្ឋបាលសុរិយោដីពាក់ព័ន្ធនឹងបុគ្គលដែលស្នើសុំចុះបញ្ជី**

ក្នុងករណីដែលមានការស្នើសុំចុះបញ្ជី ហើយបើមានមូលហេតុសមរម្យក្នុងការសង្ស័យថា បុគ្គលដែលកំពុងតែស្នើសុំចុះបញ្ជីមិនមែនជាបុគ្គលដែលអាចក្លាយជាបុគ្គលដែលមានសិទ្ធិស្នើសុំ, បុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជី, បុគ្គលដែលមានឈ្មោះក្នុងបញ្ជី ព្រមទាំងឧបាទេសិកនោះទេ រដ្ឋបាលសុរិយោដីត្រូវស្រាវជ្រាវអំពីអត្ថិភាពនៃសិទ្ធិស្នើសុំចុះបញ្ជីនោះ ដោយត្រូវទាមទារឱ្យបុគ្គលទាំងនេះ, អ្នកតំណាងនីតិបុគ្គល ឬបុគ្គលដែលពាក់ព័ន្ធផ្សេងទៀត ឱ្យបង្ហាញខ្លួននិងសាកសួរ ឬទាមទារឱ្យដាក់ឯកសារ ឬព័ត៌មានចាំបាច់ផ្សេងទៀត លើកលែងតែករណីត្រូវលើកចោលការស្នើសុំចុះបញ្ជីដោយផ្អែកបញ្ញត្តិនៃច្បាប់នេះប៉ុណ្ណោះ។

ក្នុងករណីបុគ្គលដែលស្នើសុំ, អ្នកតំណាងរបស់នីតិបុគ្គល ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលកំណត់នៅក្នុងកថាខណ្ឌខាងលើនេះ កំពុងអាស្រ័យនៅកន្លែងឆ្ងាយ ឬបើមានមូលហេតុសមរម្យផ្សេងទៀត រដ្ឋបាលសុរិយោដីដែលទទួលការស្នើសុំចុះបញ្ជី អាចផ្ទុកផ្ដាក់ឱ្យរដ្ឋបាលសុរិយោដីផ្សេងទៀតធ្វើការពិនិត្យស្រាវជ្រាវតាមកថាខណ្ឌខាងលើនេះជំនួសខ្លួនបាន។

**យោបល់៖** សូមកែកំហុសក្នុងការវាយអត្ថបទ ក្នុងកថាខណ្ឌចុងក្រោយ។

**សំណើកែកំហុស៖** សូមពិនិត្យកែកំហុសវាយអត្ថបទក្នុងមាត្រានេះ។

## ផ្នែកទី៤
## ការដកការស្នើសុំចុះបញ្ជី

### មាត្រា១៧៣._ ការដកការស្នើសុំចុះបញ្ជីបន្ត

ការដកការស្នើសុំចុះបញ្ជីអាចធ្វើឡើងនៅពេលណាក៏បាន ឱ្យតែរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្តដែលមានសមត្ថកិច្ចចុះបញ្ជី មិនទាន់បញ្ចប់នីតិវិធីចុះបញ្ជីនោះ។ ប្រសិនបើការស្នើសុំចុះបញ្ជីនោះត្រូវបានធ្វើឡើងដោយបុគ្គលច្រើននាក់ ក្នុងករណីនេះ ការដកការស្នើសុំចុះបញ្ជីនោះត្រូវធ្វើដោយបុគ្គលទាំងអស់នោះ។

ការដកការស្នើសុំចុះបញ្ជីត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយដាក់នៅរដ្ឋបាលសុរិយោដី ដែលបានទទួលការស្នើសុំចុះបញ្ជីនោះ។

ក្នុងករណីដកការស្នើសុំចុះបញ្ជី រដ្ឋបាលសុរិយោដីត្រូវប្រគល់ពាក្យសុំចុះបញ្ជីនិងឯកសារភ្ជាប់ទាំងអស់ ទៅឱ្យបុគ្គលដែលស្នើសុំ។ ប៉ុន្តែចំពោះឯកសារដែលត្រូវបានសង្ស័យថាជាឯកសារដែលបានក្លែងបន្លំឬជាឯកសារមិនត្រឹមត្រូវផ្សេងទៀត រដ្ឋបាលសុរិយោដីមិនត្រូវប្រគល់ឱ្យឡើយ ហើយត្រូវស្នើសុំការបញ្ជាក់ពីសមត្ថកិច្ចពាក់ព័ន្ធលើករណីនេះ។

**យោបល់៖** តើឯកសារមិនត្រឹមត្រូវ មានន័យដូចម្តេច? ហេតុអ្វីចាំបាច់ត្រូវស្នើសុំការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ បើរដ្ឋបាលសុរិយោដីបានចេញលិខិតបដិសេធនូវការចុះបញ្ជីដោយបញ្ជាក់មូលហេតុ? ការស្នើសុំសេចក្តីបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចគួរតែជាសិទ្ធិរបស់អ្នកស្នើសុំចុះបញ្ជី។ ឯកសារមិនត្រឹមត្រូវ ខុសពីឯកសារក្លែងបន្លំ ឬក្លែងក្លាយដូចម្តេចដែរ។ ដូច្នេះគួរលុបឃ្លា ឬជាឯកសារមិនត្រឹមត្រូវផ្សេងទៀតចេញពីវាក្យខណ្ឌចុងក្រោយនៃកថាខណ្ឌចុងក្រោយ។

**សំណើលុបចោល និងកែសម្រួល៖** សូមលុបចោល និងកែសម្រួលក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

ផ្នែកទី៤

ការចុះបញ្ជីអំពីការផ្លាស់ប្តូរឬការចុះបញ្ជីអំពីការកែតម្រូវសិទ្ធិ

### មាត្រា១៧៤._ ការចុះបញ្ជីអំពីការផ្លាស់ប្តូរឬការចុះបញ្ជីអំពីការកែតម្រូវសិទ្ធិដោយការចុះបញ្ជីបន្ថែម

ការចុះបញ្ជីអំពីការផ្លាស់ប្តូរឬការចុះបញ្ជីអំពីការកែតម្រូវសិទ្ធិ អាចធ្វើទៅបានដោយការចុះបញ្ជីបន្ថែម លុះត្រាតែមានករណីដូចខាងក្រោមប៉ុណ្ណោះ៖

១. ករណីដែលគ្មានតតិយជនដែលអាចបាត់បង់ផលប្រយោជន៍ពីការចុះបញ្ជីអំពីការផ្លាស់ប្តូរឬការចុះបញ្ជីអំពីការកែតម្រូវនោះ។

២. ករណីដែលមានតតិយជនដូចមានកំណត់ក្នុងចំណុចទី១ខាងលើនេះ ប៉ុន្តែមានការយល់ព្រមពីតតិយជននោះ។

**យោបល់៖** គួរបន្ថែម ករណីមានការផ្ទុកផ្តាក់ពីតុលាការឱ្យចុះបញ្ជីអំពីការផ្លាស់ប្តូរ ដោយសារតុលាការរកឃើញអំពើទុច្ចរិត និងកំហុសរបស់តតីយជនដែលមានឈ្មោះក្នុងបញ្ជីសុរិយោដី។

**សំណើថែងបន្ថែម៖** សូមថែងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៧៥._ ការចុះបញ្ជីអំពីការកែតម្រូវ**

ប្រសិនបើរកឃើញថាមានការភាន់ច្រឡំឬការខកខានក្នុងការចុះបញ្ជីអំពីសិទ្ធិ រដ្ឋបាលសុរិយោដីត្រូវជូនដំណឹងអំពីហេតុនោះទៅកាន់បុគ្គលមានសិទ្ធិចុះបញ្ជីនិងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី ដោយគ្មានការយឺតយ៉ាវ។ ការចុះបញ្ជីដើម្បីកែតម្រូវការភាន់ច្រឡំឬការខកខានក្នុងការចុះបញ្ជីអំពីសិទ្ធិ ត្រូវធ្វើឡើងដោយភាគីស្នើសុំចុះបញ្ជី។

ប្រសិនបើការភាន់ច្រឡំឬការខកខានក្នុងការចុះបញ្ជីអំពីសិទ្ធិ បង្កឡើងដោយសារកំហុសរបស់រដ្ឋបាលសុរិយោដី រដ្ឋបាលសុរិយោដីត្រូវចុះបញ្ជីអំពីការកែតម្រូវដោយពុំចាំបាច់មានការស្នើសុំនិងដោយគ្មានការយឺតយ៉ាវដោយការអនុវត្តនីតិវិធីចុះបញ្ជីបន្ថែម ក្នុងករណីដូចខាងក្រោមនេះ៖

១. តតិយជនដែលបាត់បង់ផលប្រយោជន៍ពីការចុះបញ្ជីអំពីការកែតម្រូវនោះ ពុំអាចមាន។

២. តតិយជនដែលអាចបាត់បង់ផលប្រយោជន៍ពីការចុះបញ្ជីអំពីការកែតម្រូវនោះ មានការយល់ព្រមចំពោះការចុះបញ្ជីអំពីការកែតម្រូវ។

បន្ទាប់ពីបានចុះបញ្ជីអំពីការកែតម្រូវដោយសារកំហុសរបស់រដ្ឋបាលសុរិយោដី រដ្ឋបាលសុរិយោដីត្រូវជូនដំណឹងអំពីបញ្ជីអំពីការកែតម្រូវនោះ ទៅកាន់បុគ្គលមានសិទ្ធិចុះបញ្ជីនិងបុគ្គលមានកាតព្វកិច្ចចុះបញ្ជីដោយគ្មានការយឺតយ៉ាវ។ ប្រសិនបើបុគ្គលមានសិទ្ធិចុះបញ្ជី បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ឬបុគ្គលមានឈ្មោះក្នុងបញ្ជីនីមួយៗមានចំនួនលើសពីម្នាក់ រដ្ឋបាលសុរិយោដីអាចជូនដំណឹងទៅបុគ្គលណាម្នាក់នៅក្នុងចំណោមបុគ្គលទាំងនោះបានហើយ។

**យោបល់៖** ការតម្រូវឱ្យរដ្ឋបាលសុរិយោដីកែតម្រូវកំហុសរបស់ខ្លួនដោយគ្មានការយឺតយ៉ាវជាគោលនយោបាយល្អ ប៉ុន្តែតើរដ្ឋបាលសុរិយោដីធ្វើបែបណា ឬសម្អាងលើអ្វី ដើម្បីកំណត់ថាពុំអាចមានតតីយជនណាម្នាក់ដែលបាត់បង់ផលប្រយោជន៍ពីការចុះបញ្ជីអំពីការកែតម្រូវនោះ? ចុះបើក្រោយពីការចុះបញ្ជីកែតម្រូវរួច តុលាការរកឃើញថាការចុះបញ្ជីកែតម្រូវនោះបាននាំឱ្យតតីយជនសុចរិតឥតកំហុសមួយនាក់ ឬច្រើននាក់ បាត់បង់ ឬខូចខាតផលប្រយោជន៍ដោយសារតែការកែតម្រូវធ្វើឡើយដោយរដ្ឋបាលសុរិយោដី ដោយគ្មានការជូនដំណឹងជាសាធារណៈជាមុន? ដូច្នេះគួរថែងបញ្ជាក់លម្អិតបន្ថែមសម្រាប់ការអនុវត្តកថាខណ្ឌទី២ នៃមាត្រានេះ។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៧៦._ ការលុបការចុះបញ្ជី**

ការលុបការចុះបញ្ជីអំពីសិទ្ធិអាចធ្វើឡើងដោយការស្នើសុំចុះបញ្ជីបាន លុះត្រាតែមានករណីខាងក្រោមនេះប៉ុណ្ណោះ៖

១. ករណីដែលគ្មានតតិយជនដែលអាចបាត់បង់ផលប្រយោជន៍ពីការចុះបញ្ជីអំពីការលុបការចុះបញ្ជីបន្តនោះ។

២. ករណីដែលមានការយល់ព្រមពីតតិយជនដែលអាចបាត់បង់ផលប្រយោជន៍ពីការចុះបញ្ជីអំពីការលុបការចុះបញ្ជីបន្តនោះ។

**យោបល់៖** គួរកំណត់បែបបទលម្អិតសម្រាប់កំណត់ និងធានាថា គ្មានតតីយជនណាមួយអាចបាត់បង់ផលប្រយោជន៍ពីការចុះបញ្ជីអំពីការលុបការចុះបញ្ជីបន្ត។

**សំណើចែងលម្អិត៖** សូមចែងលម្អិតក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៧៧._ ការលុបការចុះបញ្ជីដោយផ្អែកលើការសន្យាពិសេស**

ចំពោះការសន្យាពិសេសអំពីការរលត់សិទ្ធិដោយមរណភាពរបស់រូបវន្តបុគ្គលឬការរំលាយនីតិបុគ្គល បុគ្គលមានសិទ្ធិចុះបញ្ជីអាចស្នើសុំចុះបញ្ជីលុបការចុះបញ្ជីអំពីសិទ្ធិដែលទាក់ទងនឹងសិទ្ធិនោះតែម្នាក់ឯងបាន ប្រសិនបើសិទ្ធិនោះបានរលត់ដោយមរណភាពឬការរំលាយនោះ។

ទោះបីជាមានបញ្ញត្តិស្តីពីការស្នើសុំចុះបញ្ជីរួមគ្នាក៏ដោយ ក៏បុគ្គលមានសិទ្ធិចុះបញ្ជីអាចដាក់ពាក្យសុំលុបការចុះបញ្ជីអំពីការសន្យាពិសេសនៃការលោះតែម្នាក់ឯងបាន ប្រសិនបើអំឡុងពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជីអំពីការសន្យាពិសេសនៃការលោះនោះបានកន្លងផុត។

**យោបល់៖** មិនមានយោបល់

**មាត្រា១៧៨._ ការលុបការចុះបញ្ជីដោយពុំចាំបាច់មានការស្នើសុំ**

នៅក្រោយពេលការចុះបញ្ជីបន្តបានបញ្ចប់ ប្រសិនបើរដ្ឋបាលសុរិយោដីរកឃើញថាការចុះបញ្ជីអំពីសិទ្ធិជាករណីដែលច្បាប់ឬបទដ្ឋានគតិយុត្តផ្សេងទៀតកំណត់ថាមិនត្រូវចុះបញ្ជី ឬជាករណីដែលរដ្ឋបាលសុរិយោដីត្រូវបដិសេធការស្នើសុំចុះបញ្ជីដោយអនុលោមតាមច្បាប់នេះ រដ្ឋបាលសុរិយោដីនោះត្រូវជូនដំណឹងទៅកាន់បុគ្គលមានសិទ្ធិចុះបញ្ជី និងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី ព្រមទាំងឧបាទេសិករបស់បុគ្គលនោះ ថាការចុះបញ្ជីដែលបាន

បញ្ចប់នោះនឹងត្រូវលុប ប្រសិនបើគ្មានការតវ៉ាពីបុគ្គលដែលមានសិទ្ធិតវ៉ាអំពីការលុបការចុះបញ្ជីនោះជាលាយលក្ខណ៍អក្សរក្នុងកំលុងពេលមិនលើសពី ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងពីរដ្ឋបាលសុរិយោដី។

ប្រសិនបើមានតតិយជនដែលអាចបាត់បង់ផលប្រយោជន៍ពីការលុបការចុះបញ្ជីដែលបានបញ្ចប់នោះ រដ្ឋបាលសុរិយោដីក៏ត្រូវធ្វើការជូនដំណឹងទៅតតិយជននោះផងដែរ។

ប្រសិនបើមិនបានដឹងអំពីលំនៅឋានឬទីសំណាក់របស់បុគ្គលដែលត្រូវទទួលការជូនដំណឹងអំពីការលុបចោលការចុះបញ្ជីនោះទេ រដ្ឋបាលសុរិយោដីត្រូវជូនដំណឹងជាសាធារណៈអំពីខ្លឹមសារដែលត្រូវជូនដំណឹងជំនួសឱ្យការជូនដំណឹងទៅបុគ្គលដោយផ្ទាល់។

ក្នុងករណីដែលមានបុគ្គលបានតវ៉ាមករដ្ឋបាលសុរិយោដីចំពោះការលុបចោលការចុះបញ្ជី ប្រសិនបើយល់ឃើញថាការតវ៉ានោះគ្មានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុរិយោដីត្រូវបដិសេធការតវ៉ានោះជាលាយលក្ខណ៍អក្សរ។

ប្រសិនបើយល់ឃើញថាការតវ៉ានោះមានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុរិយោដីត្រូវទទួលស្គាល់ការតវ៉ានោះជាលាយលក្ខណ៍អក្សរ និងត្រូវជូនដំណឹងអំពីការទទួលស្គាល់នោះទៅបុគ្គលដែលបានតវ៉ា។

ប្រសិនបើគ្មានការតវ៉ាឬការតវ៉ាត្រូវបានបដិសេធ រដ្ឋបាលសុរិយោដីត្រូវលុបការចុះបញ្ជីចោលវិញដោយពុំចាំបាច់មានការពាក្យស្នើសុំ។

បែបបទនិងបរិបទនៃការលុបចោលការចុះបញ្ជី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** គួរមានបទដ្ឋានគតិយុត្តកំណត់លម្អិតអំពីការជូនដំណឹងជាសាធារណៈ ក្នុងកថាខណ្ឌទី៣ នៃមាត្រានេះ។ ក្នុងករណីរដ្ឋបាលសុរិយោដីបដិសេធការតវ៉ា ត្រូវបើកសិទ្ធិ និងទុកពេលឱ្យប្តឹងទៅតុលាការ មុននឹងរដ្ឋបាលសុរិយោដីធ្វើការលុបចោលនូវការចុះបញ្ជីនោះ។

**សំណើចែងលម្អិត៖** សូមចែងលម្អិតក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១៧៩._ ការធ្វើបដិទានការចុះបញ្ជីដែលត្រូវបានលុប

ការធ្វើបដិទានការចុះញ្ជីដែលត្រូវបានលុប អាចធ្វើទៅបានដោយការស្នើសុំរួមគ្នាស្របតាមបញ្ញត្តិស្តីពីការស្នើសុំចុះបញ្ជីរួមគ្នានៃច្បាប់នេះ។

ការធ្វើបដិទានការចុះបញ្ជីដែលត្រូវបានលុប អាចធ្វើឡើងដោយការស្នើសុំចុះបញ្ជីបាន លុះត្រាតែមានករណីខាងក្រោមនេះប៉ុណ្ណោះ៖

១. គ្មានតតិយជនដែលអាចបាត់បង់ផលប្រយោជន៍ពីការបដិទានការចុះបញ្ជីនោះ។

២.     មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីតតិយជនដែលអាចបាត់បង់ផលប្រយោជន៍ពីការបដិទានការចុះបញ្ជីនោះ។

**យោបល់៖** គួរកំណត់បែបបទលម្អិតសម្រាប់កំណត់ និងធានាថា គ្មានតតីយជនណាមួយអាចបាត់បង់ផលប្រយោជន៍ពីការចុះបញ្ជីអំពីការធ្វើបដិទានការចុះបញ្ជី។

**សំណើចែងលម្អិត៖** សូមចែងលម្អិតក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## ផ្នែកទី៦
## ការចុះបញ្ជីអំពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធ

មាត្រា១៨០._ ការចុះនៅក្នុងសៀវភៅចុះបញ្ជីដីនូវសិទ្ធិដែលជាកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

សិទ្ធិដែលកើតឡើងដោយផ្អែកលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមិនអាចតតាំងនឹងតតិយជនបានឡើយ បើសិទ្ធិនោះពុំបានធ្វើការចុះបញ្ជីនៅរដ្ឋបាលសុរិយោដីទេ។

ក្នុងករណីបានចុះបញ្ជីដីតាមកថាខណ្ឌខាងលើនេះ លក្ខខណ្ឌតតាំងនឹងតតិយជនចំពោះសិទ្ធិដែលជាកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះត្រូវបានបំពេញ ទោះបីមានឬពុំមានការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដូចមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីក៏ដោយ។

**យោបល់៖** គួរចែងបញ្ជាក់ថា បទប្បញ្ញត្តិនេះមិនអនុវត្តចំពោះចលនទ្រព្យ និងទ្រព្យសម្បត្តិផ្សេងទៀតក្រៅពីអចលនវត្ថុឡើយ។

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## ផ្នែកទី៧
## ការចុះបញ្ជីតាមការផ្ទុកផ្តាក់

**មាត្រា១៨១._ ការយកមកអនុវត្តដូចគ្នានូវបទប្បញ្ញត្តិស្តីពីការចុះបញ្ជីតាមរយៈការស្នើសុំចុះបញ្ជី**

បទប្បញ្ញត្តិស្តីពីការចុះបញ្ជីតាមរយៈការស្នើសុំចុះបញ្ជីដូចមានចែងក្នុងច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការចុះបញ្ជីតាមការផ្ទុកផ្តាក់ឱ្យចុះបញ្ជីពីតុលាការ ឬពីស្ថាប័នសាធារណៈផ្សេងទៀត។

នីតិវិធីលម្អិតនៃការផ្ទុកផ្តាក់ឱ្យចុះបញ្ជីពីតុលាការ ឬពីស្ថាប័នសាធារណៈផ្សេងទៀត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** មិនមានយោបល់

## ផ្នែកទី៨
## ចំណុចដែលត្រូវចុះបញ្ជីទៅតាមប្រភេទនៃសិទ្ធិប្រត្យក្ស

### មាត្រា១៨២._ បទប្បញ្ញត្តិទូទៅស្តីពីចំណុចដែលត្រូវចុះបញ្ជី

ចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ មានជាអាទិ៍ លេខរៀង កាលបរិច្ឆេទ ឈ្មោះឬនាមករណ៍ ថ្ងៃខែឆ្នាំកំណើត ប្រភេទទ្រព្យ មូលហេតុនៃការចុះបញ្ជី ចំណែកនៃសិទ្ធិ កិច្ចសន្យាឬការសន្យាផ្សេងៗ។

១. លេខរៀងនៃការទទួលពាក្យសុំចុះបញ្ជី ឬលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី។

២. ឈ្មោះឬនាមករណ៍របស់បុគ្គលមានសិទ្ធិចុះបញ្ជី។

៣. ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត និងឈ្មោះឪពុកម្តាយរបស់បុគ្គលដែលមានសិទ្ធិចុះបញ្ជី ឬកាលបរិច្ឆេទនៃការបង្កើតនីតិបុគ្គល ករណីបុគ្គលដែលមានសិទ្ធិចុះបញ្ជីជានីតិបុគ្គល។

៤. ប្រភេទទ្រព្យសម្បត្តិក្នុងករណីទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ទ្រព្យកម្មសិទ្ធិអវិភាគ ឧបកម្មសិទ្ធិអវិភាគ។

៥. មូលហេតុនៃការចុះបញ្ជី និង កាលបរិច្ឆេទនៃមូលហេតុនៃការចុះបញ្ជីនោះ។

៦. ឈ្មោះ ឬនាមករណ៍របស់ឧបាទេសិក មូលហេតុនៃឧបាទេសកម្ម និងកាលបរិច្ឆេទនៃឧបាទេសកម្មនោះ ក្នុងករណីមានឧបាទេសិក។

៧. ចំណែកនីមួយៗក្នុងករណីដែលបុគ្គលមានសិទ្ធិចុះបញ្ជីមានលើសពីម្នាក់។

៨. កិច្ចសន្យាហាមឃាត់មិនឱ្យបែងចែកអចលនវត្ថុអវិភាគ ប្រសិនបើមាន។

៩. ការសន្យាពិសេស អំពីការរលត់សិទ្ធិ ប្រសិនបើមាន។

១០. លេខរៀងនៃការចុះបញ្ជី។

១១. កាលបរិច្ឆេទដែលបានបញ្ចប់ការចុះបញ្ជី។

**យោបល់៖** គួរចុះបន្ថែមអំពី លិខិតគតិយុត្តនៃការបង្កើតសេវភាពសាធារណៈ ឬសេវភាពរដ្ឋបាល ប្រភេទ វិសាលភាព និងអំឡុងពេលនៃសេវភាព ឬនៃសិទ្ធិប្រត្យក្សផ្សេងទៀតផង។

**សំណើចែងបន្ថែម៖** សូមចែងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១៨៣._ ចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិជួលអចិន្ត្រៃយ៍

ក្រៅពីចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្តីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ការចុះបញ្ជីអំពីសិទ្ធិជួលអចិន្ត្រៃយ៍ត្រូវបន្ថែមចំណុចដូចខាងក្រោម៖

១. អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព។

២. ថ្លៃឈ្នួល~~ប្រសិនបើមាន~~។

៣. ពេលវេលានៃការបង់ថ្លៃឈ្នួល ប្រសិនបើមាន។

៤. ការសន្យាពិសេសពាក់ព័ន្ធនឹងការបញ្ចប់ការជួលអចិន្ត្រៃយ៍ ដែលត្រូវបានអនុញ្ញាតដោយក្រមរដ្ឋប្បវេណី ប្រសិនបើមាន។

**យោបល់៖** មិនមានយោបល់

## មាត្រា១៨៤._ ចំណុចដែលត្រូវចុះបញ្ជីអំពីផលុបភោគ

ក្រៅពីចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្តីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ការចុះបញ្ជីអំពីផលុបភោគត្រូវបន្ថែមចំណុចដូចខាងក្រោម៖

១. កម្មវត្ថុ។

២. អំឡុងពេលដែលមានអត្ថិភាពឬហេតុណាមួយ ប្រសិនបើមាន។

៣. តម្លៃថ្នូរ ប្រសិនបើមាន។

៤. ពេលវេលានៃការបង់តម្លៃថ្នូរ ប្រសិនបើមាន។

៥. ការសន្យាពិសេសពាក់ព័ន្ធនឹងការរំលត់ផលុបភោគ ដែលត្រូវបានអនុញ្ញាតដោយក្រមរដ្ឋប្បវេណី ប្រសិនបើមាន។

**យោបល់៖** ក្នុងចំនុចលេខ ៣ គួរបន្ថែម "ឬ ការសន្យាតបស្នង (ក្រៅពីតម្លៃជាប្រាក់)" និងក្នុងចំនុចលេខ ៤ គួរបន្ថែម "ឬ នៃការសន្យាតបស្នង"។

**សំណើចែងបន្ថែម៖** សូមចែងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១៨៥._ ចំណុចដែលត្រូវចុះបញ្ជីអំពីសេវភាព

ក្រៅពីចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្តីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ការចុះបញ្ជីអំពីសេវភាពលើដីបម្រើត្រូវបន្ថែម ចំណុចដូចខាងក្រោម៖

១. អត្តសញ្ញាណដីប្រើ។

២. គោលបំណងនៃការបង្កើតសេវភាព។

៣. អំឡុងពេលដែលសេវភាពមានអត្ថិភាពប្រសិនបើមាន។

៤. ទំហំសេវភាព។

៥. តម្លៃថ្នូរនៃសេវភាព ប្រសិនបើមាន។

៦. ពេលវេលានៃការបង់តម្លៃថ្នូរ ប្រសិនបើមាន។

៧. អត្តសញ្ញាណនៃសិទ្ធិ ក្នុងករណីម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ឬម្ចាស់ផលុបភោគបង្កើតសេវភាព។

៨. ការកំណត់ផ្សេងនៅក្នុងកិច្ចសន្យាបង្កើតសេវភាព ពាក់ព័ន្ធនឹងវិសាលភាពនៃជនដែលអាចទទួលបាននូវសេវភាព និងភាពទៅជាមួយគ្នានៃសេវភាព

៩. ការសន្យាពិសេសពាក់ព័ន្ធនឹងបន្ទុកនៃសោហ៊ុយសម្រាប់ការសាងសង់ការ្យ ដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ប្រសិនបើមាន។

ទោះបីជាមានបទប្បញ្ញត្តិទូទៅអំពីចំណុចដែលត្រូវចុះបញ្ជីក៏ដោយ ក៏ការចុះបញ្ជីអំពីសេវភាពលើដីបម្រើ ពុំចាំបាច់បញ្ជាក់ពីឈ្មោះឬនាមករណ៍របស់បុគ្គលដែលមានសិទ្ធិចុះបញ្ជីដែរ។

ក្នុងករណីដែលបានចុះបញ្ជីអំពីសេវភាពក្នុងសៀវភៅចុះបញ្ជីលើដីបម្រើ រដ្ឋបាលសុរិយោដីត្រូវចុះក្នុងសៀវភៅចុះបញ្ជីដីប្រើ ដោយពុំចាំបាច់មានការស្នើសុំ នូវចំណុចដូចខាងក្រោម៖

១. អត្តសញ្ញាណដីបម្រើ។

២. គោលបំណងនៃការបង្កើតសេវភាព។

៣. កាលបរិច្ឆេទនៃការចុះបញ្ជីបង្កើតសេវភាពលើដីបម្រើ។

**យោបល់៖** គួរចុះបន្ថែមអំពី លិខិតគតិយុត្តនៃការបង្កើតសេវភាពសាធារណៈ ឬសេវភាពរដ្ឋបាល ប្រភេទ វិសាលភាព និងអំឡុងពេលនៃសេវភាពពិសេសនេះផង។

**សំណើចែងបន្ថែម៖** សូមចែងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៨៦._ ករណីដែលដីប្រើស្ថិតនៅក្នុងដែនសមត្ថកិច្ចផ្សេង

នៅក្នុងករណីបានចុះបញ្ជីអំពីសេវភាព ហើយប្រសិនបើទីតាំងដីប្រើស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលសុរិយោដីផ្សេង រដ្ឋបាលសុរិយោដីដែលបានចុះបញ្ជីនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីចំណុចដែលបានចុះក្នុងសៀវភៅចុះបញ្ជីដីប្រើ ទៅរដ្ឋបាលសុរិយោដីផ្សេងនោះ ដោយគ្មានការយឺតយ៉ាវ។

រដ្ឋបាលសុរិយោដីដែលបានទទួលការជូនដំណឹងដូចមានចែងនៅក្នុងកថាខណ្ឌខាងលើនេះ ត្រូវចុះបញ្ជីអំពីខ្លឹមសារនៃការជូនដំណឹងដែលបានទទួលនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីនៃដីប្រើ ដោយពុំចាំបាច់មានការស្នើសុំ និងដោយគ្មានការយឺតយ៉ាវ។

**យោបល់៖** មិនមានយោបល់

**មាត្រា១៨៧._ ចំណុចដែលត្រូវចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ**

ក្រៅពីចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្តីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ការចុះបញ្ជីអំពីការសន្យាពិសេសនៃការលោះត្រូវបន្ថែមចំណុចដូចខាងក្រោម៖

១. ថ្លៃលក់ទិញដែលអ្នកទិញបានបង់។

២. សោហ៊ុយក្នុងការធ្វើកិច្ចសន្យា។

៣. អំឡុងពេលនៃការលោះ ប្រសិនបើមាន។

ក្នុងករណីដែលបានចុះបញ្ជីលទ្ធកម្មសិទ្ធិដោយផ្អែកលើការអនុវត្តសិទ្ធិលោះ រដ្ឋបាលសុរិយោដីត្រូវលុបការចុះបញ្ជីអំពីការសន្យាពិសេសនៃការលោះដោយពុំចាំបាច់មានការស្នើសុំ។

**យោបល់៖** មិនមានយោបល់

**មាត្រា១៨៨._ ចំណុចដែលត្រូវចុះបញ្ជី អំពីឯកសិទ្ធិ**

ក្រៅពីចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្តីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ការចុះបញ្ជីអំពីឯកសិទ្ធិត្រូវមានចំណុចដូចខាងក្រោម៖

១. ឈ្មោះឬនាមករណ៍របស់កូនបំណុល។

២. ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល។

៣. ការប្រាក់ ចំពោះការលក់អចលនវត្ថុ ប្រសិនបើមាន។

**យោបល់៖** ហេតុអ្វីមិនចុះឈ្មោះ ឬនាមករណ៍របស់ម្ចាស់បំណុល ដែលត្រូវទទួលបានការការពារ សិទ្ធិអាទិភាព និងសិទ្ធិតតាំងជាមួយតតីយជន ក្រោយពីការចុះបញ្ជីផង ?

**សំណើចែងបន្ថែម៖** សូមចែងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១៨៩._ ចំណុចដែលត្រូវចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ

ក្រៅពីចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្ដីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ការចុះបញ្ជីអំពីសិទ្ធិលើការបញ្ចាំត្រូវមានចំណុចដូចខាងក្រោម៖

១. ឈ្មោះឬនាមករណ៍របស់កូនបំណុល។

២. អំឡុងពេលមានអត្ថិភាព។

៣. ចំនួនប្រាក់ដើម។

៤. ប្រាក់ធានាសំណងឬចំនួននៃសំណងដែលបានកំណត់ជាមុននៅក្នុងកិច្ចសន្យា ប្រសិនបើមាន។

៥. ~~កំណត់ផ្សេង ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ~~ ម្ភការសន្យាពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ប្រសិនបើមាន។

លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ប្រសិនបើមាន។

បទប្បញ្ញត្តិទូទៅស្ដីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះកូនបំណុល នៅក្នុងករណីដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំគឺជាអ្នកធានាដោយវត្ថុដូចមានចែងក្នុងក្រមរដ្ឋប្បវេណី។

**យោបល់៖** ហេតុអ្វីមិនចុះឈ្មោះ ឬនាមករណ៍របស់ម្ចាស់បំណុល ដែលត្រូវទទួលបានការការពារ សិទ្ធិអាទិភាព និងសិទ្ធិតតាំងជាមួយតតីយជន ក្រោយពីការចុះបញ្ជីផង? តាមច្បាប់នេះ ក៏ដូចជាតាមក្រមរដ្ឋប្បវេណី ជាអត្ថន័យជាក់ស្ដែង តើការបញ្ចាំអចលនវត្ថុខុសពីហ៊ីប៉ូតែកអចលនវត្ថុយ៉ាងដូចម្ដេច? ប្រសិនបើគ្មានភាពខុសគ្នាខាងផ្លូវច្បាប់ទេ គួរបញ្ចូលទស្សនទានទាំងពីរ ក្នុងបញ្ញត្តិតែមួយ។ ចំពោះករណីមានការបញ្ចាំអចលនវត្ថុ តើអាចបង្កើតនិងចុះបញ្ជីហ៊ីប៉ូតែក បន្ថែមពីលើការបញ្ចាំអចលនវត្ថុនោះបានដែរឬទេ ប្រសិនបើគ្មានកិច្ចសន្យាពិសេសហាមឃាត់មិនឱ្យបង្កើតនិងចុះបញ្ជី?

**សំណើចែងបន្ថែម និងបញ្ជាក់៖** សូមចែងបន្ថែម និងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

## មាត្រា១៩០._ ចំណុចដែលត្រូវចុះបញ្ជីអំពីហ៊ីប៉ូតែក

ក្រៅពីចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្ដីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ការចុះបញ្ជីអំពីហ៊ីប៉ូតែកត្រូវមានចំណុចដូចខាងក្រោម៖

១. ឈ្មោះឬនាមករណ៍របស់កូនបំណុល។

២. ចំនួនប្រាក់ដើម។

៣. ការប្រាក់ ប្រសិនបើមាន។

៤. សំណងការខូចខាត ប្រសិនបើមាន។

៥. លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ប្រសិនបើមាន។

នៅក្នុងករណីដែលអ្នកបង្កើតហ៊ីប៉ូតែកគឺជាអ្នកធានាដោយវត្ថុដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ការចុះបញ្ជីអំពីហ៊ីប៉ូតែកត្រូវមានចំណុចអំពីឈ្មោះឬនាមករណ៍របស់បុគ្គលមានសិទ្ធិចុះបញ្ជី ចំពោះកូនបំណុលផងដែរ។

**យោបល់៖** សំណួរដូចក្នុងមាត្រា ១៨៩។ តើការអនុវត្តបច្ចុប្បន្នរបស់រដ្ឋបាលសុរិយោដី អនុញ្ញាតឱ្យមានការបង្កើត និងការចុះបញ្ជី ពហុហ៊ីប៉ូតែក លើអចលនវត្ថុតែមួយដែរឬទេ? ចំពោះករណីមានការបញ្ចាំអចលនវត្ថុ តើអាចបង្កើត និងចុះបញ្ជី ហ៊ីប៉ូតែក បន្ថែមពីលើការបញ្ចាំអចលនវត្ថុនោះបានដែរឬទេ ប្រសិនបើគ្មានកិច្ចសន្យាពិសេសហាមឃាត់មិនឱ្យបង្កើតនិងចុះបញ្ជី? តាមគោលនយោបាយសាធារណៈសម្រាប់របបហ៊ីប៉ូតែក តើការដែលម្ចាស់បំណុល ឬអ្នកផ្តល់ហិរញ្ញប្បទាន បង្ខំឱ្យទទួលយកប្រការហាមឃាត់មិនឱ្យបង្កើតនិងចុះបញ្ជីហ៊ីប៉ូតែកបន្ថែមជាមួយតតីយជន តើប្រការហាមឃាត់ក្នុងកិច្ចសន្យាបែបនេះ មានសុពលភាពអនុវត្តឬទេ?

**សំណើចែងបញ្ជាក់៖** សូមចែងបញ្ជាក់ក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៩១._ ចំណុចដែលត្រូវចុះបញ្ជីអំពីហ៊ីប៉ូតែកធានាបំណុលអណ្តែត

ក្រៅពីចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្តីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ការចុះបញ្ជីអំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវមានចំណុចដូចខាងក្រោម៖

១. ឈ្មោះឬនាមករណ៍របស់កូនបំណុល។

២. ចំនួនទឹកប្រាក់អតិបរមា។

៣. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ~~(ប្រភេទ នៃប្រតិបត្តិការដែលបង្កើតសិទ្ធិលើបំណុលដែលត្រូវបានធានា)~~។

៤. កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ស្ថាពរ ដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ប្រសិនបើមាន។

៥. ការសន្យាពិសេសពាក់ព័ន្ធនឹងសិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុល ដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ប្រសិនបើមាន។

នៅក្នុងករណីដែលអ្នកបង្កើតហ៊ីប៉ូតែកធានាបំណុលអណ្តែតគឺជាអ្នកធានាដោយវត្ថុ ដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ការចុះបញ្ជីអំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតក៏ត្រូវមានចំណុចអំពីឈ្មោះឬនាមករណ៍របស់បុគ្គលមានសិទ្ធិចុះបញ្ជី ចំពោះកូនបំណុលផងដែរ។

**យោបល់៖** ហេតុអ្វីមិនចុះឈ្មោះ ឬនាមករណ៍របស់ម្ចាស់បំណុល ដែលត្រូវទទួលបានការការពារ សិទ្ធិអាទិភាព និងសិទ្ធិតតាំងជាមួយតតីយជន ក្រោយពីការចុះបញ្ជីផង?

**សំណើចែងបន្ថែម៖** សូមចែងបន្ថែមក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

### មាត្រា១៩២._ ចំណុចដែលត្រូវចុះបញ្ជីអំពីការចាត់ចែងហ៊ីប៉ូតែក

ក្រៅពីចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្តីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកបន្ត ឬការធ្វើអនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក ត្រូវមានចំណុចដូចការចុះបញ្ជីអំពីហ៊ីប៉ូតែក ឬការចុះបញ្ជីអំពីហ៊ីប៉ូតែកដើម្បីជានាបំណុលអណ្តែតដែរ។

ការចុះបញ្ជីអំពីការចាត់ចែងហ៊ីប៉ូតែកត្រូវធ្វើតាមនីតិវិធីចុះបញ្ជីបន្ថែម។

**យោបល់៖** មិនមានយោបល់

### មាត្រា១៩៣._ ចំណុចដែលត្រូវចុះបញ្ជីអំពីឧបាទេសកម្មហ៊ីប៉ូតែករួម

ក្រៅពីចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្តីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ការចុះបញ្ជីអំពីឧបាទេសកម្មហ៊ីប៉ូតែករួមដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ត្រូវមានចំណុចដូចខាងក្រោម៖

១. សិទ្ធិពាក់ព័ន្ធនឹងអចលនវត្ថុដែលម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់អាទិភាពបានទទួលពីការសង។

២. ថ្លៃលក់អចលនវត្ថុ។

៣. ចំនួនប្រាក់សងដែលម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់អាទិភាពបានទទួល។

ការចុះបញ្ជីអំពីឧបាទេសកម្មហ៊ីប៉ូតែករួមត្រូវធ្វើតាមវិធីចុះបញ្ជីបន្ថែម។

ក្រៅពីចំណុចដែលត្រូវចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្តីពីចំណុចដែលត្រូវចុះបញ្ជីដែលមានចែងក្នុងច្បាប់នេះ ការចុះបញ្ជីអំពីឧបាទេសកម្មហ៊ីប៉ូតែករួមត្រូវមានចំណុច ដូចការចុះបញ្ជីអំពីហ៊ីប៉ូតែក ឬការចុះបញ្ជីអំពីហ៊ីប៉ូតែកដើម្បីជានាបំណុលអណ្តែតដែរ។

**យោបល់៖** មិនមានយោបល់

### មាត្រា១៩៤._ ការផ្តល់អាណត្តិឱ្យទៅបទដ្ឋានគិយុត្ត

ក្រៅពីចំណុចដែលត្រូវចុះក្នុងសៀវភៅចុះបញ្ជីកំណត់ក្នុងផ្នែកនេះ ចំណុចបន្ថែមចាំបាច់ពាក់ព័ន្ធនឹងការចុះបញ្ជី ដោយផ្អែកលើប្រភេទនៃសិទ្ធិប្រត្យក្ស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**យោបល់៖** គួរកែសម្រួលចំណងជើងនៃមាត្រានេះ ទៅជា ការផ្តល់អាណត្តិឱ្យចេញបទដ្ឋានគតិយុត្ត។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## ផ្នែកទី៩
## ការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន

### មាត្រា១៩៥._ ការលុបការចុះបញ្ជីដែលធ្វើឡើងក្រោយការចុះបញ្ជីចាត់ចែងជាបណ្តោះអាសន្ន

នៅក្រោយពេលមានការចុះបញ្ជីហាមឃាត់ការចាត់ចែងលើកម្មសិទ្ធិ ផ្អែកតាមបញ្ញត្តិស្តីពីការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ហើយនៅក្នុងករណីដែលម្ចាស់បំណុលនៃការចាត់ចែងជាបណ្តោះអាសន្នដែលពាក់ព័ន្ធនឹងការចុះបញ្ជីហាមឃាត់ការចាត់ចែងនោះ ស្នើសុំចុះបញ្ជីដោយយកកូនបំណុលនៃការចាត់ចែងជាបណ្តោះអាសន្ននោះ ធ្វើជាបុគ្គលមានកាតព្វកិច្ចចុះបញ្ជី ម្ចាស់បំណុលនោះអាចស្នើសុំលុបការចុះបញ្ជីដែលធ្វើឡើងក្រោយការចុះបញ្ជីហាមឃាត់ការចាត់ចែងបណ្តោះអាសន្ននោះដោយឯកតោភាគីបាន លុះត្រាតែការស្នើសុំធ្វើឡើងពេលជាមួយគ្នានឹងការស្នើសុំចុះបញ្ជីនោះ។

បញ្ញត្តិនៃកថាខណ្ឌខាងលើនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលនៃការចាត់ចែងជាបណ្តោះអាសន្នដែលពាក់ព័ន្ធនឹងការចុះបញ្ជីហាមឃាត់ការចាត់ចែងលើសិទ្ធិក្រៅពីកម្មសិទ្ធិ ផ្អែកតាមបញ្ញត្តិស្តីពីការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ស្នើសុំចុះបញ្ជីដោយយកកូនបំណុលនៃការចាត់ចែងជាបណ្តោះអាសន្ននោះ ធ្វើជាបុគ្គលមានកាតព្វកិច្ចចុះបញ្ជី នៅក្រោយពេលមានការចុះបញ្ជីអំពីការចាត់ចែងបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងនោះ។

ប្រសិនបើលុបការចុះបញ្ជីដែលធ្វើឡើងក្រោយការចុះបញ្ជីចាត់ចែងបណ្តោះអាសន្ន នដែលហាមឃាត់ការចាត់ចែង ដោយផ្អែកលើការស្នើសុំក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ខាងលើ រដ្ឋបាលសុរិយោដីត្រូវលុបចោលការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងនោះដោយពុំចាំបាច់មានការស្នើសុំ។

នៅក្នុងករណីម្ចាស់បំណុលនៃការចាត់ចែងបណ្ដោះអាសន្ន បានស្នើសុំលុបការចុះបញ្ជីដោយឯកតោភាគី ដោយផ្អែកលើកថាខណ្ឌទី១ ឬកថាខណ្ឌទី២ខាងលើ រដ្ឋបាលសុរិយោដីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការលុបការចុះបញ្ជីនោះ ទៅម្ចាស់សិទ្ធិនៃការចុះបញ្ជីនោះជាមុន។

**យោបល់៖** មិនមានយោបល់

**មាត្រា១៩៦._ ការផ្ដល់អាណត្តិឱ្យទៅបទដ្ឋានគិយុត្ត**

ក្រៅពីចំណុចដែលមានកំណត់ក្នុងជំពូកនេះ ចំណុចដែលចាំបាច់ផ្សេងទៀតពាក់ព័ន្ធនឹងកិច្ចការចុះបញ្ជីអំពី ការចាត់ចែងបណ្ដោះអាសន្ន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** គួរកែសម្រួលចំណងជើងនៃមាត្រានេះ ទៅជា ការផ្ដល់អាណត្តិឱ្យចេញបទដ្ឋានគតិយុត្ត។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

## ផ្នែកទី១០
## ការដាក់ពាក្យសុំតវ៉ា

**មាត្រា១៩៧._ ការដាក់ពាក្យសុំតវ៉ា**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេច ឬការមិនអើពើរបស់រដ្ឋបាលសុរិយោដីរាជធានី ខេត្ត អាចដាក់ពាក្យសុំតវ៉ាជាលាយលក្ខណ៍អក្សរទៅកាន់រដ្ឋបាលសុរិយោដីរាជធានី ខេត្តនោះបាន។

ក្នុងករណីដែលយល់ឃើញថាពាក្យសុំតវ៉ាមានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុរិយោដីរាជធានី ខេត្ត នៃកថាខណ្ឌខាងលើនេះ ត្រូវធ្វើនីតិវិធីចុះបញ្ជីឬសកម្មភាពផ្សេងទៀតស្របតាមគោលបំណងនៃពាក្យសុំតវ៉ានោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីហេតុនោះទៅបុគ្គលដែលដាក់ពាក្យសុំតវ៉ា ក្នុងអំឡុងពេលមិនលើស ពី៣(បី)សប្ដាហ៍ គិតចាប់តាំងពីថ្ងៃដែលបានទទួលពាក្យសុំតវ៉ានៃកថាខណ្ឌខាងលើនេះ។

នៅក្នុងករណីកថាខណ្ឌទី២ខាងលើនេះ ប្រសិនបើមានតតិយជនដែលមានឈ្មោះក្នុងបញ្ជី និងអាចបាត់បង់ ផលប្រយោជន៍ពីនីតិវិធីចុះបញ្ជី ឬសកម្មភាពផ្សេងទៀតនៃកថាខណ្ឌទី២ ខាងលើនេះ រដ្ឋបាលសុរិយោដី ត្រូវ ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅតតិយជននោះផងដែរ។

ក្នុងករណីដែលយល់ឃើញថាពាក្យសុំតវ៉ាគ្មានមូលហេតុត្រឹមត្រូវទេ រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ត្រូវលើកចោលពាក្យសុំតវ៉ាជាលាយលក្ខណ៍អក្សរ ហើយជូនដំណឹងទៅបុគ្គលដែលដាក់ពាក្យសុំតវ៉ា ក្នុងអំឡុងពេលមិនលើសពី៣(បី)សប្តាហ៍ គិតចាប់តាំងពីថ្ងៃដែលបានទទួលពាក្យសុំតវ៉ា។

អ្នកដាក់ពាក្យសុំតវ៉ាដែលមិនសុខចិត្តនឹងការសម្រេចបដិសេធការតវ៉ាខាងលើនេះ អាចដាក់ពាក្យសុំតវ៉ាបន្តជាលាយលក្ខណ៍អក្សរទៅកាន់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានការជូនដំណឹងអំពីការបដិសេធរបស់រដ្ឋបាលសុរិយោដី។

បុគ្គលដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសិទ្ធិប្តឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្តឹង តវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

បែបបទនិងបរិបទនៃការដាក់ពាក្យសុំតវ៉ា ការទទួលពាក្យសុំតវ៉ា ការបដិសេធការសុំតវ៉ា និងការដោះស្រាយការសុំតវ៉ាចំពោះសេចក្តីសម្រេចរបស់រដ្ឋបាលសុរិយោដី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**យោបល់៖** គាំទ្រការចែងបែបនេះ។ ស្នើឱ្យចែងតាមអត្ថន័យនៃមាត្រា១៥២.៥ អំពីការប្តឹងតវ៉ា ខាងលើដើម្បីឱ្យមានសង្គតិភាព។

## មាតិកាទី៥
## ទោសប្បញ្ញត្តិ
## មាតិកាទី៦
## អន្តរប្បញ្ញត្តិ
## មាតិកាទី៧
## អវសានប្បញ្ញត្តិ

មាត្រា១៩៨._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**យោបល់៖** ច្បាប់នេះគួរសម្រួលបន្ទុរបន្ថយអំពីការកំណត់ជាបទល្មើសព្រហ្មទណ្ឌ និងទោសទណ្ឌ ពាក់ព័ន្ធការប្រើប្រាស់ហឹង្សាបន្តិចបន្តួច ឬ និងការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិបន្តិចបន្តួច ក្នុងទំនាស់ ឬ វិវាទទាមទារសិទ្ធិលើដីធ្លីដែលមិនទាន់បានចុះបញ្ជី ដើម្បីលើកកម្ពស់សមធម៌ និងសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លី។

ផលប៉ះពាល់នៃច្បាប់នេះចំពោះច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍អនុវត្តជាធរមាន គួរតែមានការសិក្សាច្បាស់លាស់ ហើយចែងរៀបរាប់ក្នុងអវសានប្បញ្ញត្តិ ឬនិងបញ្ចូលក្នុងកំណត់ពន្យល់ជាលាយល័ក្ខណ៍អក្សរ។ លើសពីនេះរដ្ឋគួរតែជៀសវាងនូវការធ្វើច្បាប់ថ្មីជំនួសឱ្យច្បាប់ដែលមានស្រាប់ម្តងហើយម្តងទៀត ប៉ុន្តែគួរធ្វើច្បាប់កែប្រែមាត្រាពាក់ព័ន្ធជាក់លាក់តាមការចាំបាច់ ឬតាមការផ្លាស់ប្តូរនៃគោលនយោបាយសាធារណៈ ដើម្បីឱ្យអ្នកអានច្បាប់អាចដឹងថាអ្វីខ្លះដែលត្រូវបានកែប្រែ និងអ្វីខ្លះដែលរក្សានៅដដែល។

**សំណើចែង៖** សូមចែងក្នុងមាត្រានេះ ស្របតាមយោបល់ខាងលើ។

**មាត្រា១៩៩._**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

**យោបល់៖** មិនគួរប្រកាសច្បាប់នេះជាការប្រញាប់ទេ ព្រោះមានច្បាប់ភូមិបាល ឆ្នាំ២០០១ ជាធរមានសម្រាប់អនុវត្តក្នុងអន្តរកាល។ គួរទុកពេលយ៉ាងតិច ១២ ខែ ដើម្បីផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយ និងឱ្យមានការសិក្សាស៊ីជម្រៅអំពីផលប៉ះពាល់ដែលច្បាប់នេះអាចមានលើសិទ្ធិដីធ្លី ការគ្រប់គ្រងជីវដ្ឋ និងរដ្ឋបាលសុរិយោដីសម្រាប់គោលបំណងនៃការតស៊ូមតិបន្ថែម ក៏ដូចជាការបង្កើននូវការគាំទ្រសម្រាប់អនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាព។ ច្បាប់ដែលមានប្រសិទ្ធភាព គឺច្បាប់ដែលមានការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ ប្រកបដោយការយល់ដឹងច្បាស់អំពីអត្ថន័យ និងផលប៉ះពាល់របស់ច្បាប់ចំពោះពួកគេ។ ជាការចាំបាច់ណាស់ដែលត្រូវមានការចូលរួមគ្រប់គ្រាន់ និងការគាំទ្រពេញលេញពីគ្រប់ភាគី ជាពិសេស វិស័យឯកជន សមូហភាព និងប្រជាពលរដ្ឋដែលរស់នៅពឹងផ្អែកលើដីដើម្បីសម្រេចលទ្ធផលរំពឹងទុក ដែលជាគោលដៅរបស់ច្បាប់នេះ។

**សំណើកែសម្រួល៖** សូមកែសម្រួលមាត្រានេះ ស្របតាមយោបល់ខាងលើ។

**ឧបសម្ព័ន្ធនៃច្បាប់ភូមិបាល**

**សន្ទានុក្រម**

**យោបល់៖** គួរតែលុបឧបសម្ព័ន្ធ (សន្ធានុក្រម) ចោល ហើយពន្យល់ ឬផ្តល់និយមន័យនៃពាក្យគន្លឹះទាំងឡាយដែលមានប្រើក្នុងច្បាប់នេះ នៅក្នុងមាត្រា ៣ នៃច្បាប់ ដើម្បីបានជាមូលដ្ឋានគតិយុត្តរឹងមាំ សម្រាប់ការអនុវត្ត និងការបកស្រាយខ្លឹមសារនៃច្បាប់នេះ។ អង្គនីតិបញ្ញត្តិ មិនអាន ពិភាក្សា និងបោះឆ្នោតអនុម័ត ឧបសម្ព័ន្ធទេ ដូច្នេះវានាំឱ្យមានចំណោទសួរអំពីចេតនារបស់នីតិបញ្ញត្តិ ចំពោះការផ្តល់និយមន័យឱ្យពាក្យគន្លឹះទាំងឡាយ សម្រាប់គោលបំណងនៃច្បាប់នេះ។

**សំណើលុបចោល៖** សូមលុបចោល ឧបសម្ព័ន្ធ (សន្ធានុក្រម) ស្របតាមយោបល់ខាងលើ។